Toutes à l'école

វិទ្យាល័យ ហេបភីច័ន្ទតារានារីព្រែកថ្មី

# កម្រងវិញ្ញាសា សម្រាប់ជំនួយស្មារតី
# ប្រវត្តិវិទ្យា

រៀបរៀងដោយ ទី សុផល
(អ្នកសម្របសម្រួលមុខវិជ្ជា៖ ប្រវត្តិវិទ្យា និងភូមិវិទ្យា)

សម្រាប់ចែកជូនប្អូនៗសិស្សថ្នាក់ទី១២

ឆ្នាំសិក្សា២០២១-២០២២

# អារម្ភកថា

ទស្សនៈវិស័យអប់រំនាសតវត្សរ៍ទី២១ បានផ្តោតទៅលើការរីកចម្រើនខ្លាំងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិជ្ជា និងឌីជីថល (Digital) ដែលជាមូលដ្ឋានគ្រឹះរឹងមាំមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ ការអភិវឌ្ឍធនធានមនុស្ស ដើម្បីឆ្ពោះទៅរកគំនិតនវានុវត្តន៍ថ្មីៗសម្រាប់បម្រើឱ្យសេចក្តីត្រូវការរបស់សង្គមជាតិទាំងមូល។ ដោយសារនិន្នាការពិភពលោក ដែលមានការអភិវឌ្ឍឥតឈប់ឈរ ទើបរាជរដ្ឋាភិបាលកម្ពុជាដែលមានក្រសួងអប់រំ យុវជន និងកីឡា ជាសេនាធិការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សប្រកបដោយចីរភាព។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់ការប្រឡងគឺជាផ្នែកមួយមានការចាប់អារម្មណ៍ខ្លាំងពីសំណាក់ពលរដ្ឋគ្រប់មជ្ឈដ្ឋាន ហើយនរណាក៏ចាំមិនភ្លេចនូវបញ្ញត្តិមួយដែលឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បានធ្វើការបញ្ជាក់ជូនបេក្ខជនគ្រប់រូបនោះគឺ« **អ្នកចេះ គឺជាប់**» ។ ដោយសារតែបញ្ញត្តិនេះ និងកំណែទម្រង់របស់ក្រសួងអប់រំបានធ្វើឱ្យការប្រឡងគ្រប់ផ្នែកកាន់តែប្រសើរឡើងៗ។ ម៉្យាងទៀតវប្បធម៌នៃការខ្សឹបខ្សៀវរកទិញវិញ្ញាសា ការបើកចម្លងត្រូវបានបញ្ចប់ ដោយសារតែវប្បធម៌នៃការអានកើនឡើង។ ហើយអ្វីដែលជាបញ្ហាប្រឈមដែលប្អូនៗ ក៏ដូចជាសិស្ស និស្សិតទូទាំងពិភពលោកកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះគឺបញ្ហាCOVID19។

ហេតុនេះហើយសិស្សត្រូវតែខំពង្រឹងខ្លួនដើម្បីឱ្យក្លាយជា«អ្នករៀនឯករាជ្យ»។ លោកគ្រូជឿជាក់គ្រប់ពេលវេលាថាប្អូនៗជាក្មេងស្រីដែលពូកែ ក្មេងស្រីដែលបានខិតខំយកចិត្តទុកដាក់ក្នុងរៀនសូត្រ ក្មេងស្រីដែលមានឯករាជ្យភាពក្នុងការសិក្សា ដែលត្រូវតែទទួលជ័យជំនះ និងត្រូវតែក្លាយជាអនាគតស្ត្រីឆ្នើមសម្រាប់កម្ពុជា និងពិភពលោកផងដែរ ។

ក្នុងឆ្នាំសិក្សា២០២១-២០២២នេះ ជាជំនាន់ទី៥ហើយសម្រាប់ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ចំណែកសិស្សច្បងរបស់ប្អូនៗ គឺសុទ្ធតែទទួលបានជោគជ័យគ្រប់ៗគ្នា ដែលនេះជាមេរៀនគំរូដ៏ល្អមួយរបស់ពួកគាត់ សម្រាប់ប្អូនៗត្រូវខំប្រឹងប្រែងឱ្យកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីទទួលបាននិទ្ទេសល្អ និងមានឱកាសការងារល្អក្នុងប្រទេស តំបន់ និងអន្តរជាតិ។

ជាចុងក្រោយលោកគ្រូសូមជូនពរប្អូនៗ ទទួលបានជោគជ័យល្អប្រសើរគ្រប់ៗគ្នាសម្រាប់ការប្រឡងខាងមុននេះ និងជោគជ័យក្នុងដំណើរជីវិតដ៏វែងឆ្ងាយដែលប្រកបដោយស្នាមញញឹម និងការតស៊ូប្រកបដោយសីលធម៌ សច្ចធម៌ យុត្តិធម៌ និងភាពស្មោះត្រង់។

សៀវភៅនេះ ខ្ញុំបាទគ្រាន់តែកែសម្រួលឡើងវិញនូវវិញ្ញាសាមួយចំនួន ពីកម្រងវិញ្ញាសាឆ្នាំសិក្សា២០១៨-២០១៩ សម្រាប់ប្រើប្រាស់ នៅវិទ្យាល័យហេបភីច័ន្ទតារានារីព្រែកថ្មី តែប៉ុណ្ណោះ។ តែខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងក្លាយជាមិត្តដ៏ល្អ និងជាឯកសារជំនួយស្មារតីមួយសម្រាប់ប្អូនៗ និងមិត្តអ្នកអាន។

ខ្ញុំបាទសូមគោរពអធ្យាស្រ័យរាល់កំហុសដោយអចេតនាណាមួយ ដែលកើតមានក្នុងសៀវភៅនេះ ហើយយើងខ្ញុំរីករាយទទួលយកនូវមតិរិះគន់ស្ថាបនាពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន។

**ថ្ងៃចន្ទ ទី១៤ ខែមីនា ឆ្នាំ២០២២**

**ទី សុផល**

# កម្រងវិញ្ញាសាសម្រាប់ជំនួយស្មារតី

## វិញ្ញាសាត្រៀមទី១

**ប្រធាន**

1. ដូចម្តេចដែលហៅថា សមាគមអាស៊ាន? តើសមាគមអាស៊ានមានសមាជិកប៉ុន្មានប្រទេស? ចូររៀបរាប់។
2. តើកត្តាអ្វីខ្លះដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ (សកលភាវូបនីយកម្ម)?
3. ចូរពណ៌នាពីនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម ។
4. សង្គ្រាមនៅកម្ពុជាក្នុងឆ្នាំ១៩៧០-១៩៧៥, ១៩៧៩-១៩៩៨ និងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?
5. មូលហេតុអ្វីបានជាគេចាត់ទុកថា សម្តេចនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា?
6. តើព្រះបាទអង្គដួងមានតួនាទីអ្វីខ្លះក្នុងប្រវត្តិសាស្ត្រកម្ពុជា?

## អត្រាកំណែ

១-សមាគមអាស៊ាន គឺជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ សមាគមអាស៊ានមានសមាជិកចំនួន១០ ប្រទេសគឺ

- ថៃ ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧
- ម៉ាឡេស៊ី ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧
- សិង្ហបុរី ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧
- ហ្វីលីពីន ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧
- ឥណ្ឌូនេស៊ី ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៦៧
- ព្រុយណេ ដារូសាលឹម ចូលជាសមាជិកអាស៊ាន ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៨៤
- វៀតណាម ចូលជាសមាជិកអាស៊ាន ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥
- មីយ៉ាន់ម៉ា ចូលជាសមាជិកអាស៊ាន ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧
- ឡាវចូលជាសមាជិកអាស៊ាន ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៧
- កម្ពុជាចូលជាសមាជិកអាស៊ាន ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩

២-កត្តាដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ(សកលភាវូបនីយកម្ម) មាន៖

- កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោកដែលជំរុញឱ្យកាន់តែលេចឡើងនូវអស្ថិរភាព និង ផលវិបាកចំពោះបញ្ហាផ្ទៃក្នុងប្រទេសនិងទំនាក់ទំនងរវាងប្រទេសលើសកលលោក
- បញ្ហារួមជាច្រើនបានកើនឡើងដែលទាមទារឱ្យមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំរដ្ឋាភិបាល អង្គការអន្តរជាតិ សហគមន៍អន្តរជាតិ និងសមាគមអន្តរជាតិ
- មានកំណើនខ្លាំងក្នុងការបំលាស់ទីលំនៅរបស់ប្រជាជនលើពិភពលោក
- មានការរីកចម្រើននូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ
- ការរីកសាយភាយនូវបច្ចេកវិជ្ជាយោធាទំនើប។

៣-ពណ៌នាពីនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម

## អត្ថន័យ

- នយោបាយអព្យាក្រឹតនៅក្នុងសម័យសង្គមរាស្ត្រនិយមមានន័យថា ជានយោបាយរបស់ប្រជាជាតិទាំងមូលដែលនយោបាយនេះតម្រូវឱ្យប្រកាន់នូវអាកប្បកិរិយាមួយ និងជាដាច់ខាតរវាងបក្សខាងលិច និងបក្សកុម្មុយនីស្ត គឺជាអាកប្បកិរិយាមិត្តភាពមួយជាមួយបក្សទាំងពីរនេះ ដែលតែងតែទទួលជំនួយទាំងអស់ណាដែលមិនធ្វើឱ្យសាបរលាបដល់អធិបតេយ្យភាព និងអព្យាក្រឹតរបស់កម្ពុជា។
- អព្យាក្រឹតរបស់កម្ពុជាដែលបានកសាងមកនេះបានដៅទុកជាច្បាស់ថា ត្រូវរាប់អានគួរសមនឹងប្រទេសជាតិទាំងឡាយឱ្យស្មើគ្នា កុំឱ្យមានធ្ងន់ស្រាលទោះបីប្រទេសនោះកាន់លទ្ធិយ៉ាងណាក៏ដោយ អព្យាក្រឹតរបស់កម្ពុជាធ្វើបដិសណ្ឋារកិច្ចមានសេចក្តីរាប់អាន ចំពោះមហាប្រទេសស្មើគ្នា មិនថាប្រទេសនោះជាពួកក្រុមខាងកើត ខាងលិច ឬអព្យាក្រឹតទេ។
- អព្យាក្រឹតនេះ តម្រូវឱ្យកម្ពុជារក្សាទុកភ្ជាប់នៅតុល្យភាពពេញលក្ខណៈរវាងប្រជាជាតិទាំងឡាយ ហើយឱ្យកម្ពុជាទប់ទល់តស៊ូមិនព្រមចាញ់ មិនព្រមស្រយុត មិនព្រមរំលែកឱ្យដាច់ខាតចំពោះការគាបសង្កត់ ឬគំរាមរបស់ជាតិណាក៏ដោយ ហើយអព្យាក្រឹតដែលយើងបានស្ថាបនានេះបរិសុទ្ធល្អមែនហើយ តែបរិសុទ្ធពេកទៅ យើងដុសខាត់លាងទឹកឱ្យស្អាតពេកទៅ រហូតអស់ជាតិដៅទៅជារីងរាំង។

## មូលហេតុនៃការប្រកាន់យកនយោបាយអព្យាក្រឹតនៅក្នុងរបបសង្គមរាស្ត្រនិយម

- នយោបាយអព្យាក្រឹតត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវ ឆ្នាំ១៩៥៤។ សេចក្តីសម្រេចនេះគឺជាការទាមទាររបស់ចិន និងសូវៀតដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាម៉េរិក កសាងមូលដ្ឋានទ័ពនៅកម្ពុជា
- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌាសម្តេចព្រះនរោត្តមសីហនុ បានចុះហត្ថលេខាជាមួយលោក នេរុ(នាយករដ្ឋមន្ត្រីឥណ្ឌា) លើសេចក្តីប្រកាសរួមគឺការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព

- នៅថ្ងៃទី១៨-២៤ ខែមេសាឆ្នាំ ១៩៥៥ ក្នុងសន្និសីទប្រទេសអាស៊ី-អាហ្វ្រិកនាក្រុងបានឌុង(ឥណ្ឌូនេស៊ី) ទ្រង់បានធ្វើសេចក្តីអះអាងអំពីកម្មវិធីនយោបាយអព្យាក្រឹតរបស់កម្ពុជា និងការរួមរស់ជាមួយគ្នាដោយសន្តិភាព។ ក្នុងឱកាសនោះ ទ្រង់បានជួបជាមួយមេដឹកនាំចិន ជូអេនឡាយ និងមេដឹកនាំវៀតណាម ផាម វ៉ាន់ដុងដែលប្រទេសទាំងពីរសុទ្ធតែបានប្រកាសពីការកសាងទំនាក់ទំនងជាមួយកម្ពុជា ដោយឈរលើគោលការណ៍ គោរពសិទ្ធិគ្នាទៅវិញទៅមក គោរពអធិបតេយ្យភាព បូរណភាពទឹកដី និងមិនលូកដៃចូលបញ្ហាផ្ទៃក្នុងរបស់ប្រទេសជិតខាង។
- នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ។ នៅក្នុងឱកាសនោះតំណាងរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការដើរលើមាគ៌ានយោបាយអព្យាក្រឹត។

**ដើម្បីពង្រឹងនយោបាយអព្យាក្រឹត របបសង្គមរាស្ត្រនិយមបាន**

- ១៨ មីនា ១៩៥៥ ក្នុងដំណើរទស្សនកិច្ចនៅឥណ្ឌា សម្តេចនរោត្តម សីហនុ បានចុះហត្ថលេខាជាមួយលោក នេរុ លើសេចក្តីប្រកាសរួមមួយគឺការរួមរស់ជាមួយគ្នា ដោយសេចក្តីសុខសន្តិភាព
- ១៨-២៤ មេសា ១៩៥៥ ក្នុងសន្និសីទកំពូលនៃប្រជាជាតិអាស៊ី- អាហ្វ្រិក នាទីក្រុងបានឌុងព្រះអង្គបានប្រកាសពីនយោបាយអព្យាក្រឹត និងបានរួមរស់ជាមួយគ្នាដោយសន្តិភាព
- ១៤ ធ្នូ ១៩៥៥ ក្នុងពេលដែលកម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ កម្ពុជាបានប្រកាសពីមាគ៌ានយោបាយអព្យាក្រឹត
- ១៩៥៦ នៅទីក្រុងប្រ៊ីយូនី ព្រះអង្គបានចុះហត្ថលេខាលើធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ

**លទ្ធផលនៃការប្រកាន់នយោបាយអព្យាក្រឹត**

**ជំហានដំបូង**

- ធ្វើឱ្យកិត្យានុភាពកម្ពុជាល្បីសុះសាយក្នុងតំបន់
- ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ហើយទទួលស្គាល់គុណសម្បត្តិនៃនយោបាយអព្យាក្រឹត
- ប្រទេសកម្ពុជារស់ក្នុងសុខសន្តិភាពអស់រយៈពេល១៥ឆ្នាំ ក្នុងខណៈដែលប្រទេសជិតខាងដូចជាវៀតណាមស្ថិតក្នុងភ្លើងសង្គ្រាម។

**ដំណាក់កាលនៃសង្គ្រាមត្រជាក់**

នយោបាយអព្យាក្រឹតរបស់កម្ពុជាចុះខ្សោយ ដោយសារតែប្រទេសជាមហាអំណាចនៃប្លុកទាំងពីរមិនទុកកម្ពុជាក្នុងមាគ៌ាសន្តិភាព ហើយគេបានធ្វើសកម្មភាពប្រឆាំងនឹងនយោបាយអព្យាក្រឹតដូចជា៖

- សហរដ្ឋអាម៉េរិកផ្តល់ជំនួយដល់កម្ពុជាពិសេសជំនួយផ្នែកយោធាដែលជំនួយនេះមានទិសដៅ ចិញ្ចឹមពួកស្តាំនិយម។

- ប្រទេសថៃបានគាំទ្រសកម្មភាពខ្មែរសេរី ដែលជាកងទ័ពប្រឆាំងរាជរដ្ឋាភិបាល ដោយផ្តល់ដីឱ្យកសាងជុំរុំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម។
- កងទ័ពវៀតណាមខាងត្បូងបានធ្វើសកម្មភាពឈ្លានពានលើទឹកដីខ្មែរតាមព្រំដែន
- កងទ័ពវៀតណាមខាងជើងបានបង្កើតមូលដ្ឋានទ័ពលើទឹកដីខ្មែរនៅតាមព្រំដែន។ ពួកនេះបានបណ្តុះបណ្តាលកងកម្លាំងខ្មែរក្រហមដើម្បីធ្វើបដិវត្តន៍
- សកម្មភាពរបស់ប្រទេសខាងលើមានទិសដៅប្រឆាំងនឹងនយោបាយអព្យាក្រឹត។

**ការបញ្ចប់នយោបាយអព្យាក្រឹត**

- នយោបាយអព្យាក្រឹតត្រូវបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់ និងព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ ដែលមាននិន្នាការទៅរកសហរដ្ឋអាមេរិកដើម្បីទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីប្រមុខរដ្ឋ។

**មានចំណុចត្រឹមត្រូវផ្សេងទៀត**

៤-សង្គ្រាមនៅកម្ពុជា(១៩៧០-១៩៧៥), (១៩៧៩-១៩៩៨) និងរបបកម្ពុជាប្រជាធិបតេយ្យ នាំមកនូវផលវិបាកដល់កម្ពុជាដូចតទៅះ

**វិស័យសេដ្ឋកិច្ច**

- ដីស្រែ ចម្ការទុកចោលទំនេរក្លាយជាចម្ការមីន រណ្តៅគ្រាប់បែក
- រោងចក្រ សហគ្រាស ចម្ការកៅស៊ូត្រូវបំផ្លាញ
- បំផ្លាញហេដ្ឋារចនាសម្ព័ន្ធស្ពាន ផ្លូវថ្នល់ សំណង់បរិក្ខារផ្សេងៗ
- បាត់បង់ធនធាន និងអ្នកវិនិយោគទុនមិនហ៊ានចូលមក
- ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់

**វិស័យនយោបាយ**

- ប្រទេសកម្ពុជាបាត់បង់កេរ្តិ៍ឈ្មោះ កិត្តិយស លើឆាកអន្តរជាតិ
- ប្រជាជនបាត់ជំនឿលើថ្នាក់ដឹកនាំ និងអស់សង្ឃឹមលើជោគវាសនាប្រទេសជាតិ
- នាំប្រទេសទៅរកការសម្លាប់រង្គាលលើជាតិសាសន៍ឯង
- កម្ពុជាជាប្រទេសមួយរស់នៅដោយឯកោ

**វិស័យសង្គម**

- សម្លាប់មនុស្សអស់ជាងបីលាននាក់
- បន្សល់នូវអ្នកបួស ពិការ ក្មេងកំព្រា ស្ត្រីមេម៉ាយ
- បាត់បង់ធនធានមនុស្ស
- ព្រាត់ប្រាសគ្រួសារ ផ្ទះសម្បែង រងទុក្ខវេទនា គ្រោះទុរភិក្ស
- ជួបនូវអាណាធិបតេយ្យ ចោរកម្ម ពុករលួយ អយុត្តិធម៌
- បំបាត់សិទ្ធិសេរីភាពជំនឿសាសនា

**មានមតិផ្សេងៗទៀត**

៥- បានជាគេចាត់ទុកថា សម្តេចនរោត្តម សីហនុ និងសម្តេចហ៊ុន សែន ជាបិតាសន្តិភាពនៅកម្ពុជា៖

**សម្តេចនរោត្តម សីហនុ**

- ជាអ្នកនយោបាយជើងចាស់ដែលធ្លាប់នាំឯករាជ្យជូនកម្ពុជា
- ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារកសន្តិភាព
- ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC)
- ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១
- ជាអ្នកបង្រួបបង្រួមជាតិ ជាអ្នកផ្សះផ្សាជាតិដោយធ្វើការផ្សះផ្សាវិបត្តិក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ ដែលកើតចេញពីការដណ្តើមឥទ្ធិពលគ្នារវាងគណបក្សហ៊្វុនស៊ីនប៉ិច និងគណបក្សប្រជាជនកម្ពុជា បង្កើតបានជារដ្ឋាភិបាលចម្រុះ
- ជាអ្នកផ្សះផ្សារាល់វិបត្តិនយោបាយក្រោយការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ១៩៩៨-២០០៣
- មានមតិផ្សេងៗទៀត

**សម្តេចហ៊ុន សែន**

- ជាអ្នកនយោបាយវៃឆ្លាតផ្នែកការទូត
- ជាអ្នកផ្តួចផ្តើមឱ្យមានការចរចារកសន្តិភាព
- ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពនៅទីក្រុងប៉ារីស(២៣ តុលា ១៩៩១)
- ជាអ្នកធានាអះអាងសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ថ្ងៃទី២៣-២៨ ឧសភា ១៩៩៣
- ជាអ្នកផ្សះផ្សាវិបត្តិនយោបាយក្រោយបោះឆ្នោតឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៨ និងឆ្នាំ ២០១៣
- ជាអ្នកបញ្ចប់សង្គ្រាមស៊ីវិលទាំងស្រុងនៅកម្ពុជា ដោយអនុវត្តនយោបាយឈ្នះ-ឈ្នះ (យុទ្ធសាស្ត្រ ឈ្នះឈ្នះ)ដែលបានរំលាយអង្គការចាត់តាំងខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហម ឱ្យមកចូលរួមរស់ជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ នាំមកនូវសុខសន្តិភាពូបនីយកម្មនៅកម្ពុជា
- **មានមតិផ្សេងៗទៀត**

៦-ព្រះបាទអង្គដួង មានតួនាទីក្នុងប្រវត្តិសាស្ត្រកម្ពុជាដូចជា៖

**នយោបាយក្រៅប្រទេស**

- ផ្តើមគំនិតធ្វើទំនាក់ទំនងជាមួយបារាំង ដើម្បីបញ្ចៀសប្រទេសកម្ពុជាឱ្យរួចផុតពីការត្រួតត្រា ពីសំណាក់ សៀម និងអណ្ណាម

**កំណែទម្រង់**

- វិស័យរដ្ឋបាល៖ មានការរៀបចំរដ្ឋបាលខេត្ត ស្រុក ខណ្ឌ
- វិស័យហិរញ្ញវត្ថុ៖ បង្កើតរូបិយប័ណ្ណសម្រាប់ប្រើប្រាស់

- វិស័យវប្បធម៌
    - បង្កើតសាលារៀនតាមវត្ត
    - លើកទឹកចិត្តគ្រូបង្រៀន កវី បណ្ឌិត ដោយព្រះអង្គផ្ទាល់ជាអ្នកនិពន្ធ ដូចជារឿង ចំប៉ាថោង...
- វិស័យសេដ្ឋកិច្ច
    - មានប្រើរូបិយប័ណ្ណជាមធ្យោបាយក្នុងការដោះដូរ សម្រួលការធ្វើពាណិជ្ជកម្មទាក់ទាញឈ្មួញ ចិន ឥណ្ឌា
    - កសាងកំពង់ផែកំពត
    - កសាងផ្លូវពីឧដុង្គទៅកំពត
- វិស័យពន្ធដារ
    - បង្កើតឱ្យមានរបបភាសី ផ្តល់លទ្ធភាពឱ្យរដ្ឋរៀបចំថវិកាមួយដែលមានតុល្យភាព
    - ព្រះអង្គបញ្ជាមិនឱ្យគេដំឡើងពន្ធ។
- វិស័យសង្គម
    - ព្រះអង្គហាមមន្ត្រីមិនឱ្យផឹកស្រា អ្នកណាជក់អាភៀនត្រូវបណ្តេញចោល
    - ព្រះអង្គហាមមិនឱ្យធ្វើផ្ទស់បិទជិតស្ទឹង
    - ព្រះអង្គកាត់បន្ថយក្បួនដង្ហែរបស់មន្ត្រីធំៗ
    - ព្រះអង្គបញ្ជាឱ្យគេសង់សាលាធទានដើម្បីយាងទៅចែកបាយ សម្ល ដល់ប្រជារាស្ត្រក្រីក្រ

- សាសនា
    - ព្រះអង្គបានពិភាក្សាជាមួយព្រះសង្ឃអំពីបញ្ហាសាសនា និងអក្សរសាស្ត្រខ្មែរ ហើយព្រះអង្គបានយកចិត្តទុកដាក់លើធម្មយុត្តិកនិកាយ
    - ទំនុកបម្រុងព្រះពុទ្ធសាសនា ដោយកសាងវត្តអារាម
- **ចំណុចត្រឹមត្រូវផ្សេងៗទៀត**

# វិញ្ញាសាត្រៀមទី២

## ប្រធាន

1. តើអ្នកប្រាជ្ញខ្មែរឈ្មោះអ្វីដែលបានរៀបចំវចនានុក្រមខ្មែរ?
2. តើលោកប្រធានាធិបតីហ្វ្រង់គ្លីនរ៉ូស្វេលបានអនុវត្តវិធានការអ្វី ដើម្បីដោះស្រាយវិបត្តិសេដ្ឋកិច្ចពិភពលោកឆ្នាំ១៩២៩-១៩៣៣? ហើយក្នុងការអនុវត្តនោះដើម្បីព្យាបាលវិបត្តិសេដ្ឋកិច្ចពិភពលោកនេះ តើលោកប្រធានាធិបតីសហរដ្ឋអាម៉េរិកបានបង្កើតភ្នាក់ងារអ្វីខ្លះ ហើយភ្នាក់ងារនីមួយៗមានទិសដៅអ្វីខ្លះ?
3. ចូរពណ៌នាពីកត្តាសំខាន់ៗ ដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)ដួលរលំ។
4. ចូរពណ៌នាពីសមាជជាតិ ក្នុងសម័យសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០)។
5. ចូរពណ៌នាពីសមិទ្ធផលរាជរដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៩៣ ដល់ពេលបច្ចុប្បន្ន។

# អត្រាកំណែ

១-វចនានុក្រមខ្មែរបានរៀបចំឡើងដោយ **សម្តេចព្រះសង្ឃរាជ ជួនណាត។**

២-អនុវត្ត «វិធានការថ្មី(New deal)» គឺការជួយសង្គ្រោះសេដ្ឋកិច្ចជាបន្ទាន់តាមកំណែទម្រង់របស់រដ្ឋាភិបាល។ ហើយលោកបានបង្កើតភ្នាក់ងារដូចជា៖

- រដ្ឋបាលសហព័ន្ធ៖ ជួយអ្នកអត់ឃ្លាន និងគ្មានជំរក
- ភ្នាក់ងារកិច្ចការស៊ីវិល៖ បង្កើតមុខរបរឱ្យបានច្រើន
- កិច្ចការរដ្ឋបាលសាធារណៈ ជួយកសិករ បង្កើនប្រាក់ចំណូល
- ភ្នាក់ងារមូលនិធិសាជីវកម្មកម្ចី៖ ជួយប្រាក់ដល់ ប្រជាជន បង់ការប្រាក់ទៅម្ចាស់បំណុល ជៀសវាងការបាត់បង់ផ្ទះសំបែង
- ភ្នាក់ងារជួយយុវជនឱ្យមានការងារធ្វើ
- នៅឆ្នាំ១៩៣៣ បង្កើតច្បាប់ជួយធនាគារឱ្យបើកទ្វារឡើងវិញដោយរដ្ឋឱ្យខ្ចីប្រាក់។

៣-ពណ៌នាពីកត្តាសំខាន់ៗ ដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)ដួលរលំ

- ប្រជាជនតំបន់រំដោះ និងក្រុងភ្នំពេញនឿយណាយនឹងរបបសាធារណរដ្ឋខ្មែរដែលប្រកបដោយអំពើពុករលួយ និងពោរពេញដោយភាពអាប់អួរ
- ប្រជាជនភៀសសឹកមកកាន់ទីក្រុងភ្នំពេញដែលកើនប្រមាណពីរលាននាក់រស់នៅដោយបាត់បង់ការងារ ខ្វះស្បៀងអាហារ
- ទំនិញឡើងថ្លៃ
- ការដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវរបស់សហរដ្ឋអាម៉េរិកមកឧបត្ថម្ភប្រជាជនក្រុងភ្នំពេញ និងរបបសាធារណរដ្ឋខ្មែរ ត្រូវខ្មែរក្រហមកាត់ផ្តាច់ទាំងស្រុង
- នៅដើមខែមីនា ឆ្នាំ១៩៧៥ លោកលន់ នល់ បានភៀសខ្លួនតាមយន្តហោះចេញពីកម្ពុជា និងទៅរស់នៅសហរដ្ឋអាម៉េរិក

- ពួកខ្មែរក្រហមបានធ្វើការរឹតបន្តឹងការឡោមព័ទ្ធទីក្រុងភ្នំពេញ ពិសេសការនាំស្បៀងចូល
- ការចរចារវាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ និងរណសិរ្សរួបរួមជាតិខ្មែរដឹកនាំដោយសម្តេចនរោត្តម សីហនុ ពុំទទួលបានលទ្ធផលអ្វីសោះ
- សង្គមសាធារណរដ្ឋខ្មែរមានបញ្ហាពុករលួយ
- មានអំពើពុករលួយក្នុងជួរកងទ័ព គឺទាហានមានតែឈ្មោះអត់មនុស្ស(ទាហានខ្មោច)
- ទាហានក្នុងរបបសាធារណរដ្ឋខ្មែរបានចុះចូលជាមួយក្រុមខ្មែរក្រហម
- នៅខែមេសាឆ្នាំ១៩៧៥ ខ្មែរក្រហមវាយយកបានទីក្រុងភ្នំពេញ ។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-ពណ៌នាពីសមាជជាតិក្នុងសម័យសង្គមរាស្រ្តនិយម(១៩៥៥-១៩៧០)

សមាជជាតិត្រូវបាន«សង្គមរាស្រ្តនិយម» រៀបចំឡើង២៨ដង ដែលលើកទី១ ប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៥ ដោយមានការចូលរួមពីមហាជនគ្រប់ស្រទាប់ និងតំណាងបក្សផ្សេងៗ។

- សមាជជាតិប្រារព្ធឡើងក្នុងមួយឆ្នាំពីរដង ដែលមានសម្តេចនរោត្តម សីហនុ ជាប្រធាន
- សមាជជាតិគឺជាស្ថាប័ននយោបាយរបស់រដ្ឋដែលទាមទារឱ្យមានជំនួបរវាងប្រជាពលរដ្ឋ និងមន្រ្តីនៃរាជរដ្ឋាភិបាលដើម្បីពិភាក្សាអំពីប្រយោជន៍ជាតិ
- សមាជជាតិនេះត្រូវបានធ្វើឡើង២ដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សាទៅលើបញ្ហាសំខាន់ៗដែលទាក់ទងទៅនឹងនយោបាយក្នុង និងក្រៅប្រទេសហើយសមាជជាតិនេះមានតួនាទីសំខាន់នៅក្នុងវិស័យនយោបាយរបស់ប្រទេសកម្ពុជា។
- គណៈកម្មាធិការកណ្តាលសង្គមរាស្រ្តនិយមនឹងរៀបចំសមាជជាតិ ហើយត្រូវដឹកនាំដោយសម្តេចព្រះនរោត្តម សីហនុ ផ្ទាល់ព្រះអង្គ។
- នៅក្នុងសមាជជាតិលើកទី២ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៥-២៦ ខែកញ្ញា ឆ្នាំ ១៩៥៥ គេបានពិភាក្សាគ្នាស្តីពីការផ្តល់នូវសិទ្ធិបោះឆ្នោតដល់ស្ត្រីខ្មែរ និងគោលការណ៍នៃការជ្រើសរើសសភាខេត្ត ។
- សមាជអាចសម្រេចឱ្យមានការបោះឆ្នោតដកតំណាងរាស្រ្តពីមុខតំណែង ទោះបីតំណាងរាស្រ្តនោះកំពុងស្ថិតនៅក្នុងនីតិកាលនៃរដ្ឋសភាក៏ដោយ។
- សមាជជាតិលើកទី២ បានយល់ព្រមទទួលយកជំនួយរបស់សហរដ្ឋអាម៉េរិកទាំងស្រុង
- សមាជជាតិលើកទី ៣ ដែលប្រព្រឹត្តិទៅនៅថ្ងៃទី ២១-២២ ខែមេសា ឆ្នាំ១៩៥៦ បានផ្តល់ការយល់ព្រមស្តីពីការប្រកាន់យកនយោបាយអព្យាក្រឹត្យរបស់កម្ពុជានៅក្នុងឆាកអន្តរជាតិ និងការជជែកពិភាក្សាគ្នាអំពីបញ្ហាធ្វើឧស្សាហូបនីយកម្ម។
- សមាជជាតិសម័យសង្គមរាស្រ្តនិយមបានធ្វើឡើងចំនួន ២៨ដង ហើយសមាជជាតិលើកទី២៨ គឺជាសមាជចុងក្រោយបំផុតរបស់សង្គមរាស្រ្តនិយមបានប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៦៩។
- សមាជជាតិជាអង្គការថ្មីមួយដែលសង្គមរាស្រ្តនិយម បានបង្កើតឡើងដើម្បីបើកសេរីភាពឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់មជ្ឈដ្ឋានមិនប្រកាន់ថា អ្នកមាន អ្នកក្រ ឬមន្ត្រីជាន់

ខ្ពស់ឡើយ មកបញ្ចេញមតិយោបល់ទាក់ទងទៅនឹងជីវភាពនយោបាយទាំងក្នុងនិងក្រៅប្រទេស។ សមាជជាតិជាវេទិកាដែលមានលក្ខណប្រជាធិបតេយ្យផ្ទាល់ ហើយអាចសាកសួរចំពោះស្ថាប័នថ្នាក់កំពូលរបស់ជាតិ មានរដ្ឋសភា រដ្ឋាភិបាលជាដើម។

- សមាជជាតិមានតួនាទីអនុម័តលើសេចក្ដីសម្រេចផ្សេងៗដើម្បីដាក់ជូនរដ្ឋាភិបាល និងរដ្ឋសភាជាតិពិនិត្យ ហើយរដ្ឋសភាអាចចាត់ចែងធ្វើប្រជាមតិចំពោះបញ្ហាណាដែលជាសេចក្ដីសម្រេចរបស់សមាជ។
- វេទិកាសមាជនេះជាការបើកសិទ្ធិឱ្យប្រជាពលរដ្ឋខ្មែរធ្វើការរិះគន់ទៅលើមន្ត្រីរដ្ឋាភិបាល សមាជិករដ្ឋសភាណាដែលបានប្រព្រឹត្តផ្ទុយនឹងច្បាប់។
- សមាជប្រៀបបានដូចជាស្ពានសម្រាប់តភ្ជាប់ព័ត៌មានពីថ្នាក់មូលដ្ឋានមកថ្នាក់ជាតិសម្រាប់ជាមធ្យោបាយទ្រទ្រង់ និងការពារអធិបតេយ្យប្រជារាស្ត្រខ្មែរទូទៅ។
- ហេតុដែលបើកអំណាចឱ្យប្រជារាស្ត្រទូទៅ ដើម្បីចូលមកសម្រេចកិច្ចការប្រទេសជាតិជាមួយនឹងថ្នាក់ដឹកនាំប្រទេស ជាការពិសោធដែលប្រទេសឯទៀតពុំហ៊ានធ្វើ។
- តែការបើកឱ្យមានសមាជនេះគឺមានផលវិជ្ជមាន និងអវិជ្ជមាន។ លទ្ធផលជាវិជ្ជមានគឺបានធ្វើឱ្យមន្ត្រីរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សមាជិករដ្ឋសភាមានការយកចិត្តទុកដាក់ និងប្រយ័ត្នប្រយែងក្នុងការបំពេញការងាររបស់ខ្លួន។ សមាជវាហាក់ដូចជាបន្ទាត់ច្បាប់មួយទៀតដែលសម្រាប់ឱ្យមន្ត្រីរាជការអនុវត្តតាម។ ប្រសិនបើសមាជជាតិជាមធ្យោបាយស័ក្តិសិទ្ធិការពារសិទ្ធិប្រជារាស្ត្រទូទៅ មន្ត្រីអ្នករាជការតូចតាច និងជាបន្ទាត់តម្រង់ផ្លូវនយោបាយអំណាចនីតិបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិជាដើមនោះ ប្រជារាស្ត្រខ្មែរពិតជាចាត់ទុកថា សមាជជាតិជាទ្រព្យសម្បត្តិដ៏ធំធេងរបស់គេ។
- សមាជបានធ្វើឱ្យថមថយតម្លៃរបស់ខ្លួននៅខែធ្នូ ឆ្នាំ១៩៦៨ នៅពេលដែលអង្គសមាជយល់ព្រមតាមសំណើដែលឱ្យយោបល់ដោយសម្ដេចព្រះនរោត្តម សីហនុ ក្នុងការបង្កើតកាស៊ីណូមួយដែលមិនស្របនឹងមតិសាធារណៈ។
- សមាជចុងក្រោយនេះមានការប៉ះទង្គិចមតិគ្នាយ៉ាងធ្ងន់ធ្ងររវាងវាគ្មិនដែលបានចូលរួមក្នុង អង្គសមាជ និងថ្នាក់ដឹកនាំសមាជជាតិ។
- សមាជជាតិសម្រេចបានសមិទ្ធផលជាច្រើនដូចជា ៖
  - ការប្រឆាំងនឹងអំពើពុករលួយ
  - ការកំណត់ភាសាខ្មែរជាភាសាផ្លូវការ
  - សភាតំណាងរាស្ត្រមានសិទ្ធិចូលរួមក្នុងការកែលម្អសកម្មភាពរដ្ឋបាលនិងទាមទារឱ្យដាក់ទណ្ឌកម្មចំពោះមន្ត្រីអសកម្ម។

៥-សមិទ្ធផលរាជរដ្ឋាភិបាលពីឆ្នាំ១៩៩៣ ដល់ពេលបច្ចុប្បន្ន

**នយោបាយក្នុងប្រទេស**

- រាជរដ្ឋាភិបាល បានអនុវត្តនយោបាយយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ
- អនុវត្តនយោបាយឈ្នះ-ឈ្នះ (ដោយរំលាយអង្គការចាត់តាំងខ្មែរក្រហម និងធ្វើសមាហរណកម្មកងកម្លាំងខ្មែរក្រហមឱ្យមកចូលរួមរស់ជាមួយរាជរដ្ឋាភិបាលនៅឆ្នាំ១៩៩៨ នាំមកនូវសន្តិភាពរូបនីយកម្មនៅកម្ពុជា)
- រៀបចំការបោះឆ្នោតដោយខ្លួនឯង ប្រកបដោយជោគជ័យទៅតាមលទ្ធិប្រជាធិបតេយ្យនៅឆ្នាំ១៩៩៨
- កំណែទម្រង់គ្រប់វិស័យ (អប់រំ រដ្ឋបាល តុលាការ និងកម្លាំងប្រដាប់អាវុធ)
- កម្ពុជាប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស
- លើកកម្ពស់សិទ្ធិមនុស្ស និងសមភាពយេនឌ័រ
- ឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាសមាជិក អាស៊ាន (ASEAN)
- ឆ្នាំ២០០៤ កម្ពុជាបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO)
- កម្ពុជាបានក្លាយជាប្រធានអាស៊ានវិលជុំ៣លើកនៅឆ្នាំ២០០២ ,២០១២ និង ២០២២
- ក្នុងនាមជាប្រធានអាស៊ាននៅឆ្នាំ២០១២ និង២០២២ រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមក្នុងការពិភាក្សា ផ្តល់យោបល់ដល់ប្រទេសភូមា ក្នុងជម្លោះនយោបាយ
- កម្ពុជាមានទំនាក់ទំនងល្អជាមួយប្រទេសក្នុងតំបន់ និងពិភពលោក
- ចូលរួមថែរក្សាសន្តិភាពពិភពលោក (កងទ័ពមួកខៀវ...)

**ផ្នែកសេដ្ឋកិច្ច៖**

- កសិកម្មមានការរីកចម្រើនដោយរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការបង្កើតប្រព័ន្ធធារាសាស្ត្រ ការបង្កាត់ពូជ...
- អនុវត្តសេដ្ឋកិច្ចទីផ្សារសេរី កម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
- វិស័យឧស្សាហកម្មមានការរីកចម្រើនផ្នែករោងចក្រ សហគ្រាស
- ការធ្វើពាណិជ្ជកម្មក៏មានភាពងាយស្រួលជាងមុន
- ប្រជាពលរដ្ឋអាចរកការងារធ្វើបានយ៉ាងទូលំទូលាយក្នុងប្រទេស និងក្នុងតំបន់
- សេដ្ឋកិច្ចមានកំណើនខ្ពស់ក្នុងរយៈពេលវែង និងចំណូលថវិកាក៏ឡើងជាប្រចាំ
- មានកំណើនទេសចរដែលនាំឱ្យមានកំណើនការងារ និងប្រាក់ចំណូលដល់ប្រជាជន
- ការចូលជាសមាជិកអាស៊ានជាផ្នែកមួយដែលជំរុញឱ្យសេដ្ឋកិច្ចមានកំណើនជារៀងរាល់ឆ្នាំផងដែរ
- មានការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ពាន ផ្លូវអាកាស ផ្លូវដែក និងផ្លូវថ្នល់ និងពង្រីកអាកាសយានដ្ឋាន ព្រមទាំងការលើកលែងទិដ្ឋាការ។

- កម្ពុជាអាចរក្សាលំនឹងសេដ្ឋកិច្ចរបស់ខ្លួនបានក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ តាំងពីឆ្នាំ២០១៩ មក

**វិស័យសង្គម**

- កសាងសាលារៀនពីទីក្រុង ដល់ជនបទដាច់ស្រយាល
- ផ្តល់អាហារូបករណ៍ សម្រាប់និស្សិតបានធ្វើឱ្យមន្ត្រីរាជការប្រជាជន និងយុវជនកម្ពុជាបានរៀនសូត្រ និងទទួលបានឱកាសល្អៗជាច្រើនទៀត។
- បង្កើត និងជួសជុលកីឡដ្ឋានបណ្តុះបណ្តាលជំនាញ កីឡាទទួលបានមេដាយប្រាក់ សំរិទ្ធ មាស លើឆាកអន្តរជាតិ។
- អភិរក្សសម្បត្តិវប្បធម៌ទាំងរូបី និងអរូបី ព្រមទាំងបានដាក់បញ្ចូលសម្បត្តិវប្បធម៌
- កម្ពុជាជាបេតិកភណ្ឌពិភពលោក(រមណីយដ្ឋានអង្គរ ប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក របាំព្រះរាជទ្រព្យ ល្ខោនស្រមោលស្បែកធំ ចាប៉ីដងវែង..)។
- កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុង ការថែរក្សាសន្តិភាព និងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម
- មានការកសាងមណ្ឌលសុខភាព មន្ទីរពេទ្យ នៅតាមឃុំ សង្កាត់ ស្រុក ខណ្ឌ
- មានសេរីភាពសារព័ត៌មាន និងអនុញ្ញាតិឱ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- សមភាពយេនឌ័រ (ផ្តល់សិទ្ធិដល់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត)
- មានការជួយគ្នាទៅវិញទៅមករវាងប្រទេសសមាជិកតាមរយៈការផ្ទេរបទពិសោធ។
- យកចិត្តទុកដាក់ចំពោះសិស្ស និស្សិត ក្នុងការថែរក្សាសុខភាព ផ្តល់វ៉ាក់សាំងការពារជំងឺកូវីដ១៩
- បានយកចិត្តទុកដាក់ក្នុងការថែរក្សាសុខភាពប្រជាជន និងផ្តល់វ៉ាក់សាំងការពារកូវីដ១៩ ជូនកុមារចាប់ពីអាយុ៣ឆ្នាំនិងពលរដ្ឋទូទៅ
- គោលការណ៍ណែនាំ«៣កុំ ៣ការពារ»។

**មានមតិផ្សេងៗទៀត**

## វិញ្ញាសាត្រៀមទី៣

**ប្រធាន**

1. តើមូលហេតុអ្វីបានជាព្រះបាទ នរោត្តម សីហនុ បានដាក់រាជ្យជូនព្រះបិតា និងបង្កើតអង្គការ«សង្គម»?
2. តើមូលហេតុអ្វីបានជាកម្ពុជាប្រកាន់យកនយោបាយអព្យាក្រឹត?
3. តើនយោបាយអព្យាក្រឹតផ្តល់ផលវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះដល់កម្ពុជា?
4. តើជម្លោះប្រដាប់អាវុធដែលធ្លាប់កើតមាននៅកម្ពុជាប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចយ៉ាងដូចម្តេចខ្លះ?
5. តើការជម្លៀសប្រជាជន ពលកម្មដោយបង្ខំ និងការបំបាត់កម្មសិទ្ធិឯកជនផ្តល់ផលវិបាកអ្វីខ្លះដល់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរហូតមកដល់បច្ចុប្បន្ន?
6. តើហេតុអ្វីបានជាពិភពលោក ត្រូវបែងចែកជាពីរប្លុក ក្រោយសង្គ្រាមលោកលើកទី២?

## អត្រាកំណែ

១-បានជាសម្តេចព្រះនរោត្តម សីហនុ បានដាក់រាជ្យជូនព្រះបិតា និងបង្កើតអង្គការសង្គមរាស្ត្រនិយម ព្រោះ៖

- បើតាមគុណធម៌វិញគឺប្រហែលព្រះអង្គធ្វើឡើងដើម្បីតបស្នងសងគុណចំពោះព្រះគុណូបការៈរបស់ព្រះរាជបិតាព្រះអង្គមានជំនឿដោយស្មោះស្ម័គ្រថា ព្រះរាជកិច្ចរបស់ព្រះអង្គជា ព្រះមហាក្សត្រសោយរាជ្យនោះបានចប់សព្វគ្រប់ហើយក្រោយថ្ងៃ០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣
- ព្រះអង្គជារាជាដែលត្រូវទទួលបន្ទុកមួយទៀតគឺការដោះស្រាយបញ្ហាសង្គមនិងការពង្រីករបៀបប្រជាធិបតេយ្យ ពិតប្រាកដ ដោយរំលាយស្ថានភាពមួយដែលអំណាចរាជការប្រមូលផ្តុំទៅក្នុងកណ្តាប់ដៃឯកសិទ្ធនៃជនមួយក្រុមតូច។
- ព្រះអង្គឈ្វេងយល់ថាព្រះមហាក្សត្រសោយរាជ្យ និងបំពេញកិច្ចការនេះពុំបានឡើយ
- បំណងប្រាថ្នាមួយដើម្បីបម្រើប្រជាជាតិខ្មែរ
- មានគោលដៅរំលាយគណបក្សផ្សេងៗតាមរយៈការបង្កើតចលនាសង្គមរាស្ត្រនិយម។
- មានចម្លើយត្រឹមត្រូវផ្សេងទៀត។

២-មូលហេតុបានជាប្រទេសកម្ពុជាប្រកាន់នយោបាយអព្យាក្រឹត៖

- នយោបាយអព្យាក្រឹតត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចនៃសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤។ សេចក្តីសម្រេចនេះគឺជាការទាមទាររបស់ចិន និងសូវៀតដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាម៉េរិក កសាងមូលដ្ឋានទ័ពនៅកម្ពុជា។
- នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៥ ក្នុងដំណើរទេស្សនកិច្ចនៅឥណ្ឌាសម្តេច នរោត្តម សីហនុ បានចុះហត្ថលេខាជាមួយលោក នេរុ (នាយករដ្ឋមន្ត្រីឥណ្ឌា) លើសេចក្តីប្រកាសរួមគឺការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព។

- នៅថ្ងៃទី១៨-២៤ ខែមេសា ឆ្នាំ១៩៥៥ ក្នុងសន្និសីទប្រទេសអាស៊ី-អាហ្វ្រិកនាក្រុងបានឌុង(ឥណ្ឌូណេស៊ី) ទ្រង់បានធ្វើសេចក្តីអះអាងអំពីកម្មវិធីនយោបាយអព្យាក្រឹតរបស់កម្ពុជា និងការរួមរស់ជាមួយគ្នាដោយសន្តិភាព។ ក្នុងឱកាសនោះ ទ្រង់បានជួបជាមួយមេដឹកនាំចិន ជូអេនឡាយ និងមេដឹកនាំវៀតណាម ផាម វ៉ាន់ដុងដែលប្រទេសទាំងពីរសុទ្ធតែបានប្រកាសពីការកសាងទំនាក់ទំនងជាមួយកម្ពុជា ដោយឈរលើគោលការណ៍ គោរពសិទ្ធិគ្នាទៅវិញទៅមក គោរពអធិបតេយ្យភាពបូរណភាពទឹកដីនិងមិនលូកដៃចូលបញ្ហាផ្ទៃក្នុងរបស់ប្រទេសជិតខាង។
- នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៥៥ កម្ពុជាបានចូលជាសមាជិកអង្គការសហប្រជាជាតិ។ នៅក្នុងឱកាសនោះតំណាងរាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការដើរលើមាគ៌ានយោបាយអព្យាក្រឹត។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៣-ផលវិជ្ជមាន និងផលអវិជ្ជមាននៃនយោបាយអព្យាក្រឹតៈ

**ផលវិជ្ជមាន**

- ធ្វើឱ្យកិត្យានុភាពកម្ពុជាល្បីសុះសាយក្នុងតំបន់
- ក្រុមអ្នកប្រឆាំងពុំហ៊ានប៉ះពាល់ ហើយទទួលស្គាល់គុណសម្បត្តិនៃនយោបាយអព្យាក្រឹត
- ប្រទេសកម្ពុជារស់ក្នុងសុខសន្តិភាពអស់រយៈពេល១៥ឆ្នាំ ក្នុងខណៈដែលប្រទេសជិតខាងដូចជាវៀតណាមស្ថិតក្នុងភ្លើងសង្គ្រាម។
- កម្ពុជាអាចទទួលយកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីអភិវឌ្ឍប្រទេសជាតិ
- កម្ពុជាមានសេរីភាពក្នុងការទំនាក់ទំនងជាមួយប្រទេសដទៃដោយមិនប្រកាន់នូវមនោគមវិជ្ជា
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

**ផលអវិជ្ជមាន**

- ប្រទេសថៃបានគាំទ្រសកម្មភាពខ្មែរសេរីដែលជាកងទ័ពប្រឆាំងរាជរដ្ឋាភិបាល
- ថៃបានផ្តល់ដីឱ្យកសាងជុំរុំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម
- អាម៉េរិកគាំទ្រពួកស្តាំនិយម
- វត្តមានពួកទ័ពយៀកកុង និងវៀតណាមខាងជើងកាន់តែច្រើនឡើងនៅប្រទេសកម្ពុជា
- នយោបាយអព្យាក្រឹតត្រូវបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។
- ធ្វើឱ្យបែកបាក់ផ្ទៃក្នុង
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-ជម្លោះប្រដាប់អាវុធបានប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ចដូចជា៖

សេដ្ឋកិច្ចរបស់ប្រទេសជាតិរីកចម្រើនបានគឺអាស្រ័យដោយធនធានមនុស្ស និងមានកត្តារួមផ្សំពីវិស័យផ្សេងៗដូចជា វិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម វិស័យឧស្សាហកម្ម វិស័យកសិកម្ម និងសកម្មភាពវិជ្ជមាននានាក្នុងសង្គម។ ដូចនេះហើយនៅពេលមានសង្គ្រាមសង្គមទាំងមូលនឹងជួបនូវបញ្ហាជាទម្ងន់ ហើយនាំឱ្យប៉ះពាល់ដល់សេដ្ឋកិច្ចដូចជា៖

- បាត់បង់អ្នកចេះដឹងមួយចំនួនដោយសារសង្គ្រាម
- ប្រជាជនសកម្មត្រូវបានស្លាប់ដោយសារតែបុរសត្រូវទៅធ្វើទាហាន និងបន្សល់នូវប្រជាជនទន់ខ្សោយដូចជាចាស់ជរា ជនពិការ និងស្ត្រីមេម៉ាយ។
- គ្រឹះស្ថានបណ្តុះបណ្តាលនានាអាចបញ្ឈប់ និងអាក់ខានជាញឹកញាប់
- ដីកសិកម្មត្រូវបានបំផ្លាញ
- ពុំមានកសិផលសម្រាប់ប្រកួតប្រជែងជាមួយបរទេស
- ទេសចរមានការធ្លាក់ចុះ
- ឧស្សាហកម្ម សិប្បកម្មឈប់ដំណើរការ និងមិនមានការប្រកួតប្រជែងជាមួយប្រទេសជិតខាង និងប្រទេសដទៃផ្សេងទៀតដែលនាំឱ្យឧស្សាហកម្មនិងសិប្បកម្មមានការធ្លាក់ចុះ។
- ចំនួនវិនិយោគគិនថយចុះ ឬក៏មិនមាន
- ហានិភ័យក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ច
- ប្រជាជនឥតការងារធ្វើ
- ទំនិញឡើងថ្លៃ
- សង្គមទាំងមូលពោរពេញទៅដោយជម្លោះប្រដាប់អាវុធជាហេតុនាំឱ្យគ្មានពេលអភិវឌ្ឍវិស័យសេដ្ឋកិច្ច
- អត្រាស្លាប់មានការកើនឡើង
- ហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំផ្លាញដែលជំរុញឱ្យមានការចំណាយបន្ថែម
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៥-ការជម្លៀសប្រជាជន ពលកម្មដោយបង្ខំ និងការបំបាត់កម្មសិទ្ធិឯកជនផ្តល់ផលវិបាកដល់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងរហូតមកដល់បច្ចុប្បន្ន៖

**ក.ប្រទេសជាតិ**

- បាត់បង់កិត្តិយសលើឆាកអន្តរជាតិ
- ត្រូវបានពិភពលោកស្គាល់ថាជាប្រទេសធ្លាប់ជាវាលពិឃាដ
- បាត់បង់នូវកិត្យានុភាពជាតិ
- សេដ្ឋកិច្ចជាតិមានការអន់ថយ
- កាត់ផ្តាច់នូវនិរន្តរភាពជាតិ
- កម្ពុជាពេលនោះក្លាយទៅជាវាលពិឃាដ

ខ.ប្រជាជន

- បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា
- ប្រជាជននៅសម័យនោះហូបមិនគ្រប់គ្រាន់ ខ្វះជីវជាតិ
- អ្នកចេះដឹងមួយចំនួនរស់នៅដោយការលាក់ខ្លួន
- បាត់បង់អ្នកចេះដឹង
- ប្រជាជននៅក្នុងរបបនោះបាត់បង់នូវសាសនា វប្បធម៌ ប្រពៃណី
- ប្រជាជននៅក្នុងរបបងាយរងគ្រោះគ្រប់បែបយ៉ាង គ្មានពេទ្យ គ្មានច្បាប់សម្រាប់ការពារពួកគាត់
- ប្រជាជនរាប់សែននាក់ រត់ចាកចេញពីប្រទេស
- គ្រាប់មីនរាប់លានត្រូវបានកប់ក្នុងដី បណ្តាលឱ្យមនុស្សស្លាប់ និងពិការ
- ប្រជាជនកម្ពុជា បានទទួលរងនូវជំងឺវិបត្តិផ្លូវចិត្ត
- បញ្ញវន្ត មន្ត្រី មេសាសនា ប្រជាជនស្លូតត្រង់ ត្រូវបានស្លាប់
- កាត់បន្ថយសមត្ថភាព ក្នុងការស្តារ កសាង អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក្រោយឆ្នាំ១៩៧៩
- អ្នកប្រឆាំងត្រូវបានសម្លាប់
- សិទ្ធិសេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...។
- ប្រជាជនដែលបន្សល់ពីរបបខ្មែរក្រហមមានជំងឺបាក់ស្បាត
- **ចម្លើយត្រឹមត្រូវផ្សេងទៀត**

**គ.ចំពោះប៉ុល ពត និងមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតដែលជាជនជាតិខ្មែរដែរ**

- ខូចកេរ្តិ៍ឈ្មោះ
- ជាប់ឈ្មោះក្នុងប្រវត្តិសាស្ត្រថាជាមេដឹកនាំផ្តាច់ការ សម្លាប់ជាតិសាសន៍ឯង និងមនុស្សជាតិ
- ប្រជាជនស្អប់នាំឱ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះកូន ចៅ សាច់ញាតិរបស់ខ្លួន និងប្រជាជនផ្សេងទៀត
- **ចម្លើយត្រឹមត្រូវផ្សេងទៀត**

៦-ក្រោយសង្គ្រាមលោកលើកទី២ ពិភពលោកត្រូវបានបែងចែកជាពីរប្លុកដោយសារៈ

- ការបែងចែកផលប្រយោជន៍ មិនស្មើគ្នាក្រោយសង្គ្រាម ដណ្តើមអនុត្តរភាព តាមសន្និសីទក្រុងយ៉ាល់តា និងសន្និសីទ ពតស្តាំ(Potsdam) ឆ្នាំ១៩៤៥ ស្តីពីការបែងចែកទ្វីបអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២
    - ការបែងចែកទឹកដីអាល្លឺម៉ង់ដោយមហាអំណាចទាំងបួន ជាបួនតំបន់កាន់កាប់
    - ការបែងចែកទីក្រុងប៊ែរឡាំងជាបួនផ្នែក
    - ភាពទ័លច្រកផ្នែកនយោបាយ និងភាពប្រេះឆាគ្នា នៃមហាអំណាចសម្ព័ន្ធមិត្ត ដែលធ្វើឱ្យដំណោះស្រាយពីបញ្ហាអាល្លឺម៉ង់ ត្រូវបរាជ័យ
    - សូវៀតសន្យាវាយជប៉ុន និងធ្វើឱ្យជប៉ុនបរាជ័យក្រោយអាល្លឺម៉ង់ចាញ់សង្គ្រាម៣ខែ
- ឥទ្ធិពលនៃសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)
    - នៅក្នុងសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើនគ្រប់គ្រងដោយអាល្លឺម៉ង់
    - នៅចុងបញ្ចប់នៃសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ត្រូវរំដោះដោយសូវៀត និងអាម៉េរិក
    - សេដ្ឋកិច្ចទ្វីបអឺរ៉ុបចុះទន់ខ្សោយ ងាយទទួលរងឥទ្ធិពល ហើយអឺរ៉ុបត្រូវពឹងផ្អែកលើជំនួយ អាម៉េរិក និងសូវៀត
- ការប្រជែងគ្នារបស់មហាអំណាចពីរគឺ សហរដ្ឋអាម៉េរិក និងសហភាពសូវៀត
    - នៅក្នុងសង្គ្រាម មហាអំណាចសហរដ្ឋអាម៉េរិក អង់គ្លេស និងសូវៀត បានរួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងណាស៊ីអាល្លឺម៉ង់ តែមហាអំណាចទាំងនេះមានលក្ខណៈប្លែកគ្នាទាំងស្រុង ទាំងផ្នែកមនោគមវិជ្ជានយោបាយ និងសេដ្ឋកិច្ច
    - ការមិនទុកចិត្តគ្នារវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀតនៅចុងបញ្ចប់នៃសង្គ្រាម
    - ការប្រជែងមនោគមវិជ្ជា នយោបាយ បែបប្រជាធិបតេយ្យសេរី និងកុម្មុយនីស្ត
    - ការប្រជែងផ្នែកសេដ្ឋកិច្ច តាមបែបមូលធននិយម និងសង្គមនិយម
    - ការប្រជែងផ្នែកសព្វាវុធ អាវុធនុយក្លេអ៊ែរ ព្រមទាំងការប្រជែងបច្ចេកវិជ្ជា និងការទូត
    - ឥទ្ធិពលកុម្មុយនីស្តបានរីករាលដាលយ៉ាងរហ័សនៅអឺរ៉ុប និងទូទាំងពិភពលោក ធ្វើឱ្យមានការប្រជែងពីអាម៉េរិក
    - អឺរ៉ុបប៉ែកខាងកើតត្រូវរំដោះដោយសូវៀតក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានធ្លាក់ក្រោមឥទ្ធិពលកុម្មុយនីស្តសូវៀត និងក្រោយមកប្រកាន់យករបបកុម្មុយនីស្តតាមបែបសូវៀត

- អឺរ៉ុបខាងលិចត្រូវបានរំដោះដោយអង់គ្លេស និងអាម៉េរិក ព្រមទាំងសម្ព័ន្ធមិត្ត ខាងលិចក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥បានប្រកាន់យករបបប្រជាធិបតេយ្យ
- ទ្រឹស្តីទ្រូម៉ាន់ និងផែនការម៉ាសាល ឆ្នាំ១៩៤៧ អាម៉េរិក អនុវត្តនយោបាយ ទប់ទល់ និងរុញច្រានរបបកុម្មុយនីស្ត

**ពន្យល់សង្គ្រាមត្រជាក់៖**

- សង្គ្រាមត្រជាក់គឺជាការប្រឈមមុខដាក់គ្នារវាងសហរដ្ឋអាម៉េរិក(ប្លុកសេរី) ជាមួយ សហភាពសូវៀត (ប្លុកកុម្មុយនីស្ត) ផ្នែកមនោគមវិជ្ជានយោបាយ បច្ចេកវិទ្យា សព្វាវុធ សេដ្ឋកិច្ច ការទូត។
- សង្គ្រាមត្រជាក់បានធ្វើឱ្យពិភពលោកត្រូវបែងចែកពីរប្លុក គឺប្លុកសង្គមនិយម និងប្លុក មូលធននិយម។
- សង្គ្រាមនេះបានបង្កើតឱ្យមានជម្លោះ និងវិបត្តិជាច្រើននៅលើពិភពលោក ដូចជាវិបត្តិ នៅ អាល្លឺម៉ង់ សង្គ្រាមនៅឧបទ្វីបកូរ៉េ វិបត្តិព្រែកជីកស៊ុយអេ វិបត្តិនៅគុយបា សង្គ្រាម ឥណ្ឌូចិន។
- សង្គ្រាមនេះត្រូវបានបញ្ចប់នៅពេលដែលសហភាពសូវៀតដួលរលំ នៅឆ្នាំ១៩៩១
- **ចំណុចត្រឹមត្រូវផ្សេងៗទៀត**

## វិញ្ញាសាត្រៀមទី៤

**ប្រធាន**

1. តើពិភពលោកនាពេលបច្ចុប្បន្ននេះ កំពុងជួបប្រទះនឹងបញ្ហាធំៗអ្វីខ្លះ ?
2. ចូរវិភាគពីតួនាទីព្រះពុទ្ធសាសនាក្នុងសង្គមកម្ពុជា។
3. ចូរពិពណ៌នាពីការកសាងជាតិឡើងវិញក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩-១៩៩០។
4. ចូរពណ៌នាពីគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុនសែនក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា។
5. កម្ពុជាដែលជាសមាជិកមួយរបស់អាស៊ាន ក៏នឹងត្រូវក្លាយជាផ្នែកមួយនៃតំបន់ពាណិជ្ជកម្មសេរីនេះដែរ។ តើកម្ពុជាបានក្លាយជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាននៅថ្ងៃខែឆ្នាំណា ? តើការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាននេះអាចផ្តល់ផលប្រយោជន៍អ្វីខ្លះដល់កម្ពុជា ? តើអ្វីដែលអាចជាឧបសគ្គនៃលំហូរវិនិយោគមកកម្ពុជា ?

## អត្រាកំណែ

១-ពិភពលោកនាពេលបច្ចុប្បន្ននេះកំពុងជួបប្រទះនូវបញ្ហា៖

- **បញ្ហាបរិស្ថាន៖** បម្រែបម្រួលអាកាសធាតុ គ្រោះធម្មជាតិ (គ្រោះរាំងស្ងួត កំណើនកំដៅផែនដី ភ្លើងឆេះព្រៃ រញ្ជួយដី ព្យុះភ្លៀង ទឹកជំនន់) និងសំរាម។
- **បញ្ហាកំណើនប្រជាជន៖** ឧបត្ថម្ភថាមពល សុវត្ថិភាពស្បៀង ភាពក្រីក្រ ជនអន្តោប្រវេសន៍។
- **ជនអន្តោប្រវេសន៍៖** ការជួញដូរមនុស្ស គ្រឿងញៀន ពលកម្មកុមារ។
- **បញ្ហាសន្តិសុខស្បៀង៖** កង្វះស្បៀងចោទជាបញ្ហានាំមកនូវភាពក្រីក្រ និង គ្រោះទុរ្ភិក្ស ជំងឺឆ្លង (កង្វះអនាម័យ ខ្វះការការពារ)
- **បញ្ហាសង្គ្រាម និងអស្ថិរភាពសន្តិសុខសង្គម៖** សង្គមហាក់គ្មានសមត្ថភាពបង្កើតប្រព័ន្ធសន្តិសុខឱ្យប្រសើរ សម្រាប់មនុស្សជាតិ អស្ថិរភាពដោយការកើតឡើងនូវអាវុធប្រល័យលោក ការកើតឡើងនូវភេរវកម្មអន្តរជាតិ។
- **ឧក្រិដ្ឋកម្មឆ្លងដែន៖** ការជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ធ្វើចរាចរណ៍ ក្រដាសប្រាក់ក្លែងក្លាយ ការជំរិតទារប្រាក់តាមប្រព័ន្ធអិនធឺណែត
- **ការរាលដាលនៃជំងឺកូវីដ-១៩៖** ជំងឺនេះបានប៉ះពាល់ដល់អាយុជីវិតមនុស្ស សង្គម សេដ្ឋកិច្ច ...។
- **ចម្លើយត្រឹមត្រូវផ្សេងទៀត។**

២-តួនាទីព្រះពុទ្ធសាសនាក្នុងសង្គមកម្ពុជា៖

- អប់រំមនុស្សឱ្យប្រកាន់ភ្ជាប់នូវសច្ចៈធម៌ ស្គាល់បុណ្យ បាប ចេះធ្វើអំពើល្អ
- បណ្តុះនូវចំណេះផ្នែកសីលធម៌ គុណទោស បុណ្យបាប ប្រកាន់ភ្ជាប់នូវសច្ចៈធម៌
- ជាមជ្ឈមណ្ឌលអប់រំផ្លូវចិត្ត
- បណ្តុះនូវការអប់រំពលរដ្ឋសាកល តាមរយៈព្រះធម៌
- បណ្តុះនូវសីលធម៌ អត្តចរិកថ្លៃថ្នូរក្នុងការរស់នៅក្នុងសង្គម
- បណ្តុះស្មារតីសាមគ្គីភាពផ្នែកនយោបាយ
- មានចំណុចត្រឹមត្រូវផ្សេងទៀត

៣-ការកសាងជាតិឡើងវិញ ក្រោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៩-១៩៩០៖

**វិស័យនយោបាយ**

- លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ
- ធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញ
- អនុវត្តនយោបាយបង្រួបបង្រួមជាតិ
- ទប់ស្កាត់ការរស់ឡើងវិញនៃរបបកម្ពុជាប្រជាធិបតេយ្យ
- ត្រូវធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសគាំទ្ររដ្ឋាភិបាលក្រុងភ្នំពេញ និងខិតខំស្វែងរកការគាំទ្រពីសំណាក់អន្តរជាតិ
- កំណត់នូវកាតព្វកិច្ចយោធានាឆ្នាំ១៩៨៥
- ស្វែងរកមធ្យោបាយដើម្បីធ្វើការចរចាជាមួយរដ្ឋាភិបាលត្រីភាគី

**វិស័យសេដ្ឋកិច្ច**

- បង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬប្រវាស់ដៃគ្នាដើម្បីជួយប្រជាជន
- បញ្ហាចម្បងក្នុងការដោះស្រាយស្បៀងជូនប្រជាជន គឺសហភាពសូវៀត ប្រទេសវៀតណាម និងប្រទេសសង្គមនិយម បានផ្គត់ផ្គង់ស្បៀងអាហារ សម្ភារៈប្រើប្រាស់ ពូជស្រូវ...
- ឆ្នាំ១៩៨០ រដ្ឋាភិបាលបានបង្កើតក្រដាសប្រាក់ឱ្យប្រើប្រាស់ឡើងវិញ
- នៅឆ្នាំ១៩៨៣-១៩៨៦ គោលនយោបាយរបស់រណសិរ្សបានប្តូរពីក្រុមសាមគ្គីទៅជាម្ចាស់ការទាំងស្រុងដោយឈានទៅរករបបកម្មសិទ្ធឯកជន
- ខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច(ផ្លូវថ្នល់ កំពង់ផែ...)
- ធ្វើយ៉ាងណាដើម្បីឱ្យមានកំណើនទេសចរ និងវិនិយោគគិន

**ផ្នែកវប្បធម៌**

- លើកកម្ពស់សិល្បៈគ្រប់ទម្រង់ឡើងវិញដោយប្រមែប្រមូលអ្នកមានជំនាញមកជួយបណ្តុះបណ្តាល និងរៀបចំឡើងវិញ
- បង្កើតនូវនាយកដ្ឋាន មន្ទីរ...សាលាផ្នែកសិល្បៈ វប្បធម៌ខ្មែរ
- សាលាវិចិត្រសិល្បៈបានបើកទ្វារឡើងវិញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១
- វត្តអារាមត្រូវបានជួសជុល និងដំណើរការឡើងវិញ

- ការជ្រើសរើសគូស្រករ និងការរៀបការតាមប្រពៃណីមានការបើកទូលាយឡើងវិញ។

#### វិស័យអប់រំ

- អនុវត្តតាមពាក្យស្លោក«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះ»
- ជំរុញការអភិវឌ្ឍធនធានមនុស្ស
- មានការកសាងសាលារៀន
- ធ្វើការប្រមែប្រមូលអ្នកចេះដឹងមកចូលរួមរៀបចំក្នុងក្រសួងអប់រំ
- បើកវគ្គបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត
- រដ្ឋបានរៀបចំប្រព័ន្ធអប់រំឱ្យបើកទូលាយ និងពង្រីកបន្ថែមពីទីក្រុងរហូតដល់តំបន់ដាច់ស្រយាល
- សាលារៀនបានបើកទ្វារទទួលសិស្សពីមត្តេយ្យរហូតដល់ឧត្តមសិក្សា
- រដ្ឋាភិបាលបានបំផុសចលនាអក្ខរកម្ម
- សម្ភារៈសិក្សាក៏មានសមរម្យតាមរយៈអំណោយរបស់សហភាពសូវៀត វៀតណាម និងប្រទេសសង្គមនិយមដទៃទៀត។

#### វិស័យសង្គមកិច្ច

- មណ្ឌលកុមារកំព្រាជាច្រើនបានបើកទ្វារ និងទទួលកុមារប្រមាណ៦ ០០០នាក់ នៅទូទាំងប្រទេស
- ជនពិការ និងស្ត្រីមេម៉ាយត្រូវបានបែងចែកទៅតាមក្រុមសាមគ្គី
- សាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការមួយចំនួនក៏បានបើកទ្វារ
- ការផ្គត់ផ្គង់ទឹកស្អាត និងភ្លើងអគ្គិសនីបានចាប់ផ្តើមបន្តិចម្តងៗ
- ច្បាប់ការពារកម្មសិទ្ធិឯកជនដោយផ្តល់កម្មសិទ្ធិដល់ប្រជាពលរដ្ឋខ្មែរត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៧។

#### វិស័យសុខាភិបាល

- មន្ទីរពេទ្យជាច្រើនបានដំណើរការឡើងវិញ ប៉ុន្តែកង្វះខាតធនធានមនុស្ស គ្រឿងបរិក្ខារ ថ្នាំពេទ្យនៅតែជាបញ្ហាប្រឈមដ៏សំខាន់
- មហាវិទ្យាល័យវិជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រត្រូវបើកឱ្យដំណើរការវិញនៅថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៨០
- សាលាសុខាភិបាលមជ្ឈិម និងខេត្តក្រុងបានបើកឱ្យដំណើរការឡើងវិញជាបន្តបន្ទាប់។

#### វិស័យសង្គម

- រំដោះប្រជាជនចេញពីរបបខ្មែរក្រហម
- ទប់ស្កាត់អំពើអសកម្មក្នុងសង្គម ការជួញដូរមនុស្ស អាវុធ គ្រឿងញៀន

- លើកកម្ពស់វិស័យសុខាភិបាល
- ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
- ពង្រឹងសុខសន្តិភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមដើម្បីទាក់ទាញវិនិយោគគិន
- បង្កើតសេដ្ឋកិច្ចទីផ្សារសេរី
- ដាក់កងកម្លាំងប្រដាប់អាវុធយាមកាមនៅតំបន់ដែលខ្លួនរស់នៅដើម្បីការពារសន្តិសុខប្រជាជន និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់។

**មានមតិត្រឹមត្រូវផ្សេងទៀត**

៤-ពណ៌នាពីគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុន សែន និងការបញ្ចប់សង្គ្រាមនៅកម្ពុជា៖

កម្ពុជាបានទទួលនូវសន្តិភាពពេញលេញបន្ទាប់ពីការអនុវត្តនូវគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចហ៊ុន សែន ដែលគោលនយោបាយនេះ នាំមកដល់កម្ពុជានូវ៖

- សុខសន្តិភាពពេញលេញ
- ជានាសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូប
- ជានាអាជីពនិងមុខរបរ
- ការទទួលស្គាល់លើកម្មសិទ្ធិនៃចលនទ្រព្យនិងអចលនទ្រព្យ
- ប្រទេសជាតិមានការអភិវឌ្ឍ។

នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ការបោះឆ្នោតជាតិលើកទី២បានដំណើរការតាមការគ្រោងទុកដោយមានវត្តមានរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ។ គណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតដោយទទួលបាន ៦៤អាសនៈក្នុងរដ្ឋសភា រីឯគណបក្សហ៊្វុនស៊ិនប៉ិចទទួលបាន៤៣អាសនៈ។ តាមរដ្ឋធម្មនុញ្ញ រាជរដ្ឋាភិបាលត្រូវជ្រើសតាំងដោយសំឡេងគាំទ្រពីភាគបីនៃចំនួនតំណាងរាស្ត្រ។ កត្តានេះបានជំរុញឱ្យមានកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិចក្នុងការបង្កើតរាជរដ្ឋាភិបាលមួយរួមគ្នា។ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិត្រូវបានតែងតាំងជាប្រធានរដ្ឋសភា សម្តេច ជា ស៊ីមជាប្រធានព្រឹទ្ធសភា ឯសម្តេច ហ៊ុន សែនជានាយករដ្ឋមន្ត្រី។ នៅចុងឆ្នាំ១៩៩៨ និងដើមឆ្នាំ១៩៩៩ ក្រុមខ្មែរក្រហមបានធ្វើសមាហរណកម្មទាំងស្រុងជាមួយ រាជរដ្ឋាភិបាល។ កម្ពុជាបានទទួលនូវសន្តិភាពពេញលេញបន្ទាប់ពីការអនុវត្តនូវគោលនយោបាយឈ្នះ-ឈ្នះ របស់សម្តេចហ៊ុន សែន។ អំពីផលប្រយោជន៍ ដែលទទួលបានពីនយោបាយ ឈ្នះ-ឈ្នះ ដែលទទួលបានដូចជា៖ បានបញ្ចប់សង្គ្រាមប្រដាប់អាវុធទាំងស្រុង លែងមានតទៅទៀត ហើយនៅក្នុងប្រទេសកម្ពុជា។

1. ដំណើរការនៃការបញ្ចប់សង្គ្រាម នៅក្នុងប្រទេសកម្ពុជា នៅតំបន់គ្រប់គ្រង ដោយអតីតខ្មែរក្រហម ចាប់ពីដើមឆ្នាំ ១៩៩៦ ដល់ចុងឆ្នាំ១៩៩៨ គឺមិនមានការប្រើប្រាស់អាវុធ ហើយក៏មិនមានមនុស្សស្លាប់ ដោយគ្រាប់កាំភ្លើងដែរ។
2. ជាប្រវត្តិសាស្ត្រនៃការឯកភាពទឹកដី បញ្ចប់នូវតំបន់ត្រួតត្រាច្រើន មកជាតំបន់ត្រួតត្រាតែមួយ មានព្រះមហាក្សត្រតែមួយ មានរដ្ឋធម្មនុញ្ញតែមួយ មានរាជរដ្ឋាភិបាលតែមួយ និងមានកងកម្លាំងតែមួយដែលបានធ្វើឱ្យប្រទេសកម្ពុជាទទួលបាននូវការបង្រួបបង្រួមជាតិ សន្តិភាព និងទទួលបាននូវការអភិវឌ្ឍគ្រប់វិស័យ។

3. ប្រជាពលរដ្ឋដែលរស់នៅជិតតំបន់សមរភូមិប្រយុទ្ធ និងទីកន្លែងសមរភូមិក្តៅ លែងមានការព្រួយបារម្ភរឿងសង្គ្រាម និងលែងព្រួយបារម្ភរស់ នៅព្រាត់ប្រាសគ្នារវាងប្តីប្រពន្ធ និងកូនទៀតហើយ។
4. កម្ពុជា គឺជាប្រទេសដែលទទួលបានសុខសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ ដែលបានឈានពីប្រទេសក្រីក្រទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងឆ្ពោះទៅកាន់ប្រទេស ដែលមានប្រាក់ចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយនឹងឆ្ពោះទៅកាន់ជាប្រទេស ដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្រោយពីបញ្ចប់សង្គ្រាម គឺសម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញនូវយុទ្ធសាស្ត្រ ២សំខាន់ ក្នុងការអភិវឌ្ឍប្រទេសគឺះ
    - ប្រែក្លាយតំបន់សមរភូមិក្តៅ ទៅជាតំបន់អភិវឌ្ឍន៍ និងតំបន់ទីផ្សារ
    - ប្រែក្លាយតំបន់ព្រំដែនជាមួយប្រទេសជិតខាងឱ្យទៅជាតំបន់ដែលមានសន្តិភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការល្អ។
5. កម្ពុជា គឺជាប្រទេសដែលទទួលបានសុខសន្តិភាព និងការអភិវឌ្ឍគ្រប់វិស័យ ដែលបានឈានពីប្រទេសក្រីក្រទៅជាប្រទេស ដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប និងឆ្ពោះទៅកាន់ប្រទេស ដែលមានប្រាក់ចំណូលមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយនឹងឆ្ពោះទៅកាន់ជាប្រទេស ដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្រោយពីបញ្ចប់សង្គ្រាម គឺសម្តេចតេជោនាយករដ្ឋមន្ត្រីបានដាក់ចេញនូវយុទ្ធសាស្ត្រ ២សំខាន់ ក្នុងការអភិវឌ្ឍប្រទេសគឺដោយសារការខិតខំប្រឹងប្រែងរបស់ សម្តេចតេជោ ហ៊ុន សែន គឺប្រទេសកម្ពុជាត្រូវបានទទួលស្គាល់ ជាលក្ខណៈអន្តរជាតិ តាមរយៈកិច្ចប្រជុំអន្តរជាតិសំខាន់ៗ ជាច្រើនដូចជា EMEC, CLMV និង CLV ជាដើម។ ទន្ទឹមនឹងនេះកម្ពុជាក៏ធ្លាប់បានទទួលធ្វើជាម្ចាស់ផ្ទះ នៃកិច្ចប្រជុំកំពូលអាស៊ាន និងត្រៀមខ្លួនទទួលធ្វើជាម្ចាស់ផ្ទះក្នុងកិច្ចប្រជុំកំពូលអន្តរជាតិជាច្រើនទៀត។ ទន្ទឹមនឹងនេះកម្ពុជាក៏បានបញ្ជូនកងទ័ពទៅចូលរួមរក្សាសន្តិភាព ជាមួយអង្គការសហប្រជាជាតិផងដែរ។
6. ក្រោយពេលបញ្ចប់សង្គ្រាមភ្លាមគឺ មានពាណិជ្ជករ និងអ្នកវិនិយោគគិនជាច្រើនមកវិនិយោគនៅក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់ជាពិសេសចំនួនភ្ញៀវទេសចរគឺកើនឡើងជារៀងរាល់ឆ្នាំ។

## អត្ថាធិប្បាយសម័យប្រឡង២៤ សីហា ២០១៥ (ថ្នាក់សង្គម)

៤-ពណ៌នាពីនយោបាយឈ្នះ-ឈ្នះ៖

- **វិស័យនយោបាយ**
  - សមាហរណកម្មកងទ័ពខ្មែរក្រហមជាមួយកងទ័ពរដ្ឋាភិបាលធ្វើឱ្យកងកម្លាំងមានការឯកភាពដើម្បីស្តារប្រទេស និងកសាងប្រទេស
  - ក្រោយពីដកកម្លាំងខ្មែរក្រហមដួលរលំ នៅតាមតំបន់ព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
  - មានមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមព្រំដែន
  - មានការបែងចែកដីធ្លីកាន់កាប់ ជាកម្មសិទ្ធដល់បងប្អូនជនភៀសខ្លួន(អតីតខ្មែរក្រហម)
  - បងប្អូនខ្មែរក្រហមត្រូវបានផ្តល់នាទីនិងបុណ្យស័ក្តិដែលគាត់ធ្លាប់មានពីមុន។
- **វិស័យសេដ្ឋកិច្ច**
  - ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន ប្រទេសក្នុងតំបន់និងមហាអំណាចពិភពលោកធំៗ
- **វិស័យសង្គម**
  - ពីឆ្នាំ១៩៩៣ ដល់បច្ចុប្បន្នកម្ពុជាមានសុខសុវត្ថិភាពពេញលេញ
  - ធ្វើឱ្យមានឯកភាពជាតិ ការបង្រួបបង្រួមជាតិ
  - ធ្វើឱ្យមានសមិទ្ធផលជាច្រើនបានកើតឡើង ដូចជាសាលារៀនពីមត្តេយ្យរហូតដល់សាកលវិទ្យាល័យ មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្ពានអាកាស ប្រព័ន្ធធារាសាស្ត្រ ជាពិសេសសេដ្ឋកិច្ចមានការរីកចម្រើន និយាយរួមគឺមានការរីកចម្រើនលើគ្រប់វិស័យ។
- **វិស័យអប់រំ**
  - ធ្វើកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំពីបឋមដល់ឧត្តមសិក្សា។

៥-កម្ពុជាបានក្លាយជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាននៅថ្ងៃ៣១ខែធ្នូឆ្នាំ២០១៥។

- ផលប្រយោជន៍សម្រាប់កម្ពុជា
  - ចំពោះកម្ពុជា សហគមន៍សេដ្ឋកិច្ចអាស៊ានគឺជាទីផ្សារប្រកបដោយសក្តានុពលមួយ ទាំងទីផ្សារទំនិញ និងសេវាកម្ម និងទីផ្សារការងារ។
  - ក្រុមហ៊ុនសហគ្រាសនៅកម្ពុជាអាចនាំទំនិញទៅលក់នៅគ្រប់កន្លែង នៅក្នុងតំបន់អាស៊ាន ដោយមិនមានឧបសគ្គខាងពន្ធគយ ក៏ប៉ុន្តែ ទំនិញដែលផលិតនៅក្នុងប្រទេសផ្សេងទៀត ក្នុងតំបន់អាស៊ានក៏អាចត្រូវនាំចូលមកលក់នៅក្នុងប្រទេសកម្ពុជាដោយមិនមានបង់ពន្ធគយដូចគ្នាដែរ។
  - ប្រជាជនកម្ពុជាទូទៅអាចទទួលផលចំណេញពីការនាំចូលទំនិញដោយមិនបង់ពន្ធ ដោយសារតែវាមានតម្លៃថោក ហើយអាចមានជម្រើសច្រើន ប៉ុន្តែរដ្ឋាភិបាលកម្ពុជានឹងត្រូវបាត់បង់ចំណូលពីការប្រមូលពន្ធនាំចូល។
  - លំហូរវិនិយោគពីអាស៊ានមកក្នុងប្រទេសកម្ពុជា។

- បង្កើនទីផ្សារ សម្រាប់ការនាំចេញវត្ថុធាតុដើមកម្ពុជា ។
- ឧបសគ្គនៃលំហូរវិនិយោគមកកម្ពុជា
    - អភិបាលកិច្ច និងនីតិរដ្ឋ៖ កង្វះតម្លាភាព បញ្ហាពុករលួយ ការអនុវត្តច្បាប់មិនគ្រប់ជ្រុងជ្រោយ និងកង្វះឯករាជ្យនៃប្រព័ន្ធតុលាការ អាចធ្វើឱ្យអ្នកវិនិយោគមានការរារែកមិនហ៊ានមករកស៊ី នៅក្នុងប្រទេសកម្ពុជា ហើយអាចបង្វែរទៅកាន់ប្រទេសអាស៊ានផ្សេងទៀត ដែលគេមើលឃើញថាមានហានិភ័យទាបជាង។
    - កង្វះធនធានមនុស្ស៖ការខ្វះខាតធនធានមនុស្សនេះក៏អាចធ្វើឱ្យរោងចក្រសហគ្រាសបរទេសមានការរារែកមិនចង់មកបោះទីតាំងផលិត នៅក្នុងប្រទេសកម្ពុជាផងដែរ ឬក៏គេមកបោះទីតាំងផលិតដែរ ។

# វិញ្ញាសាត្រៀមទី៥

**ប្រធាន**

1. ហេតុអ្វីកម្ពុជាចាំបាច់ស្វែងរកកិច្ចចរចាការពារពីបារាំង ដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំង?
2. តើសង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០និង១៩៦០បាននាំមកអ្វីខ្លះ ដល់ឧបទ្វីបឥណ្ឌូចិន?
3. ចូរពណ៌នាពីចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យ?
4. តើអាស៊ានជាអ្វី?ហើយប្រទេសកម្ពុជាបានទទួលផលអ្វីខ្លះពីការចូលរួមជាសមាជិកអាស៊ាន?
5. ចូរពណ៌នាពីផលវិបាកនៃសង្គ្រាមស៊ីវិលនៅកម្ពុជាដែលផ្ទុះឡើងពីឆ្នាំ១៩៧០-១៩៧៥។
6. ចូរបកស្រាយពីតួនាទី«វប្បធម៌សន្ទនា» នៅក្នុងសង្គមប្រជាធិបតេយ្យ។

# អត្រាកំណែ

១- កម្ពុជាចាំបាច់ស្វែងរកកិច្ចចរចា ការពារ ពីបារាំងដោយចុះសន្ធិសញ្ញាអាណាព្យាបាលជាមួយបារាំងពីព្រោះ ៖

- កម្ពុជាកាន់តែទន់ខ្សោយទៅៗ និងកើតមានជាវិបត្តិផ្ទៃក្នុង
- សៀម និងយួនមានបំណងចង់លេបត្របាក់យកទឹកដីខ្មែរ ដោយយកទន្លេមេគង្គជាព្រំដែនរួម
- កម្ពុជាចង់បានមហាអំណាចអឺរ៉ុបមកជួយការពារទឹកដី និងពូជសាសន៍ខ្មែរ

២-សង្គ្រាមត្រជាក់ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ និង១៩៦០បាននាំមកដល់ឧបទ្វីបឥណ្ឌូចិនរួមមានដូចជា៖

- កើតនូវចលនាទាមទារឯករាជ្យ
- កើតនូវកម្លាំងនយោបាយច្រើនក្រុមក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១
- ប្រទេសក្នុងតំបន់ឥណ្ឌូចិនទទួលបានឯករាជ្យ
- មានស្វ័យភាពក្នុងការដឹកនាំប្រទេស
- ប្រទេសកម្ពុជាទទួលបានអព្យាក្រឹត
- កម្ពុជាខិតខំរក្សាសុខសន្តិភាពក្នុងបរិការណ៍នៃសង្គ្រាមត្រជាក់និងភ្លើងសង្គ្រាមនៅវៀតណាម
- ការតស៊ូនយោបាយរវាងពួកស្តាំនិយម និងឆ្វេងនិយមនៅក្នុងសង្គមរាស្ត្រនិយម
- មានការអភិវឌ្ឍលើគ្រប់វិស័យ
- កម្ពុជាមានស្ថិរភាព និងបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិ
- មានការគាបសង្កត់ពីសំណាក់មហាអំណាចសេរី និងកុម្មុយនីស្ត
- សង្គ្រាមនៅវៀតណាមបានផ្ទុះឡើង
- វៀតណាមបានបែងចែកជាពីរប្រទេសគឺខាងជើង(កុម្មុយនីស្ត) និងខាងត្បូង(សេរី)
- ប្រទេសឡាវបែងចែកជាពីរ(កុម្មុយនីស្ត-សេរី)
- វៀតណាមដាក់ចេញគោលនយោបាយបង្រួបបង្រួមប្រទេសតាមរយៈបដិវត្តឥណ្ឌូចិនឆ្នាំ១៩៦៥

- ការប្រកួតប្រជែងរវាងសហរដ្ឋអាម៉េរិក ចិន សហភាពសូវៀត ដែលបានបង្កមហន្តរាយដល់ឥណ្ឌូចិន
- កម្ពុជាមានទំនាស់ជាមួយប្រទេសជិតខាង
- កម្ពុជាងាកពីអាម៉េរិកទៅចាប់ដៃចិន និងវៀតណាមខាងជើង
- សហរដ្ឋអាម៉េរិកចាប់ផ្ដើមដកខ្លួនចេញពីវៀតណាម ហើយបានដាក់ចេញគោលនយោបាយកាត់ផ្ដាច់ផ្លូវលំហូរដីមិញនិងការផ្គត់ផ្គង់យុទ្ធោបករណ៍និងស្បៀងដល់ពួកវៀតកុង និងទាហានវៀតណាមខាងជើង និងការទម្លាក់គ្រាប់បែកកម្ទេចមូលដ្ឋានសឹកលើទឹកដីកម្ពុជា។
- ចម្លើយត្រឹមត្រូវផ្សេងទៀត

៣- ពណ៌នាពីចលនាតស៊ូ ដើម្បីរំដោះប្រទេសកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យៈ

- ខែមករា ១៩៧៦ លោក ហ៊ូ នឹម បានចេញមុខប្រឆាំងនឹងប៉ុល ពត
- ដើមខែមីនា ១៩៧៦ ប្រជាជននៅចម្ការហ្លួង សៀមរាប ទាមទារដំឡើងកម្រិតជីវភាព
- ដើមខែមករា ១៩៧៧ ប្រជាជនភូមិភាគឧត្តរ និងបាត់ដំបងប្រឆាំងនឹងប៉ុល ពត
- ខែមីនា-មេសា ១៩៧៧ ប្រជាជនកំពង់ធំ កំពង់ឆ្នាំង មណ្ឌលគិរី និងចម្ការហ្លួង ងើបប្រឆាំង
- ថ្ងៃទី២ ធ្នូ ១៩៧៨ មហាសន្និបាតបានសម្រេចបង្កើតជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែល ដឹកនាំដោយលោក ហេង សំរិន
- មានជំនួយពីកងទ័ពវៀតណាម និងប្រជាជនកម្ពុជា
- ក្នុងរយៈពេលតែបីសប្ដាហ៍ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពរំដោះប្រជាជន បានរំដោះបានស្ទើរតែទាំងស្រុង
- ថ្ងៃទី៧ មករា ១៩៧៩ ប្រជាជនខ្មែរបានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។
- ចម្លើយត្រឹមត្រូវផ្សេងទៀត

៤-អាស៊ានជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។ បង្កើតដើម្បីពន្លឿនវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រអប់រំ និងដោះស្រាយបញ្ហាប្រកបទៅដោយសន្តិវិធី។ មិនតែប៉ុណ្ណោះជាការប្រមូលផ្ដុំទីផ្សារដ៏ធំមួយនៅអាស៊ីអាគ្នេយ៍ដើម្បីអភិវឌ្ឍន៍ទីផ្សារអន្តរជាតិតាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការ ការពារស្ថិរភាពនយោបាយសេដ្ឋកិច្ច ក្នុងតំបន់ ក៏ដូចជាទប់ទល់ការប្រកួតប្រជែងពីប្រទេសមហាអំណាចធំៗលើពិភពលោក។

➢ ប្រទេសកម្ពុជាបានទទួលផលប្រយោជន៍ពីការចូលរួមជាសមាជិកអាស៊ានដូចជាៈ

**ផ្នែកនយោបាយ**

- សម្រេចបាននូវផ្នែកមួយនៃមុំពីរនៃយុទ្ធសាស្ត្រត្រីកោណគឺសមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់
- កម្ពុជាលែងជាប្រទេសឯកា តទៅទៀត
- កម្ពុជាអាចឈរស្មើមុខស្មើមាត់ជាមួយប្រទេសដែលជាសមាជិក និងចូលរួមនូវរាល់ការសម្រេចចិត្តនៅក្នុងតំបន់
- កម្ពុជាបានរក្សានូវសន្តិសុខ សេរីភាព និងអធិបតេយ្យភាព

- កម្ពុជាអាចចូលរួមដោះស្រាយបញ្ហាផ្សេងៗជាមួយប្រទេសសមាជិកអាស៊ាន
- កម្ពុជាអាចដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី។

**ផ្នែកសេដ្ឋកិច្ច**

- កម្ពុជាអាចក្លាយជាកន្លែងវិនិយោគដ៏ទាក់ទាញ
- ការធ្វើពាណិជ្ជកម្មមានភាពងាយស្រួលជាងមុន
- ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្នុង និងក្រៅប្រទេស
- ទេសចរមានការកើនឡើង
- ការចូលជាសមាជិកអាស៊ានជាផ្នែកមួយដែលជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំ។
- កម្ពុជាអាចទទួលបានប្រាក់កម្ចីដ៏ច្រើនពីធនាគារអភិវឌ្ឍអាស៊ី និងប្រទេសជាមិត្តទាំង៩ក្នុងអត្រា ការប្រាក់ទាប ហើយមានរយៈពេលយូរ
- កម្ពុជាទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍខាងវិស័យផ្សេងៗដូចជា កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម។

**ផ្នែកទំនាក់ទំនង**

- ជួយជំរុញឱ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់
- ការលើកលែងទិដ្ឋាការក្នុងប្រទេសសមាជិកអាស៊ាន
- ការផ្លាស់ប្តូរចំណេះដឹង សង្គមកិច្ច វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់ ព្រមទាំងផ្នែកអប់រំវិទ្យាសាស្ត្របច្ចេកទេសពីបណ្តាប្រទេសសមាជិកអាស៊ាន។

**ផ្នែកសង្គម**

- កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខសង្គមទប់ស្កាត់ ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម

**មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៥- ផលវិបាកនៃសង្គ្រាមស៊ីវិលនៅកម្ពុជាដែលផ្ទុះឡើងពីឆ្នាំ១៩៧០-១៩៧៥៖

**ផលវិបាកខាងនយោបាយ**

- ប្រទេសជាតិត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ កិត្យានុភាពលើឆាកអន្តរជាតិ
- កើតមានអស្ថិរភាពនយោបាយ
- ផ្តល់ឱកាសល្អឱ្យពួកខ្មែរក្រហមផ្សព្វផ្សាយគោលនយោបាយរួចឈានទៅឡើងកាន់អំណាច។

**ផលវិបាកខាងសេដ្ឋកិច្ច**

- ដីស្រែចម្ការត្រូវបោះបង់ចោល ក្លាយជាចម្ការមីន រណ្តៅគ្រាប់
- រោងចក្រសហគ្រាស៧៥% ត្រូវបានបំផ្លាញ
- ចម្ការកៅស៊ូត្រូវបោះបង់
- ស្ពាន ថ្នល់ ប្រឡាយទឹក ៧០-៨០%ត្រូវខូចខាត
- សេដ្ឋកិច្ចជាតិត្រូវស្រុតចុះ។

**ផលវិបាកខាងសង្គម**

- សម្លាប់មនុស្សជាងមួយលាននាក់
- បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ ចាស់ជរា
- ប្រជាជនភៀសខ្លួនពីជនបទមកកាន់ទីក្រុង រស់នៅវេទនា
- កើតមានអំពើពុករលួយ អយុត្តិធម៌ ភាពអនាធិបតេយ្យទូទាំងប្រទេស
- បំផ្លាញធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ គ្រឹះស្ថានសិក្សា វត្តអារាម មន្ទីរពេទ្យ...។

៦- តួនាទី«វប្បធម៌សន្ទនា» នៅក្នុងសង្គមប្រជាធិបតេយ្យគឺ៖

- បញ្ចៀសបានសង្គ្រាមពាក្យសម្ដី និងទំនាស់ផ្សេងៗនៅក្នុងសង្គម
- ដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី
- ផ្ដល់ភាពស្មោះត្រង់ និងជឿជាក់ទៅលើគ្នាទៅវិញទៅមក
- បង្កើនភាពសាមគ្គី និងកិច្ចសហប្រតិបត្តិការប្រសើរជាងមុន
- ជាវេទិកាជជែកដេញដោលនិងពិភាក្សាឈរលើគោលការណ៍សន្តិភាព ស្មើភាព
- ពុំមានការគំរាមកំហែងគ្នាទៅវិញទៅមក
- ជាគំរូល្អដល់សង្គមជាតិប្រកបដោយ ភាពជឿទុកចិត្តពីសំណាក់ប្រជាជន
- គោរពគ្នាទៅវិញទៅមកនាំមកនូវភាពថ្លៃថ្នូរ
- មានទំនួលខុសត្រូវលើផលប្រយោជន៍ជាតិក្នុងសង្គមប្រជាធិបតេយ្យ
- បញ្ចៀសបានរាល់អំពើហិង្សា និងសង្គ្រាម។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

# វិញ្ញាសាត្រៀមទី៦

## ប្រធាន

1. ចូរវិភាគពីតម្លៃនៃសន្តិភាពដែលកម្ពុជាទទួលបានសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។
2. តើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១ មានប្រទេសណាខ្លះចូលរួម?
   ក.តើផ្តោតសំខាន់ទៅលើចំណុចសំខាន់អ្វីខ្លះ?
   ខ.តើកិច្ចចរចានេះ ផ្តល់សារៈសំខាន់អ្វីខ្លះដល់ប្រទេសកម្ពុជា?
3. តើគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យមានប៉ុន្មានប្រការ?អ្វីខ្លះ? តើអ្នកយល់យ៉ាងណាអំពីគោលនយោបាយនេះ?
4. នៅឆ្នាំ១៩៨៩ រដ្ឋសភានៃប្រទេសកម្ពុជា បានធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៩ អ្វីខ្លះ?
   ក. តើមុខព្រួញសេដ្ឋកិច្ចនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺអ្វី? វិធានការផលិតស្បៀងគឺអ្វី? នាំចេញអ្វីខ្លះ?
   ខ. តើ ក៥ ជាអ្វី? មានគោលបំណងអ្វី?
   គ. តើគណៈគ្រប់គ្រងរបបនេះមាននរណាខ្លះ? មានលក្ខណៈដូចម្តេច?
5. តើអ្វីទៅជាកម្មវិធីអនុគ្រោះពន្ធ(EBA)«គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ»?
6. ចូរអធិប្បាយពីនយោបាយអព្យាក្រឹត របស់សម្តេចព្រះនរោត្តម សីហនុ នាសម័យសង្គមរាស្ត្រនិយមក្នុងទសវត្សរ៍ឆ្នាំ១៩៦០។

## អត្រាកំណែ

១-តម្លៃនៃសន្តិភាពដែលកម្ពុជាទទួលបានសម្រាប់ការអភិវឌ្ឍនយោបាយ សេដ្ឋកិច្ច និងសង្គមៈ

**តម្លៃសន្តិភាព**ៈកម្ពុជាបានសុខសន្តិភាពជៀសផុតពីសង្គ្រាម

- **នយោបាយ**
  - មានការរួបរួមគ្នាដើម្បីអភិវឌ្ឍប្រទេស
  - មានទំនាក់ទំនងល្អជាមួយបរទេសផ្នែកការទូត សេដ្ឋកិច្ច...។
- **សេដ្ឋកិច្ច**
  - ជួយជំរុញវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ឱ្យមានការអភិវឌ្ឍ
  - ងាយស្រួលក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង
- **សង្គម**
  - មានការទប់ស្កាត់សង្គ្រាម និងការខ្វែងគំនិតគ្នាក្នុងសង្គម
  - លើកស្ទួយការគោរពសិទ្ធមនុស្ស សេរីភាពគ្រប់បែបយ៉ាងក្នុងសង្គមប្រជាធិបតេយ្យ
  - ទប់ស្កាត់អំពើពុករលួយ
  - ធ្វើឱ្យរដ្ឋមានលទ្ធភាពសម្រេចផែនការនានាតាមការកំណត់
  - ជួយឱ្យមានសន្តិភាព និងសន្តិសុខក្នុងសង្គម
  - ជាមាគ៌ានាំសង្គមមានការអភិវឌ្ឍជាចីរភាព
- **មានមតិត្រឹមត្រូវផ្សេងទៀត**

២-កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១ មានប្រទេសចំនួន ១៨ ចូលរួមគឺ អូស្ត្រាលី ប្រ៊ុយណេ កាណាដា ចិន យូហ្គោស្លាវី អាម៉េរិក បារាំង ឥណ្ឌា ឥណ្ឌូណេស៊ី ជប៉ុន ឡាវ ម៉ាឡេស៊ី ហ្វីលីពីន អង់គ្លេស សឹង្ហបុរី ថៃ សូវៀត និងវៀតណាម។ បន្ថែមពីនេះ មានអគ្គលេខាធិការនៃ អង្គការសហប្រជាជាតិ និងមានការចូលរួមពីតំណាងនៃ ចលនាមិនចូលពីបក្សសម្ព័ន្ធក៏ចូលរួមផងដែរ។

**ក.ផ្តោតសំខាន់ទៅលើចំណុចសំខាន់ដូចខាងក្រោម៖**

- ទី១ កិច្ចព្រមព្រៀងទាក់ទងនឹងអធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិ
- ទី២ សេចក្តីថ្លែងការណ៍ ស្តីពីការស្តារ និងកសាងកម្ពុជាឡើងវិញ។

**ខ.កិច្ចចរចានេះ ផ្តល់សារៈសំខាន់ដល់ប្រទេសកម្ពុជាដូចជា៖**

- បញ្ហាជម្លោះរវាងខ្មែរ និងខ្មែរ
- នាំមកនូវសន្តិភាពជូនជាតិកម្ពុជា
- រៀបចំការបោះឆ្នោតជាសកលនៅកម្ពុជាក្រោមការត្រួតពិនិត្យនៃអង្គការសហប្រជា ជាតិ
- បង្កើតឱ្យមានការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ
- បញ្ចប់សង្គ្រាម ដែលបានកើតមានរ៉ាំរ៉ៃជាច្រើនឆ្នាំមកហើយ។
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

៣-គោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ មាន៨ប្រការ៖

1. ជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញទាំងអស់
2. លុបបំបាត់ទីផ្សារ
3. លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
4. ផ្សឹកព្រះសង្ឃឱ្យទៅធ្វើកសិកម្មតាមទិសដៅដែលគេទៅដល់តាមមូលដ្ឋានជនបទ
5. ប្រហារជីវិតមេដឹកនាំរបបសាធារណរដ្ឋខ្មែរ
6. បង្កើតសហករណ៍កម្រិតខ្ពស់នៅទូទាំងប្រទេស។
7. បណ្តេញជនជាតិភាគតិចវៀតណាម ឱ្យចេញទាំងអស់
8. បញ្ជូនទ័ពឱ្យទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម។

៤- នៅឆ្នាំ១៩៨៩រដ្ឋសភានៃប្រទេសកម្ពុជា បានធ្វើវិសោធនកម្មទៅលើរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៧៩ មាន ដូចខាងក្រោម៖

- សម័យប្រជុំវិសាមញ្ញថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩គេបានធ្វើវិសោធនកម្ម ដោយធ្វើការប្តូរឈ្មោះប្រទេសពីសាធារណរដ្ឋប្រជាមានិតកម្ពុជា ទៅជារដ្ឋកម្ពុជា
- ប្តូរទង់ជាតិ និងភ្លេងជាតិ
- ជ្រើសរើសយកព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ
- បង្កើតច្បាប់ការការពារកម្មសិទ្ធិឯកជន និងរបបទីផ្សារសេរី
- ប្រទេសកម្ពុជាជាប្រទេសអព្យាក្រឹត និងមិនចូលបក្សសម្ព័ន្ធ
- ទោសប្រហារជីវិតត្រូវបានលុបចោល

- សេរីភាពសារព័ត៌មាន និងអង្គការសង្គមស៊ីវិលត្រូវបានបង្កើតឡើង។

ក. មុខព្រួញសេដ្ឋកិច្ចនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាគឺមាន ស្រូវ ព្រៃឈើ កៅស៊ូ ត្រី។ វិធានការផលិតស្បៀងមាន ៣យ៉ាង ក្នុងផលិតកម្មស្បៀងពេលនោះគឺ៖

- ពង្រីកផ្ទៃដីកសិកម្ម
- បង្កើនរដូវដាំដុះ
- ធ្វើឱ្យមានប្រពលវប្បកម្ម

មានការនាំចេញនូវដំណាំកៅស៊ូដែលមាននៅរតនគិរី កំពង់ចាម ក្រចេះ កំពង់សោម។

ខ. «ក៥» មានន័យថា កេណ្ឌ កងកម្លាំង កាប់ឆ្ការព្រៃ ការពារព្រំដែន កម្ពុជា។ មានគោលបំណងគឺ កាប់ឆ្ការព្រៃដែលជាជម្រករបស់ពួកខ្មែរក្រហម ដែលបានលាក់ខ្លួន ហើយបានបង្កជាការរំខានដល់ការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ និងទប់ទល់ការវាយចូលរបស់ក្រុមខ្មែរក្រហម។

គ. គណៈគ្រប់គ្រងរបបនេះមាន៖

- គណបក្សប្រជាជនកម្ពុជា ដឹកនាំដោយលោក ប៉ែន សុវណ្ណ លុះឆ្នាំ១៩៨១ ជំនួសដោយលោក ហេង សំរិន។ អ្នកដែលអាចចូលជាបេក្ខជន ឬជនស្នូល ត្រូវបានឆ្លងកាត់ការពិនិត្យប្រវត្តិរូប យ៉ាងហ្មត់ចត់បំផុត។
- ក្រុមប្រឹក្សាបដិវត្តន៍ ឬគណៈរដ្ឋមន្ត្រី មានរដ្ឋមន្ត្រី១៧ រូប ដែលពីដំបូង មានលោកប៉ែន សុវណ្ណ ជាប្រធាន លុះដល់ឆ្នាំ១៩៨១ លោក ចាន់ ស៊ី បានឡើងមកជំនួស។
- ក្រុមប្រឹក្សារដ្ឋមានលោក ហេង សំរិន ជាប្រធាន។ លោកមានតួនាទី ជាអ្នកធ្វើការវិនិច្ឆ័យលើ បញ្ហាច្បាប់របស់រដ្ឋដូចជា រៀបចំក្រម ច្បាប់ព្រហ្មទណ្ឌ និងកែប្រែទោសប្រហារជីវិតជាដើម។
- រដ្ឋសភាជាតិ មានសមាជិក១១៧រូប កើតឡើងដោយការបោះឆ្នោតរដ្ឋសភាឆ្នាំ១៩៨១ ប្រជុំលើកទី១នៅខែមិថុនាឆ្នាំ១៩៨១ដើម្បីជ្រើសរើសប្រធានសភា គណៈរដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋ។

៥-កម្មវិធីអនុគ្រោះពន្ធ «គ្រប់មុខទំនិញទាំងអស់លើកលែងតែអាវុធ» ហៅកាត់ថា EBA គឺជាផ្នែកមួយនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ Generalized Scheme of Preferences ឬ GSP) របស់សហភាពអឺរ៉ុបផ្តល់ឱ្យដល់ក្រុមប្រទេសកំពុងអភិវឌ្ឍ។ ក្រោមកម្មវិធីអនុគ្រោះពន្ធ EBA នេះ សហភាពអឺរ៉ុបផ្តល់ឱ្យជាឯកតោភាគី ឬដោយខ្លួនឯង នូវលទ្ធភាពនាំចេញផលិតផលគ្រប់មុខទំនិញសព្វសារពើ លើកលែងតែអាវុធ និងគ្រាប់រំសេវតែប៉ុណ្ណោះ ទៅកាន់ទីផ្សារតែមួយរបស់សហភាពអឺរ៉ុប ដោយមិនចាំបាច់បង់ពន្ធ និងដោយគ្មានកូតាកំណត់ ដល់បណ្តារដ្ឋទាំងអស់ ដែលត្រូវចាត់ចូលក្នុងជំពូកជាក្រុមប្រទេសដែលមានការអភិវឌ្ឍន៍តិចតួចបំផុត (LDC) របស់អង្គការសហប្រជាជាតិ។កម្មវិធីអនុគ្រោះពន្ធ EBA ក៏ដូចជាប្រព័ន្ធអនុគ្រោះពន្ធទូទៅ GSP ទាំងមូលដែរ មានគោលដៅជួយដល់ក្រុមប្រទេសកំពុងអភិវឌ្ឍ ក្នុងកិច្ចប្រឹងប្រែងឈានទៅកាត់បន្ថយភាពក្រីក្រ លើកកម្ពស់អភិបាលកិច្ចល្អ និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយជួយជ្រោមជ្រែងក្រុមប្រទេសទាំងនោះ ឱ្យបង្កើតចំណូលបន្ថែមតាមរយៈការធ្វើពាណិជ្ជកម្ម ឬជំនួញអន្តរជាតិ។ លទ្ធភាពនៃការទទួលបានកម្មវិធីអនុគ្រោះពន្ធ EBA នេះ គឺស្ថិត

ក្រោមលក្ខខណ្ឌដែលថាប្រទេសទទួលអត្ថប្រយោជន៍ពីកម្មវិធីអនុគ្រោះពន្ធនេះ ត្រូវគោរពតាមគោលការណ៍ស្នូលទាំង ១៥ ស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិការងារ (ដូចដែលមានគូសបញ្ជាក់ក្នុងឧបសម្ព័ន្ធទី៨ ជំពូក ក នៃបទបញ្ញត្តិស្ដីពីប្រព័ន្ធអនុគ្រោះពន្ធទូទៅ របស់សហភាពអឺរ៉ុប) របស់អនុសញ្ញាអង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ (ILO)។

**ចំណាំ៖** មានចម្លើយត្រឹមត្រូវផ្សេងទៀត

៦-អធិប្បាយពីគោលនយោបាយ«អព្យាក្រឹត» នៅក្នុងកំឡុងទសវត្សរ៍ឆ្នាំ១៩៦០ ជំនាន់សង្គមរាស្ត្រនិយមរបស់សម្ដេចនរោត្តម សីហនុ៖

- **អត្ថន័យនៃនយោបាយ«អព្យាក្រឹត»ក្នុងសម័យសង្គមរាស្ត្រនិយមមានន័យថាជានយោបាយដែលមិនចូលបក្សសម្ព័ន្ធណាមួយរវាងប្លុកកុម្មុយនីស្ត និងប្លុកសេរី។**
- **ទំនាក់ទំនងជាមួយប្លុកសេរី**
  - ទំនាក់ទំនងជាមួយប្លុកសេរី មានការធ្លាក់ចុះបន្ទាប់ពីមានការទន្ទ្រានចូលទឹកដីខេត្តស្ទឹងត្រែង(ទីតាំងបច្ចុប្បន្នគឺនៅខេត្តរតនៈគិរី) របស់កម្ពុជាដោយខុសច្បាប់ពីសំណាក់កងទ័ពវៀតណាមខាងត្បូង នៅក្នុងឆ្នាំ១៩៥៨ ហើយពុំមានការអើពើពីសំណាក់សហរដ្ឋអាម៉េរិក
  - ការប៉ុនប៉ងទម្លាក់សម្ដេចនរោត្តម សីហនុ នៅឆ្នាំ១៩៥៩ មានជាប់ពាក់ព័ន្ធជាមួយ CIA របស់សហរដ្ឋអាម៉េរិក
  - នៅត្រឹមឆ្នាំ១៩៦២ ថៃ និងវៀតណាមខាងត្បូង កាន់តែគំរាមកំហែងខ្លាំងមកលើបូរណភាពទឹកដីកម្ពុជា។ នៅខែតុលា ឆ្នាំ១៩៦២ អ្នកតំណាងថៃនៅអង្គការសហប្រជាជាតិ បានទាមទារយកទឹកដី បាត់ដំបង សៀមរាប និងកំពង់ធំ។ ចំណែកយន្តហោះរបស់វៀតណាមខាងត្បូង បានទម្លាក់គ្រាប់បែកទៅលើភូមិខ្មែរជាច្រើននៅតាមជាយដែន។
  - នៅឆ្នាំ១៩៦៣ រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្ដេចនរោត្តម សីហនុ បានឈប់ទទួលជំនួយយោធាពីសហរដ្ឋអាម៉េរិក ដែលមានតម្លៃជាប្រាក់ចំនួន១៥ភាគរយនៃថវិកាជាតិ
  - ចាប់ពីកិច្ចប្រជុំកំពូលនៃទីក្រុងបានឌុង ឆ្នាំ១៩៥៥ មក កម្ពុជាបានបត់ឆ្វេងទៅជាមួយពួកកុម្មុយនីស្ត ហើយក៏ចេះតែ ឃ្លាតឆ្ងាយពីលោកសេរីបន្តិចម្ដងៗ រហូតឈានទៅដល់ការផ្ដាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយសហរដ្ឋអាម៉េរិកនៅឆ្នាំ ១៩៦៥។
  - នៅថ្ងៃទី២ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ មានដំណើរទស្សនកិច្ចរបស់លោកជំទាវ Jacqueline Kennedy មកដល់ទីក្រុងភ្នំពេញ ដែលចាប់ពីពេលនោះបរិយាកាសរវាងសហរដ្ឋអាម៉េរិក និងកម្ពុជា កាន់តែប្រសើរឡើងវិញ។ លទ្ធផលនាំមកនូវការបើកស្ថានទូតជាថ្មីឡើងវិញនាថ្ងៃទី១៦ សីហា ១៩៦៩។
  - នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ សម្ដេចព្រះនរោត្តម សីហនុ បានប្ដូរគោលនយោបាយពីមុន ទ្រង់បានផ្ដើម ផ្សារភ្ជាប់សម្ព័ន្ធភាពការទូតជាថ្មីជាមួយសហរដ្ឋអាម៉េរិក ដោយ

អនុញ្ញាតឱ្យអាម៉េរិកទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញ ហើយបានតែងតាំងលោកសេនាប្រមុខលន់ នល់ ដែលតែងតែប្រឆាំងនឹងលទ្ធិកុម្មុយនីស្តជានាយករដ្ឋមន្ត្រីថ្មី។

### ទំនាក់ជាមួយប្លុកកុម្មុយនីស្ត

- នៅក្នុងសន្និសីទទីក្រុងបានឌុង ឆ្នាំ១៩៥៥ សម្តេចនរោត្តម សីហនុ បានជួបនឹងមេដឹកនាំសំខាន់ៗ ដែលពេលនោះពួកគេបានអូសទាញឱ្យកម្ពុជានៅជាប្រទេសអព្យាក្រឹត។ ក្នុងពេលនោះផងដែរ សម្តេចក៏បានជួបនឹងមេដឹកនាំចិន ជូ អេនឡាយ វៀតណាមខាងជើង ផាម វ៉ាន់ដុង។
- នៅឆ្នាំ១៩៥៦ សម្តេចនរោត្តម សីហនុ បានយាងទៅធ្វើទស្សនកិច្ចនៅប្រទេសចិន ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាពកម្ពុជា-ចិន។ តាមរយៈកិច្ចព្រមព្រៀងបានផ្តល់ឱកាសឱ្យពួកវៀតកុង បង្កើតទីស្នាក់ការភូមិភាគ របស់គេនៅក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៥៧។
- នៅខែកក្កដា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជា បានភ្ជាប់ទំនាក់ទំនងទូតជាមួយប្រទេសចិនកុម្មុយនីស្ត
- ខណៈពេលផ្តាច់ជំនួយពីអាម៉េរិក ប្រទេសចិន និងវៀតណាមកុម្មុយនីស្ត បានសន្យាថានឹងផ្តល់ជំនួយដើម្បីជួយជ្រោមជ្រែងសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែអ្វីៗទាំងនោះគ្រាន់តែជាការសន្យាប៉ុណ្ណោះ ផ្ទុយទៅវិញពួកគេបានជាន់ឈ្លីសេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ចុះយ៉ាងខ្លាំង ព្រមទាំងបង្ករបិបត្តិនយោបាយគាំទ្រខ្មែរក្រហមឱ្យប្រឆាំងនឹងរដ្ឋាភិបាលសង្គមរាស្ត្រនិយម
- កម្ពុជា បានអនុញ្ញាតឱ្យកងទ័ព វៀតណាមខាងជើង យៀកកុង ប្រើប្រាស់ទឹកដីខ្មែរនៅតំបន់ភូមិភាគខាងកើតប្រទេស និងផ្តល់ស្បៀង គ្រឿងសព្វាវុធយុទ្ធភណ្ឌដល់យៀកកុង យៀកណាមខាងជើងផង។ ចាប់ពីពេលនោះមកកម្ពុជាបានធ្លាក់ខ្លួនយ៉ាងជ្រៅផងដែរទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២។
- កងទ័ពកុម្មុយនីស្ត បានប្រើប្រាស់ទឹកដីកម្ពុជាភាគឦសាន និងខាងកើតដើម្បីចល័តទ័ពមកវាយវៀតណាមខាងត្បូង ហើយប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៤ សម្រាប់ដឹកជញ្ជូនស្បៀង និងសម្ភារសឹកទៅផ្គត់ផ្គង់កងទ័ពវៀតណាមខាងជើង

### លទ្ធផល នយោបាយអព្យាក្រឹតរបស់កម្ពុជាចុះខ្សោយ

- ប្រទេសជាមហាអំណាចនៃប្លុកទាំងពីរ មិនទុកកម្ពុជាឱ្យរស់នៅក្នុងមាគ៌ាសន្តិភាព ហើយគេបានធ្វើសកម្មភាពប្រឆាំងនឹងនយោបាយអព្យាក្រឹត
- សហរដ្ឋអាម៉េរិកផ្តល់ជំនួយដល់កម្ពុជាពិសេសជំនួយផ្នែកយោធាដែលជំនួយនេះមានទិសដៅ ចិញ្ចឹមពួកស្តាំនិយម គោលបំណងផ្តួលរំលំសម្តេចនរោត្តមសីហនុ
- ប្រទេសថៃបានគាំទ្រសកម្មភាពខ្មែរសេរី ដែលជាកងទ័ពប្រឆាំងរាជរដ្ឋាភិបាល ដោយផ្តល់ដីឱ្យ កសាងជុំរុំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម

- កងទ័ពវៀតណាមខាងត្បូងបានធ្វើសកម្មភាពឈ្លានពានលើទឹកដីខ្មែរតាមព្រំដែន
- កងទ័ពវៀតណាមខាងជើងបានបង្កើតមូលដ្ឋានទ័ពលើទឹកដីខ្មែរនៅតាមព្រំដែន។ ពួកនេះបានបណ្តុះបណ្តាលកងកម្លាំងខ្មែរក្រហមដើម្បីធ្វើបដិវត្តន៍។ សកម្មភាពរបស់ប្រទេសខាងលើមានទិសដៅប្រឆាំងនឹងនយោបាយ អព្យាក្រឹត។

- សរុបសេចក្តីមក នយោបាយអព្យាក្រឹតត្រូវបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែ មីនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈ ដើម្បីទម្លាក់សម្តេច នរោត្តម សីហនុ ពីប្រមុខរដ្ឋ។ ការអូសទាញទាំងនេះបានធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២ ដោយជៀសពុំរួច ហើយទីបំផុតកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## វិញ្ញាសាត្រៀមទី៧

## ប្រធាន

1. ដូចម្តេចដែលហៅថាសង្គ្រាមត្រជាក់?
2. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
   ក-ចូររៀបរាប់ពីការបែកវណ្ណៈសង្គម។
   ខ-តើវប្បធម៌ខ្មែរមានលក្ខណៈដូចម្តេច?
3. តើការប្រើប្រាស់ថាមពលដែលបញ្ចេញកាបូនឌីអុកស៊ីតបណ្តាលឱ្យកើតគ្រោះធម្មជាតិអ្វីខ្លះ? កន្លងមកតើប្រទេសកម្ពុជាបានទទួលរងគ្រោះធម្មជាតិអ្វី? ហើយបានរងវិនាសកម្មអ្វីខ្លះ?
4. ចូរពិពណ៌នាពីដំណើរដើមហេតុដែលនាំឱ្យផ្ទុះសង្គ្រាមវៀតណាមនៅចន្លោះពីឆ្នាំ១៩៥៥ ដល់ឆ្នាំ១៩៧៥។
5. តើផលវិជ្ជមាននិងផលអវិជ្ជមាននៃកំណែទម្រង់របស់បារាំងមកលើប្រទេសកម្ពុជាមានអ្វីខ្លះ?
6. ចូរពន្យល់ពីមូលហេតុដែលនាំឱ្យសង្គ្រាមលោកលើកទី២ ផ្ទុះឡើងនៅទ្វីបអឺរ៉ុប និងផលវិបាកសម្រាប់ពិភពលោក។

## អត្រាកំណែ

១-សង្គ្រាមត្រជាក់គឺជាការប្រឈមមុខដាក់គ្នារវាងប្លុកលោកខាងលិច ដែលប្រកាន់យកលទ្ធិសេរីនិយម (Liberalism) និងប្លុកលោកខាងកើត ដែលប្រកាន់យកលទ្ធិកុម្មុយនីស្ត (Communism)។ ការប្រឈមមុខរវាង ប្លុកទាំងពីរនេះ កើតមានក្នុងវិស័យមនោគមវិជ្ជា នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម យោធា ការទូត និងទំនាក់ទំនងអន្តរជាតិ។

២- ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

**ក-វណ្ណៈសង្គមមានពីរះ**

- **ប្រជាជនមូលដ្ឋាន ឬប្រជាជនចាស់**

ប្រជាជនមូលដ្ឋានជាអ្នកដែលរស់នៅជនបទគ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជាមុនថ្ងៃ១៧ មេសា១៩៧៥។ ខ្មែរក្រហមបានបែងចែកអ្នកទាំងនេះជាប្រជាជនពេញសិទ្ធ ឬប្រជាជនត្រៀម។ ពួកនេះជាសមាជិកគ្រួសារក្រីក្រហើយត្រូវបានអនុញ្ញាតឱ្យទៅបោះឆ្នោតឬឈរឈ្មោះឱ្យគេបោះឆ្នោត ទោះបីការបោះឆ្នោតមានតែម្តងក៏ដោយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦។ ប្រជាជនចាស់អាចក្លាយជាប្រធានសហករណ៍ ឬប្រធានកងផ្សេងៗ។

- **ប្រជាជនថ្មី ឬប្រជាជន១៧មេសា**

ប្រជាជនថ្មីជាអ្នកដែលត្រូវបានគេជម្លៀសចេញពីទីក្រុង នាខែមេសាឆ្នាំ១៩៧៥។ ពួកនេះជាមនុស្សដែលគេមិនអាចជឿទុកចិត្តបាន ហើយទទួលបានការស្អប់ខ្ពើម និងការសង្ស័យពីសំណាក់អង្គការ។ ប្រជាជនថ្មីត្រូវបានអង្គការចាត់ទុកថាជាបញ្ញើក្អែក ហើយគ្មានសិទ្ធអ្វីទាំងអស់។

## ខ-លក្ខណៈរបស់វប្បធម៌ខ្មែរ

- **អាពាហ៍ពិពាហ៍**
  - វប្បធម៌នៃមង្គលការរបស់ខ្មែរត្រូវបានលុបបំបាត់ចោល គឺប្រជាជនខ្មែរត្រូវបានគេបង្ខំឱ្យរៀបការក្នុងពិធីតែមួយដែលមានចំនួនពី៣គូទៅ១០គូក្នុងពិធីតូច ហើយពី៣០គូទៅ៥០គូ ឬរហូតដល់១០០គូ។
  - សម្លៀកបំពាក់ ប្រពៃណី ពិធីរាំវង់ ចម្រៀងប្រពៃណី និងពិធីតាមបែបសាសនាត្រូវបានហាមឃាត់។
  - កូនក្រមុំ និងកូនកំលោះតម្រូវឱ្យរៀបការទាំងរាងកាយស្គាំងស្គម ល្វិតល្វៃ ដោយការទទួលទានអាហារមិនគ្រប់គ្រាន់ និងការងារហួសកម្លាំង។
  - ឪពុកម្តាយបងប្អូនបង្កើត និងមិត្តភក្តិ ក៏មិនបានមកចូលរួមអបអរសាទរដែរ ដោយហេតុថា ខ្មែរក្រហមឱ្យប្រជាជនទាំងអស់ចាត់ទុកអង្គការគឺជាឪពុកម្តាយ ។
  - ខ្មែរក្រហមប្រឆាំងនឹងទំនៀមទម្លាប់នៃអរិយធម៌ជាទូទៅ ជាពិសេសអរិយធម៌នៃប្រជាជាតិខ្មែរតែម្តង។ អាស្រ័យហេតុនេះ ទើបបានជាខ្មែរក្រហមច្រើនតែបង្ខំឱ្យយុវនារីដែលមានរូបសម្ផស្សស្អាតៗ ចរិតឆ្មើងឆ្មៃ ដែលកម្រនឹងចៃចង់បាននោះរៀបការជាមួយយោធាពិការ កំបុតជើង ខ្វាក់ភ្នែកម្ខាង និងមានរូបរាងអាក្រក់ក្រៃលែង ។
- **សីលធម៌**
  - សីលធម៌ខ្មែរត្រូវបានបាត់បង់
  - កូនមិនដឹងគុណឪពុកម្តាយគឺកូនអាចសម្លាប់ឪពុកម្តាយរបស់ខ្លួនដោយចោទថាជាខ្មាំងប្រឆាំងអង្គការ។
- **វត្តអារាម និងសាលារៀន**
  - វត្តអារាមត្រូវបានគេបំផ្លាញ
  - ព្រះសង្ឃត្រូវបានគេផ្សឹកឬយកទៅសម្លាប់ចោលដោយពុំស្គាល់អ្វីបាបបុណ្យឡើយ
  - ចំណែកឯសាលារៀនត្រូវបានបិទទ្វារជាហេតុធ្វើឱ្យឃ្លាំងវប្បធម៌ជាតិសាបសូន្យ
- **សិល្បៈ**
  - ចម្រៀង សិល្បៈប្រែក្លាយទៅជាសិល្បៈបែបបដិវត្តន៍។
  - អ្នកសិល្បៈ អ្នកចម្រៀង តន្ត្រីករ អ្នកនិពន្ធ ប្រហែលជា៩០ភាគរយត្រូវបានបាត់បង់ជីវិត
  - ទាំងសិល្បៈ និងចម្រៀងទាំងអស់ជាសិល្បៈឃោសនាដើម្បីឱ្យមហាជនបម្រើបដិវត្តន៍ដើរតាមមនោគមវិជ្ជាកុម្មុយនីស្ត បណ្តុះគំនិតជាតិនិយម បណ្តុះស្អប់ខ្ពើមការជិះជាន់តែប្រមូលកម្លាំងកសិករ និងកម្មករ ឱ្យក្រោកឈរតស៊ូ ដើម្បីផ្តួលរំលំវណ្ណៈសក្តិភូមិ និងបណ្តុះសតិអារម្មណ៍យុវជន យុវនារី ឱ្យមានស្មារតីស្នេហាជាតិដោយ អង់អាចក្លាហានតាមរយៈមនោគមវិជ្ជារបស់អង្គការ និងបង្ហាញពីការកសាងវប្បធម៌ថ្មីផងដែរ។
  - ចំពោះសិល្បៈគេមានរៀបប្រគំឡើងនាពេលយប់ក្រោយការប្រជុំជីវភាព និងបញ្ចប់ការងារ។

### ការអប់រំ

- ការអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាការអនុវត្ត និងការរៀនសូត្រជាក់ស្តែងនៅលើការងារគឺជាការអប់រំដ៏សំខាន់ និងចាំបាច់ជាងទ្រឹស្តីនៅក្នុងសៀវភៅទៅទៀត។
- ប្រព័ន្ធអប់រំត្រូវបានបំផ្លាញចោល សាលារៀនត្រូវបានបិទទ្វារ គ្រូបង្រៀនត្រូវបានរំលាយក្របខណ្ឌដែលនេះបានបង្ហាញថា ជាការបដិសេធចោលនូវសមត្ថភាពរបស់អ្នកចេះដឹង ខ្មែរក្រហមជឿជាក់ថានឹងអាចកសាងកម្ពុជាឆ្ពោះទៅយុគសម័យមួយដែលអាចឱ្យកសិករ និងអ្នកមានចំណេះដឹងតិចតួចអាចរស់នៅដោយស្មើភាពគ្នា តែប្រជាជនមូលដ្ឋានត្រូវបានជ្រើសរើសឱ្យធ្វើជាគ្រូបង្រៀន។
- អង្គការអប់រំកុមារា កុមារីទាំងអស់ដែលត្រូវចាត់ទុកជាកូនអង្គការឱ្យ៖
    - ស្រឡាញ់ និងដឹងគុណអង្គការតែមួយគត់
    - មានឆន្ទៈដាច់ខាត និងជឿជាក់លើអង្គការតែមួយគត់
    - យកការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយពេលខ្លះកុមារហ៊ានសម្លាប់ឪពុកម្តាយរបស់ខ្លួនដោយចោទថាខ្មាំង
    - ហ៊ានធ្វើពលីកម្មគ្រប់យ៉ាងចំពោះអង្គការ។
- ប្រព័ន្ធអប់រំកម្ពុជាប្រជាធិបតេយ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះកុមារ។ សម័យនោះកុមារត្រូវចែកតាមកង និងបង្ខំឱ្យធ្វើការដូចជា រើសអាចម៍គោ កាត់ទន្ទ្រានខេត្ត ប្រមូលជីលាមកមនុស្ស ជញ្ជូនសម្ភារៈសឹកទៅសមរភូមិ។
- ចម្លើយត្រឹមត្រូវផ្សេងទៀត

៣- ការប្រើប្រាស់ថាមពលដែលបញ្ចេញដោយការបូនឌីអុកស៊ីតបណ្តាលឱ្យឡើងកម្តៅនៅលើផែនដីដែលនាំឱ្យមាន៖

- កង្វក់អាកាស
- ភ្លៀងអាស៊ីត
- គ្រោះរាំងស្ងួត

ប្រទេសកម្ពុជាទទួលរងគ្រោះនូវគ្រោះធម្មជាតិជាច្រើនដូចជា៖

- គ្រោះទឹកជំនន់
- រាំងស្ងួត
- ភ្លើងឆេះព្រៃ
- កំណើនកម្តៅផែនដី
- រដូវមិនទៀងទាត់។

បញ្ហាទាំងអស់នេះនាំឱ្យ៖

- បាត់បង់ព្រៃឈើ
- បាត់បង់សត្វព្រៃ

- ខូចផលដំណាំប្រជាជន
- លិចលង់ផ្ទះសម្បែងប្រជាជន
- សឹកស្រទាប់ដី
- ធ្វើឱ្យមនុស្សស្លាប់ដោយសារកម្ដៅ។

៤-ពិពណ៌នាពីដើមហេតុដែលនាំឱ្យផ្ទុះសង្គ្រាមវៀតណាម នៅចន្លោះពីឆ្នាំ១៩៥៥ដល់ឆ្នាំ១៩៧៥

- សង្គ្រាមវៀតណាមគឺជាជម្លោះប្រដាប់អាវុធដ៏សំខាន់មួយនៅក្នុងប្រវត្តិនៃសង្គ្រាមត្រជាក់។ វាគឺជាសង្គ្រាម រវាងវៀតណាមខាងជើង (វៀតណាមកុម្មុយនីស្ត) គាំទ្រដោយប្លុកកុម្មុយនីស្ត និងវៀតណាមខាងត្បូង ដែលមានជំនួយពីកងទ័ពអាម៉េរិក។
- សង្គ្រាមនេះថា «សង្គ្រាមឥណ្ឌូចិនលើកទី២» បន្តពីសង្គ្រាមឥណ្ឌូចិនលើកទី១ គឺសង្គ្រាមរវាងមហាអំណាចអាណានិគមបារាំង និងវៀតណាម នៅចន្លោះពីឆ្នាំ១៩៤៥ដល់ឆ្នាំ១៩៥៤។
- ផលវិបាកដែលបន្សល់ទុកដោយសង្គ្រាមឥណ្ឌូចិនលើកទី១នេះហើយ ដែលជាឫសគល់នាំឱ្យមានសង្គ្រាមឥណ្ឌូចិនលើកទី២ ឬសង្គ្រាមវៀតណាម។
- ប្រទេសវៀតណាមត្រូវបានពុះចែកជាពីរ នៅក្នុងអំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១គឺនៅឆ្នាំ១៩៤៩ហើយបារាំងដែលជាអ្នកផ្ដួចផ្ដើមគំនិតបង្កើតរដ្ឋាភិបាល វៀតណាមខាងត្បូង ដោយដាក់ឱ្យស្ថិតក្រោមការដឹកនាំរបស់ព្រះចៅបាវដាយ អតីតអធិរាជនៃនគរអាណ្ណាម ដោយនៅពេលនោះ បារាំងមានការគាំទ្រពីសហរដ្ឋអាម៉េរិក។
- ក្នុងអំឡុងសង្គ្រាមលោកលើកទី២ សហរដ្ឋអាម៉េរិកធ្លាប់គាំទ្រចលនាតស៊ូវៀតណាមដឹកនាំដោយហូជីមិញដើម្បីប្រឆាំងនឹងជប៉ុន ហើយមេដឹកនាំអាម៉េរិកក៏តែងតែប្រកាន់ជំហរប្រឆាំងនឹងអាណានិគមផងដែរ ទាំងអាណានិគមនៅឥណ្ឌូចិន ក៏ដូចជាអាណានិគមនៅបណ្ដាប្រទេសផ្សេងៗទៀតនៅទូទាំងពិភពលោក។
- សង្គ្រាមលោកលើកទី២ត្រូវបញ្ចប់ ហើយនៅពេលដែលពិភពលោកត្រូវធ្លាក់ចូលទៅក្នុងសង្គ្រាមត្រជាក់ អាម៉េរិកបែរជាទៅគាំទ្របារាំងក្នុងការបង្ក្រាបចលនាទាមទារឯករាជ្យនៅវៀតណាមទៅវិញ។
- បារាំងគឺជាសម្ព័ន្ធមិត្តដ៏សំខាន់របស់អាម៉េរិកចំណែកឯចលនាទាមទារឯករាជ្យវៀតណាម ដែលដឹកនាំដោយហូជីមិញ គឺជាចលនាកុម្មុយនីស្តគាំទ្រដោយសហភាពសូវៀត និងចិន។
- មេដឹកនាំអាម៉េរិកបានក្បត់នឹងគោលគំនិតប្រឆាំងអាណានិគមរបស់ខ្លួន ធ្វើយ៉ាងណាឱ្យតែអាចបញ្ចៀសកុំឱ្យតំបន់ឥណ្ឌូចិនត្រូវធ្លាក់ក្រោមការកាន់កាប់របស់ពួកកុម្មុយនីស្ត។
- នៅទីបំផុតបារាំងនៅតែត្រូវចាញ់ពួកកុម្មុយនីស្តវៀតណាមគឺបរាជ័យនៅឌៀនបៀនហ្វូនៅឆ្នាំ១៩៥៤ ហើយអាម៉េរិកក៏ចាប់ផ្ដើមផុងខ្លួនបន្តិចម្ដងៗកាន់ តែជ្រៅទៅក្នុងជម្លោះនៅឥណ្ឌូចិន។

- នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ បារាំងបានចុះកិច្ចព្រមព្រៀងបញ្ចប់សង្គ្រាមឥណ្ឌូចិន នៅក្នុងសន្និសីទក្រុងហ្សឺណែវ ដោយបារាំងបានសុខចិត្តប្រគល់ឯករាជ្យដល់វៀតណាម ក៏ប៉ុន្តែនៅក្នុងសន្និសីទក្រុងហ្សឺណែវនេះ ប្រទេសវៀតណាមត្រូវបានគេបន្តទុកឱ្យនៅពុះចែកជាពីរដដែល ដោយបានត្រឹមតែកំណត់ថា វៀតណាមទាំងពីរនឹងត្រូវបង្រួបបង្រួមគ្នាមកវិញ នៅក្រោយការបោះឆ្នោតជាតិមួយ ដែលគេគ្រោងរៀបចំធ្វើឡើងនៅទូទាំងប្រទេសវៀតណាមនៅឆ្នាំ១៩៥៦។
- វៀតណាមខាងត្បូងបានបដិសេធមិនគោរពតាមកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដោយលើកហេតុផលថាវៀតណាមខាងត្បូង មិនមែនជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងហ្សឺណែវនេះទេ គឺមានតែគណៈប្រតិភូមកពីវៀតណាមខាងជើងតែប៉ុណ្ណោះ ដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។
- សហរដ្ឋអាម៉េរិកវិញ បានរិះគន់ផែនការបោះឆ្នោតដែលចែងក្នុងកិច្ចព្រមព្រៀងក្រុងហ្សឺណែវ ដោយលើកហេតុផលថា ខ្លួនបានទាមទារឱ្យការបោះឆ្នោតជាតិវៀតណាមនេះត្រូវរៀបចំធ្វើដោយអ.ស.ប ដើម្បីធានានូវភាពសេរី និងយុត្តិធម៌ ក៏ប៉ុន្តែ សហភាពសូវៀត ដែលជាសម្ព័ន្ធមិត្តរបស់វៀតណាមខាងជើងបានជំទាស់។
- លោកង៉ូ ឌិនហៀម បានបណ្តេញព្រះចៅបាវដាយពីអំណាច រួចហើយបង្កើតជារបបសាធារណរដ្ឋមួយឡើងដោយប្រកាសតាំងខ្លួនឯងជាប្រធានាធិបតី។
- ចលនាឧទ្ទាមកុម្មុយនីស្តស្និទ្ធនឹងវៀតណាមខាងជើងក៏បានចាប់ផ្តើមរីកដុះដាលឡើងកាន់តែខ្លាំង នៅក្នុងទឹកដីវៀតណាមខាងត្បូង គឺចលនាឧទ្ទាមដែលត្រូវបានគេហៅជាទូទៅថា«វៀតកុង»។
- ការកើនឡើងនៃចលនាឧទ្ទាមកុម្មុយនីស្តវៀតកុង នៅវៀតណាមខាងត្បូង លោក Dwight Eisenhower ប្រធានាធិបតីអាម៉េរិកបានបង្កើនការគាំទ្រកាន់តែខ្លាំងដល់របបដឹកនាំរបស់លោកង៉ូ ឌិន ហៀម តាមរយៈការផ្តល់ជំនួយជាលុយ និងគ្រឿងសព្វាវុធ ព្រមទាំងបញ្ជូនទីប្រឹក្សាយោធាជាច្រើននាក់ឱ្យទៅជួយហ្វឹកហ្វឺនពង្រឹងកម្លាំងទ័ពវៀតណាមខាងត្បូង ដើម្បីប្រយុទ្ធតទល់នឹងវៀតណាមកុម្មុយនីស្ត។

៥-លទ្ធផលវិជ្ជមាននិងអវិជ្ជមាននៃកំណែទម្រង់របស់បារាំងមកលើប្រទេសកម្ពុជា៖

**ចម្លើយទី១៖**

**ក. លទ្ធផលវិជ្ជមាន**

- បារាំងបានបង្កើតសាលាចុងបូព៌ាប្រទេសដើម្បីស្រាវជ្រាវ ចងក្រង ផ្សព្វផ្សាយពីអរិយធម៌ សិល្បៈ ចម្លាក់ ប្រវត្តិសាស្ត្ររបស់ខ្មែរ និងជួសជុលប្រាសាទបុរាណខ្មែរជាច្រើន។ នេះធ្វើឱ្យមរតកអតីតកាលខ្មែរដែលកប់បាត់បានរស់ឡើងវិញ។ កិច្ចការនេះបានផ្តល់ប្រយោជន៍ជាច្រើនដល់ខ្មែរ ដូចជាការមានទំនុកចិត្ត និងមោទនភាពជាតិតាមរយៈភាពរុងរឿងនៃចក្រភពអង្គរ ព្រមទាំងពញាក់ស្មារតីខ្មែរឱ្យចេះសាមគ្គីតាមរយៈមេរៀនប្រវត្តិសាស្ត្រ
- ក្រោមការគាបសង្កត់របស់បារាំង សៀមបានប្រគល់ឱ្យខ្មែរវិញនូវខេត្តម្លូព្រៃ ទន្លេរពៅ

ស្ទឹងត្រែង កោះកុង ត្រាច(ត្រាត, ក្រាត) នៅឆ្នាំ១៩០៤ និងបាត់ដំបង សៀមរាប សិរីសោភ័ណនៅឆ្នាំ ១៩០៧ ...។

- នៅឆ្នាំ១៩០៨ បារាំងបានធ្វើផែនទីមួយឈ្មោះ ផែនទីដងរែក ដែលទទួលស្គាល់ដោយតំណាងបារាំង-សៀម និងតុលាការអន្តរជាតិរហូតដល់បច្ចុប្បន្ន។ ផែនទីនេះផ្តល់សារប្រយោជន៍ខ្លាំងណាស់ដល់កម្ពុជាក្នុងរឿងក្តីប្រាសាទព្រះវិហារ ។
- កំណែទម្រង់ដែលនាំមកនូវទំនើបកម្មនៅកម្ពុជា៖
    - វិស័យរដ្ឋបាល៖ បារាំងបានកែទម្រង់វិស័យរដ្ឋបាលខ្មែរឱ្យមានប្រសិទ្ធភាព និងមានរបៀបរៀបរយ។
    - វិស័យសង្គម ៖
        - ការកែទម្រង់លើប្រព័ន្ធពន្ធដារ រដ្ឋបាល ការពង្រឹងច្បាប់កម្មសិទ្ធិដីធ្លី និងការលុបបំបាត់ទាសភាពបានធ្វើឱ្យមានការប្រែប្រួលវិស័យចិត្តសាស្ត្រសង្គម
        - ការបង្កើតឡើងនូវការចុះបញ្ជីដីធ្លី និងការបង្កើតនូវកម្មសិទ្ធិលើដីធ្លីបានផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់បុរាណ
        - ការបង្កើតប្រព័ន្ធច្បាប់ថ្មីធ្វើឱ្យសង្គមខ្មែរមានភាពម្ចាស់ការនិង ស្ថិរភាពពិសេសម្ចាស់ដីតូចតាច
    - វិស័យសិក្សាធិការ ៖
        - មានការបង្កើតសាលាតាមវត្ត សាលាតាមឃុំ និងសាលាបឋមសិក្សារីឯសាលាមធ្យមសិក្សាដែលបង្កើតដំបូងមានអនុវិទ្យាល័យព្រះស៊ីសុវត្ថិ
        - មានការដាក់ទោសដល់ឪពុកម្តាយណាដែលមិនបញ្ជូនកូនទៅរៀន
        - មានការបង្កើតគណៈកម្មាធិការរៀបចំវចនានុក្រមខ្មែរ ដើម្បីធ្វើឱ្យភាសាជាតិមានលក្ខណៈប្រាកដនិយមនៅឆ្នាំ១៩១៥
    - វិស័យសេដ្ឋកិច្ច៖ ពឹងផ្អែកលើកសិកម្ម និងកសិ-ឧស្សាហកម្មដូចជា ម្រេច ក្រចៅ ថ្នាំជក់ កៅស៊ូ...
    - វិស័យកសិកម្ម ៖ ការបង្កើតប្រព័ន្ធកសិកម្ម«កសិដ្ឋាន»។ កំណែទម្រង់នេះបានធ្វើឱ្យកម្ពុជាមានមុខមាត់លើទីផ្សារអន្តរជាតិ ព្រមទាំងបង្កើតបាននូវប្រព័ន្ធផ្គត់ផ្គង់ផលិតផលលើទីផ្សារ។
    - វិស័យសុខាភិបាល៖ មានការបង្កើតមន្ទីរពេទ្យ
    - វិស័យគមនាគមន៍៖ការកសាងស្ពានព្រះមុនីវង្សឆ្លងកាត់ទន្លេបាសាក់ ផ្លូវរថភ្លើងមួយខ្សែប្រវែង២៧៥គីឡូម៉ែត្រ ដែលតភ្ជាប់ពីភ្នំពេញទៅអារញ្ញដោយកាត់តាមប៉ោយប៉ែត ព្រមទាំងផ្លូវថ្នល់ ផ្លូវអាណានិគម ផ្លូវខេត្ត និងផ្លូវលំជនបទ។

**ខ. លទ្ធផលអវិជ្ជមាន**

- សង្គមខ្មែរបានលេចឡើងនូវសកម្មភាពពាណិជ្ជកម្មយ៉ាងសកម្មក្នុងការទិញដូរអចលនវត្ថុ ការដាក់បញ្ចាំ និងការធ្វើជំនួញស្រូវ អង្ករ នៅទីក្រុង ដែលជាទំនាក់ទំនងប្រព័ន្ធ «ទីផ្សារ»។ ស្របពេលជាមួយគ្នា យើងសង្កេតឃើញថា ពួកអ្នកមាន និងអ្នកជំនួញភាគច្រើនជាជនជាតិចិន និងយួន ចំណែកឯ កសិករខ្មែរភាគច្រើនក្លាយជាជនរងគ្រោះអស់ដីធ្លី ដោយការលក់-បញ្ចាំ។
- បារាំងបានធ្វើការជិះជាន់ គាបសង្កត់ និងប្រមូលពន្ធដារគ្រប់ប្រភេទយ៉ាងធ្ងន់ធ្ងរដែលធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រ
- បារាំងបានកេណ្ឌប្រជាពលរដ្ឋខ្មែរឱ្យបម្រើយោធាបារាំងក្នុងសង្គ្រាមលោកលើកទី១ និងទី២
- ទឹកដីកម្ពុជាមួយចំនួនដែលស្ថិតនៅប៉ែកខាងកើតទន្លេមេគង្គដូចជាអាតាពើ (Attopeu)ត្រូវបានបារាំងសម្រេចប្រគល់ទៅឱ្យកូសាំង ស៊ីននៅឆ្នាំ១៨៩៣។ ទឹកដីដ៏មានជីជាតិ និងសម្បូរទៅដោយធនធានធម្មជាតិនេះផ្ដល់សារៈសំខាន់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងនយោបាយរបស់សៃហ្គន ជាពិសេសកូសាំងស៊ីនដែលជាទឹកដីក្រោមការគ្រប់គ្រងផ្ទាល់របស់បារាំង។ បារាំងបានពន្យល់ពីហេតុ ផលនៃការកាត់ដីនេះទៅឱ្យកូសាំងស៊ីនថាព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម បដិសេធមិនព្រមទទួលដោយសារកង្វះខាតថវិកាក្នុងការគ្រប់គ្រង។ ក្រោយមក ទឹកដីអាតាពើត្រូវបានបារាំងកាត់ទៅឱ្យឡាវវិញ។
- នៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បារាំងបានដាក់បញ្ចូលកោះត្រល់ទៅក្នុងដែនរដ្ឋបាលកូសាំងស៊ីន។
- បារាំងប្រមូលយកវត្ថុកេតនភណ្ឌរបស់ខ្មែរទៅស្រុកបារាំង។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

**ចម្លើយបែបទី២**

**ផលវិជ្ជមាន**

- ការទាមទារយកមកវិញនូវទឹកដីខ្មែរពីសៀម
  - ខេត្តស្ទឹងត្រែងនៅឆ្នាំ១៨៩៣
  - ខេត្តកោះកុង ត្រាច(ត្រាត, ក្រាត) ម្លូរព្រៃ ទន្លេរពៅ នៅឆ្នាំ១៩០៤
  - ខេត្តសៀមរាប បាត់ដំបង សេរីសោភ័ណ្ឌ នៅឆ្នាំ១៩០៧
- វិស័យកសិកម្មដំណាំកសិឧស្សាហកម្មមានការរីកចម្រើន
- ក្នុងរាជ្យព្រះបាទមុនីវង្សមានការកសាងផ្លូវគមនាគមន៍ ផ្លូវដែក ស្ពាន...
- ក្នុងរាជ្យព្រះបាទស៊ីសុវត្ថិការសិក្សាបានចាប់ផ្ដើម
- ឆ្នាំ១៩១៥ រៀបចំវចនានុក្រមខ្មែរ
- លុបបំបាត់របបទាសភាព

- បង្កើតអភិក្រមទំនើបកម្ម ឬសង្គមស៊ីវិល័យ
- គូសផែនទីដងរែកនៅឆ្នាំ១៩០៨ ទុកជាប្រយោជន៍ដល់ខ្មែរ
- មានការចងក្រងប្រវត្តិខេត្ត
- សិក្សាស្រាវជ្រាវ ចងក្រងពីអរិយធម៌ប្រវត្តិសាស្ត្រខ្មែរ និងធ្វើការផ្សព្វផ្សាយទៅលើឆាកអន្តរជាតិ និងជួយជួសជុល ការពារប្រាសាទខ្មែរ
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

**ផលអវិជ្ជមាន**

- ជីវភាពប្រជាជនកាន់តែក្រីក្រ
- ជំរិតទារពន្ធដារយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យប្រជាពលរដ្ឋខ្មែរមានគម្លាតរវាងអ្នកមាន និងអ្នកក្រ ទីក្រុង និងជនបទ
- កេណ្ឌប្រជាជនខ្មែរឱ្យទៅបម្រើយោធាស្លាប់នៅសមរភូមិសង្គ្រាមលោកលើកទី១និង លោកលើកទី២
- តំបន់ដាឡាត់ កាត់ទៅឱ្យវៀតណាម
- ខេត្តត្រាចត្រូវធ្លាក់ក្នុងដៃប្រទេសសៀម
- បារាំងបានដឹកជញ្ជូនវត្ថុកេតនភ័ណ្ឌទៅស្រុកបារាំង
- ឆ្នាំ១៩០៧ កាត់ខេត្តត្រាចទៅឱ្យសៀម
- ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៣៩ បារាំងដាក់បញ្ចូលកោះត្រល់ចូលក្នុងដែនរដ្ឋបាលកូសាំងស៊ីន
- ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំងបានកាត់ទឹកដីកម្ពុជាក្រោមឱ្យទៅវៀតណាម។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## ៦.សង្គ្រាមលោកលើកទី២

### មូលហេតុនៃសង្គ្រាមលោកលើកទី២

- **សន្ធិសញ្ញាក្រុងវែរសៃ ថ្ងៃទី២៨ ខែមិថុនា ១៩១៩**
  - បែងចែកផលប្រយោជន៍មិនស្មើគ្នាក្នុងចំណោមមហាអំណាចដែលឈ្នះសង្គ្រាម
  - អ៊ីតាលី និងជប៉ុនមិនសប្បាយចិត្តចំពោះសន្ធិសញ្ញានេះ
  - ដាក់លក្ខខណ្ឌធ្ងន់ធ្ងរចំពោះប្រទេសអាល្លឺម៉ង់ ដូចជាសំណងការខូចខាតក្នុងសង្គ្រាម ការកាត់ផ្តាច់ដែនដី និងការកម្រិតផ្នែកយោធា ដែលជាហេតុធ្វើឱ្យហ៊ីត្លែរ យកជាលេសក្នុងការបញ្ឆេះគំនិតជាតិនិយមអាល្លឺម៉ង់ឡើង
- **វិបត្តិនយោបាយ**
  - នយោបាយប្រឆាំងនឹងឥទ្ធិពលកុម្មុយនីស្តរបស់មហាអំណាចអឺរ៉ុប និងសហរដ្ឋអាម៉េរិក
  - នយោបាយឯកោនិយមរបស់សហរដ្ឋអាម៉េរិក
  - ការចូលកាន់អំណាចនៃពួកហ្វាស៊ីស អ៊ីតាលី និងពួកណាស៊ី អាល្លឺម៉ង់

- នយោបាយបញ្ចៀសសង្គ្រាមរបស់បារាំង និងអង់គ្លេស
- នយោបាយឈ្លានពានរបស់អាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន

### វិបត្តិសេដ្ឋកិច្ច

- ការធ្លាក់ចុះនៃសេដ្ឋកិច្ចទ្វីបអឺរ៉ុបនៅក្រោយសង្គ្រាម
- មហាវិបត្តិសេដ្ឋកិច្ចពិភពលោកដែលផ្ទុះឡើងនៅអាម៉េរិក បានជះឥទ្ធិពលជាខ្លាំងផងដែរដល់បណ្តាប្រទេសនានា ជាពិសេសនៅទ្វីបអឺរ៉ុប
- បន្ទាប់ពីវិបត្តិ សេដ្ឋកិច្ចអាល្លឺម៉ង់ទទួលបានការ លូតលាស់យ៉ាងឆាប់រហ័ស ក្លាយជាមហាអំណាចសេដ្ឋកិច្ចមួយដ៏ខ្លាំងនៅទ្វីបអឺរ៉ុប។
- អាល្លឺម៉ង់បានបង្កើតគោលនយោបាយស្វះស្វែងរកទីផ្សារនៅទូទាំងពិភពលោកដើម្បីផលិតផលឧស្សាហកម្មរបស់ខ្លួន មិនត្រឹមតែប៉ុណ្ណោះ អាល្លឺម៉ង់មានបំណងដណ្តើមយកទីផ្សារនានារបស់ពួក មហាអំណាចអាណានិគមនិយម អង់គ្លេស បារាំង សហរដ្ឋអាម៉េរិក ទាំងនៅទ្វីបអាស៊ី និងអាហ្វ្រិក។

### វិបត្តិសង្គម

- កើតចេញពីវិបត្តិសង្គមនេះបានធ្វើឱ្យពួកហ្វាស៊ីសអ៊ីតាលី និងណាហ្ស៊ីអាល្លឺម៉ង់ ចូលកាន់អំណាច និងអនុវត្តនយោបាយផ្តាច់ការ

### យោធានិយម

- ដើម្បីសម្រេចផែនការត្រួតត្រាពិភពលោកទាំងមូល អ៊ីត្លែរបានស្តាបនាឧស្សាហកម្មសឹកមួយឱ្យមានលក្ខណៈសម្បើម ជាងមុន
- កងទ័ពអាល្លឺម៉ង់ត្រូវហ៊ីត្លែរបំពាក់អាវុធយុទ្ធភណ្ឌសព្វសារពើយ៉ាងទំនើបៗ ព្រមទាំងទទួលបានការហ្វឹកហាត់ប្រកបទៅដោយវិន័យតឹងរឹង និងម៉ឺងម៉ាត់ជាងទ័ពនានានៅអឺរ៉ុប
- នៅឆ្នាំ១៩៣៧ សន្ធិសញ្ញា រ៉ូម-ប៊ែរឡាំង-តូក្យូ ត្រូវបានបង្កើតឡើង
- នៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ១៩៣៩ កិច្ចព្រមព្រៀងស្តីពីការមិនឈ្លានពានគ្នារវាងអាល្លឺម៉ង់ សូវៀតត្រូវបានចុះ ហត្ថលេខា
- នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៣៩ កងទ័ពអាល្លឺម៉ង់ បានចូលឈ្លានពានប្រទេសប៉ូឡូញ ដោយយកលេសថា កងទ័ពប៉ូឡូញ បានចូលឈ្លានពានអាល្លឺម៉ង់

### ជាតិនិយម

- លើកតម្កើងជាតិសាសន៍ខ្លួនឯង
- ធ្វើឱ្យជាតិសាសន៍អាល្លឺម៉ង់មានឈាមបរិសុទ្ធ ហើយខ្លាំងពូកែ
- បណ្តុះមនោសញ្ចេតនាស្នេហាសង្គម និងប្រពៃណីរបស់ជនជាតិអាល្លឺម៉ង់
- ទ្រឹស្តីជាតិនិយមរបស់ជប៉ុន គឺអាស៊ីសម្រាប់អាស៊ី (អាស៊ីសម្រាប់ជប៉ុន)

### ចំណុចត្រឹមត្រូវផ្សេងទៀត

## ផលវិបាកនៃសង្គ្រាមលោកលើកទី២

### នយោបាយ

- ចុងបញ្ចប់នៃសង្គ្រាមពិភពលោកធ្លាក់ចូលក្រោមឥទ្ធិពលនៃមហាអំណាចពីរ ដែលប្រជែងយកតួនាទីជាមហាអំណាចផុតលេខ គឺសហរដ្ឋអាម៉េរិក និងសហភាពសូវៀត
- លទ្ធិកុម្មុយនីស្ត បានរីករាលដាលចូលទៅក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសនៅអឺរ៉ុបខាងកើត ដែលត្រូវបានរំដោះដោយកងទ័ពក្រហមសូវៀត
- ក្រោយសង្គ្រាមបញ្ចប់ពិភពលោកធ្លាក់ចូលក្នុងសង្គ្រាមថ្មីមួយទៀតគឺសង្គ្រាមត្រជាក់
- សង្គ្រាមលោកលើកទី២ បានធ្វើឱ្យពិភពលោកឈានចូលទៅក្នុងយុគសម័យ នៃអាវុធបរមាណូ(The Nuclear Age)
- សង្គ្រាមលោកបានធ្វើឱ្យផុសឡើងនូវលទ្ធិជាតិនិយម (The Nationalism) និងចលនាទាមទារឯករាជ្យ (The Independence movement) ក្នុងទ្វីបអាស៊ី អាហ្វ្រិក និងអាម៉េរិកឡាទីន
- ការចាប់បដិសន្ធិនៃអង្គការអន្តរជាតិ និងរបៀបរបបពិភពលោកថ្មីមួយ
- ផែនទីពិភពលោកមានការប្រែប្រួល ភូមិសាស្ត្រនយោបាយមានការផ្លាស់ប្តូរ។

### សេដ្ឋកិច្ច

- ភាពហិនហោច ៖ ផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ រោងចក្រ លំនៅស្ថាន ត្រូវបានបំផ្លាញ ដោយការ ទម្លាក់គ្រាប់បែក ឬការប្រយុទ្ធ ពិសេស នៅប្រទេសអាល្លឺម៉ង់ និងនៅអឺរ៉ុបខាងកើត។
- ការផ្អាក សកម្មភាព ខាងផ្នែកពាណិជ្ជកម្ម អន្តរជាតិ
- សេដ្ឋកិច្ចទ្វីបអឺរ៉ុបមានការធ្លាក់ចុះខ្លាំង ស្ទើរក្ស័យធន់ បាត់បង់តួនាទីជាមហាអំណាចសេដ្ឋកិច្ច
- អតិផរណា
- ការជំពាក់បំណុលបរទេស
- ការពុះចែកទ្វីបអឺរ៉ុបជាជម្រៀកៗ
- សហរដ្ឋអាម៉េរិកក្លាយជាមហាអំណាចសេដ្ឋកិច្ចធំបំផុតនៅលើពិភពលោក
- កូនបំណុលសហរដ្ឋអាម៉េរិក១៩៤០ មាន៩ពាន់លានដុល្លារ កើនដល់៥៨ពាន់លានដុល្លារ ឆ្នាំ១៩៤៥
- ប្រាក់ដុល្លារក្លាយជារូបិយបណ្ណអន្តរជាតិ សម្រាប់សម្រាប់វិស័យពាណិជ្ជកម្ម

### សង្គម

- កងទ័ព និងប្រជាជនស៊ីវិល ចន្លោះពី ៤០លាន ទៅ ៦០លាននាក់ ត្រូវបាត់បង់ជីវិត
- ប្រមាណ៦២លាននាក់ត្រូវរងរបួស និងពិការ
- បន្សល់ទុកនូវស្ត្រីមេម៉ាយ កុមារកំព្រា ព្រាត់ប្រាស់គ្នា...

### ចំណុចត្រឹមត្រូវផ្សេងទៀត

## វិញ្ញាសាត្រៀមទី៨

**ប្រធាន**

1. តើ «ដូយម៉ឺយ» មានគោលការណ៍យ៉ាងណាខ្លះ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម?
2. នៅមុនព្រឹត្តិការណ៍ថ្ងៃទី១៨ មីនា១៩៧០ តើសេដ្ឋកិច្ចប្រទេសកម្ពុជាមានស្ថានភាពដូចម្ដេច?
3. តើសង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានផលវិបាកអ្វីខ្លះសម្រាប់កម្ពុជា?
4. របបកម្ពុជាប្រជាធិបតេយ្យ
   - ក-តើនាយករដ្ឋមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យឈ្មោះអ្វី?
   - ខ-តើហេតុអ្វីបានជាគេជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?
   - គ-ចូររៀបរាប់ពីសត្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
5. ចូរវិភាគពីមូលហេតុដែលនាំឱ្យមានរដ្ឋប្រហារថ្ងៃទី១៨ មីនា ១៩៧០។
6. ចូរវិភាគពីនយោបាយក្រៅប្រទេស នៃអព្យាក្រឹតរបស់កម្ពុជាក្នុងទសវត្សរ៍ឆ្នាំ១៩៦០។

## អត្រាកំណែ

១-គោលការណ៍មូលដ្ឋានរបស់«**ដូយម៉ឺយ**» ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាមគឺថែរក្សាស្ថិរភាពនយោបាយនៅក្នុងសង្គមកសាងទំនាក់ទំនងល្អលើនយោបាយការបរទេសក្នុងឆាកអន្តរជាតិ និងតំបន់ ដើម្បីជំរុញប្រទេសចេញឱ្យផុត ពីស្ថានភាពហ៊ុមព័ទ្ធ ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងជំរុញប្រទេសឱ្យចូលរួមទៅក្នុងសមាហរណកម្មនយោបាយ និងសេដ្ឋកិច្ចលើសកលលោក។

២- សេដ្ឋកិច្ចកម្ពុជាមុនថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០គឺ

- សកម្មភាពសេដ្ឋកិច្ចមានដំណើរការរាំងស្ទះដោយសារតែ
  - មានការបាត់បង់ប្រាក់ចំណូលដែលជាលទ្ធផលនៃការរត់ពន្ធ
  - ការគ្រប់គ្រងឧស្សាហកម្មមិនបានល្អ
  - ការចំណាយខ្វះតុល្យភាព
- ក្នុងវិស័យនីហរ័ណ-អាហរ័ណផ្នែកសេដ្ឋកិច្ច ត្រូវបានធ្វើជាតូបនីយកម្ម និងបានបិទទ្វារធនាគារ ឯកជនខ្មែរ។
- ពាណិជ្ជកម្មក្រៅប្រទេសជួបនិងបញ្ហាអោក់ អេួល ដោយសារការបាត់បង់ជំនាញគ្រប់គ្រងរបស់ សហគ្រាស និងកង្វះខាតបច្ចេកទេសជំនាញ។
- រដ្ឋាភិបាលបាត់បង់ចំណូលទៅលើការនាំចេញ ដោយសារតែការនាំចេញគេចពន្ធនិងពាណិជ្ជកម្ម លួចលាក់...។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៣-សង្គ្រាមពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ មានផលវិបាកដូចជា៖

**ក.ផលវិបាកក្នុងសង្គម**

- សង្គ្រាមបានសម្លាប់ជីវិតមនុស្សជាងមួយលាននាក់
- បន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា ចាស់ជរា ជនពិការ
- ប្រជាជនភៀសខ្លួនពីជនបទចូលមកទីក្រុងរស់ដោយទុក្ខវេទនា
- អំពើពុករលួយ ភាពអយុត្តិធម៌ អនាធិបតេយ្យទូទាំងប្រទេស
- បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

**ខ.ផលវិបាកសេដ្ឋកិច្ច**

- ដីស្រែចម្ការត្រូវបោះបង់ចោល ក្លាយជាចម្ការមីន រណ្តៅគ្រាប់បែក
- រោងចក្រសហគ្រាស៧៥% ត្រូវបំផ្លិចបំផ្លាញ
- ចម្ការកៅស៊ូត្រូវបោះបង់ចោល
- ផ្លូវថ្នល់ ស្ពាន ៧០% ទៅ៨០% ត្រូវអន្តរាយ
- សេដ្ឋកិច្ចជាតិធ្លាក់ចុះ
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

**គ.វិស័យនយោបាយ**

- ប្រទេសជាតិត្រូវបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ កិត្យានុភាពលើឆាកអន្តរជាតិ
- អស្ថិរភាពនយោបាយដោយសង្គ្រាមស៊ីវិលបានបង្កវិនាសកម្មលើគ្រប់វិស័យ
- ផ្តល់ឱកាសដល់ពួកខ្មែរក្រហមឡើងកាន់អំណាចបាន។
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

៤- របបកម្ពុជាប្រជាធិបតេយ្យ

ក-នាយករដ្ឋមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺ ប៉ុល ពត ឬ សាឡុត ស ។

ខ-បានជាខ្មែរក្រហមជម្លៀសប្រជាជនទាំងអស់ចេញពីទីក្រុងព្រោះដើម្បីកម្ទេចចោល អ្នករស់នៅទីក្រុង និងកសាងកម្ពុជាថ្មីមួយដោយផ្អែក លើការពង្រីកផលិតកម្មស្រូវ ថែមទាំងមានលេសថាអាម៉េរិកទម្លាក់គ្រាប់បែកហើយខ្វះមធ្យោបាយក្នុងការដឹកជញ្ជូនស្បៀងមកផ្គត់ផ្គង់។

គ- សត្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖

**១.សត្រូវខាងក្នុង**

- អ្នករដ្ឋការរបស់របបសាធារណរដ្ឋខ្មែរ
- បញ្ញវន្ត
- ក្រុមជនជាតិភាគតិច
- ជនជាតិភាគតិចតំបន់ភ្នំ
- ជនជាតិខ្មែរអ៊ីស្លាម
- ជនជាតិភាគតិចវៀតណាម
- ជនជាតិភាគតិចចិន
- ក្រុមកម្មាភិបាលខ្មែរក្រហមដែលស្ថិតក្នុងការសង្ស័យថាក្បត់បដិវត្តន៍។

**២-សត្រូវខាងក្រៅ:** មានសហរដ្ឋអាម៉េរិកថៃ វៀតណាម និងអតីតសហភាពសូវៀត។

៥-វិភាគពីមូលហេតុដែលនាំឱ្យមានរដ្ឋប្រហារថ្ងៃទី១៨ មីនា ១៩៧០។ រដ្ឋប្រហារនេះកើតឡើងដោយសារតែនៅចុងសម័យសង្គមរាស្ត្រនិយមជួបនូវបញ្ហាដូចជា៖

**ក.សេដ្ឋកិច្ចមានសភាពដំណើររាំងស្ទះ**

- បាត់ប្រាក់ចំណូលបណ្តាលមកពីការគេចពន្ធ និងការលក់ស្រូវឱ្យពួកយៀកកុង
- ការគ្រប់គ្រងឧស្សាហកម្មរដ្ឋមិនបានល្អ
- ការចំណាយខ្វះតុល្យភាព
- បញ្ហាកសិកម្មជួបនឹងវិបត្តិ ប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ទិន្នផលកសិកម្មទាប។
- ដើម្បីគេចពីសង្គ្រាមវៀតណាមឆ្នាំ១៩៦៣ សម្តេចព្រះនរោត្តម សីហនុ បានបដិសេដជំនួយអាម៉េរិកឯជំនួយរបស់ចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ

**ខ.នយោបាយ**

- ព្រះអង្គប្រកាន់នូវនយោបាយអព្យាក្រឹតលំអៀងទៅរកកុម្មុយនីស្ត
- នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួន ជាពិសេសទ្រង់ស៊ីសុវត្ថិសិរិមតៈបានចាប់ផ្តើមធ្វើផែនការក្បត់សម្តេចព្រះនរោត្តម សីហនុ
- នៅថ្ងៃទី២៣ខែតុលាឆ្នាំ១៩៦៩ព្រះអង្គម្ចាស់សិរិមតៈបានកាន់តំណែងជំនួសលោកលន់ នល់

**គ.សង្គមកម្ពុជា និងវត្តមានវៀតណាមខាងជើង**

- នៅដើមឆ្នាំ១៩៧០ កងកម្លាំងខ្មែរក្រហម បានបង្កអសន្តិសុខ និងកាន់កាប់ទឹកដីស្មើ១/៥ លើទឹកដី កម្ពុជាទាំងមូល
- ការបែកបាក់សាមគ្គីជាតិនៅឆ្នាំ១៩៦៧
- សង្គមកម្ពុជាចែកមនុស្សជា៣ក្រុមផ្សេងៗគ្នាគឺ ក្រុមឆ្វេងនិយម ស្តាំនិយម និងក្រុមនិយមកណ្តាល។
- អំពើពុករលួយ បក្សពួកនិយម

- ក្រុមអ្នកមានជិះជាន់អ្នកក្រីក្រ
- ថ្ងៃទី៨-៩ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងវៀតណាមខាងជើង និងវៀតកុងដែលបំផុសដោយកងទ័ពនៅខេត្តស្វាយរៀង
- ថ្ងៃទី១១-១៦ ខែមីនា ឆ្នាំ១៩៧០ មានកុបកម្មវាយកម្ទេច បំផ្លាញអគារស្ថានទូតវៀតណាមខាងជើងនិងការិយាល័យរណសិរ្សសេរីកាជាតិវៀតណាមខាងត្បូងនៅក្រុងភ្នំពេញ
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៦.គោលនយោបាយក្រៅប្រទេសនៃគោលនយោបាយអព្យាក្រឹតរបស់កម្ពុជា នាទសវត្សរ៍ឆ្នាំ១៩៦០

នៅដើមទសវត្សរ៍ឆ្នាំ១៩៦០ នយោបាយអព្យាក្រឹតរបស់កម្ពុជាស្ថិតនៅលើផ្លូវរបត់មួយយ៉ាងធំពោលគឺនៅពេលនោះ កម្ពុជាបានងាកទៅរកពួកកុម្មុយនីស្ត ជាជាងធ្វើទំនាក់ទំនងជាមួយពួកលោកសេរីជាពិសេសជាមួយសហរដ្ឋអាម៉េរិក

- **ទំនាក់ទំនងជាមួយប្លុកសេរី**
  - នៅថ្ងៃទី២៥ មិថុនា ១៩៥៨ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សុរាម្រឹត បានបញ្ជូនព្រះសារលិខិតមួយច្បាប់អំពាវនាវឱ្យសហរដ្ឋអាម៉េរិកចាត់វិធានការគ្រប់បែបយ៉ាងក្នុងការទន្ទ្រានចូលទឹកដីខេត្តស្ទឹងត្រែងរបស់កម្ពុជា ដោយខុសច្បាប់ពីសំណាក់កងទ័ពវៀតណាមខាងត្បូង។
  - នៅពេលនោះរដ្ឋាភិបាលអាម៉េរិកបានឆ្លើយតបមកវិញ ថាខ្លួនមិនអាចធ្វើអន្តរាគមន៍ក្នុងរឿងនេះបានទេ ប៉ុន្តែក៏មិនបណ្តោយឱ្យកម្ពុជាយកគ្រឿងសព្វាវុធរបស់អាម៉េរិកទៅប្រើប្រាស់ប្រឆាំងនឹងកងទ័ពវៀតណាមខាងត្បូង ដែលជាសម្ព័ន្ធមិត្តរបស់សហរដ្ឋអាម៉េរិកនោះឡើយ។
  - ការប៉ុនប៉ងទម្លាក់សម្តេចនរោត្តម សីហនុ នៅឆ្នាំ១៩៥៩ មានជាប់ពាក់ព័ន្ធជាមួយ CIA របស់សហរដ្ឋអាម៉េរិក
  - ការមិនទុកចិត្តរបស់សហរដ្ឋអាម៉េរិកចំពោះសង្គមរាស្ត្រនិយម និងភាពមិនអើពើរបស់សហរដ្ឋអាម៉េរិក ចំពោះកម្ពុជា និងការឈ្លានពានរបស់វៀតណាមខាងត្បូងចូលមកទឹកដីកម្ពុជា យ៉ាងនេះហើយដែលនាំឱ្យសម្តេចព្រះនរោត្តម សីហនុ គ្មានជម្រើសអ្វីក្រៅពីចងសម្ព័ន្ធមិត្តជាមួយប្រទេសជាសមាជិកវ៉ាសូវី ប្រទេសមិនចូលបក្សសម្ព័ន្ធនិងប្រទេសកុម្មុយនីស្តឡើយ។
  - នៅត្រឹមឆ្នាំ១៩៦២ ថៃ និងវៀតណាមខាងត្បូងកាន់តែគំរាមកំហែងខ្លាំងមកលើបូរណភាពទឹកដីកម្ពុជា។ នៅខែតុលា ឆ្នាំ១៩៦២ អ្នកតំណាងថៃនៅអង្គការសហប្រជាជាតិ បានទាមទារយកទឹកដី បាត់ដំបង សៀមរាប និងកំពង់ធំ ពីខ្មែរចំណែកយន្តហោះរបស់វៀតណាមខាងត្បូង បានទម្លាក់គ្រាប់បែកទៅលើភូមិខ្មែរជាច្រើននៅតាមជាយដែន។

- នៅឆ្នាំ១៩៦៣ រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេចនរោត្តម សីហនុ បានផ្តាច់ជំនួយយោធាពីសហរដ្ឋអាមេរិក ដែលមានតម្លៃជាប្រាក់ចំនួន១៥ ភាគរយនៃថវិកាជាតិ
- ចាប់ពីកិច្ចប្រជុំកំពូលនៃទីក្រុងបានឌុង ឆ្នាំ១៩៥៥ មក កម្ពុជាបានបត់ឆ្វេងទៅជាមួយពួកកុម្មុយនីស្ត ហើយក៏ចេះតែ ឃ្លាតឆ្ងាយពីលោកសេរីបន្តិចម្តងៗ រហូតឈានទៅដល់ការផ្តាច់ទំនាក់ទំនងការទូតទាំងស្រុងជាមួយសហរដ្ឋអាមេរិកនៅឆ្នាំ ១៩៦៥។
- នៅថ្ងៃទី២ ដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៦៧ មានដំណើរទស្សនៈកិច្ចរបស់លោកជំទាវ Jacqueline Kennedy មកដល់ទីក្រុងភ្នំពេញ ដែលចាប់ពីពេលនោះបរិយាកាសរវាងសហរដ្ឋអាមេរិក និងកម្ពុជាកាន់តែប្រសើរឡើងវិញ។ លទ្ធផលនាំមកនូវការបើកស្ថានទូតជាថ្មីឡើងវិញនាថ្ងៃទី១៦ សីហា ១៩៦៩។
- នៅចុងទសវត្សរ៍ឆ្នាំ១៩៦០ សម្តេចព្រះនរោត្តម សីហនុបានប្តូរគោលនយោបាយពីមុន ទ្រង់បានផ្តើមផ្សាភ្ជាប់សម្ព័ន្ធភាពការទូតជាថ្មីជាមួយសហរដ្ឋអាមេរិក ដោយអនុញ្ញាតឱ្យអាមេរិកទម្លាក់គ្រាប់បែកលើផ្លូវលំហូជីមិញ ហើយបានតែងតាំងលោកសេនាប្រមុខលន់ នល់ ដែលតែងតែប្រឆាំងនឹងលទ្ធិកុម្មុយនីស្តជានាយករដ្ឋមន្ត្រីថ្មី។

**ទំនាក់ទំនងជាមួយប្លុកកុម្មុយនីស្ត**

- នៅក្នុងសន្និសីទទីក្រុងបានឌុង ឆ្នាំ១៩៥៥ សម្តេចនរោត្តម សីហនុ បានជួបនឹងមេដឹកនាំសំខាន់ៗ ដែលពេលនោះពួកគេបានអូសទាញឱ្យកម្ពុជានៅជាប្រទេសអព្យាក្រឹត។ ក្នុងពេលនោះផងដែរសម្តេចក៏បានជួបនឹងមេដឹកនាំចិន ជូ អេនឡាយ។
- នៅឆ្នាំ១៩៥៦ សម្តេចនរោត្តម សីហនុ បានយាងទៅធ្វើទស្សនៈកិច្ចនៅប្រទេសចិន ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមិត្តភាពកម្ពុជា-ចិន។ តាមរយៈកិច្ចព្រមព្រៀងបានផ្តល់ឱកាសឱ្យពួកវៀតកុង បង្កើតទីស្នាក់ការភូមិភាគ របស់គេនៅក្រុងភ្នំពេញ ក្នុងឆ្នាំ១៩៥៧។
- នៅខែកក្កដា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជា បានភ្ជាប់ទំនាក់ទំនងទូតជាមួយប្រទេសចិនកុម្មុយនីស្ត
- ខណៈពេលផ្តាច់ជំនួយពីអាមេរិក ប្រទេសចិន និងវៀតណាមកុម្មុយនីស្ត បានសន្យាថានឹងផ្តល់ជំនួយដើម្បីជួយជ្រោមជ្រែងសេដ្ឋកិច្ចកម្ពុជា ប៉ុន្តែអ្វីៗទាំងនោះគ្រាន់តែជាការសន្យាប៉ុណ្ណោះ ផ្ទុយទៅវិញពួកគេបានជាន់ឈ្លីសេដ្ឋកិច្ចកម្ពុជាឱ្យធ្លាក់ចុះយ៉ាងខ្លាំង ព្រមទាំងបង្កវិបត្តិនយោបាយគាំទ្រខ្មែរក្រហម ឱ្យប្រឆាំងនឹងរដ្ឋាភិបាលសង្គមរាស្ត្រនិយម
- កម្ពុជា បានអនុញ្ញាតឱ្យកងទ័ព វៀតណាមខាងជើង យៀកកុង ប្រើប្រាស់ទឹកដីខ្មែរនៅតំបន់ភូមិភាគខាងកើតប្រទេស និងផ្តល់ស្បៀង គ្រឿងសព្វាវុធយុទ្ធភណ្ឌដល់យៀកកុង យៀកណាមខាងជើងផង។ ចាប់ពីពេលនោះមកកម្ពុជាបានធ្លាក់ខ្លួនយ៉ាងជ្រៅផងដែរទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២។

- កងទ័ពកុម្មុយនីស្ត បានប្រើប្រាស់ទឹកដីកម្ពុជាភាគឦសាន និងខាងកើតដើម្បីចល័តទ័ពមកវាយវៀតណាមខាងត្បូង ហើយប្រើប្រាស់កំពង់ផែក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៤ សម្រាប់ដឹកជញ្ជូនស្បៀង និងសម្ភារៈសឹកទៅផ្គត់ផ្គង់កងទ័ពវៀតណាមខាងជើង

### លទ្ធផល

- នយោបាយអព្យាក្រឹតរបស់កម្ពុជាចុះខ្សោយ ដោយសារតែប្រទេសជាមហាអំណាចនៃប្លុកទាំងពីរមិនទុកកម្ពុជាឱ្យរស់នៅក្នុងមាគ៌ាសន្តិភាព ហើយគេបានធ្វើសកម្មភាពប្រឆាំងនឹងនយោបាយអព្យាក្រឹតដូចជា៖
  - សហរដ្ឋអាម៉េរិកផ្តល់ជំនួយដល់កម្ពុជាពិសេសជំនួយផ្នែកយោធាដែលជំនួយនេះមានទិសដៅ ចិញ្ចឹមពួកស្តាំនិយម គោលបំណងផ្តួលរំលំសម្តេចនរោត្តមសីហនុ
  - ប្រទេសថៃបានគាំទ្រសកម្មភាពខ្មែរសេរី ដែលជាកងទ័ពប្រឆាំងរាជរដ្ឋាភិបាលដោយផ្តល់ដីឱ្យកសាងជុំរុំហាត់ទ័ព កសាងស្ថានីយវិទ្យុផ្សាយសំឡេង ដើម្បីប្រឆាំងនយោបាយសង្គមរាស្ត្រនិយម
  - កងទ័ពវៀតណាមខាងត្បូងបានធ្វើសកម្មភាពឈ្លានពានលើទឹកដីខ្មែរតាមព្រំដែន
  - ការអូសទាញកម្ពុជា ពីសំណាក់ប្រទេសកុម្មុយនីស្តនានា ជាពិសេសប្រទេសចិន
  - កងទ័ពវៀតណាមខាងជើងបានបង្កើតមូលដ្ឋានទ័ពលើទឹកដីខ្មែរនៅតាមព្រំដែន។ ពួកនេះបានបណ្តុះ បណ្តាល កងកម្លាំងខ្មែរក្រហមដើម្បីធ្វើបដិវត្តន៍។ សកម្មភាពរបស់ប្រទេសខាងលើមានទិសដៅប្រឆាំងនឹងនយោបាយអព្យាក្រឹត។

សរុបសេចក្តីមក នយោបាយអព្យាក្រឹតរបស់កម្ពុជានាទសវត្សរ៍ឆ្នាំ១៩៦០ ពុំអាចរក្សាបាននូវជំហអព្យាក្រឹតរបស់ខ្លួនបានទេ ពីព្រោះនៅពេលនោះប្រទេសមហាអំណាចមនោគមវិជ្ជាទាំងពីរ បានរិះរកគ្រប់មធ្យោបាយដើម្បីអូសទាញឱ្យកម្ពុជាចូលរួមនៅក្នុងប្លុករបស់ពួកគេរៀងៗខ្លួន។ នយោបាយអព្យាក្រឹតត្រូវបញ្ចប់ដោយសារកម្លាំងខាងក្នុង គឺការធ្វើរដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដោយលោក លន់ នល់ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ សិរីមតៈដើម្បីទម្លាក់សម្តេច នរោត្តម សីហនុ ពីប្រមុខរដ្ឋ។ ការអូសទាញទាំងនេះបានធ្វើឱ្យកម្ពុជា ធ្លាក់ចូលទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២ ដោយជៀសពុំរួច ហើយទីបំផុតកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍។

### ចំណុចត្រឹមត្រូវផ្សេងទៀត

## វិញ្ញាសាត្រៀមទី៩

**ប្រធាន**

1. តើកម្ពុជាទទួលបានឯករាជ្យពេញបរិបូរណ៍ពីបារាំងនៅថ្ងៃខែឆ្នាំណា?
2. ចូរពណ៌នាពីចលនាតស៊ូដើម្បីរំដោះកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ។
3. តើសន្និសីទក្រុងហ្សឺណែវ មានអត្ថន័យយ៉ាងដូចម្ដេចចំពោះឯករាជ្យភាពកម្ពុជា?
4. តើមានបុព្វហេតុអ្វីខ្លះដែលនាំឱ្យមានការផ្លាស់ប្ដូរមេដឹកនាំនាថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០?
5. តើសកម្មភាពដែលខ្មែរក្រហមបានប្រព្រឹត្តិក្នុងពេលកាន់អំណាច បានផ្ដល់ផលប៉ះពាល់ដូចម្ដេចខ្លះ ចំពោះប្រទេសជាតិ ប្រជាជន និងចំពោះខ្លួនឯង?
6. តើសន្តិភាពបានដើរតួនាទីយ៉ាងដូចម្ដេចខ្លះ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាលើគ្រប់វិស័យ?

## អត្រាកំណែ

១-កម្ពុជាទទួលបានឯករាជ្យពេញបរិបូរណ៍ពីបារាំងនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

២-ពណ៌នាពីចលនាតស៊ូដើម្បីរំដោះប្រទេសកម្ពុជាចេញពីរបបកម្ពុជាប្រជាធិបតេយ្យ៖

- ខែមករា ១៩៧៦ លោក ហ៊ូ នឹម បានចេញមុខប្រឆាំងនឹងប៉ុល ពត
- ដើមខែមីនា ១៩៧៦ ប្រជាជននៅចម្ការហ្លួង សៀមរាប ទាមទារដំឡើងកម្រិតជីវភាព
- ដើមខែមករា ១៩៧៧ ប្រជាជនភូមិភាគឧត្តរ និងបាត់ដំបងប្រឆាំងនឹងប៉ុល ពត
- ខែមីនា-មេសា ១៩៧៧ ប្រជាជនកំពង់ធំ កំពង់ឆ្នាំង មណ្ឌលគិរី និងចម្ការហ្លួងងើបប្រឆាំង
- ថ្ងៃទី២ ធ្នូ ១៩៧៨ មហាសន្និបាតបានសម្រេចបង្កើតជារណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែល ដឹកនាំដោយលោក ហេង សំរិន
- មានជំនួយពីកងទ័ពវៀតណាម និងប្រជាជនកម្ពុជា
- ក្នុងរយៈពេលតែបីសប្ដាហ៍ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពរំដោះប្រជាជន បានរំដោះបានស្ទើរតែទាំងស្រុង
- ថ្ងៃទី៧ មករា ១៩៧៩ប្រជាជនខ្មែរបានរួចផុតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។

៣-សន្និសីទក្រុងហ្សឺណែវដែលមានអត្ថន័យទាក់ទងនឹងឯករាជ្យភាពរបស់កម្ពុជា៖

- ការបញ្ឈប់សកម្មភាពយោធាទាំងស្រុងនៅកម្ពុជាចាប់ពីថ្ងៃទី៧ សីហា ១៩៥៤
- ដកកងទ័ពចេញពីកម្ពុជាទាំងអស់ក្នុងកំឡុងពេល៩០ថ្ងៃ
- រំលាយកម្លាំងខ្មែរឥស្សរៈក្នុងរយៈពេល៣០ថ្ងៃ
- ការធ្វើសេចក្ដីប្រកាសធានាដល់អ្នកធ្លាប់ចូលរួមចលនាតស៊ូធានាសិទ្ធិអាយុជីវិត អនុវត្តសេរីភាព ប្រជាធិបតេយ្យ
- ការធ្វើសេចក្ដីប្រកាសពីការសម្រេចនៃការចូលនយោបាយអព្យាក្រឹត ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ជាតិតែមួយ
- ការរៀបចំឱ្យមានការបោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥

៤-បុព្វហេតុដែលនាំឱ្យមានការផ្លាស់ប្តូរមេដឹកនាំនាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០៖

- **នយោបាយ**
  - នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួន ជាពិសេសទ្រង់ស៊ីសុវត្ថិ សិរិមតៈ បានចាប់ផ្តើមធ្វើផែនការក្បត់សម្តេចនរោត្តម សីហនុ
  - នៅឆ្នាំ១៩៦៩កងខេមរភូមិន្ទរងការវាយប្រហារពីចលនាបះបោររបស់ក្រុមកុម្មុយនីស្ត ហើយប្រជាជនបានប្តឹងពីវត្តមានវៀតណាម
  - លោកលន់ នល់ មានសុទិដ្ឋិនិយមក្នុងការជួយសង្គ្រោះប្រទេសកម្ពុជាឱ្យផុតពីការឈ្លានពានរបស់ប្រទេសជិតខាង។
  - សាឡុត ស បានតាំងបញ្ជាការដ្ឋាននៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ហើយដាក់ឈ្មោះចលនារបស់ខ្លួនថា បក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក.)ដែលមានមូលដ្ឋាននៅភូមិភាគឥសាន និងពាយ័ព្យ។

- **សេដ្ឋកិច្ចមានសភាពដំណើររាំងស្ទះមុន១៨ មីនា ១៩៧០**
  - បាត់ប្រាក់ចំណូលបណ្តាលមកពីការគេចពន្ធ និងការលក់ស្រូវឱ្យពួកយៀកកុង
  - ការគ្រប់គ្រងឧស្សាហកម្មរដ្ឋមិនបានល្អ
  - ការចំណាយខ្វះតុល្យភាព
  - បញ្ហាកសិកម្មជួបនឹងវិបត្តិ ប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ទិន្នផលកសិកម្មទាប។
  - បញ្ហាជំនួយពីបរទេស៖ ដើម្បីគេចចេញពីសង្គ្រាមនៅវៀតណាមនៅឆ្នាំ១៩៦៣ សម្តេចនរោត្តម សីហនុ បានបដិសេធជំនួយយោធាពីអាម៉េរិកដែលមានតម្លៃចំនួន ១៥ភាគរយនៃថវិកាជាតិ ឯជំនួយពីប្រទេសចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ។

- **សង្គម**
  - កើតអំពើពុករលួយ និងបក្សពួកនិយមស្ទើរគ្រប់ស្ថាប័ន
  - នៅដើមឆ្នាំ១៩៧០ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា)ទ័ពរបស់ខ្មែរក្រហម (បានបង្កអសន្តិសុខ និងបានកាន់កាប់ទឹកដីស្មើ១/៥ លើទឹកដីកម្ពុជាទាំងមូល។
  - ប្រជាជនក្រីក្រទទួលរងនូវការជិះជាន់ពីសំណាក់អ្នកមានអំណាច
  - ក្នុងសង្គមកម្ពុជាចែកមនុស្សជា៣ក្រុមដោយមិនដឹងខ្លួន(ក្រុមនិយមកណ្តាល ក្រុមស្តាំនិយម ក្រុមឆ្វេងនិយម)
  - វត្តមានកងទ័ពវៀតកុង និងវៀតណាមខាងជើងនៅកម្ពុជាកើនឡើងពី៤០០០០នាក់ កើនដល់៨០០០០នាក់។

- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៥-របបកម្ពុជាប្រជាធិបតេយ្យ មានផលប៉ះពាល់មកលើ៖

- **ប្រទេសជាតិ**
  - បាត់បង់កិត្តិយសលើឆាកអន្តរជាតិ
  - ត្រូវបានពិភពលោកស្គាល់ថាជាប្រទេសធ្លាប់ជាវាលពិឃាដ
  - បាត់បង់នូវកិត្យានុភាពជាតិ
  - សេដ្ឋកិច្ចជាតិមានការអន់ថយ
  - កាត់ផ្តាច់នូវនិរន្តរភាពជាតិ
  - កម្ពុជាពេលនោះក្លាយទៅជាវាលពិឃាដ

- **ប្រជាជន**
  - បន្សល់ទុកស្ត្រីមេម៉ាយ ក្មេងកំព្រា
  - ប្រជាជនរាប់សែននាក់ រត់ចាកចេញពីប្រទេស
  - គ្រាប់មីនរាប់លានត្រូវបានកប់ក្នុងដី បណ្តាលឱ្យមនុស្សស្លាប់ និងពិការ
  - ប្រជាជនកម្ពុជា បានទទួលរងនូវជំងឺវិបត្តិផ្លូវចិត្ត
  - បញ្ញវន្ត មន្ត្រី មេសាសនា ប្រជាជនស្លូតត្រង់ ត្រូវបានស្លាប់ កាត់បន្ថយសមត្ថភាពក្នុងការស្តារ កសាង អភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
  - អ្នកប្រឆាំងត្រូវបានសម្លាប់
  - សាសនា រូបិយប័ណ្ណ វប្បធម៌ ប្រពៃណីត្រូវបានបំផ្លាញ
  - សិទ្ធិសេរីភាព កម្មសិទ្ធិឯកជន តម្រូវការជាមូលដ្ឋានត្រូវបានដកហូត...។

- **ចំពោះប៉ុល ពត និងមេដឹកនាំកំពូលផ្សេងទៀត**
  - ខូចកេរ្តិ៍ឈ្មោះ
  - ជាប់ឈ្មោះក្នុងប្រវត្តិសាស្ត្រថាជាមេដឹកនាំផ្តាច់ការ សម្លាប់ជាតិសាសន៍ឯង និងមនុស្សជាតិ
  - ប្រជាជនស្អប់ខ្ពើម
  - មានវិប្បដិសារីចំពោះខ្លួនឯង
  - បងប្អូន និងសាច់ញាតិរបស់ខ្លួនអាចរងនូវការរិះគន់

- **មានចំណុចត្រឹមត្រូវផ្សេងទៀត**

៦- សន្តិភាពបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍប្រទេសកម្ពុជាលើគ្រប់វិស័យដូចតទៅ៖

- **វិស័យនយោបាយ**
  - មានការរួបរួមគ្នាដើម្បីអភិវឌ្ឍប្រទេស
  - មានទំនាក់ទំនងល្អជាមួយបរទេសផ្នែកការទូត សេដ្ឋកិច្ច...
  - ធ្វើឱ្យកម្ពុជាបានសុខសន្តិភាព( សន្តិភាវូបនីយកម្ម) និងមានស្ថិរភាពនយោបាយ

- ធ្វើឱ្យកម្ពុជារៀបចំការបោះឆ្នោតដោយខ្លួនឯង ក្នុងការជ្រើសរើសមេដឹកនាំតាមបែបប្រជាធិបតេយ្យ
- សន្តិភាពបាននាំមកនូវ ឯករាជ្យ អធិបតេយ្យភាព និងបូរណភាពទឹកដី ពិតប្រាកដ
- កម្ពុជាអាចជាសមាជិកអង្គការ ស្ថាប័នអន្តរជាតិ(អាស៊ាន,WTO...) និងបានក្លាយជាប្រធានអាស៊ានវិលជុំដោយពុំមានអាក់ខាននៅឆ្នាំ២០០២,២០១២,២០២២។

## វិស័យសេដ្ឋកិច្ច

- ជួយជំរុញវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ឱ្យមានការអភិវឌ្ឍ
- ងាយស្រួលក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់បែបយ៉ាង
- មានកំណើនការវិនិយោគពីឯកជន បង្កើនទុនពីបរទេស
- បង្កើនការងារដល់ប្រជាពលរដ្ឋ ចៀសវាងការធ្វើចំណាកស្រុក និងកាត់បន្ថយភាពក្រីក្រ
- មានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយអាស៊ាន និងមហាអំណាចធំៗលើពិភពលោក
- បានមានកំណើនភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលបង្កើនការងារ និងប្រាក់ចំណូលជូនប្រជាជន
- ការកសាងហេដ្ឋារចនាមាន ផ្លូវជាតិ ផ្លូវដែក ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយបំពាក់ប្រព័ន្ធទឹក ភ្លើង ពីទីក្រុង ដល់ជនបទ

## វិស័យសង្គម

- មានការទប់ស្កាត់សង្គ្រាម និងការខ្វែងគំនិតគ្នាក្នុងសង្គម
- លើកស្ទួយការគោរពសិទ្ធិមនុស្ស សេរីភាពគ្រប់បែបយ៉ាងក្នុងសង្គមប្រជាធិបតេយ្យ
- ទប់ស្កាត់អំពើពុករលួយ
- ធ្វើឱ្យរដ្ឋមានលទ្ធភាពសម្រេចផែនការនានាតាមការកំណត់
- ជួយឱ្យមានសន្តិភាព និងសន្តិសុខក្នុងសង្គម
- ជាមាគ៌ានាំសង្គមមានការអភិវឌ្ឍជាចីរភាព
- ចម្លើយត្រឹមត្រូវផ្សេងៗទៀត។

## វិញ្ញាសាត្រៀមទី១០

### ប្រធាន

1. តើរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តមសីហនុបានប្រព្រឹត្តិទៅនៅថ្ងៃខែឆ្នាំណា?
2. ចូររៀបរាប់ពីគោលការណ៍ទាំង៨ ចំណុចសម្រាប់ការអនុវត្តនៅទូទាំងប្រទេសរបស់ពួកខ្មែរក្រហម។
3. ចូរពន្យល់ពីឥទ្ធិពលនៃសង្គ្រាមវៀតណាមទៅលើការបង្កើតអាស៊ាននៅក្នុងឆ្នាំ១៩៦៧។
4. តើសម្តេចព្រះនរោត្តម សីហនុ មានជំហរយ៉ាងដូចម្តេចខ្លះ បានជាបារាំងព្រមប្រគល់ឯករាជ្យឱ្យខ្មែរ។
5. ចូរពណ៌នាពីគោលនយោបាយនៃការបង្រួបបង្រួមជាតិកម្ពុជា?
6. តើការចូលជាសមាជិកអាស៊ានធ្វើឱ្យកម្ពុជាទទួលបានផលប្រយោជន៍អ្វីខ្លះ? ក្នុងការបង្កើតសហគមន៍ សេដ្ឋកិច្ចអាស៊ាន តើអ្វីខ្លះជាបញ្ហាប្រឈមរបស់កម្ពុជា?

## អត្រាកំណែ

១-រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុបានប្រព្រឹត្តិទៅនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

២-គោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ មាន៨ប្រការៈ

- ជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញទាំងអស់
- លុបបំបាត់ទីផ្សារ
- លុបបំបាត់ការប្រើប្រាស់ និងចរាចរណ៍រូបិយប័ណ្ណ
- ផ្សឹកព្រះសង្ឃឱ្យទៅធ្វើកសិកម្មតាមទិសដៅដែលគេទៅដល់តាមមូលដ្ឋានជនបទ
- ប្រហារជីវិតមេដឹកនាំរបប លន់ នល់
- បង្កើតសហករណ៍កម្រិតខ្ពស់នៅទូទាំងប្រទេស។
- បណ្តេញជនជាតិភាគតិចវៀតណាម ឱ្យចេញទាំងអស់
- បញ្ជូនទ័ពឱ្យទៅតាមព្រំប្រទល់ ជាពិសេសព្រំប្រទល់វៀតណាម។

៣-ឥទ្ធិពលនៃសង្គ្រាមវៀតណាមទៅលើការបង្កើតអាស៊ានឆ្នាំ១៩៦៧

- ក្រោយសន្ធិសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៥៤ អាម៉េរិកបានបង្កើត សេអាតូ(SEATO) ដែលជាហេតុធ្វើឱ្យប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍អស្ថិរភាពផ្នែកនយោបាយ
- សមាជិកស្ថាបនិកបានសម្រេចចិត្តសហការគ្នាបង្កើតសមាគមនេះឡើង ដោយមានគោលដៅរួម ជំរុញឱ្យមានសន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍសង្គម និងវប្បធម៌ ក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។
- ធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍មានអស្ថិរភាព សេដ្ឋកិច្ច សង្គម
- ធ្វើឱ្យតំបន់អាស៊ីអាគ្នេយ៍ជួបនឹងបញ្ហានយោបាយធ្ងន់ធ្ងរដូចជាៈ
    - មានការប្រឈមមុខដាក់គ្នារវាងប្លុកសេរី និងប្លុកកុម្មុយនីស្ត
    - មនោគមវិជ្ជាកុម្មុយនីស្តរាលដាលខ្លាំង

- បញ្ហាសេដ្ឋកិច្ចនៅអាស៊ីអាគ្នេយ៍ពិបាកក្នុងការប្រកួតប្រជែងជាមួយពិភពលោក ដោយសារតែសង្គ្រាមឥណ្ឌូចិនលើកទី២នេះ វាបានជំរុញឱ្យប្រទេសស្ថាបនិកអាស៊ានមើលឃើញពីបុព្វហេតុសេដ្ឋកិច្ច
- ឆ្នាំ១៩៦៧ ប្រទេសដែលជាស្ថាបនិកទាំងប្រាំបានរកវិធីសាស្ត្រដើម្បីទប់ស្កាត់ និងសង្គ្រាមនៅវៀតណាម ជាពិសេសប្រទេសថៃបានសហការជាមួយនឹងសហរដ្ឋអាម៉េរិកដើម្បីទប់ស្កាត់ឥទ្ធិពលកុម្មុយនីស្ត។

៥-ជំហាររបស់សម្តេចព្រះនរោត្តម សីហនុក្នុងការទាមទារឯករាជ្យពីបារាំង៖

**ក.ការទាមទារនៅក្រៅប្រទេស**

- ចាប់ពីដើមខែកុម្ភៈ ដល់ដើមខែមិថុនា ឆ្នាំ១៩៥៣ សម្តេចនរោត្តម សីហនុ បានធ្វើសកម្មភាពទាមទារឯករាជ្យ នៅក្រៅប្រទេសដូចជាយាងទៅបារាំង(៩កុម្ភៈ) យាងចេញពីបារាំងទៅកាណាដា និងសហរដ្ឋអាម៉េរិក(១១មេសា) យាងត្រឡប់ពីជប៉ុន(១៤ឧសភា) យាងទៅប្រទេសថៃ នៅថ្ងៃទី១៣ មិថុនា ១៩៥៣។

**ខ.នៅក្នុងប្រទេស**

- ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៥៣ ក្រោយពេលត្រឡប់មកពីក្រុងបាងកកវិញ ព្រះមហាក្សត្របានគង់នៅតំបន់ស្វយ័តគឺខេត្តសៀមរាប បាត់ដំបង កំពង់ធំ និងកំណត់ថាមិនយាងមកភ្នំពេញទេ បើមិនបានឯករាជ្យបូរិបូរណ៍ជូនជាតិ។
- ព្រះអង្គបានរៀបចំផែនការសីហនុ ជាមួយឯកឧត្តមប៉ែន នុត និងឯកឧត្តមប្រាក់ប្រាព្រឿងនៅថ្ងៃទី២២ មិថុនា១៩៥៣។
- ព្រះរាជសារថ្លែងនៅបាត់ដំបង ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥៣ គឺឱ្យប្រជាពលរដ្ឋប្រុស ស្រី ក្រោកឈរតស៊ូ ដើម្បីទាមទារឯករាជ្យ។
- ព្រះមហាក្សត្រមានបំណងជាបឋម ចង់បម្រើប្រជារាស្ត្រ ដោយស្វែងរកសម្រេចជាប្រយោជន៍ នូវឧត្តមគតិឯករាជ្យនៃមាតុភូមិខ្មែរ។
- **មានចម្លើយត្រឹមត្រូវផ្សេងៗ**

៥-គោលនយោបាយបង្រួបបង្រួមជាតិ ដើម្បីស្វែងរកសន្តិភាពនៅកម្ពុជា ៖

- **គោលនយោបាយ ចរចារកសន្តិភាព នៅកម្ពុជា**
  - សន្តិភាពកើតចេញពីឥស្សរជនបង្រួបបង្រួមជាតិខ្មែរពីររូបគឺសម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តមហ៊ុន សែន
  - ឆ្នាំ១៩៨៤ សម្តេច សីហនុ ទ្រង់មានព្រះរាជបំណងចង់ឱ្យមានការបង្រួបបង្រួមជាតិ
  - ឆ្នាំ១៩៨៥ សភាពការណ៍នយោបាយនៅអាស៊ី អនុគ្រោះដល់ការចរចាសន្តិភាពនៅកម្ពុជា
  - នៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥ ឯកឧត្តមហ៊ុន សែនត្រូវបានជ្រើសរើសជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី(នាយករដ្ឋមន្ត្រី)
  - នៅឆ្នាំ១៩៨៧ ជំនួបកំពូលរវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀត បានធ្វើឱ្យស្ថានការណ៍នយោបាយនៅកម្ពុជាប្រសើរជាងមុន

- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ មានការជួបគ្នាលើកទី១នៅហ្វែអង់តាជឺន័រ ប្រទេសបារាំងរវាងសម្តេចព្រះនរោត្តម សីហនុ និងឯកឧត្តមហ៊ុន សែន
- នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៨៨ ជំនួបលើកទី២ រវាងសម្តេចព្រះនរោត្តមសីហនុ និងឯកឧត្តមហ៊ុន សែនបានឯកភាពគ្នាទៅលើរូបភាពចាត់តាំងពីអនាគតកម្ពុជា...
- នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៩ ជាជំនួបដែលបង្ហាញពីការចាប់យកបញ្ហារបស់ខ្មែរមកទុកក្នុងដៃខ្មែរដើម្បីដោះស្រាយ
- នៅឆ្នាំ១៩៨៩ ការចុះខ្សោយនៃសហភាពសូវៀត
- ចាប់ថ្ងៃទី២១ ដល់២៦ ខែកញ្ញា ឆ្នាំ១៩៨៩ ការដកទ័ពវៀតណាមចេញពីកម្ពុជាជាលើកចុងក្រោយ
- ក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC: Supreme National Council) បានបង្កើតឡើងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០
- សន្និសីទក្រុងតូក្យូ ឆ្នាំ១៩៩០ ជាស្ពានតភ្ជាប់ពីការគាំងដំណើរនាឆ្នាំ១៩៨៩ ទៅកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១
- ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងក្រុងប៉ារីស
- ខែវិច្ឆិកា ឆ្នាំ១៩៩១ ការយាងត្រឡប់មកកម្ពុជាវិញរបស់សម្តេចព្រះនរោត្តម សីហនុ
- ថ្ងៃទី២៣ ដល់២៨ ខែឧសភា ឆ្នាំ១៩៩៣ ការបោះឆ្នោតជាសកលនៅកម្ពុជា
- ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជា

**យុទ្ធសាស្ត្រឌីហ្វីដ(DIFID) និងឈ្នះ-ឈ្នះ**

យុទ្ធសាស្ត្រឌីហ្វីដ(DIFID=D:Divide,I:Isolate, F: Finish, I: Integrete, D: Develop) ដែលមានយុទ្ធសាស្ត្រ៥៖

- បំបែក៖ ធ្វើការបំបែកកម្លាំងរបស់ភាគីខ្មែរក្រហម
- ឯកា៖ ធ្វើឱ្យកម្លាំងរបស់ខ្មែរក្រហម នៅឯកា
- បញ្ចប់៖ បញ្ចប់សកម្មភាព និងអង្គការចាត់តាំងរបស់ខ្មែរក្រហម
- សមាហរណកម្ម៖ ធ្វើសមាហរណកម្មកម្លាំងដែលព្រមចូលរួមជាមួយរដ្ឋាភិបាល
- អភិវឌ្ឍ៖ អភិវឌ្ឍទីតាំងដែលធ្វើសមារណកម្មហើយ។

**គោលនយោបាយឈ្នះ-ឈ្នះ** គឺជាយុទ្ធសាស្ត្រគោលការណ៍ដែលបានកើតឡើងនៃថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ដើម្បីបញ្ចប់សង្គ្រាមនៅកម្ពុជារបស់សម្តេចហ៊ុន សែន ដែលគោលនយោបាយនេះនាំមកដល់កម្ពុជានូវ៖

- សុខសន្តិភាពពេញលេញ
- ជានាសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូប
- ជានាអាជីពនិងមុខរបរ
- ការទទួលស្គាល់លើកម្មសិទ្ធិនៃចលនទ្រព្យ និងអចលនទ្រព្យ
- ប្រទេសជាតិមានការអភិវឌ្ឍ

- **ចម្លើយត្រឹមត្រូវផ្សេងៗទៀត។**

៦-ការចូលជាសមាជិកអាស៊ានបានធ្វើឱ្យកម្ពុជាទទួលបាននូវ៖

**ផលប្រយោជន៍**

- **ផ្នែកនយោបាយ**
  - សម្រេចបាននូវផ្នែកមួយនៃមុំពីរនៃយុទ្ធសាស្ត្រត្រីកោណគឺសមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់
  - កម្ពុជាលែងជាប្រទេសឯកាតទៅទៀត
  - កម្ពុជាអាចឈរស្មើមុខស្មើមាត់ជាមួយប្រទេសដែលជាសមាជិក និងចូលរួមនូវរាល់ការសម្រេចចិត្តនៅក្នុងតំបន់
  - កម្ពុជាបានរក្សានូវសន្តិសុខ សេរីភាព និងអធិបតេយ្យភាព
  - កម្ពុជាអាចចូលរួមដោះស្រាយបញ្ហាផ្សេងៗជាមួយប្រទេសសមាជិកអាស៊ាន
  - កម្ពុជាអាចដោះស្រាយបញ្ហាព្រំដែនដោយសន្តិវិធី។

- **ផ្នែកសេដ្ឋកិច្ច**
  - កម្ពុជាអាចក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ
  - ការធ្វើពាណិជ្ជកម្មមានភាពងាយស្រួលជាងមុន
  - ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្រុង និងក្រៅប្រទេស
  - ទេសចរមានការកើនឡើង
  - ការចូលជាសមាជិកអាស៊ានជាផ្នែកមួយដែលជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំ។
  - កម្ពុជាអាចទទួលបានប្រាក់កម្ចីដ៏ច្រើនពីធនាគារអភិវឌ្ឍអាស៊ី(IDB) និងប្រទេសជាមិត្តទាំង៥ក្នុងអត្រា ការប្រាក់ទាប ហើយមានរយៈពេលយូរ
  - កម្ពុជាទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍខាងវិស័យដូចជាៈកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្មជាដើម។

- **ផ្នែកទំនាក់ទំនង**
  - ជួយជំរុញឱ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវថ្នល់
  - ការលើកលែងទិដ្ឋាការក្នុងប្រទេសសមាជិកអាស៊ាន
  - ការផ្លាស់ប្តូរចំណេះដឹង សង្គមកិច្ច វប្បធម៌ និងប្រពៃណីទំនៀមទម្លាប់ ព្រមទាំងផ្នែកអប់រំវិទ្យាសាស្ត្របច្ចេកទេសពីបណ្តាប្រទេសសមាជិកអាស៊ាន។

- **ផ្នែកសង្គម**
  - កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាព និងសន្តិសុខសង្គមទប់ស្កាត់ ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម

- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

**បញ្ហាប្រឈមចំពោះកម្ពុជាក្នុងការចូលជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន(៣១ ធ្នូ ២០១៥)៖**

- កម្ពុជានាំចូលទំនិញច្រើនជាងនាំចេញ ហើយការនាំចេញនេះទៀតសោត ដែលភាគច្រើនបំផុតជាការនាំចេញផលិតផលក្នុងវិស័យកាត់ដេរ មានទីផ្សារចម្បង នៅអឺរ៉ុប និងសហរដ្ឋអាមេរិកឯណោះ មិនមែននៅក្នុងតំបន់អាស៊ាននោះទេ។
- អភិបាលកិច្ច និងនីតិរដ្ឋ
  - កង្វះតម្លាភាព បញ្ហាពុករលួយ ការអនុវត្តច្បាប់មិនគ្រប់ជ្រុងជ្រោយ
  - កង្វះឯករាជ្យនៃប្រព័ន្ធតុលាការ អាចធ្វើឲ្យអ្នកវិនិយោគមានការរារែកមិនហ៊ានមករកស៊ី នៅក្នុងប្រទេសកម្ពុជា ហើយអាចបង្វែរទៅកាន់ប្រទេសអាស៊ានផ្សេងទៀត ដែលគេមើលឃើញថាមានហានិភ័យទាបជាង។
- កង្វះធនធានមនុស្ស
  - ការខ្វះខាតធនធានមនុស្សនេះ ក៏អាចធ្វើឱ្យរោងចក្រសហគ្រាសបរទេសមានការរារែកមិនចង់មកបោះទីតាំងផលិត នៅក្នុងប្រទេសកម្ពុជាផងដែរ ឬក៏គេមិនមកបោះទីតាំងផលិតដែរ
  - ចំណែកឯខាងការងារជំនាញវិញ កម្ពុជាអាចនឹងត្រូវប្រឈមមុខនឹងលំហូរនៃពលករជំនាញមកពីប្រទេសផ្សេងទៀតក្នុងតំបន់អាស៊ាន ដែលពលករខ្មែរពិបាកនឹងប្រកួតប្រជែងជាមួយ។

## វិញ្ញាសាត្រៀមទី១១

**ប្រធាន**

1. ចូររៀបរាប់ឈ្មោះថ្នាក់ដឹកនាំកំពូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យឱ្យបានចំនួនប្រាំរូប។
2. តើនយោបាយអព្យាក្រឹតនៅក្នុងសម័យសង្គមរាស្ត្រនិយមមានន័យដូចម្ដេច?
3. តើជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹងបញ្ហាអ្វីខ្លះ?
4. តើវិស័យសុខាភិបាលនាសម័យខ្មែរក្រហមមានលក្ខណៈបែបណា? ចូរពន្យល់។
5. ហេតុអ្វីបានជាខ្មែរក្រហមធ្វើបដិវត្ត?
6. ចូរពណ៌នាពីសមិទ្ធផលសម័យសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០)។

## អត្រាកំណែ

១-ឈ្មោះថ្នាក់ដឹកនាំកំពូលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

- ប៉ុល ពត
- នួន ជា
- ខៀវ សំផន
- សុន សេន
- អៀង សារី

២-នយោបាយអព្យាក្រឹតនៅក្នុងសម័យសង្គមរាស្ត្រនិយម

- ជានយោបាយរបស់ប្រជាជាតិទាំងមូលដែលនយោបាយនេះតម្រូវឱ្យប្រកាន់នូវអាកប្បកិរិយាមួយ និងជាដាច់ខាតរវាងបក្សខាងលិច និងបក្សកុម្មុយនីស្ត គឺជាអាកប្បកិរិយាមិត្តភាពមួយជាមួយបក្សទាំងពីរនេះ ដែលតែងតែទទួលជំនួយទាំងអស់ណាដែលមិនធ្វើឱ្យសាបរលាបដល់អធិបតេយ្យភាព និងអព្យាក្រឹតរបស់កម្ពុជា។
- អព្យាក្រឹតរបស់កម្ពុជាដែលបានកសាងមកនេះបានដៅទុកជាច្បាស់ថា ត្រូវរាប់អានគួរសមនឹងប្រទេសជាតិទាំងឡាយឱ្យស្មើគ្នា កុំឱ្យមានធ្ងន់ស្រាលទោះបីប្រទេសនោះកាន់លទ្ធិយ៉ាងណាក៏ដោយអព្យាក្រឹតរបស់កម្ពុជា ធ្វើបដិសណ្ឋារកិច្ចមានសេចក្តីរាប់អានចំពោះមហាប្រទេសស្មើគ្នា មិនថាប្រទេសនោះជាពួកក្រុមខាងកើត ខាងលិច ឬអព្យាក្រឹតទេ។
- អព្យាក្រឹតនេះតម្រូវឱ្យកម្ពុជារក្សាទុកភ្ជាប់នៅតុល្យភាពពេញលក្ខណៈ រវាងប្រជាជាតិទាំងឡាយ ហើយឱ្យកម្ពុជាទប់ទល់តស៊ូមិនព្រមចាញ់ មិនព្រមស្រយុត មិនព្រមរំលែកឱ្យដាច់ខាតចំពោះការគាបសង្កត់ ឬគំរាមរបស់ជាតិណាក៏ដោយ ។
- ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសអព្យាក្រឹត។ ព្រះរាជាណាចក្រកម្ពុជាពុំត្រូវការចងស្ពានមេត្រីខាងផ្លូវសឹកឬខាងផ្លូវគំនិតជាមួយនឹងបរទេសទេ។ ព្រះរាជាណាចក្រកម្ពុជា ពុំបង្កសង្គ្រាមប្រឆាំងនឹងបរទេសណាមួយទេ។

៣-ជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹងបញ្ហាបានជួបប្រទះនូវបញ្ហាជាច្រើន ដូចជា៖

- ធ្វើការងារហួសកម្លាំង
- គ្មានសិទ្ធិសេរីភាព
- ហូបមិនគ្រប់គ្រាន់
- គ្មានជម្រកត្រឹមត្រូវ
- គ្មានសម្លៀកបំពាក់សមរម្យ
- កាប់សម្លាប់គ្មានជំនុំជម្រះ
- រស់ដោយភាពភិតភ័យ
- បាត់បង់ប្រពៃណី ទំនៀមទម្លាប់
- ប្រឈមនឹងជំងឺដោយសារតែការខ្វះថ្នាំសង្កូវ
- យុវជននិងយុវនារីត្រូវបានគេបង្ខំឱ្យរៀបការជាមួយមនុស្សដែលខ្លួនមិនស្រលាញ់
- ប្រជាជនខ្មែរទូទាំងប្រទេសបានត្រូវកេណ្ឌយកទៅធ្វើស្រែ ដូចទាសករ
- ប្រជាជនដែលជា អ្នកខំបង្កបង្កើតផល រកតែអាហារបរិភោគសឹងមិនបាន
- ការរស់នៅហាក់ដូចជារស់នៅក្នុងគុកឥតជញ្ជាំង
- បែកបាក់ ព្រាត់ប្រាសគ្រួសារតាមរយៈការស្លាប់ដោយអត់អាហារ ការសម្លាប់...។
- មានចំណុចត្រឹមត្រូវផ្សេងទៀត

៤-ពណ៌នាពីវិស័យសុខាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

រដ្ឋមន្ត្រីក្រសួងសុខាភិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺលោកជួន ជឿន។ មន្ទីរពេទ្យបានបិទទ្វារ ហើយនៅទីក្រុងភ្នំពេញគេឃើញមានមន្ទីរពេទ្យចំនួន៣ តែប៉ុណ្ណោះដែលបានបើកទ្វារគឺ៖

១. មន្ទីរពេទ្យ១៧ មេសា(អតីតមន្ទីរពេទ្យមិត្តភាពកម្ពុជា-សូវៀត)

២. មន្ទីរពេទ្យព្យាបាលកុមារ(អតីតមន្ទីរពេទ្យកាល់ម៉ែត)

៣. មន្ទីរពេទ្យ៩៨ (អតីតមន្ទីរពេទ្យកេតុមាលា)។

**ក.ស្ថានភាពមន្ទីរពេទ្យ**

- នៅតាមជនបទមានមន្ទីរពេទ្យច្រើនបង្គួរដែរ ដែលមន្ទីរពេទ្យទាំងនោះធ្វើជារោងប្រក់ស្បូវ និងមាន លក្ខណៈតូចចង្អៀត។
- មន្ទីរពេទ្យទាំងនោះហាក់ដូចជាចែកគ្នាដាច់គឺមានមន្ទីរពេទ្យសម្រាប់យោធានិងសម្រាប់ពលករ។
- នៅក្នុងតំបន់គ្រប់គ្រង ដោយខ្មែរក្រហម មន្ទីរពេទ្យ បណ្តោះអាសន្នខ្លះ ដែលបង្កើតឡើង ជាលក្ខណៈចល័ត ពីកន្លែងមួយទៅកន្លែងមួយ និងទំនងជាទទួលបានជំនួយពីពួកកុម្មុយនីស្តវៀតណាមផងនោះ បានដំណើរការទៅល្អបង្គួរ ។

- មន្ទីរពេទ្យបង្អែកទាំងអស់នោះបានព្យាបាល យុទ្ធជនរបួស និងអ្នកជំងឺ ចាប់តាំងពីក្នុងអំឡុងសង្គ្រាមស៊ីវិល និងរហូតមកដល់សម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**ខ.គ្រូពេទ្យ និងការប្រើប្រាស់ថ្នាំ**

ចំនួនគ្រូពេទ្យមិនមានគ្រប់គ្រាន់នោះទេ ហើយគេក៏ឃើញមានពេទ្យជនជាតិចិនផងដែរ។ គ្រូពេទ្យទាំងនោះគឺជា៖

- គ្រូពេទ្យបដិវត្តន៍ ដែលមានជំនាញតិចតួច ដែលអាចត្រឹមតែអានអក្សរបារាំង អក្សររុស្ស៊ីបានបន្តិចបន្តួច
- គ្រូពេទ្យដែលមានជំនាញ បានលាក់ប្រវត្តិរូបដើម្បីគេចពីការសម្លាប់
- ការព្យាបាលដោយប្រើថ្នាំបុរាណ ដែលផលិតពីដើមឈើ ឫសឈើ
- មន្ទីរពេទ្យសម្រាលកូន មានក្រុមយុទ្ធជន និងយុទ្ធនារី ជាអ្នកបម្រើការនៅទីនោះ
- ជំងឺអ្វីក៏ប្រើថ្នាំអាចម៍ទន្សាយ
- ថ្នាំគេចាក់ឱ្យ បេខ្លូ ទឹកក្រហមៗ ដបទឹកក្រូច
- របបអាហារនៅមន្ទីរពេទ្យគឺគ្រាន់បើជាងសហករណ៍បន្តិច

**គ.អ្នកជំងឺ**

- ប្រជាជនកម្ពុជានៅតាមទីជនបទមិនសូវមានសុខុមាលភាព ល្អប្រសើរ ប៉ុន្មានទេ
- ជំងឺរ៉ាំរ៉ៃដូចជា ជំងឺក្រពះ និង ជំងឺគ្រុនចាញ់ បានកើតមានជាញឹកញាប់ ហើយបានយាយីសុខភាពរបស់ពួកគេ
- ដោយសារតែក្នុងរបបកម្ពុជាប្រជាធិបតេយ្យហូបបាយរួមនៅតាមសហករណ៍ជាលក្ខណៈសមូហភាព នោះធ្វើឱ្យប្រជាជនហូបចុកមិនគ្រប់គ្រាន់ និង ខ្វះជីវជាតិ ដែលធ្វើឱ្យប៉ះពាល់ដល់ សុខភាពប្រជាជន កាន់តែធ្ងន់ធ្ងរ នាំឱ្យមានចំនួនអ្នកស្លាប់កើនឡើងរហូត។

៥-បានជាខ្មែរក្រហមធ្វើបដិវត្តន៍ព្រោះ៖

- ការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជា និងការតស៊ូ
- មនោគមវិជ្ជាខ្មែរក្រហម
- បដិវត្តន៍វប្បធម៌ចិន
- ប្រវត្តិដ៏វែងអន្លាយនៃជីវិតក្នុងប្រទេសកម្ពុជានៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី១
- ប៉ុល ពតគិតថាខ្លួនគាត់ជាមនុស្សជាតិនិយមម្នាក់
- ឥទ្ធិពលនៃបដិវត្តន៍វប្បធម៌បារាំង ចំពោះនិស្សិតខ្មែរនៅស្រុកបារាំង
- មេដឹកនាំខ្មែរក្រហមបានមើលឃើញសង្គមពុករលួយ និងការជិះជាន់ពីពួកអ្នកមានអំណាច
- ការភ័យខ្លាចធ្ងន់ធ្ងរទៅលើការឈ្លានពានរបស់ប្រទេសវៀតណាមមកលើប្រទេសកម្ពុជា

- គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ
  - គោលការណ៍កាត់ក្បាលតម្រូវម្ជុក
  - គោលនយោបាយមហាលោតផ្លោះ មហាអស្ចារ្យ
  - នយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ
- បដិវត្តន៍សង្គមនិយម
  - ចំពោះបដិវត្តន៍កសិករពួកខ្មែរក្រហមបានជ្រើសរើសបដិវត្តន៍កសិករដោយកសិករគឺជាវណ្ណៈឈានមុខ
  - ការគ្រប់គ្រងបែបស្វយ័ត ដែលកម្ពុជាចែកជា៦ភូមិភាគ និង៣២តំបន់។
  - នយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ
  - ការគ្រប់គ្រងតាមបែបផ្ដាច់ការវណ្ណៈអធន
  - ការបង្កើតមនុស្សថ្មី ការទិតៀន និងស្វ័យទិតៀន ដោយការអប់រំកុមារដោយផ្ដាច់ពួកគេចេញពីឥទ្ធិពលមាតាបិតា និងក្រុមគ្រួសារ។
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

៦- សមិទ្ធផលសម័យសង្គមរាស្ត្រនិយម

**វិស័យសេដ្ឋកិច្ច**

- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ធ្វើការជ្រើសរើសពូជ ធ្វើនយោបាយទឹក ប្រើប្រាស់ជី ចាក់ថ្នាំបង្ការដល់សត្វពាហនៈដែលជាកម្លាំងអូសទាញ បង្កើតរុក្ខទិវាគ្រប់ខេត្ត-ក្រុង។
- វិស័យនេសាទមានការរីកចម្រើនដែលអាចបម្រើជីវភាពប្រជាជនប្រចាំថ្ងៃ និងនាំចេញទៅលក់នៅបរទេសថែមទៀត។

**វិស័យគមនាគមន៍**

- ពង្រីកកំពង់ផែភ្នំពេញ និងកសាងកំពង់ផែនៅក្រុងព្រះសីហនុ
- កសាងផ្លូវជាតិលេខ៤ប្រវែង២២៦គីឡូម៉ែត្រ
- ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង(បច្ចុប្បន្នអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ) និង កសាងអាកាសយានដ្ឋានអន្តរជាតិសៀមរាប...
- កសាងផ្លូវរថភ្លើងខ្សែទី២ ពីភ្នំពេញ ទៅក្រុងព្រះសីហនុ ប្រវែង២៧០គីឡូម៉ែត្រ និងកសាងស្ពានជ្រោយចង្វារ(ស្ពានមិត្តភាពកម្ពុជា-ជប៉ុន)
- ភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ សាន់ហ្វ្រាន់ស៊ីស្កូ ក្រុងអូសាកា...។

**វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម**

- ក្រុមហ៊ុនធំៗរបស់បារាំង និងសាខាក្រុមហ៊ុនសហរដ្ឋអាម៉េរិកជាច្រើនបានដាក់ទុនវិនិយោគនៅកម្ពុជា

- នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ រាជរដ្ឋាភិបាលបានសម្រេច និងអនុវត្តការកែប្រែប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស ដោយធ្វើការហាមឃាត់ក្រុមហ៊ុនពាណិជ្ជកម្មក្រៅប្រទេស និងធនាគារឯកជនខាងពាណិជ្ជកម្មនៅក្នុងស្រុក។
- រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យក្រុមហ៊ុនបរទេសខ្លះបន្តសកម្មភាពរបស់ខ្លួនដូចជាក្រុមហ៊ុន សែល ក្រុមហ៊ុនអេសូ និងកាល់តិច។
- រដ្ឋបានបង្កើតក្រុមហ៊ុនឈ្មោះក្រុមហ៊ុនអាហារ័ណនីហារ័ណជាតិ ហៅកាត់ថា «សូណិចស៊ីម» ដែលមាន៦០ភាគរយជាទុនរបស់រដ្ឋ និង៤០ភាគរយជាទុនពាណិជ្ជករកម្ពុជា
- នៅឆ្នាំ១៩៦៤ ក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋពីរទៀតត្រូវបានបង្កើតឡើងគឺ ៖ ក្រុមហ៊ុនខ្មែរនៃការទិញផលិតផលកសិកម្ម ហៅកាត់ថា សូ៉ាប៉ា និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល ហៅកាត់ថា សូណាព្រីម។
- ប្រាក់រៀលដែលជារូបិយវត្ថុក្នុងស្រុកត្រូវបានចរាចរណ៍ទូទាំងប្រទេស។ ចំពោះវិស័យធនាគារ គេឃើញមានក្រុមហ៊ុនបរទេសពីរគឺ៖ អង់គ្លេសមានធនាគារ ឆាទែរិច និងហុងកុង សៀងហៃ ជប៉ុន មានធនាគារអេហ្វូតូក្យូ។
- ធនាគារទាំងនេះបានបញ្ចប់បេសកម្មរបស់ខ្លួនក្រោយពីរាជរដ្ឋាភិបាលអនុវត្តការកែប្រែប្រព័ន្ធធនាគារ។ ការផ្តល់ឥណទានត្រូវបានធ្វើដោយធនាគារពាណិជ្ជកម្មរដ្ឋឈ្មោះឥណទានជាតិ។
- រាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា រោងចក្រវាយនភណ្ឌ រោងចក្រក្តារបន្ទះ រោងចក្រកែវ រោងចក្រក្រដាស រោងចក្រស៊ីម៉ងត៍ រោងចក្របាវក្រចៅ រោងចក្រស្ករស រោងចក្រដំឡើងត្រាក់ទ័រ រោងចក្រចម្រាញ់ប្រេងកាត និងរោងចក្រស្រាបៀ។
- មានការកសាងទំនប់វារីអគ្គិសនីនៅស្ទឹងប្រាល គិរីរម្យ និងនៅព្រែកត្នោតក្នុងខេត្តកំពង់ស្ពឺ

## វិស័យវប្បធម៌

- រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់វិស័យសិក្សាធិការដោយបណ្តុះបណ្តាលគ្រូបង្រៀន និងកសាងសាលារៀនពីបឋម ដល់សាកលវិទ្យាល័យព្រមទាំងធ្វើយុទ្ធនាការបំបាត់អនក្ខរភាព។
- បានបញ្ជូននិស្សិតទៅសិក្សានៅបរទេសពិសេសប្រទេសបារាំង ព្រមទាំងកសាងអន្តេវាសិកដ្ឋាននៅទីនោះផងដែរ។
- លើកស្ទួយវិស័យកីឡាឱ្យមានសន្ទុះខ្លាំងក្លា ដោយបណ្តុះបណ្តាលកីឡាគ្រប់ខេត្តក្រុង និងជួលគ្រូមកពីបរទេសមកបង្ហាត់បង្រៀន និងកសាងពហុកីឡាដ្ឋានអូឡាំពិក។
- មានការយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះព្រះពុទ្ធសាសនា ដោយបង្កើតពុទ្ធិកបឋមសិក្សា រហូតដល់ពុទ្ធិកមហាវិទ្យាល័យ។
- រាជរដ្ឋាភិបាលបានចាត់វិធានការថែរក្សាសម្បត្តិវប្បធម៌ បេតិកភណ្ឌជាតិ ព្រមទាំងបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ និងសាលមហោស្រពតាមខេត្ត-ក្រុង។

## វិស័យសង្គមកិច្ច

- កសាងមន្ទីរពេទ្យជាច្រើនដូចជា៖ មន្ទីរពេទ្យកុមារគន្ធបុប្ផា ឱសថាល័យព្រះសុរាម្រឹត មហាវិទ្យាល័យភូមិន្ទវិជ្ជាពេទ្យ មន្ទីរសម្ភពផះង៉ាង៉ាម(មន្ទីរពេទ្យព្រះកេតុមាលា) មន្ទីរពេទ្យព្រះកុសុមៈ(ពេទ្យលោកសង្ឃ)
- ចាត់វិធានការការពារ ដោយចាក់ថ្នាំការពាររោគរាតត្បាត ព្រមទាំងរក្សាអនាម័យតាមលំនៅដ្ឋាន ជីកអណ្តូងទឹក សង់ផ្ទះ ជីកស្រះ។
- ទប់ស្កាត់អំពើពេស្យាចារ និងបង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគោក
- ផ្តល់សិទ្ធិឱ្យស្ត្រីមានសិទ្ធិបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត(៦ មករា ១៩៥៨)។

## វិស័យនយោបាយ

- កម្ពុជាបានទទួលសុខសន្តិភាពក្នុងរយៈពេល១៥ឆ្នាំ
- កម្ពុជាបានក្លាយជាសមាជិកអង្គការសហប្រជាជាតិនាថ្ងៃទី១៤ ធ្នូ ១៩៥៥

## អំពីរឿងអក្ខរកម្ម

- កិច្ចឃោសនាដើម្បីអក្ខរកម្មដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៦៤

## បុរីកសិកម្ម

- បុរីកសិកម្មចាប់ផ្តើមបង្កើតឡើង ជាពិសេសនៅក្នុងស្រុកលាច ខេត្តពោធិ៍សាត់

## អំពីក្រសួងយុត្តិធម៌

មានការចេញសេចក្តីព្រាងច្បាប់ពីរស្តីពីសន្តិសុខតាមថ្នល់ និងជំនួញទិញចូលលក់ចេញ ហើយត្រូវបន្ថែមសេចក្តីព្រាងច្បាប់៦ ទៀតស្តីពី៖

- កិច្ចសន្យាអស់រយៈកាលដ៏យូរ
- វិធានការនិរទេសចេញពីទឹកដី
- ចុះកំណើតជាខ្មែរទាមទារជាតិដែលកើតនៅបរទេស
- កាតព្វកិច្ចខាងទាហានដែលមានសញ្ជាតិ២
- បុព្វសិទ្ធិ(ច្បាប់រដ្ឋប្បវេណី)
- សិទ្ធិស្ត្រីមេម៉ាយត្រឹមត្រូវតាមច្បាប់ ជាប្រពន្ធទី១ គ្មានកូនស្តីពីសង្គមគ្រួសារ តម្រូវទៅតាមបញ្ហាដែលមានចោទឡើងក្នុងសមាជជាតិលើកទី២១។

## អំពីឃោសនាការជាតិ

- មានព្រឹត្តិប័ត្រប្រចាំថ្ងៃចេញផ្សាយជាភាសាបារាំងនិងជាភាសាខ្មែរមានឈ្មោះថា «បររដ្ឋាភិបាលនៃសង្គមរាស្ត្រនិយម»
- មានទស្សនាវដ្តីប្រចាំខែដូចជា កម្ពុជា, សង្គម ជាដើម។
- មានវិទ្យុផ្សាយសម្លេង

## វិញ្ញាសាត្រៀមទី១២

**ប្រធាន**

1. តើអ្នកនយោបាយរូបណាដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកនាឆ្នាំ១៩៩៨?
2. ប្រវត្តិសាស្ត្រគឺជាគ្រូម្នាក់ដ៏ល្អ។តើធ្វើដូចម្តេចដើម្បីកុំឱ្យរបបប្រល័យពូជសាសន៍ឆ្នាំ១៩៧៥-១៩៧៩ កើតឡើងវិញ?
3. ចូររៀបរាប់ពីតួនាទីរបស់រដ្ឋនៅក្នុងដំណើរវិវត្តសកលភាវូបនីយកម្ម។
4. ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់មនុស្ស?
5. មានមតិមួយពោលថា៖ ការបង្កើតសាលាបាលី ការបង្កើតសាលាបារាំងចុងបូព៌ា(EFEO) ការបង្កើតបណ្ណាល័យជាតិ និងការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតនាដើមសតវត្សរ៍ទី២០ បានជួយឱ្យខ្មែររកឃើញ វិញនូវអត្តសញ្ញាណជាតិ។ ចូរពន្យល់មតិនេះ។
6. តើអាស៊ានគេបង្កើតឡើងដើម្បីអ្វី? ចូរធ្វើអត្ថាធិប្បាយពីមូលហេតុដែលជំរុញឱ្យកម្ពុជាចូលជាសមាជិកអាស៊ាន?

## អត្រាកំណែ

១-អ្នកនយោបាយដែលបានបញ្ចប់សង្គ្រាមក្នុងស្រុកក្នុងឆ្នាំ១៩៩៨គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន។**

២-ដើម្បីទប់ស្កាត់កុំឱ្យមានរបបប្រល័យពូជសាសន៍កើតឡើងសារជាថ្មី៖

- ទប់ស្កាត់កុំឱ្យមានអំពើហិង្សា និងការប្រើប្រាស់អាវុធ
- ទប់ស្កាត់សង្គ្រាមនៅលើទឹកដីកម្ពុជា
- ទប់ស្កាត់ការបែកបាក់សាមគ្គី ឬ ជម្លោះផ្ទៃក្នុង និងជាមួយបរទេស
- ទប់ស្កាត់មនោគមវិជ្ជាព្រៃផ្សៃ និងមិនជាប្រយោជន៍ជាតិ
- ទប់ស្កាត់ការទម្លាក់រដ្ឋាភិបាលស្របច្បាប់ដោយប្រដាប់អាវុធ ឬសកម្មភាពខុសច្បាប់
- ទប់ស្កាត់ភាពអយុត្តិធម៌សង្គម
- ទប់ស្កាត់អំពើពុករលួយ
- ទប់ស្កាត់សកម្មភាពជ្រុលនិយម
- ទប់ស្កាត់និទណ្ឌភាព(ការមិនត្រូវបានផ្តន្ទាទោស)
- ទប់ស្កាត់ការបង្កើតតំបន់អប្បគមន៍
- ការពារវប្បធម៌សន្តិភាព
- ការពារសន្តិភាព និងស្ថិរភាពសង្គម
- ការពារលទ្ធិប្រជាធិបតេយ្យ និងគោរពច្បាប់រដ្ឋ
- ដោះស្រាយបញ្ហាដោយសន្តិវិធី
- គោរពសិទ្ធិមនុស្ស ជំនឿ ពិពិធភាពក្នុងសង្គម
- រក្សាភាពយុត្តិធម៌ និងតម្លាភាព
- លើកស្ទួយវិស័យអប់រំ និងអ្នកចេះដឹង

- អប់រំភាពជាពលរដ្ឋដែលមានការយោគយល់គ្នាទៅវិញទៅមក
- បញ្ចូលការអប់រំស្តីពីផលវិបាកនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍ក្នុងកម្មវិធីសិក្សា
- សិក្សាប្រវត្តិសាស្ត្រ និងតាមដានស្ថានភាពក្នុងប្រទេស និងជុំវិញពិភពលោក
- បំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវខ្ពស់
- អភិវឌ្ឍវិស័យសេដ្ឋកិច្ច វិស័យវប្បធម៌ វិស័យអប់រំ វិស័យទំនាក់ទំនង...។
- **មានចំណុចត្រឹមត្រូវផ្សេងៗទៀត**

៣- តួនាទីរបស់រដ្ឋនៅក្នុងដំណើរវិវត្តសកលភាវូបនីយកម្ម

**តួនាទីរដ្ឋក្នុងនយោបាយអន្តរជាតិគឺ ៖**

- ជាឧបករណ៍ផ្តាច់មុខក្នុងការពារបូរណភាពដែនដីខ្លួន
- រដ្ឋជាផ្នែកមួយនៃសហគមន៍អន្តរជាតិ ប៉ុន្តែរដ្ឋនីមួយៗមានព្រំដែនសកម្មភាពរបស់ខ្លួនច្បាស់លាស់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ និងក្នុងការប្រកួតប្រជែងដើម្បីផលប្រយោជន៍ជាតិរៀងៗខ្លួន
- រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរ បញ្ជូនកម្លាំងពលករទៅបំពេញការងារនៅក្រៅប្រទេស និងការពារពួកគេគ្រប់ពេលវេលាស្របទៅតាមច្បាប់
- រកមធ្យោបាយគ្រប់បែបយ៉ាងដើម្បីរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ចសេរីអន្តរជាតិជាមួយសេដ្ឋកិច្ចជាតិ
- កិច្ចសហប្រតិបត្តិការអន្តរជាតិរវាងធនាគារឯកជនក្តី ឬធនាគារជាតិក្តីត្រូវគេទទួលស្គាល់ថាជាកិច្ចព្រមព្រៀងពហុជាតិ ប៉ុន្តែត្រូវតែទទួលស្គាល់នូវតួនាទីរដ្ឋដែលជាអ្នកគ្រប់គ្រងផងដែរ ដែលក្នុងនោះមានការទទួលខុសត្រូវក្នុងការសម្របសម្រួល និងពិនិត្យពីស្ថាប័នហិរញ្ញវត្ថុជាតិដែលបំពេញការងារសម្រាប់រដ្ឋាភិបាលជាដើម។

**រដ្ឋមានតួនាទីចំពោះខ្លួនឯងក្នុងសហគមន៍អន្តរជាតិដូចជា ៖**

- អធិបតេយ្យភាពលើទឹកដីខ្លួនគ្រួតត្រា
- ពិតមែនជារដ្ឋមួយនៃសហគមន៍អន្តរជាតិ ប៉ុន្តែរដ្ឋត្រូវធ្វើការប្រណាំងប្រជែងដើម្បីផលប្រយោជន៍ជាតិ។ ដើម្បីផលប្រយោជន៍សេដ្ឋកិច្ចរដ្ឋ ត្រូវទប់ទល់នឹងអនុភាពសេដ្ឋកិច្ចរបស់ប្រទេសដែលមានសេដ្ឋកិច្ចខ្លាំងជាង ។

**តួនាទីរបស់រដ្ឋក្នុងការអភិវឌ្ឍសេដ្ឋកិច្ច**

- ការពារយន្តការសេដ្ឋកិច្ច៖ ការបង្កើតឡើងនូវមូលដ្ឋានច្បាប់ ។ តួនាទីនេះផ្សារភ្ជាប់ទៅនឹងការការពារ និងសម្របសម្រួលការងាររបស់ស្ថាប័ន និងភ្នាក់ងារសេដ្ឋកិច្ចនានាដោយផ្អែកលើមូលដ្ឋានច្បាប់ ការធានាស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមជាដើម។
- ស្ថិរភាវូបនីយកម្មម៉ាក្រូសេដ្ឋកិច្ច៖ ជំរុញកំណើនសេដ្ឋកិច្ច ការគ្រប់គ្រងអត្រាអតិផរណា ។

៤-មូលហេតុដែលខ្មែរក្រហមសម្លាប់មនុស្ស៖

- មកពីប្រកាន់យកបដិវត្តន៍កុម្មុយនីស្តធ្វើជាមាគ៌ាតស៊ូនោះ តម្រូវឱ្យមានការ «កម្ទេច» ដើម្បី «កសាងជាថ្មី»
- គោលការណ៍ «មហាលោតផ្លោះមហាអស្ចារ្យ» ដើម្បីសម្រេចគោលដៅឱ្យឆាប់រហ័ស
- គំនិតស្នេហាជាតិនិយមជ្រុលងងឹតងងុលដោយតម្រូវឱ្យជឿជាក់តែលើអង្គការមួយ បើពុំនោះទេត្រូវសម្លាប់ចោល
- ការអប់រំបំពាក់កំហឹងវណ្ណៈដល់កម្មាភិបាលខ្មែរក្រហម តាំងពីមុនឆ្នាំ១៩៧៥ ឱ្យប្រឆាំង និងសងសឹកចំពោះវណ្ណៈក្រៅពីកម្មករ កសិករក្រីក្រ ដោយមេដឹកនាំជាន់ខ្ពស់របស់អង្គការ
- នយោបាយវិមជ្ឈការសិទ្ធិអំណាចកាប់សម្លាប់មនុស្សដល់កម្មាភិបាលថ្នាក់ទាបដែលភាគច្រើនជាមនុស្សមានការសិក្សាតិចតួច ឬល្ងង់ខ្លៅ និងបានក្លាយជាអ្នកដឹកនាំតាមមូលដ្ឋាន
- ប៉ុល ពត មានជំងឺសង្ស័យថាមានសត្រូវលាក់មុខនៅជុំវិញខ្លួនកំពុងរៀបផែនការក្បត់សម្លាប់គាត់ ទើបគាត់ចាត់ការសម្លាប់សមមិត្តរបស់ខ្លួនយ៉ាងរង្គាលតាមខ្សែនីមួយៗ
- គោលនយោបាយបោសសម្អាត សម្រិតសម្រាំង ខ្មាំង (purge) ចាប់តាំងពីមន្ត្រីរដ្ឋការ និងយោធាក្នុងរបបចាស់, ប្រជាជន១៧មេសា រហូតដល់កម្មាភិបាលក្នុងជួរបក្សរបស់ខ្លួន ដែលអង្គការចោទថា ជាភ្នាក់ងារខ្មាំងស៊ីរូងផ្ទៃក្នុង មាន CIA, KGB និងភ្នាក់ងារយួន គឺសំដៅលើ៖ អ្នកធ្លាប់រៀនសូត្រនៅស្រុកយួន យួនវៀតកុងលើកឱ្យធ្វើជាប្រធាន ឬមេបញ្ជាការយោធា យួនបណ្តុះបណ្តាលក្នុងតំបន់រំដោះអំឡុងឆ្នាំ១៩៧០-១៩៧៣។ អ្នកទាំងនោះត្រូវមេខ្មែរក្រហមចោទ លាបពណ៌ថា៖ «ក្បាលយួនខ្លួនខ្មែរ»
- ការអនុវត្តនយោបាយប្រល័យពូជសាសន៍ និង៦ក្រិដ្ឋកម្មសង្គ្រាម(ការកាប់សម្លាប់សងសឹកនឹងរបប លន់ នល់ ការស្អប់ខ្ពើមប្រជាជនទីក្រុង)
- ការសម្លាប់ដោយការអត់ឃ្លាន និងជំងឺដម្កាត់ផ្សេងៗ
- នយោបាយវាតទីដណ្តើមទឹកដី
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៥-ការបង្កើតសាលាបាលី ការបង្កើតសាលាបារាំងចុងបូព៌ា(EFEO) ការបង្កើតបណ្ណាល័យជាតិ និងការបង្កើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនាដើមសតវត្សទី២០ បាន ជួយឱ្យខ្មែររកឃើញវិញនូវអត្តសញ្ញាណជាតិដូចតទៅ៖

- **និយមន័យ«អត្តសញ្ញាណជាតិ»** គឺជាគ្រឿងសម្គាល់ជាតិមានដូចជា អក្សរសាស្ត្រ អក្សរសិល្ប៍ ប្រពៃណី ទំនៀមទម្លាប់ បេតិកភណ្ឌ ទង់ជាតិ ស្នាដៃបុព្វបុរស។
- **សាលាបាលី**

  - សាលបាលីត្រូវបានបង្កើតឡើងនៅឆ្នាំ១៩១៤ និងក្លាយជាសាលាបាលីជាន់ខ្ពស់នៅឆ្នាំ១៩២២ និងត្រូវបានប្តូរឈ្មោះទៅជាគ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា ឬពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតនៅឆ្នាំ១៩៥៥
  - ភាសាបាលីជាភាសាក្នុងព្រះពុទ្ធសាសនាដែលជនជាតិខ្មែរគោរពបូជា និងជាមូលដ្ឋាននៃខេមរភាសា ការលើកតម្កើនព្រះពុទ្ធសាសនា ជាពិសេសការអប់រំជាភាសាបាលីជាមធ្យោបាយដ៏ស័ក្តិសិទ្ធក្នុងការថែរក្សាវប្បធម៌ និងអត្តសញ្ញាណជាតិ
  - ក្នុងភាសាខ្មែរមានពាក្យកម្ចីជាច្រើនពីភាសាបាលី
  - ការបង្កើតសាលាបាលីបានកាត់បន្ថយឥទ្ធិពលសៀមមកលើប្រទេសកម្ពុជាដោយសារព្រះសង្ឃមិនចាំបាច់ចាកចេញទៅរៀននៅស្រុកសៀមដែលជាដើមហេតុធ្វើឱ្យទទួលយកវប្បធម៌ និងឥទ្ធិពលសៀមទាំងវិស័យអប់រំក៏ដូចជាសាសនានៅស្រុកខ្មែរ
  - ការការពារ និងផ្សព្វផ្សាយព្រះពុទ្ធសាសនាមានភាពទូលំទូលាយ
  - សាលាបាលីជាគ្រឹះស្ថានបណ្តុះបណ្តាលធនធានមនុស្សដ៏សំខាន់ក្នុងសតវត្សរ៍ទី២០
  - បញ្ញវន្តដែលរៀនចប់ពីសាលាបាលីជាច្រើនរូបបានតែង និពន្ធ វចនានុក្រមខ្មែរ អត្ថបទអក្សរសិល្ប៍ ស្រាវជ្រាវរុករក និងថែរក្សាវប្បធម៌ អរិយធម៌ខ្មែរ...។
  - **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

- **សាលាបារាំងចុងបូព៌ាប្រទេស(EFEO)៖**

  - ប្រមូលផ្តុំអ្នកប្រាជ្ញបារាំងដែលមានជំនាញខុសៗគ្នាជាពិសេសជំនាញបុរាណវិទ្យា និងសិលាចារឹកក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងពីប្រវត្តិសាស្ត្រ អរិយធម៌ វប្បធម៌ និង អក្សរសាស្ត្រខ្មែរជាដើម
  - សាលាបារាំងចុងបូព៌ាប្រទេសបានចាប់ផ្តើមជួសជុល អភិរក្ស និងស្រាវជ្រាវពីប្រាសាទខ្មែរ
  - សាលាបារាំងចុងបូព៌ាប្រទេសបានធ្វើឱ្យអតីតកាលរបស់ខ្មែរ និងព្រលឹងជាតិខ្មែរដែលកប់បាត់ បានរស់ឡើងវិញ និងបង្កើតឡើងនូវស្មារតីស្នេហាជាតិ ជាតិនិយម អត្តសញ្ញាណខ្មែរក្នុងចំណោមប្រជាជន និងបញ្ញវន្តខ្មែរ។
  - មេរៀនប្រវត្តិសាស្ត្រ និងភាពរុងរឿងរបស់ខ្មែរក្នុងសម័យអង្គរធ្វើឱ្យខ្មែរចេះរួបរួមសាមគ្គីគ្នា។
  - **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## បណ្ណាល័យជាតិ

- បង្កើតព្រះរាជបណ្ណាល័យកម្ពុជា(១៩២៥) គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់ក្នុងការលើកកម្ពស់ការរៀន និងការអាននៅកម្ពុជា
- លើកកម្ពស់ការបោះពុម្ពផ្សាយអត្ថបទព្រះពុទ្ធសាសនា
- ប្រមូល រៀបចំ និងអភិរក្សអក្សរសិល្ប៍ ជាភាសាខ្មែរ និងបាលី
- រក្សាទុកនូវគម្ពីរ និងឯកសារទាំងឡាយដែលទាក់ទងនឹងខ្មែរ
- សិស្ស និងគ្រូអាចអាន និងធ្វើការសិក្សាស្រាវជ្រាវ
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## វិទ្យាស្ថានពុទ្ធសាសនាបណ្ឌិត្យ(សម្ពោធនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៣០)

- ត្រួតពិនិត្យ និងរៀបចំការកែសម្រួល ការបកប្រែ និងសរសេរគម្ពីរព្រះត្រៃបិដកជាភាសាបាលី-ខ្មែរ
- បោះពុម្ពផ្សាយព្រះត្រៃបិដក
- បោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវអំពីវប្បធម៌ និងអរិយធម៌ខ្មែរ។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៦-មូលហេតុនៃការបង្កើតអាស៊ាន ៖

- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងការអភិវឌ្ឍវប្បធម៌ក្នុងតំបន់ ដោយឈរលើស្មារតីស្មើភាព និងសមភាគី
- ជំរុញឱ្យមានស្ថិរភាព និងសន្តិសុខក្នុងតំបន់តាមរយៈការគោរពដ៏ខ្ជាប់ខ្ជួននូវយុត្តិធម៌ និងគោលការណ៍ច្បាប់ទាំងឡាយក្នុងទំនាក់ទំនងរវាងប្រទេសក្នុងតំបន់ និងប្រកាន់ខ្ជាប់នូវធម្មនុញ្ញសហប្រជាជាតិ
- ជំរុញកិច្ចសហការ និងជួយគ្នាទៅវិញទៅមកលើការងារជាផលប្រយោជន៍រួមក្នុងវិស័យសេដ្ឋកិច្ច វប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ និងរដ្ឋបាល
- ជួយគ្នាទៅវិញទៅមកតាមរូបភាពផ្តល់សម្ភារបរិក្ខាសម្រាប់បណ្តុះបណ្តាល និងស្រាវជ្រាវក្នុងវិស័យអប់រំ វិជ្ជាជីវៈ បច្ចេកទេស និងរដ្ឋបាល
- សហការគ្នាឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីប្រើប្រាស់លើវិស័យកសិកម្ម និងឧស្សាហកម្មឱ្យបានច្រើនដើម្បីពង្រីកពាណិជ្ជកម្ម រួមមានការសិក្សាអំពីពាណិជ្ជកម្មអន្តរជាតិលើមុខទំនិញប្រើប្រាស់ ការកែលម្អមធ្យោបាយដឹកជញ្ជូន និងគមនាគមន៍ និងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ
- ជំរុញឱ្យមានការសិក្សាពីតំបន់អាស៊ីអាគ្នេយ៍
- រក្សាកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងមានផលប្រយោជន៍ជាមួយអង្គការអន្តរជាតិនានា និងអង្គការក្នុងតំបន់ដែលមានស្រាប់។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## មូលហេតុដែលកម្ពុជាចូលជាសមាជិកអាស៊ាន

- កម្ពុជាលែងមានការព្រួយបារម្ភចំពោះរឿងគំរាមកំហែងផ្នែកសន្តិសុខ និងលែងនៅឯកោទៀតហើយ
- កម្ពុជានឹងមានសន្តិភាព និងស្ថិរភាពក្នុងតំបន់ ព្រមទាំងអាចដោះស្រាយបញ្ហារួមជាមួយអាស៊ាន ជាអាទិភាពបញ្ហាព្រំដែន និងបញ្ហានយោបាយប្រចាំតំបន់ដោយសន្តិវិធី
- មានការផ្លាស់ប្ដូរចំណេះដឹងលើផ្នែកសង្គមកិច្ច វប្បធម៌ ព្រមទាំងទំនៀមទម្លាប់ប្រពៃណី រវាងសមាជិកអាស៊ានទាំងអស់
- ការផ្លាស់ប្ដូរគ្នាផ្នែកធនធានមនុស្ស វិទ្យាសាស្ត្រ និងបច្ចេកទេសថ្មីថែមទៀត
- ការផ្លាស់ប្ដូរគ្នាទៅវិញទៅមករវាងប្រព័ន្ធសិក្សាធិការ
- កម្ពុជានឹងទទួលបាននូវប្រាក់កម្ចីបន្ថែមទៀតពីធនាគារអភិវឌ្ឍន៍អាស៊ី និងបណ្ដាប្រទេសជាមិត្តទាំង៩ ក្នុងអត្រាការប្រាក់ទាប និងរយៈពេលយូរ
- កម្ពុជានឹងលេចមុខមាត់លើឆាកអន្តរជាតិ មានមុខមាត់ស្មើនឹងប្រទេសក្នុងសមាគមអាស៊ាន និងមានសិទ្ធិធ្វើសហប្រតិបត្តិការរួមគ្នាដោយសមភាព។
- កម្ពុជានឹងទទួលបានផលចំណេញយ៉ាងច្រើនខាងផ្នែកកិច្ចការនយោបាយការបរទេស និងកិច្ចការសេដ្ឋកិច្ច
- កម្ពុជានឹងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍខាងវិស័យផ្សេងៗទៀតដូចជាកសិកម្ម និងទេសចរណ៍...
- ក្រោយពីចូលអាស៊ាន កម្ពុជានឹងយល់ដឹង ព្រមទាំងទទួលបាននូវបទពិសោធន៍ពីខ្លឹមសារសំខាន់នៃតំបន់និយម និងសាកលនិយម ព្រមទាំងយល់នូវទំនាក់ទំនងការទូត
- អាស៊ានបានជួយឱ្យកម្ពុជាដើរតួនាទីយ៉ាងសំខាន់ខាងនយោបាយក្នុងតំបន់ និងលើឆាកអន្តរជាតិ
- កម្ពុជាមានឱកាសជាច្រើនទៀតដើម្បីស្រូបយកមកនូវ អត្ថប្រយោជន៍ខាងសេដ្ឋកិច្ចពីអាស៊ាន ក៏ដូចជាពីសមាគមអន្តរជាតិ
- កម្ពុជាអាចបញ្ចូលចរន្ត និងលំនាំនៃការរីកលូតលាស់ខាងសេដ្ឋកិច្ចនៅក្នុងប្រទេសរបស់ខ្លួនទៅនឹងលំនាំ អភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ ពិសេសកម្ពុជាអាចទទួលបាននូវបច្ចេកវិទ្យា និងបទពិសោធន៍ថ្មីៗពីសមាជិកចាស់ទាំងឡាយ តាមរយៈបំលាស់ប្ដូរគ្នាលើបទពិសោធន៍ និងចំណេះដឹង
- កម្ពុជាអាចវាស់បាននូវកម្រិតល្បឿនលូតលាស់របស់សេដ្ឋកិច្ច និងការធ្វើកំណែទម្រង់ផ្សេងៗ ដើម្បីឈានទៅរកទីផ្សារក្នុងតំបន់ និងឆាកអន្តរជាតិនាសតវត្សទី២១នេះ
- សមាហរណកម្មកម្ពុជាទៅក្នុងសមាគមអាស៊ាន បាននាំមកនូវការចូលរួមយ៉ាងសកម្មក្នុងទំនាក់ទំនងរវាងប្រទេសជាសមាជិក ដូចជាការចរាចរទំនិញ សេវាកម្ម ដើមទុន និងពលកម្មដែលកើតចេញពីទំនាក់ទំនងជិតស្និទ្ធ នៃនយោបាយហិរញ្ញវត្ថុ និងសេដ្ឋកិច្ចក្នុងចំណោមសមាជិករបស់ខ្លួន

- អាស៊ាន១០ ជាទីផ្សារដ៏ធំមួយនៅក្នុងតំបន់ ដែលមានប្រជាជនជាង ៥០០លាននាក់ សម្បូរដោយវត្ថុធាតុដើម ធនធានធម្មជាតិ និងផ្ទៃដីដ៏ទូលំទូលាយ ព្រមទាំងជាតំបន់មួយ កំពុងទាក់ទាញខាងទេសចរណ៍ និងបានផ្តល់ឱកាស យ៉ាងច្រើនសន្ធឹកសន្ធាប់សម្រាប់សេដ្ឋកិច្ចជាតិ
- កម្ពុជាទទួលបាននូវអត្ថប្រយោជន៍ពីវិស័យអភិវឌ្ឍន៍ធនធានមនុស្ស ការអប់រំ និងការកាត់បន្ថយភាពក្រីក្រ ពិសេសមន្ត្រីរាជការ ពីក្រសួងជំនាញនានា និងនិស្សិតជាច្រើនបានទទួលអាហារូបករណ៍ទៅបណ្តុះបណ្តាលនៅ ប្រទេសអាស៊ាន និងដៃគូចរចានានា លើផ្នែកភាសា បច្ចេកទេសជំនាញ និងទ្រឹស្តីជាដើម។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

# វិញ្ញាសាត្រៀមទី១៣

## ប្រធាន

1. តើប្រាសាទបាយ័នកសាងឡើងក្នុងរជ្ជកាលស្ដេចអង្គណា?
2. តើជម្លោះនៅមជ្ឈិមបូព៌ាចាប់ផ្ដើមឡើងពីបញ្ហាអ្វីខ្លះ? ហើយរដ្ឋអ៊ីស្រាអែលត្រូវបានបង្កើតឡើងនៅពេលណា?
3. តើមូលហេតុអ្វីបានជាចាំបាច់មានកិច្ចព្រមព្រៀងព្រំដែន? តើការបោះបង្គោលព្រំដែនរវាងកម្ពុជាជាមួយប្រទេសថៃ ឡាវ វៀតណាម នាំឱ្យកម្ពុជាទទួលបានផលប្រយោជន៍អ្វីខ្លះ?
4. ចូរពន្យល់ពីមូលហេតុនៃការដួលរលំនៃប្រទេសអឺរ៉ុបខាងកើត នាចុងទសវត្សរ៍ឆ្នាំ១៩៨០ និង ដើមទសវត្សរ៍ឆ្នាំ១៩៩០ និងការបង្កើតពិភពលោកឯកប៉ូល។
5. ចូរពណ៌នាពីនយោបាយឈ្នះ-ឈ្នះរបស់ សម្ដេចហ៊ុន សែន។
6. ចូរពន្យល់ពីមូលហេតុដែលនាំឱ្យមានរដ្ឋប្រហារ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។

## អត្រាកំណែ

១-ប្រាសាទបាយ័នកសាងឡើងក្នុងរជ្ជកាលព្រះបាទជយវម៌្មទី៧(ជ័យវរ័ន្មទី៧)។

២-ជម្លោះនៅមជ្ឈិមបូព៌ាសំដៅលើភាពតានតឹងផ្នែកនយោបាយ យោជា រវាងប្រទេសអារ៉ាប់ និងអ៊ីស្រាអែល។ ហើយជម្លោះមជ្ឈិមបូព៌ាផ្ដើមឡើងពីៈ

- ការទាមទារដែនដីកំណើតរបស់ពួកជ្វីហ្វ ឬការបង្កើតរដ្ឋអ៊ីស្រាអែល
    - ពួកជ្វីហ្វចង់បានទឹកដីកំណើតរបស់ខ្លួននៅលើទឹកដីប៉ាលេស្ទីនមកវិញ
    - ពួកអារ៉ាប់នៅលើដែនដីប៉ាលេស្ទីនព្រួយបារម្ភខ្លាចបាត់បង់ទឹកដីទៅក្នុងកណ្ដាប់ដៃពួកជ្វីហ្វវិញ។
- ជម្លោះជាតិសាសន៍អារ៉ាប់ និងជ្វីហ្វ
- ជម្លោះសាសនា(Zionism-Moslem)
- បញ្ហាចម្រុះជាតិសាសន៍
- ការជ្រៀតជ្រែកពីមហាអំណាច ឬនយោបាយរបស់មហាអំណាចក្នុងការគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា។

រដ្ឋអ៊ីស្រាអែលត្រូវបានបង្កើតតាមរយៈដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ហើយមេដឹកនាំពួកជ្វីហ្វនៅប៉ាឡេស្ទីន គឺលោក David Ben-Gourion ក៏បានប្រកាសបង្កើតរដ្ឋអ៊ីស្រាអែលជាផ្លូវការ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៤៨។

៣-មូលហេតុក្នុងការមានកិច្ចព្រមព្រៀងព្រំដែន

- ការពារអធិបតេយ្យភាព និងបូរណភាពទឹកដី
- ការពារការឈ្លានពានពីបរទេស
- ជៀសវាងវិវាទជាមួយប្រទេសជិតខាង
- ព្រំដែនដែលមានសន្តិភាព និងការអភិវឌ្ឍ
- ពង្រឹងការគ្រប់គ្រងរដ្ឋបាល
- បង្ហាញពីព្រំដែនជាក់លាក់
- ចង់បានព្រំដែនដែលមានស្ថិរភាព និងស្ថាពរ។

ផលប្រយោជន៍នៃការបោះបង្គោលព្រំដែនរវាងកម្ពុជាជាមួយប្រទេសថៃ ឡាវ វៀតណាមៈ

- សហប្រតិបត្តិការសេដ្ឋកិច្ច សង្គម នយោបាយ និងវប្បធម៌រវាងកម្ពុជា និងប្រទេសជិតខាងមានការរីកចម្រើន
- កម្ពុជាមានព្រំដែនជាក់លាក់ និងជាផ្លូវការដែលមានការទទួលស្គាល់ពីប្រទេសជិតខាង និងសហគមន៍អន្តរជាតិ
- លែងមានការឈ្លានពានទឹកដីកម្ពុជាពីសំណាក់ប្រទេសជិតខាង
- នាំមកនូវសន្តិភាព និងស្ថិរភាពផ្នែកនយោបាយរវាងរដ្ឋ និងរដ្ឋទាំងដែនដីគោក និងលំសមុទ្ទ
- នាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-មូលហេតុនៃការដួលរលំនៃប្រទេសអឺរ៉ុបខាងកើតនាចុងទសវត្សឆ្នាំ១៩៨០ និងដើមទសវត្សឆ្នាំ១៩៩០ និងការបង្កើតពិភពលោកឯកប៉ូលៈ

- កំណែទម្រង់ប៉េរេស្ត្រូយការរបស់សហភាពសូវៀតនាឆ្នាំ១៩៨៩ ដែលជាការបើកចំហពីវិស័យសេដ្ឋកិច្ច និងនយោបាយពីការគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត
- លោកហ្គោបាឆូវ បានសម្រេចចិត្តកាត់បន្ថយអន្តរាគមន៍យោធារបស់សូវៀតនៅបរទេស និងងាកមកស្តារសេដ្ឋកិច្ចក្នុងប្រទេសខ្លួនឯងផ្ទាល់
- ការដកកងទ័ពរបស់សហភាពសូវៀតចេញពីអាហ្វហ្កានីស្ថាននាឆ្នាំ១៩៨៩
- ការបន្ធូរបន្ថយអំណាចកុម្មុយនីស្តនៅអឺរ៉ុបខាងកើត
- លោកហ្គោបាឆូវបានបញ្ជាក់ថាគ្រប់ប្រជាជាតិគួរតែជ្រើសរើសផ្លូវដើរដោយខ្លួនឯង
- លោកហ្គោបាឆូវ បានប្រកាសកាត់បន្ថយទ័ពរបស់សូវៀតដែលកំពុងឈរជើងនៅប្រទេសកុម្មុយនីស្ត និងតំបន់អឺរ៉ុបខាងកើត
- ការងើបបះបោររបស់ប្រជាជននៅអឺរ៉ុបខាងកើត
- ការដួលរលំជញ្ជាំងប៊ែរឡាំង
- ការដួលរលំបានចាប់ផ្តើមជាបន្តបន្ទាប់ ដែលចាប់ផ្តើមដំបូងនៅ ប៉ូឡូញ ហុងគ្រី អាឡឺម៉ង់ខាងកើត យូហ្គោស្លាវីគី ប៊ុលការី និងរ៉ូម៉ានី។
- **មានចម្លើយត្រឹមត្រូវផ្សេងៗទៀត**

៥-ពណ៌នាពីនយោបាយឈ្នះ-ឈ្នះ របស់សម្តេចហ៊ុន សែន៖

- **វិស័យនយោបាយ**
  - សមាហរណកម្មកងទ័ពខ្មែរក្រហមជាមួយកងទ័ពរដ្ឋាភិបាលដើម្បីស្តារប្រទេសឡើងវិញ
  - នៅតាមព្រំដែនមានសុខសុវត្ថិភាព និងការអភិវឌ្ឍ
  - មាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនតាមព្រំដែន
  - មានការបែងចែកកម្មសិទ្ធិឯកជន
  - មានការផ្តល់តួនាទី បុណ្យស័ក្តិ ដល់បងប្អូនខ្មែរក្រហម ដែលធ្លាប់មានពីមុន
- **វិស័យសេដ្ឋកិច្ច**
  - សេដ្ឋកិច្ចជាតិមានការរីកចម្រើនគួរឱ្យកត់សម្គាល់
  - មានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងអន្តរជាតិ
- **វិស័យសង្គម**
  - កម្ពុជាមានសុវត្ថិភាព សន្តិភាពពេញលេញ
  - មានឯកភាពជាតិ និងបង្រួបបង្រួមជាតិ
  - មានការកសាងសមិទ្ធិផលច្រើន
  - មានកំណែទម្រង់វិស័យអប់រំ
- **មានចំណុចត្រឹមត្រូវផ្សេងទៀតៗ**

**នយោបាយនេះនាំមកដល់កម្ពុជានូវ៖**

- សុខសន្តិភាពពេញលេញ
- ធានាសុវត្ថិភាពសម្រាប់មនុស្សគ្រប់រូប
- ធានាអាជីពនិងមុខរបរ
- ការទទួលស្គាល់លើកម្មសិទ្ធិនៃចលនទ្រព្យនិងអចលនទ្រព្យ។

- **មានចំណុចត្រឹមត្រូវផ្សេងទៀតៗ**

៦-មូលហេតុនៃរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុពីតំណែងមាន ៖

- **វិបត្តិនយោបាយ**
  - ឥទ្ធិពលនៃសង្គ្រាមត្រជាក់បាននាំកម្ពុជាឱ្យអនុវត្តនយោបាយអព្យាក្រឹតមិនចំទិសដៅ និងលូកដៃចូលក្នុងសង្គ្រាមនៅវៀតណាម
  - អ្នកនយោបាយខ្មែរបែកបាក់សាមគ្គីជាតិ និងមានការផ្លាស់ប្តូររដ្ឋាភិបាលជាញឹកញាប់

- នៅដើមឆ្នាំ១៩៧០ កងកម្លាំងកុម្មុយនីស្តកម្ពុជា(ទ័ពខ្មែរក្រហម)បានបង្កអសន្តិសុខ និងកាន់កាប់ទឹកដី១/៥ នៃទឹកដីកម្ពុជាទាំងមូល
- រដ្ឋាភិបាលពុំអាចទប់ស្កាត់ការបះបោររបស់ប្រជាជនប្រឆាំងនឹងវត្តមានប្រជាជន និងកងទ័ពវៀតណាម កាន់តែច្រើនឡើងនៅលើទឹកដីកម្ពុជា
- នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សជាន់ខ្ពស់មួយចំនួនជាពិសេសទ្រង់ សិរីមតៈ បានចាប់ផ្តើមធ្វើផែនការក្បត់

## ✚ វិបត្តិសេដ្ឋកិច្ច

- ការធ្វើជាតូបនីយកម្មបានធ្វើឱ្យធនាគារឯកជន ក្រុមហ៊ុនឯកជនត្រូវបិទទ្វារ ប្រជាជនឥតការងារធ្វើ
- រដ្ឋបាត់បង់ប្រាក់ចំណូល ដោយសារទំនិញគេចពន្ធ អំពើពុករលួយ ការបដិសេធជំនួយពីសហរដ្ឋអាម៉េរិក
- ទំនិញឡើងថ្លៃ អតិផរណាក្រដាសប្រាក់
- ការដឹកជញ្ជូន និងពាណិជ្ជកម្មត្រូវរាំងស្ទះ
- ពាណិជ្ជកម្មក្រៅប្រទេសជួបនិងបញ្ហារអាក់រអួលដោយសារការបាត់បង់ជំនាញគ្រប់គ្រងរបស់ សហគ្រាស និងកង្វះខាតបច្ចេកទេសជំនាញ
- បញ្ហាកសិកម្មជួបនឹងវិបត្តិ ប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ទិន្នផលកសិកម្មទាប
- ដើម្បីគេចពីសង្គ្រាមវៀតណាមឆ្នាំ១៩៦៣ សម្តេច នរោត្តមសីហនុ បានបដិសេធជំនួយអាម៉េរិកឯជំនួយរបស់ចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ

## ✚ វិបត្តិសង្គម

- ការបែកបាក់សាមគ្គីជាតិ
- សង្គមជួបនូវអំពើពុករលួយ បក្ខពួកនិយម អនាធិបតេយ្យ អយុត្តិធម៌ ចោរកម្ម
- ប្រជាជនរស់នៅតាមព្រំដែនកម្ពុជា-វៀតណាមរងនូវការទម្លាក់គ្រាប់បែក
- ភាពចលាចល បាតុកម្ម កុប្បកម្មប្រឆាំងនឹងវត្តមានប្រជាជន និងកងទ័ពវៀតណាមកាន់តែច្រើនឡើងលើទឹកដីកម្ពុជា
- នៅដើមឆ្នាំ១៩៧០ កងកម្លាំងខ្មែរក្រហម បានបង្កអសន្តិសុខ និងកាន់កាប់ទឹកដីស្មើ ១/៥ លើទឹកដី កម្ពុជាទាំងមូល
- សង្គមកម្ពុជាចាប់ផ្តើមមានការខ្វែងគំនិតគ្នាចាប់តាំងពីឆ្នាំ១៩៦៧
- សង្គមកម្ពុជាចែកមនុស្សជា៣ក្រុមផ្សេងៗគ្នាគឺ ក្រុមឆ្វេងនិយម ស្តាំនិយម និងក្រុមនិយមកណ្តាល
- កើតឡើងនូវអំពើពុករលួយ បក្សពួកនិយម និងក្រុមអ្នកមានជិះជាន់អ្នកក្រីក្រ

## ✚ ចម្លើយត្រឹមត្រូវផ្សេងទៀត។

# វិញ្ញាសាត្រៀមទី១៤

## ប្រធាន

1. ចូរពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម។
2. ចូរពណ៌នាពីមូលហេតុដែលនាំឱ្យកម្ពុជាទទួលយកអាណាព្យាបាលបារាំង។
3. ចូរពណ៌នាពីតួនាទីរបស់សហគមន៍អាស៊ាននៅអាស៊ីអាគ្នេយ៍។
4. ចូរអធិប្បាយពីរបបសាធារណរដ្ឋខ្មែរ(១៩៧០-១៩៧៥)។
5. ចូរអធិប្បាយដោយសង្ខេបពីប្រទេសកម្ពុជាសម័យហ្វូណន។

## អត្រាកំណែ

១-ពណ៌នាអំពីទិដ្ឋភាពវិជ្ជមាន និងអវិជ្ជមាននៃសកលភាវូបនីយកម្ម

- **ទិដ្ឋភាពវិជ្ជមាន**
  - ធ្វើឱ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ច
  - ការប្រើប្រាស់បច្ចេកវិទ្យាមានការរីកចម្រើន និងប្រើប្រាស់បច្ចេកវិទ្យាទំនើបគ្រប់វិស័យ
  - ធ្វើឱ្យមានការរីកចម្រើនផ្នែកទូរគមនាគមន៍អន្តរជាតិ
  - មានលក្ខណៈល្អប្រសើរផ្នែកសេដ្ឋកិច្ចទីផ្សារសេរី
  - ការទំនាក់ទំនងមានភាពរហ័ស និងកាន់តែជិត
  - បង្កើតកិច្ចសហប្រតិបត្តិការល្អដើម្បីដោះស្រាយរាល់បញ្ហារួមរបស់ពិភពលោក
  - កាន់តែងាយស្រួលក្នុងការបំលាស់ទីរបស់ពលរដ្ឋ
  - ងាយស្រួយក្នុងវិស័យសិក្សាស្រាវជ្រាវ

- **ទិដ្ឋភាពអវិជ្ជមាន**
  - ប្រទេសតូចតាចត្រូវបាត់បង់អធិបតេយ្យភាពរបស់ខ្លួនចំពោះមុខមហាអំណាច
  - មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងពីសំណាក់ប្រទេសមហាអំណាចមកលើប្រទេសទន់ខ្សោយដែលនាំឱ្យមានការផ្លាស់ប្តូរនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គម
  - បង្កឱ្យមានសង្គ្រាមរវាងរដ្ឋ និងរដ្ឋ
  - ធ្វើឱ្យមានការរីកសាយភាយយ៉ាងខ្លាំង នូវបច្ចេកវិជ្ជាទំនើបដែលបង្កឱ្យមានការគំរាមកំហែងដល់ពិភពលោក
  - កំណើនប្រជាជននាំឱ្យមានបញ្ហាចោទដល់ប្រជានជន និងសង្គម
  - ប្រព័ន្ធផ្សាយរណោបក៏អាចជាប្រភពបញ្ហាដែលធ្វើឱ្យរដ្ឋាភិបាលរឹតតែបាត់បង់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មាន។

- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

២-ពណ៌នាពីមូលហេតុដែលនាំឱ្យកម្ពុជាទទួលយកអាណាព្យាបាលបារាំង

**វិស័យនយោបាយ**

- បានជួយសរសេរប្រវត្តិខេត្តឡើងវិញ
- សៀម អណ្ណាម គាបសង្កត់ និងចង់យកកម្ពុជាចែកគ្នា
- ធ្វើឱ្យមានឯកភាពអំណាចរាជបល្ល័ង្ក

**វិស័យសង្គម**

- ធ្វើឱ្យសង្គមកម្ពុជាមានស្ថិរភាព
- មានការរៀបចំរដ្ឋបាលថ្នាក់មូលដ្ឋានតាមលំដាប់ថ្នាក់
- រៀបចំប្រព័ន្ធតុលាការ
- បារាំងបាននាំសង្គមកម្ពុជាឱ្យក្លាយជាទំនើបកម្ម

**វិស័យសេដ្ឋកិច្ច**

- សេដ្ឋកិច្ចកម្ពុជាមានការធ្លាក់ចុះ និងស្ថិតក្រោមការគាបសង្កត់ពីសំណាក់សៀម-អាណ្ណាម
- បារាំងបានអនុវត្តសេដ្ឋកិច្ចទីផ្សារសេរី
- បារាំងបានយកចិត្តទុកដាក់លើវិស័យអប់រំដោយនាំឱ្យមានការអភិវឌ្ឍធនធានមនុស្ស

**វិស័យវប្បធម៌**

- មានការជួសជុលប្រាសាទដែលបាក់បែកឡើងវិញ
- មានការជួយអភិរក្សវប្បធម៌ខ្មែរ
- មានការនាំចូលនូវសិល្បៈទំនើប
- ជួយរក្សាអត្តសញ្ញាណខ្មែរ

៣-តួនាទីរបស់សហគមន៍អាស៊ាន នៅអាស៊ីអាគ្នេយ៍

**វិស័យនយោបាយ**

- រក្សាសន្តិសុខ សន្តិភាព ក្នុងតំបន់និងអន្តរជាតិ
- ចូលរួមដោះស្រាយវិវាទ ឬជម្លោះក្នុងតំបន់ និងអន្តរជាតិ
- ធ្វើឱ្យមានឯកភាពក្នុងការដឹកនាំស្របតាមលទ្ធិប្រជាធិបតេយ្យ

**វិស័យសេដ្ឋកិច្ច**

- ជំរុញការអភិវឌ្ឍវិស័យសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក
- ជំរុញកិច្ចសហប្រតិបត្តិការផ្នែកពាណិជ្ជកម្ម និងអភិវឌ្ឍទីផ្សារដើម្បីប្រកួតប្រជែងនៅប្រទេសជឿនលឿន

- បង្កើនកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ដើម្បីបង្កើនការងារ និងប្រាក់ចំណូលដល់ប្រជាជន

**វិស័យសង្គម**

- ជំរុញកិច្ចសហប្រតិបត្តិការផ្នែកវប្បធម៌ ជំនឿសាសនា និងប្រពៃណី ទំនៀមទម្លាប់
- ផ្លាស់ប្តូរបទពិសោធន៍ផ្នែកអប់រំសិក្សាធិការ ការបណ្តុះបណ្តាលធនធានមនុស្ស បច្ចេកវិជ្ជា និងវិទ្យាសាស្រ្ត
- លើកកម្ពស់សិទ្ធិមនុស្ស និងសមភាពយេនឌ័រក្នុងតំបន់ និងពិភពលោក។

**មានចំណុចត្រឹមត្រូវផ្សេងទៀត**

៤-អធិប្បាយពីរបបសាធារណរដ្ឋខ្មែរ

**ការលេចឡើងនៃរបបសាធារណរដ្ឋខ្មែរ**

ស្ថានភាពប្រទេសកម្ពុជាមុនព្រឹត្តិការណ៍១៨ មីនា ១៩៧០មានបញ្ហាជាច្រើនដូចជា៖

- **បញ្ហាកសិកម្ម** ៖ ជួបវិបត្តិដោយប្រព័ន្ធធារាសាស្រ្តគ្មានប្រសិទ្ធភាព ជាហេតុធ្វើឱ្យទិន្នផលកសិកម្មទាប
- **បញ្ហាឧស្សាហកម្ម**៖ រដ្ឋគ្រប់គ្រងឧស្សាហកម្មមិនបានល្អ ហើយការចំណាយខ្វះតុល្យភាព
- **បញ្ហាពាណិជ្ជកម្ម**៖ សម្តេចនរោត្តម សីហនុ បានធ្វើជាតូបនីយកម្មក្នុងវិស័យនីហរណ៍អាហរណ៍ផ្នែកសេដ្ឋកិច្ច និងបិទទ្វារធនាគារឯកជនខ្មែរទាំងឡាយ។ ការធ្វើជាតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេសបានជំរុញឱ្យមានពាណិជ្ជកម្មលួចលាក់ជាមួយពួកបះបោរកុម្មុយនីស្តនៅវៀតណាម។ ឆ្នាំ១៩៦៧ ផលស្រូវកម្ពុជាមួយភាគបួនត្រូវបានលក់ដោយគេចពន្ធទៅឱ្យកម្លាំងកុម្មុយនីស្ត វៀតណាម ព្រោះពួកគេបានឱ្យតម្លៃខ្ពស់ជាងរដ្ឋ
- **បញ្ហាជំនួយពីបរទេស** ៖ ដើម្បីគេចចេញពីសង្គ្រាមនៅវៀតណាមនៅឆ្នាំ១៩៦៣ សម្តេចនរោត្តម សីហនុ បានបដិសេធជំនួយយោធាពីអាម៉េរិកដែលមានតម្លៃចំនួន១៥ភាគរយនៃថវិកាជាតិ ឯជំនួយពីប្រទេសចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ។
- ក្នុងឆ្នាំ១៩៦៥ សាឡុត ស(ប៉ុល ពត) ទៅវៀតណាមខាងជើងដើម្បីចូលរួមការពិគ្រោះយោបល់
- ក្នុងដំណើរទស្សនកិច្ចនៅប្រទេសចិនឆ្នាំ១៩៦៦ សាឡុត ស បានឃើញបដិវត្តន៍វប្បធម៌ចិន ដែលធ្វើឱ្យគាត់យកគំរូតាម
- ក្រោយពីត្រឡប់មកពីប្រទេសចិនវិញ សាឡុត ស បានតាំងបញ្ជាការដ្ឋាននៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ហើយដាក់ឈ្មោះចលនារបស់ខ្លួនថាបក្សកុម្មុយនីស្តកម្ពុជាដែលមានមូលដ្ឋាននៅភូមិភាគឦសាន និងពាយ័ព្យ។

- នៅដើមឆ្នាំ១៩៧០ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជាបានបង្កអសន្តិសុខ និងបានកាន់កាប់ទឹកដីស្មើ១/៥ លើទឹកដីកម្ពុជាទាំងមូល។ ក្នុងពេលនោះ ពួកនិស្សិត និងគ្រូបង្រៀនជាច្រើននៅទីក្រុងភ្នំពេញពេញចិត្តនឹងមនោគមវិជ្ជាថ្មី ដែលជាលទ្ធផលនៃបដិវត្តន៍វប្បធម៌ចិន។
- នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួនជាពិសេសទ្រង់ស៊ីសុវត្ថិ សិរិមតៈ បានចាប់ផ្ដើមធ្វើផែនការក្បត់សម្ដេចនរោត្តម សីហនុ
- ចំណែកលោកលន់ នល់ ដែលជានាយករដ្ឋមន្ត្រីពុំបានជំទាស់នឹងសម្ដេចនរោត្តម សីហនុ ចំពោះការបដិសេធជំនួយពីសហរដ្ឋអាម៉េរិកនិងចងសម្ព័ន្ធភាពជាមួយកុម្មុយនីស្តក្នុងការដឹកជញ្ជូនអាវុធឆ្លងទឹកដីកម្ពុជាទេ។
- មន្ត្រីរបស់លោក លន់ នល់ ក្លាយជាអ្នកមានស្ដុកស្ដម្ភ ដោយសារការរកស៊ីលក់អាវុធ ថ្នាំពេទ្យ និងផ្គត់ផ្គង់គ្រឿងផ្សេងៗដល់កុម្មុយនីស្តវៀតណាម។
- នៅឆ្នាំ១៩៦៩ កងខេមរភូមិន្ទរងការវាយប្រហារពីចលនាបះបោររបស់ក្រុមកុម្មុយនីស្ត ហើយប្រជាជនបានប្ដឹងពីវត្តមានវៀតណាម។
- លោកលន់ នល់ មានសុទិដ្ឋិនិយមក្នុងការជួយសង្គ្រោះប្រទេសកម្ពុជាឱ្យផុតពីការឈ្លានពានរបស់ប្រទេសជិតខាង។

## រដ្ឋប្រហារ១៨ មីនា ១៩៧០

- ថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៦៩ សម្ដេចនរោត្តម សីហនុ បានផ្ដល់អំណាចឱ្យលោក លន់ នល់ និងទ្រង់ស៊ីសុវត្ថិ សិរិមតៈ ក្នុងការដឹកនាំរាជរដ្ឋាភិបាលដែលមានឈ្មោះថា «រាជរដ្ឋាភិបាលស្រោចស្រង់ជាតិ»
- នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៦៩ ទ្រង់ស៊ីសុវត្ថិ សិរិមតៈ បានកាន់តំណែងជំនួសលោកលន់ នល់។ ក្នុងកំឡុងជាងពីរខែបន្ទាប់មកទៀតអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ និងសហសេវិកបានខិតខំរៀបចំសណ្ដាប់ធ្នាប់សាធារណៈក្នុងប្រទេសដូចជា៖បិទទ្វារកាស៊ីណូ បង្កើតសេវាសាធារណៈ និងឯកជន ធ្វើឯកជនូបនីយកម្មធនាគារ...។
- ថ្ងៃទី៨-៩ ខែមីនា ឆ្នាំ១៩៧០ មានបាតុកម្មប្រឆាំងវៀតណាមខាងជើង និងវៀតកុងដែលបំផុសដោយកងទ័ពនៅខេត្តស្វាយរៀង
- ថ្ងៃទី១១-១៦ខែមីនា ឆ្នាំ១៩៧០ មានកុបកម្មវាយកម្ទេច បំផ្លិចបំផ្លាញអគារស្ថានទូតវៀតណាមខាងជើងនិងការិយាល័យរណសិរ្សសេរីកាជាតិវៀតណាមខាងត្បូងនៅក្រុងភ្នំពេញ។
- ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ព្រឹត្តិការណ៍រដ្ឋប្រហារផ្ទុះឡើងយ៉ាងស្ងៀមស្ងាត់ដឹកនាំដោយលោក លន់ នល់ និងទ្រង់ សិរីមតៈ
- គេក្សោទុកសភាជាឧបករណ៍ពង្រឹងអំណាច ដោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដដែល គេបានកោះប្រជុំសភាទាំងពីរដើម្បីបោះឆ្នោតអនុម័ត។

## សង្គមសម័យសាធារណរដ្ឋខ្មែរ

- ការវាយប្រហាររបស់សហរដ្ឋអាម៉េរិក
- ចាប់ពីឆ្នាំ១៩៦៩ ទឹកដីកម្ពុជាតែងរងការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាម៉េរិក និងកាន់តែធ្ងន់ធ្ងរនៅឆ្នាំ១៩៧៣។
- ការវាយប្រហាររបស់ខ្មែរក្រហម
- ចាប់ពីឆ្នាំ១៩៧០ ពួកខ្មែរក្រហមបានបង្កអសន្តិសុខ និងកាន់កាប់តំបន់ជនបទ និងទីប្រជុំជនតូចៗនៅពាសពេញផ្ទៃប្រទេស។
- ចាប់ពីឆ្នាំ១៩៧២ ពួកខ្មែរក្រហមបានចាប់ផ្តើមផ្តោតទៅលើទីប្រជុំជនធំៗ ដោយបាញ់ផ្លោងចូលភ្នំពេញ និងកម្ទេចស្ពានជ្រោយចង្វារ...។
- ការទម្លាក់គ្រាប់បែក ការបាញ់ផ្លោង ការបាញ់រះ ការបាញ់ផ្តក់រវាងភាគីជម្លោះកម្ពុជាបានធ្វើឱ្យប្រជាជននាំគ្នាភៀសខ្លួនមករស់នៅទីរួមខេត្ត និងទីក្រុងភ្នំពេញ។
- ក្នុងអំឡុងសង្គ្រាម៥ឆ្នាំ ក្រុងភ្នំពេញដូចជាបន្ទាយមួយដែលត្រូវខ្មាំងឡោមព័ទ្ធ និងបានជួបបន្ទូវ ៖
  - កំណើនប្រជាជនហួសប្រមាណ ព្រោះប្រជាជន១/៣ ភៀសខ្លួនមកកាន់ទីក្រុង
  - ប្រជាជនរងទុក្ខលំបាកវេទនា និងកំសត់ទុរគត ព្រោះខ្វះស្បៀង ម្ហូបអាហារឡើងថ្លៃហួសប្រមាណ...
  - អ្នកស្រែចម្ការដែលឃ្លាតពីភូមិស្រុកបាត់បង់មុខរបរ គ្មានការងារធ្វើព្រាត់ប្រាសគ្រួសារ...
  - សង្គ្រាមបានបន្សល់នូវស្ត្រីមេម៉ាយ ក្មេងកំព្រា អ្នកមានជំងឺ អ្នករបួស ជនពិការជាច្រើនសែននាក់
  - ក្រុងភ្នំពេញដែលធ្លាប់តែធើតឆាយ និងជាគជ់នៅអាស៊ីអាគ្នេយ៍បានក្លាយជាទីប្រជុំជនដែលមានប្រជាជនជាងពីរលាននាក់រស់នៅយ៉ាងលំបាកតោកយ៉ាកបំផុត។

## ស្ថានភាពសេដ្ឋកិច្ចសម័យសាធារណរដ្ឋខ្មែរ

- ជនភៀសខ្លួនគ្មានការងារធ្វើ និងជួបប្រទះនូវកង្វះស្បៀងអាហារប្រចាំថ្ងៃ
- អតិផរណាប្រាក់រៀលចេះតែបន្ត
- តម្លៃទំនិញចេះតែឡើងថ្លៃហួសកម្រិត។
- ដើម្បីផ្គត់ផ្គង់ទីក្រុងភ្នំពេញ រដ្ឋាភិបាលសាធារណរដ្ឋខ្មែរពឹងផ្អែកលើស្បៀងមួយចំនួនដែលរដ្ឋាភិបាលអាម៉េរិកផ្តល់ឱ្យដោយដឹកតាមកងនាវាតាមដងទន្លេមេគង្គ។
- នៅខែមករា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានកាត់ផ្តាច់ស្បៀងដែលឡើងតាមដងទន្លេដូច្នេះគឺនៅសល់តែផ្លូវអាកាសប៉ុណ្ណោះ។

### សង្គ្រាមឆ្នាំ១៩៧០-១៩៧៥

ប្រទេសជួបសង្គ្រាម និងពោរពេញដោយអំពើហិង្សានិងទុក្ខក្រៀមក្រំ ព្រមទាំងជួបស្ថានភាពជាច្រើនទៀតដូចជា ៖

- សេដ្ឋកិច្ចជាតិត្រូវរាំងស្ទះដោយសង្គ្រាម
- ទីក្រុង និងទីប្រជុំជនមួយចំនួនធំត្រូវកាត់ផ្ដាច់ពីគ្នាដោយកម្លាំងខ្មែរក្រហម
- រដ្ឋាភិបាលលន់ នល់គ្រប់គ្រងបានតែទីក្រុង និងទីប្រជុំជនមួយចំនួន
- ដោយស្ថានភាពជំងឺ(ស្លាប់មួយចំហៀងខ្លួននៅឆ្នាំ១៩៧១) លោក លន់ នល់ មិនអាចគ្រប់គ្រងនយោបាយដូចមុនឡើយ។
- ឥស្សរជននយោបាយច្រើនរូបនៅភ្នំពេញបង្កើតបក្សពួក និងប្រមូលទ្រព្យសម្បត្តិ ភ្លេចប្រយោជន៍ជាតិ ក្នុងនោះក៏មានលោកលន់ ណុន (ប្អូនប្រុស លន់ នល់) ដែរ
- នាយទាហានខ្លះលក់យុទ្ធោបករណ៍ឱ្យពួកខ្មែរក្រហម។
- នៅដើមឆ្នាំ១៩៧៣ ពួកខ្មែរក្រហមបានពិសោធធ្វើកម្មវិធីសហករណ៍នីយកម្ម និងអនុវត្តដោយបង្ខំក្នុងតំបន់មួយចំនួនដែលពួកគេគ្រប់គ្រង ស្របពេលដែលសហរដ្ឋអាម៉េរិកទម្លាក់គ្រាប់បែក។

### ការដួលរលំរបបសាធារណរដ្ឋខ្មែរ

- ប្រជាជនតំបន់រំដោះនិងក្រុងភ្នំពេញនឿយណាយនឹងរបបសាធារណរដ្ឋខ្មែរ ប្រកបដោយអំពើពុករលួយ និងពោរពេញដោយភាពអាប់អួរ
- ប្រជាជនភៀសសឹកមកកាន់ទីក្រុងភ្នំពេញដែលកើនប្រមាណពីរលាននាក់រស់នៅដោយបាត់បង់ការងារ ខ្វះស្បៀងអាហារ...
- ទំនិញឡើងថ្លៃ
- ការដឹកជញ្ជូនស្បៀង និងគ្រាប់រំសេវរបស់សហរដ្ឋអាម៉េរិកមកឧបត្ថម្ភប្រជាជនក្រុងភ្នំពេញ និងរបបសាធារណរដ្ឋខ្មែរ ត្រូវខ្មែរក្រហមកាត់ផ្ដាច់ទាំងស្រុង
- នៅដើមខែមីនា ឆ្នាំ១៩៧៥ លោកលន់ នល់ បានភៀសខ្លួនតាមយន្តហោះចេញពីកម្ពុជា និងទៅរស់នៅសហរដ្ឋអាម៉េរិក
- ពួកខ្មែរក្រហមបានធ្វើការរឹតបន្តឹងការឡោមព័ទ្ធទីក្រុងភ្នំពេញ ពិសេសការនាំស្បៀងចូល
- ការចរចារវាងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ និងរណសិរ្សរួបរួមជាតិខ្មែរដឹកនាំដោយសម្ដេចនរោត្ដម សីហនុពុំទទួលបានលទ្ធផលអ្វីសោះ។
- ក្នុងដំណាក់កាលចុងក្រោយ សាឡុត ស បានសម្រេចចិត្តដណ្ដើមយកក្រុងភ្នំពេញដោយមិនចាំបាច់រង់ចាំការយល់ព្រមពីសម្ព័ន្ធមិត្តវៀតណាម ប្រកបដោយជោគជ័យថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

### ការខូចខាតដោយសារសង្គ្រាម និងផលវិបាក

សង្គ្រាមឆាបឆេះអស់រយៈពេល៥ឆ្នាំ(១៩៧០-១៩៧៥) ដែលបង្កនូវការខូចខាត និងផលវិបាកដូចតទៅ ៖

- សង្គ្រាមបានសម្លាប់ប្រជាជនកម្ពុជាជាងមួយលាននាក់
- ប្រជាជនភៀសខ្លួនពីជនបទចូលទីក្រុង រស់ដោយខ្វះស្បៀង ជួបភាពអនាធិបតេយ្យ អំពើហិង្សា ចោរកម្ម...
- អំពើសូកប៉ាន់រីកដុះដាលដល់វិស័យសិក្សាធិការ
- បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម...
- ដីស្រែចម្ការត្រូវបោះបង់ចោល ព្រមទាំងក្លាយទៅជាចម្ការមីន និងរណ្ដៅគ្រាប់ B៥២
- រោងចក្រឧស្សាហកម្ម៧៥ភាគរយ ត្រូវបំផ្លិចបំផ្លាញ
- ចម្ការកៅស៊ូត្រូវបាត់បង់
- ផ្លូវថ្នល់ និងស្ពានពី៧០ភាគរយ ទៅ៨០ភាគរយត្រូវអន្តរាយ។
- អស្ថិរភាពនយោបាយដោយសង្គ្រាមស៊ីវិល បានបង្កវិនាសកម្មលើគ្រប់វិស័យដែលជាឱកាសឱ្យខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥។

ដូចនេះសង្គ្រាមបានបង្កមហន្តរាយ និងបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ គ្រឹះសេដ្ឋកិច្ច សង្គម និងនាំកម្ពុជាទៅរករបបប្រល័យពូជសាសន៍។

### មានចម្លើយត្រឹមត្រូវផ្សេងទៀត

៥-អធិប្បាយសង្ខេបពីប្រទេសកម្ពុជាសម័យហ្វូណាន

អាណាចក្រហ្វូណានជារដ្ឋខ្មែរដំបូងដែលត្រូវបានប្រវត្តិវិទូកំណត់ថា កើតឡើងពីសតវត្សរ៍ទី១ ដល់ពាក់កណ្ដាលសតវត្សរ៍ទី៦នៃគ្រិស្តករាជ។ ពាក្យហ្វូណាន ត្រូវបានគេប្រើប្រាស់នៅក្នុងកំណត់ហេតុរបស់បេសកទូតចិនដែលមកដល់ស្រុកខ្មែរកាលពីសតវត្សរ៍ទី៣នៃគ្រិស្តសករាជ។

អាណាចក្រហ្វូណានមានវិសាលភាពយ៉ាងធំទូលាយនិងជាមហាអំណាចដ៏ខ្លាំងពូកែនៅតំបន់អាស៊ីអាគ្នេយ៍។

### អត្ថន័យនៃពាក្យ«ហ្វូណាន»

- ហ្វូណាន ជាឈ្មោះដែលចិនហៅនាពេលនោះ ដែលមានន័យថា«អ្នកមាននៅភាគខាងត្បូង»។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

### វិសាលភាពទឹកដី និងរាជធានី

- រាជទូតចិនបានកត់ត្រាស្ដីពីទីតាំងរបស់ហ្វូណានថា«ហ្វូណានមានចម្ងាយ៣០០០លី (១លី ស្មើនឹង០,៥៧៦គ.ម) ខាងលិចលីនយី(ចម្ប៉ា) ហើយព្រំប្រទល់ភាគខាងត្បូងលីនយីជាប់នឹងហ្វូណាន។ ហ្វូណានលាតសន្ធឹងតាមឈូងសមុទ្រដ៏ធំមួយដែលមានទទឹង៣០០០លី ពីកើតទៅលិច។ ហ្វូណានមានទន្លេធំមួយហូរពីបស្ចិម ឬ

ភាគពាយព្យចាក់ទៅសមុទ្ទ។ នៅខាងលិចហ្វូណានមានតំបន់ធំមួយទៀតហៅថា ទុនស៊ុន(មន)»។

- រាជធានីរបស់ហ្វូណាន មានឈ្មោះថា វ្យាធបុរៈ (បច្ចុប្បន្នគឺនៅស្រុកអង្គរបុរី ខេត្តតាកែវ)

## នយោបាយ

- ហ្វូណាន មានមេដឹកនាំដំបូងជាស្ត្រី គឺព្រះនាងលីវយី ក្រោយមកគ្រប់គ្រងដោយបុរសក្នុងរបបបិតាធិបតេយ្យ វិញ ដែលមានព្រះបាទហ៊ុន ទៀន ជាក្សត្រដំបូងបន្ទាប់ពីព្រះនាងលីវយី។ រាជាចុងក្រោយនៃសម័យហ្វូណាន គឺព្រះបាទរុទ្រវម៌្ម
- ព្រះរាជាល្បីល្បាញនាសម័យហ្វូណាន មានដូចជាព្រះបាទហ៊ុនទៀន ព្រះបាទហ្វាន់ចេម៉ាន់(ស្រីមារៈ) ព្រះបាទកៅណ្ឌិន្យជ័យវម៌្ម...
- ហ្វូណាន ទទួលយកឥទ្ធិពលការគ្រប់គ្រងរដ្ឋតាមបែបឥណ្ឌា
- ព្រះរាជាមានសិទ្ធិអំណាចគ្រប់បែបយ៉ាង ដូចជា មេសាសនា មេទ័ព អ្នកគ្រប់គ្រង និងជាតុលាការ
- ព្រះរាជាសម័យហ្វូណានអនុវត្តនយោបាយពង្រីកអាណាចក្រ ដោយធ្វើសញ្ជ័យលើរដ្ឋតូចៗ យករដ្ឋតូចៗធ្វើជាចំណុះ
- សាមន្តរដ្ឋទាំងអស់ត្រូវស្បថថា ស្មោះត្រង់នឹងមហារាជ ហើយនាំសួយសារអាករថ្វាយព្រះអង្គរាល់ឆ្នាំ
- អាណាចក្រហ្វូណាន ចងសម្ព័ន្ធមិត្តជាមួយរដ្ឋធំៗ ដូចជាចិន និងឥណ្ឌាជាដើម ដោយនៅក្នុងសតវត្សរ៍ទី៣ មានគណៈបេសកទូតចិន និងរាជទូតឥណ្ឌាបានមកដល់ហ្វូណាន
- រាជធានីហ្វូណាន ជាមណ្ឌលអំណាចដែលមានរាជាធិរាជគង់នៅ និងមានការរីកចម្រើនជាងរដ្ឋចំណុះនានាទាំងផ្នែកសេដ្ឋកិច្ច នយោបាយ វប្បធម៌ និងសាសនា។

## សេដ្ឋកិច្ច

- អាណាចក្រហ្វូណានមានសេដ្ឋកិច្ចរីកចម្រើនខ្លាំង ជាមហាអំណាចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- អាណាចក្រនេះ សម្បូរទៅដោយរ៉ែគ្រប់ប្រភេទ សម្បូរដោយ សត្វបក្សី សត្វទឹក ព្រមទាំងមានទីតាំងភូមិសាស្ត្រអំណោយផលគ្រប់យ៉ាង
- ហ្វូណានមានការរីកចម្រើនដោយសារ ពាណិជ្ជកម្មតាមផ្លូវសមុទ្រដោយមានកំពង់ផែអន្តរជាតិអូរកែវ(បច្ចុប្បន្នស្ថិតនៅកម្ពុជាក្រោម) ហើយអូរកែវ អាចជាកន្លែងសំចតនិងផ្ទុកទំនិញរវាងឥណ្ឌា និងចិន។ នៅស្ថានីយ៍អូរកែវ គេបានរកឃើញវត្ថុសិល្បៈជាច្រើន ដែលនាំចូលពីចិន ឥណ្ឌា សិរីលង្កា ព្រមទាំងមានកាក់របស់រ៉ូម៉ាំង ដែលវត្ថុទាំងនោះគឺផលិតឡើង នាសតវត្សរ៍ទី២ និងទី៣។

- កសិកម្ម មានប្រព័ន្ធធារាសាស្រ្ត និងការអភិវឌ្ឍកសិកម្មនៅតំបន់អង្គរបុរី ៖ ប្រជាជនរស់នៅប្រមូលផ្តុំជាពិសេសតាមដងទន្លេមេគង្គ មាត់បឹង ដែលផ្អែកលើការនេសាទ និងផលិតកម្មស្រូវ។ ប្រឡាយទឹកខ្វាត់ខ្វែងជុំវិញរាជធានី និងមានជីកស្រះ និងអាងទឹកសម្រាប់កសិកម្ម អ្នកស្រុកចូលចិត្តធ្វើកសិកម្ម គេសាបព្រោះ១ឆ្នាំដើម្បីប្រមូលផល៣ឆ្នាំ
- ក្នុងវិស័យសិប្បកម្ម ខ្មែរសម័យនោះមានជំនាញជាងទង យ៉ាងស្ទាត់ជំនាញ ខ្មែរប៉ិនប្រសប់ធ្វើចិញ្ចៀន កងដៃ ក្រវិល អំពីមាស ប្រាក់ សំណ ខ្មែរប្រសប់សូនរូប ត្បាញសូត្រចរបាប់ និងស្លកែវ។

## សង្គម

- ប្រជាជនហ្វូណាន រស់នៅប្រមូលផ្តុំគ្នាជាភូមិ មានផ្ទះពី៥០ ទៅ៦០ខ្នង សង់ផុតពីដី នៅមុខភូមិមានស្រះទឹកមួយប្រើរួមគ្នា
- អ្នកស្រុកហ្វូណាន មានសម្បុរខ្មៅស្រអែម កម្ពស់មធ្យម១.៦២ ម៉ែត្រ សក់រួញអង្គាដី ពាក់ក្រវិលទាំងប្រុសទាំងស្រី
- អ្នកក្រស្លៀកចងក្បិន លែងខ្លួនទទេ(ប្រុស) បើស្រីស្លៀកចោមពុង ពួកគេដើរជើងទទេ ក្នុងផ្ទះគ្មានសម្ភារតុបតែងឡើយ
- ប្រជាជនចេះជីកព្រែក និងរៀបចំប្រព័ន្ធធារាសាស្រ្តដើម្បីធ្វើកសិកម្ម
- ប្រជារាស្រ្តមានកាតព្វកិច្ចត្រូវបង់ពន្ធដាក់រាជឃ្លាំង។

## វប្បធម៌ សាសនា

- ហ្វូណានសំបូរទៅដោយអ្នកប្រាជ្ញ និងអ្នកចេះដឹងផ្សេងៗ។ ប្រជាជនចេះប្រមូលសៀវភៅ និងឯកសារសិក្សាដែលមានកម្រិតខ្ពស់។
- ខ្មែរអាចផលិតសម្ភារៈដីដុតដែលមានទ្រង់ទ្រាយល្អស្អាត រលោង លម្អដោយក្បាច់សាមញ្ញៗ និងលាបពណ៌ក្រហមផ្ទិនតិចតួច។
- ជាងចំណានៗចេះធ្វើគ្រឿងអលង្ការពីមាស និងវត្ថុមានតម្លៃសម្រាប់ស្តេចនិងមន្រ្តីធំៗ
- ជាងចម្លាក់អាចឆ្លាក់បដិមាថ្ម បានយ៉ាងល្អប្រណីត
- ចំពោះអាពាហ៍ពិពាហ៍ អ្នកស្រុកហ្វូណាន បើកសិទ្ធិឱ្យកូនប្រុស ស្រីរើសគូស្រករដោយខ្លួនឯង
- ពិធីរំលាយសព មានបួនបែបគឺ កប់ ដុត ចោលក្នុងព្រៃ និងក្នុងទឹក
- ហ្វូណានទទួលយកសាសនាធំៗ២ ពីប្រទេសឥណ្ឌា គឺព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ហើយអ្នកស្រុក ក៏នៅរក្សាផងដែរនូវជំនឿដើមរបស់ខ្លួនគឺការគោរពដូនតាបុព្វបុរស និងអារុក្ខអារក្សអ្នកតា(ជីវចលនិយម)។
- អាណាចក្រហ្វូណាន មានសុខដុមនីយកម្ម ខាងសាសនា និងជំនឿ ដែលនាំឱ្យមានសន្តិភាព

- ស្ថាបត្យកម្ម សាសនា នៅប្រទេសកម្ពុជាដំបូងគេគឺប្រាសាទអាស្រមមហាឬស្សី កសាងនៅចង្កេះភ្នំដា (អង្គរបុរី) មានកាលបរិច្ឆេទចន្លោះសតវត្សរ៍ទី៥ និងទី៦ ដែលប្រាសាទនេះគឺយកលំនាំ តាមស្ថាបត្យកម្មនៅតំបន់ភាគខាងត្បូងប្រទេសឥណ្ឌា។ ប្រាសាទមួយទៀតគឺស្ថាបនានៅលើ កំពូលភ្នំដាប៉ុន្តែត្រូវបានគេកសាងប្រាសាទនាសតវត្សរ៍ទី១១ ពីលើជំនួស ដែលមានឈ្មោះថា«ប្រាសាទភ្នំដា»។ ក្រៅពីនេះគេឃើញមានសំណង់រូងភ្នំនៅទីនោះ(ភ្នំដា) ដែលជាសំណង់សម្រាប់ឧទ្ទិសដល់អាទិទេព ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា(មហាយាន)។
- រដ្ឋហ្វូណានទទួលឥទ្ធិពលព្រហ្មញ្ញសាសនា ចាប់ផ្តើមរៀបចំរាជធានីដែលមានរាងត្រីកោណ និងទីក្រុងរាងចតុកោណហ៊ុមព័ទ្ធដោយគូទឹក។

**មានចម្លើយត្រឹមត្រូវផ្សេងទៀត**

# វិញ្ញាសាត្រៀមទី១៥

## ប្រធាន

1. តើខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនាថ្ងៃខែឆ្នាំណា?
2. ចូរធ្វើអត្ថាធិប្បាយពីអត្ថន័យព្រមព្រៀងទីក្រុងប៉ារីសក្នុងដំណោះស្រាយជម្លោះនយោបាយកម្ពុជា។
3. ចូរប្រៀបធៀបខ្លឹមសារជាប្រវត្តិសាស្ត្រនៃសន្និសីទក្រុងហ្សឺណែវ១៩៥៤ និងសន្និសីទក្រុងប៉ារីស១៩៩១។
4. តើសម្តេចព្រះបាទនរោត្តមសីហនុ និងសម្តេចហ៊ុន សែនមានតួនាទីអ្វីខ្លះក្នុងការបញ្ចប់សង្គ្រាម នៅកម្ពុជា។
5. ចូរពណ៌នាពីដំណើរនៃការកសាងជាតិឡើងវិញចាប់ពីឆ្នាំ១៩៩៨ មកដល់បច្ចុប្បន្ន។

## អត្រាកំណែ

១-ខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

២-អត្ថន័យនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងដំណោះស្រាយជម្លោះនយោបាយកម្ពុជា៖

- **កិច្ចព្រមព្រៀងទីក្រុងប៉ារីសប្រព្រឹត្តិទៅនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងមានការចូលរួមពីប្រទេសហត្ថលេខីចំនួន១៨។**
- **គោរពឯករាជ្យ អធិបតេយ្យ បូរណភាព អព្យាក្រឹត និងឯកភាពជាតិរបស់កម្ពុជា**
  - បទឈប់បាញ់រវាងភាគីជម្លោះក្នុងសង្គ្រាមស៊ីវិលខ្មែរ និងការកាត់រំសាយទ័ព
  - គូភាគីជម្លោះផ្ទៃក្នុងកម្ពុជា និងដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស ត្រូវបានរំលាយ ហើយបង្កើតទៅជាគណបក្សនយោបាយ(គណបក្សប្រជាជនកម្ពុជា គណបក្សហ៊ុនស៊ិនប៉ិច...)
  - ប្រទេសជាហត្ថលេខីផ្សេងទៀត មានកាតព្វកិច្ចគោរពឯករាជ្យ អធិបតេយ្យ បូរណភាព និងអព្យាក្រឹតគ្នាទៅវិញទៅមក
  - ការដកកងទ័ពវៀតណាមចេញពីកម្ពុជា
  - ការនាំមកនូវសន្តិភាពពេញលេញដល់កម្ពុជា
- **សេចក្តីថ្លែងការណ៍ស្តីអំពីការកសាងប្រទេសកម្ពុជាឡើងវិញ**
  - ការកំណត់អាណត្តិរបស់អ៊ុនតាក់ ដើម្បីមកពិនិត្យមើលបទឈប់បាញ់រក្សាសន្តិភាព និងរៀបចំការបោះឆ្នោត ទៅតាមអ្វីដែលមានចែងក្នុងកិច្ចព្រមព្រៀង
  - ការរៀបចំតាមបែបប្រជាធិបតេយ្យ
  - ការធ្វើមាតុភូមិនិវត្តន៍របស់ជនជាតិភៀសខ្លួនខ្មែរ ជាពិសេសពីជុំរុំជនភៀសខ្លួននៅជាយដែនខ្មែរ-ថៃ ឱ្យវិលត្រឡប់មកក្នុងប្រទេសកម្ពុជាវិញ

- កំណត់គោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា(រួមមានដូចជា គោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ប្រជាជន និងគោលការណ៍នីតិរដ្ឋ ជាដើម)
- ប្រទេសហត្ថលេខីសន្យាផ្តល់ជំនួយដើម្បីស្តារនិងអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ។

**មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៣-ប្រៀបធៀបខ្លឹមសារជាប្រវត្តិសាស្ត្រនៃសន្និសីទក្រុងហ្សឺណែវ១៩៥៤ និងសន្និសីទក្រុងប៉ារីស ១៩៩១៖

**ចំណុចដូចគ្នា**

- សិទ្ធិពលរដ្ឋ និងការបោះឆ្នោត
- ព្រមព្រៀងបញ្ឈប់ការបាញ់គ្នានៅកម្ពុជា
- ការដកកម្លាំងទ័ពបរទេសចេញពីកម្ពុជា
- គោរពអធិបតេយ្យភាព និងបូរណភាពដែនដីរបស់កម្ពុជា

**ចំណុចខុសគ្នា**

- សន្និសីទក្រុងហ្សឺណែវ១៩៥៤ សេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំងស្តីពីការដកទ័ពបារាំងចេញពីទឹកដីឥណ្ឌូចិន និង គោរពឯករាជ្យ អធិបតេយ្យនៃប្រទេសកម្ពុជា ក្នុងឥណ្ឌូចិន។ សេចក្តីថ្លែងការណ៍របស់តំណាងសហរដ្ឋអាមេរិកស្តីពីឥរិយាបទរបស់ខ្លួនទាក់ទងនឹងកិច្ចព្រមព្រៀងហ្សឺណែវ
- សន្និសីទក្រុងប៉ារីស ១៩៩១
    - មានការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា
    - មានការបង្កើតអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា
    - ការប្រគល់សិទ្ធិឱ្យ UNTAC/APRONUCគ្រប់គ្រងប្រទេសកម្ពុជា
    - ការធ្វើមាតុភូមិនិវត្តជនភៀសខ្លួនខ្មែរដែលរស់នៅជាយដែនថៃ
    - ការកសាងកម្ពុជាឡើងវិញដែលថ្ងៃក្រោយក្លាយទៅជា ICORC
    - ការផ្ទេរអំណាច និងគ្រប់គ្រងកងទ័ព៖ ក្រសួង៥ដែលត្រូវគ្រប់គ្រងដោយអ៊ុនតាក់
    - កងទ័ពគ្រប់ភាគីទាំងអស់ត្រូវគ្រប់គ្រងនៅក្នុងបន្ទាយទាំងអស់
    - ដោះលែង ឈ្លើយសឹក និងជនស៊ីវិល ដែលជាប់ឃុំ
    - គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា
    - ការស្តារ និងការកសាងប្រទេសឡើងវិញ។

៤-តួនាទីរបស់សម្តេចព្រះនរោត្តម សីហនុ និងសម្តេច ហ៊ុន សែន ក្នុងការបញ្ចប់សង្គ្រាមនៅកម្ពុជា៖

- **សម្តេចព្រះនរោត្តម សីហនុ**

  - ជាតំណាងចលនាត្រីភាគី
  - ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC)
  - ជាអ្នកផ្តួចផ្តើមគំនិតឱ្យមានកិច្ចចរចាបញ្ចប់សង្គ្រាមនៅកម្ពុជាដែលនាំមានកិច្ចព្រមព្រៀង២៣ តុលា ១៩៩១ ដើម្បីបញ្ចប់សង្គ្រាម
  - ជាបិតាផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ ជាក់ស្តែងក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានវិបត្តិនយោបាយគឺការបែងចែកអំណាចនៃគណបក្សនយោបាយពីរគឺគណបក្សហ្វុនស៊ិនប៉ិច និងគណបក្សប្រជាជន

- **សម្តេចហ៊ុន សែន**

  - តំណាងរដ្ឋាភិបាល នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា
  - ជាអ្នកផ្តួចផ្តើមឱ្យមានកិច្ចចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា និងជាដៃគូចរចាជាមួយសម្តេចព្រះបាទនរោត្តម សីហនុ
  - ចូលរួមកិច្ចចរចាសន្តិភាព២៣ ខែតុលា ឆ្នាំ១៩៩១ ដែលនាំឱ្យប្រទេសកម្ពុជាឈានទៅដល់ការបោះឆ្នោតឆ្នាំ១៩៩៣
  - ផ្តល់កិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់ ដើម្បីឱ្យមានការបោះឆ្នោតមួយនៅកម្ពុជា
  - ក្រោយឆ្នាំ១៩៩៣ សម្តេចបានព្រមព្រៀងធ្វើសមាហរណកម្មដើម្បីបញ្ចប់វិបត្តិនយោបាយនៅកម្ពុជា ដោយកម្ទេចអង្គការចាត់តាំងនយោបាយ និងយោធារបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៩៨។

៥-ដំណើរការកសាងជាតិពីឆ្នាំ១៩៩៨ រហូតដល់បច្ចុប្បន្ន៖

- **វិស័យនយោបាយ**

  - ឆ្នាំ១៩៩៨ មានការធ្វើសមាហរណកម្មកងទ័ពខ្មែរក្រហម និងកងទ័ពរដ្ឋាភិបាល ដែលនាំឱ្យមានកម្លាំងឯកភាពគ្នាដើម្បីស្តារប្រទេស និងកសាងប្រទេសកម្ពុជាឡើងវិញ
  - ក្រោយពីកងកម្លាំងខ្មែរក្រហមដួលរលំ នៅតាមតំបន់ព្រំដែនមានសុវត្ថិភាព និងការអភិវឌ្ឍ
  - ការកម្ទេចរចនាសម្ព័ន្ធអង្គការចាត់តាំងខ្មែរក្រហម
  - ការបែងចែកដីធ្លីកាន់កាប់ជាកម្មសិទ្ធិដល់បងប្អូនអតីតខ្មែរក្រហម
  - បងប្អូនខ្មែរក្រហមទទួលបានតួនាទី និងបុណ្យស័ក្តិដែលធ្លាប់មានពីមុន
  - កម្ពុជាក្លាយជាសមាជិកអង្គការ ស្ថាប័នអន្តរជាតិនានា
  - មានកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងពិភពលោក
  - មានភាពយោគយល់ និងសហប្រតិបត្តការផ្នែកនយោបាយ
  - កម្ពុជាបានក្លាយជាម្ចាស់ផ្ទះក្នុងកម្មវិធីសង្គម និងវប្បធម៌
  - កម្ពុជាបានក្លាយជាប្រធានអាស៊ាន៣លើក(២០០២,២០១២,២០២២)

### វិស័យសង្គម

- កម្ពុជាមានសន្តិភាព សុខសុវត្ថិភាព
- មានការកសាងសាលារៀន មន្ទីរពេទ្យ ...។
- មានកសាងស្ពានជាច្រើនដូចជា ស្ពានគ្យឺបាសា (ស្ពានអ្នកលឿង) ស្ពានឆ្លងកាត់ទន្លេមេគង្គតភ្ជាប់ខេត្តស្ទឹងត្រែង និង ខេត្តព្រះវិហារ៣ ស្ពានតាខ្មៅ ស្ពានព្រះមុនីវង្សចាស់ និង ថ្មី ស្ពានអាកាសទី ១ ក្បាលថ្នល់ ស្ពានអាកាស ៧ មករា៧ ស្ពានអាកាសស្ទឹងមានជ័យ ស្ពានជ្រោយចង្វាចាស់ ស្ពានជ្រោយចង្វាថ្មី មិត្តភាពកម្ពុជា-ចិន សេកុង ស្ពានព្រែកក្ដាម ស្ពានព្រែកញ្ញៅ ស្ពានមិត្តភាពកម្ពុជា-ចិន ព្រែកតាមាក់ ស្ពានគីហ្សូណា ស្ពានតេជោមរកត( ស្ពានកោះពស់ ) ស្ពានកោះកុង ស្ពានជ្រៃធំ-ឡុងប៊ិញ ស្ពានកោះធំ ឆ្លងទន្លេបាសាក់ គម្រោងសាងសង់ស្ពានធំៗចំនួន ។
- មានការកំណែទម្រង់គ្រប់វិស័យដែលនាំឱ្យសង្គមមានការរីកចម្រើន
- លប់បំបាត់អំពើពុករលួយក្នុងសង្គម
- រដ្ឋាភិបានបានអនុវត្តនូវចំណុចគោលក្នុងសង្គមដូចជា អភិបាលកិច្ចល្អ ការលើកស្ទួយវិស័យកសិកម្ម ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជន និងការងារ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្សជាដើម។
- ក្រោមឆ័ត្រសន្តិភាពរដ្ឋាភិបាលបានបន្តអភិវឌ្ឍប្រទេសលើគ្រប់វិស័យ
- ក្នុងបរិបទកូវីដ១៩ រដ្ឋាភិបាលបានយកចិត្តទុកដាក់ទៅលើសុខមាលភាពប្រជាជន ដោយចាត់វិធានការការពារ ចាក់វ៉ាក់សាំងដល់ពលរដ្ឋ។

### វិស័យសេដ្ឋកិច្ច

- ថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ កម្ពុជាក្លាយជាសមាជិកអាស៊ាន ដែលនាំឱ្យមានទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិកាន់តែមានការកើនឡើង
- កម្ពុជាអនុវត្តិសេដ្ឋកិច្ចទីផ្សារសេរី
- កម្ពុជាក្លាយជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាននាឆ្នាំ២០១៥ ដែលនាំឱ្យមានលំហូអ្នកវិនិយោគកាន់តែច្រើននៅកម្ពុជា
- កម្ពុជាក្លាយជាសមាជិកWTO
- មានការរីកចម្រើនផ្នែកឧស្សាហកម្ម ជាពិសេសឧស្សាហកម្មកាត់ដេរ
- វិស័យទេសចរណ៍មានការរៀបចំ កែប្រែនាំដែលអាចទាក់ទាញទេសចរ

### វិស័យវប្បធម៌

- មានការយកចិត្តទុកដាក់ផ្នែកវិស័យកីឡា
- មានការយកចិត្តទុកដាក់ក្នុងការកំណែទម្រង់វិស័យអប់រំដូចជាកម្មវិធីសិក្សា ការគ្រប់គ្រងសាលារៀន ផ្ដល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងតម្លើងប្រាក់បៀវត្សរ៍មន្ត្រីរាជការជាដើម។

- អភិរក្សសម្បត្តិវប្បធម៌ រូបី អរូបី ព្រមទាំងដាក់បញ្ចូលសម្បត្តិវប្បធម៌ជាបេតិកភ័ណ្ឌពិភពលោកដូចជាប្រាសាទអង្គរវត្ត ប្រាសាទព្រះវិហារ ចាប៉ីដងវែង ...។

**ការអនុវត្តច្បាប់**

- មានសេរីភាពផ្នែកសារព័ត៌មាន និងអនុញ្ញាតឱ្យមានសិទ្ធិសេរីភាពក្នុងការបង្កើតអង្គការសង្គមស៊ីវិល
- មានការទប់ស្កាត់ការជួញដូរមនុស្ស ការជួយដូរគ្រឿងញៀននិងអំពើភេរវកម្ម។
- មានការដាក់ឱ្យអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក

**មានចំណុចត្រឹមត្រូវផ្សេងទៀត**

## វិញ្ញាសាត្រៀមទី១៦

### ប្រធាន

1. តើប្រធានាធិបតីខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរឈ្មោះអ្វី?
2. តើប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថាអាស៊ាន(ASEAN) បង្កើតឡើងក្នុងគោលបំណងអ្វី?
3. តើថ្នាក់ដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យណាខ្លះដែលត្រូវបានយកមកជំនុំជម្រះ?
4. តើកត្តាអ្វីដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាម ហើយងាកមករកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម?
5. ចូរពណ៌នាពីសម័យសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០)។
6. ចូរពណ៌នាពីមូលហេតុដែលនាំឱ្យរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ដួលរលំ។

## អត្រាកំណែ

១-ប្រធានាធិបតីខ្មែរក្នុងសម័យសាធារណរដ្ឋខ្មែរឈ្មោះ **លន់ នល់** ។

២-គោលបំណងនៃការបង្កើតអាស៊ាននេះឡើងដូចដែលបានកំណត់នៅក្នុងសន្ធិសញ្ញាអាស៊ានគោលបំណងរបស់អាស៊ានមានដូចជា៖

- បង្កើនល្បឿនកំណើតសេដ្ឋកិច្ច វឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់
- លើកកម្ពស់សន្តិភាពនិងស្ថិរភាពនៅក្នុងតំបន់
- ជំរុញកិច្ចសហប្រតិបត្តិការ និងការឧបត្ថម្ភជួយគ្នាទៅវិញទៅមកដោយមិនរំពឹងផលប្រយោជន៍តបស្នង
- ផ្តល់ជំនួយដល់គ្នាទៅវិញទៅមកក្នុងទម្រង់ជាការបណ្តុះបណ្តាលនិងការស្រាវជ្រាវឧបករណ៍
- កិច្ចសហប្រតិបត្តិការដើម្បីធ្វើឱ្យមានភាពល្អប្រសើរខាងវិស័យកសិកម្ម និងឧស្សាហកម្ម ដើម្បីលើកកម្ពស់ជីវភាពប្រជាជន
- លើកកម្ពស់ការសិក្សានៅអាស៊ីអាគ្នេយ៍
- រក្សាមិត្តភាពដើម្បីប្រយោជន៍កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិដែលមានគោលបំណងដូចគ្នា ឬស្រដៀងគ្នា។

៣-មេដឹកនាំខ្មែរក្រហមដែលត្រូវបានយកមកជំនុំជម្រះនៅតុលាការខ្មែរក្រហមយោង តាមច្បាប់ស្តីពីការបង្កើតតុលាការខ្មែរក្រហម បុគ្គលដែលនឹងត្រូវយកមកជំនុំជម្រះនៅតុលាការខ្មែរក្រហមមានពីរប្រភេទ គឺ មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តិ នៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ មកទល់ពេលនេះ មានអតីតមេដឹកនាំខ្មែរក្រហមចំនួន ៥នាក់ ហើយដែលត្រូវបានតុលាការធ្វើការចោទប្រកាន់ ក្នុងនោះរួមមាន៖

- នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភាកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានគេស្គាល់ថា ជាបងទីពីរ បន្ទាប់ពីប៉ុល ពត។

- ខៀវ សំផន ប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។
- អៀង សារី ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ។
- អៀង ធីរិទ្ធិ (ប្រពន្ធអៀង សារី) រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច នៃកម្ពុជាប្រជាធិបតេយ្យ។
- កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រធានមន្ទីរ ស-២១ ឬគុកទួលស្លែង។

៤-កត្តាដែលនាំឱ្យកម្ពុជាអាចបញ្ចប់សង្គ្រាមហើយងាកមករកការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមៈ

### ឆន្ទៈនៃការបង្រួបបង្រួមជាតិរបស់ខ្មែរ

- ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៨៧ មានការជួបគ្នារវាងសម្តេចព្រះនរោត្តមសីហនុនិងសម្តេច ហ៊ុន សែន នៅទីក្រុងហ្វែអង់តាដឺន័រ ប្រទេសបារាំង
- ការចរចានៅខែមករាឆ្នាំ១៩៨៨
- រដ្ឋាភិបាលក្រុងភ្នំពេញធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៨៩
- ចាប់ពីឆ្នាំ១៩៨៩មក វេទិកាបស់សម្តេចព្រះនរោត្តម សីហនុ និងសម្តេចហ៊ុន សែន ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបានប្រព្រឹត្តិទៅជាបន្តបន្ទាប់
- ថ្ងៃទី១០ កញ្ញា ១៩៩០ បង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ SNC ដែលមានសម្តេចព្រះនរោត្តម សីហនុ ជាព្រះប្រធាន
- ថ្ងៃទី២៣-២៤ មិថុនា ១៩៩១ នៅទីក្រុងយ៉ាកាតា គូបដិបក្ខខ្មែរទាំងបួន បានជួបជុំគ្នា និងបានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ
- ថ្ងៃទី២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស
- នៅឆ្នាំ១៩៩៣រៀបចំការបោះឆ្នោតជាសកលដោយសេរី អព្យាក្រឹត និងយុត្តិធម៌នៅកម្ពុជា

### កត្តាខាងក្រៅប្រទេស

- កំណែទម្រង់ប៉េរេស្ត្រូយការបស់សូវៀត
- ការដកទ័ពរបស់សូវៀតចេញពីអាហ្វហ្កានីស្ថាន
- ការដួលរលំនៃរបបកុម្មុយនីស្តនៅអឺរ៉ុបខាងកើត នាចុងទស្សវត្សរ៍ឆ្នាំ១៩៨០
- ជំនួបរវាងសហរដ្ឋអាម៉េរិកនិងសហភាពសូវៀតឆ្នាំ១៩៨៧
- ការផ្តាច់ជំនួយរបស់សហភាពសូវៀតចំពោះប្រទេសវៀតណាម
- ការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជាជាលើកចុងក្រោយនាឆ្នាំ១៩៨៩
- ការដួលរលំនៃអតីតសហភាពសូវៀតនៅឆ្នាំ១៩៩១
- ការបញ្ចប់សង្គ្រាមត្រជាក់នៅឆ្នាំ១៩៩១
- ការជួយអន្តរាគមរបស់អាស៊ាន អង្គការសហប្រជាជាតិ បានធ្វើឱ្យភាគីខ្មែរព្រមចូលតុចរចា

- ការចូលរួមធ្វើការចរចារវាងតំណាងកុម្មុយនីស្តគឺប្រទេសវៀតណាម និងប្រទេសឥណ្ឌូនេស៊ី តំណាងឱ្យអាស៊ាន ដើម្បីដោះស្រាយពីបញ្ហាកម្ពុជា
- អង្គការសហប្រជាជាតិចូលរួមរៀបចំការបោះឆ្នោតនៅកម្ពុជានាឆ្នាំ១៩៩៣

### ការផ្សះផ្សាជាតិក្រោយឆ្នាំ ១៩៩៣ និងនយោបាយឈ្នះ-ឈ្នះ

- ការបង្កើតរដ្ឋាភិបាលចម្រុះក្រោយការបោះឆ្នោត
- ធ្វើការទប់ស្កាត់មិនឱ្យពួកខ្មែរក្រហមវិលត្រឡប់មកកាន់អំណាចវិញ
- ការដាក់ចេញនូវគោលនយោបាយ ឈ្នះ-ឈ្នះ របស់សម្តេចហ៊ុន សែន

### មានចម្លើយត្រឹមត្រូវផ្សេងទៀត

៥-ពណ៌នាពីសម័យសង្គមរាស្ត្រនិយម(១៩៥៥-១៩៧០)

### ការលេចឡើងនៃរបបសង្គមរាស្ត្រនិយម

- រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ បានបញ្ញត្តពីអំណាចព្រះមហាក្សត្រដោយទ្រង់សោយរាជ្យពេញមួយជីវិតប៉ុន្តែមិនកាន់អំណាច ហើយរាល់ទស្សនៈនយោបាយរបស់ព្រះមហាក្សត្រត្រូវដាក់ឱ្យសភាអនុម័តទើបយកទៅអនុវត្ត
- សភាតែងតែជំទាស់រាល់គំនិតទស្សនៈនយោបាយរបស់ព្រះមហាក្សត្រ
- ព្រះរាជាពុំចង់ឃើញការខ្វែងគំនិតគ្នា និងបែកបាក់គ្នាក្នុងរង្វង់អ្នកដឹកនាំ
- ព្រះរាជាចង់ឱ្យប្រជាជន អ្នកនយោបាយគ្រប់និន្នាការ នយោបាយស្ថិតក្រោមម្លប់រាជបល្ល័ង្កតែមួយដូចនេះហើយបានជាព្រះអង្គដាក់រាជ្យនៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៥៥ ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៥៥ ដោយចូលរួមការបោះឆ្នោតនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៥៥
- ប្រជាជនមានការជឿជាក់លើអង្គការសង្គមរាស្ត្រនិយមដោយសារតែ
  - ប្រជាប្រិយភាពរបស់សម្តេចព្រះនរោត្តម សីហនុ
  - ភាពរឹងមាំនៃរចនាសម្ព័ន្ធដឹកនាំអង្គការ«សង្គម» ថ្នាក់មូលដ្ឋាន
  - ក្បាលម៉ាស៊ីនដឹកនាំមានការចុះចូលមកពីគណបក្សផ្សេង
  - វិស័យហិរញ្ញវត្ថុរឹងនាំ។

### សមាជជាតិ

- មានជាតិមានចំនួន២៨លើក
- សមាជជាតិជាតិត្រូវប្រារព្ធឡើងមួយឆ្នាំ២ដង
- សមាជជាតិវេទិកាប្រជាធិបតេយ្យ
- សមាជជាតិជាវេទិកាអាចឱ្យពលរដ្ឋបញ្ចេញគំនិតយោបល់និងបង្ហាញពីតម្រូវការ រួមទាំងបញ្ហាដែលគាត់បានជួបប្រទះ
- សមាជជាតិ ជាស្ថាប័នការពារអំណាចសង្គមរាស្ត្រនិយម សម្តេចព្រះនរោត្តម សីហនុ បានទាមទារឱ្យគេអនុម័តបញ្ចូលសមាជទៅជាស្ថាប័នរដ្ឋតាមច្បាប់

- សមាជជាតិសម្រេចបានសមិទ្ធផលជាច្រើនដូចជា ការប្រឆាំងនឹងអំពើពុករលួយ ការកំណត់ភាសាខ្មែរជាផ្លូវការ...

### នយោបាយអព្យាក្រឹត

- នយោបាយអព្យាក្រឹតបានដាក់ឱ្យចេញនៅឆ្នាំ១៩៥៧
- គោរពតាមស្មារតីសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៥
- ដើម្បីរក្សាសន្តិភាពនៅកម្ពុជា
- ដើម្បីរួមរស់ដោយសន្តិសហវិជ្ជមាន
- ទប់ទល់នឹងឥទ្ធិពលសង្គ្រាមត្រជាក់
- មានសន្តិសន្តិភាពអស់រយៈពេល១៥ឆ្នាំ
- សង្គ្រាមត្រជាក់បានធ្វើឱ្យនយោបាយអព្យាក្រឹតបានផុតរលត់ដោយរដ្ឋប្រហារថ្ងៃទី១៨ ខែមីនាឆ្នាំ១៩៧០។

### សមិទ្ធផល

- វិស័យសេដ្ឋកិច្ច
    - រដ្ឋាភិបាលមានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយពង្រីកផ្ទៃដីកសិកម្ម ការជ្រើសរើសពូជ នយោបាយទឹក និងការប្រើប្រាស់ជី
    - វិស័យនេសាទមានការរីកចម្រើនគួរឱ្យកត់សម្គាល់
    - ព្រៃឈើជាធនធានដ៏សំខាន់សម្រាប់ពលរដ្ឋខ្មែរ
- វិស័យគមនាគមន៍
    - មានការពង្រីកកំពង់ផែ
    - មានការកសាងផ្លូវជាតិ ផ្លូវក្រាលគ្រួសក្រហម ផ្លូវលំ ជាច្រើនខ្សែ
    - មានការភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូក្យូ សាន់ហ្វាន់ស៊ីស្កូ អូសាកា...
- វិស័យពាណិជ្ជកម្ម និងឧស្សាហកម្ម
    - មានក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បរទេស
    - មានការប្រកួតប្រជែងផ្នែកពាណិជ្ជកម្មជាមួយបរទេស
    - មានការរីកចម្រើនផ្នែកអហារ័ណ នីហរ័ណជាតិ
- វិស័យធនាគារ
    - ប្រាក់រៀលចរាចរនៅទូទាំងប្រទេស
    - មានធនាគារបរទេសជាច្រើននៅកម្ពុជា
- វិស័យវប្បធម៌
    - ការអប់រំមានការរីកចម្រើន អាចប្រណាំងប្រជែងបាននៅក្នុងតំបន់
    - មានការកសាងសាលារៀនជាច្រើន
    - មានការលើកកម្ពស់ដល់មន្ត្រីអប់រំ

- យកចិត្តទុកដាក់ផ្នែកវប្បធម៌ សិល្បៈ...
- ផ្នែកកីឡាមានការរីកចម្រើន មានការកសាងកន្លែងស្នាក់នៅសម្រាប់កីឡាករ មានការកសាងពហុកីឡដ្ឋាន...

- វិស័យសង្គម
  - មានការយកចិត្តទុកដាក់លើវិស័យសុខាភិបាល
  - ការអនុវត្តច្បាប់មានភាពតឹងរឹង ដែលនាំឱ្យពលរដ្ឋក្លាយជាអ្នកមានវិន័យ។

**ដំណាក់កាលចុងក្រោយនៃរបបសង្គមរាស្ត្រនិយម**

- វិស័យសេដ្ឋកិច្ច
  - **បញ្ហាកសិកម្ម** ៖ ជួបវិបត្តិដោយប្រព័ន្ធធារាសាស្ត្រគ្មានប្រសិទ្ធភាព ជាហេតុធ្វើឱ្យទិន្នផលកសិកម្មទាប
  - **បញ្ហាឧស្សាហកម្ម** ៖ រដ្ឋគ្រប់គ្រងឧស្សាហកម្មមិនបានល្អ ហើយការចំណាយខ្វះតុល្យភាព
  - **បញ្ហាពាណិជ្ជកម្ម** ៖ សម្ដេចនរោត្តម សីហនុ បានធ្វើជាតូបនីយកម្មក្នុងវិស័យនីហរ័ណ អាហរ័ណផ្នែកសេដ្ឋកិច្ច និងបិទទ្វារធនាគារឯកជនខ្មែរទាំងឡាយ។ ការធ្វើជាតូបនីយកម្មពាណិជ្ជកម្មក្រៅប្រទេសបានជំរុញឱ្យមានពាណិជ្ជកម្មលួចលាក់ ជាមួយពួកបះបោរកុម្មុយនីស្តនៅវៀតណាម។ ឆ្នាំ១៩៦៧ ផលស្រូវកម្ពុជាមួយភាគបួនត្រូវបានលក់ដោយគេចពន្ធទៅឱ្យកម្លាំងកុម្មុយនីស្ត វៀតណាម ព្រោះពួកគេបានឱ្យតម្លៃខ្ពស់ជាងរដ្ឋបញ្ហាខាងលើនេះបានធ្វើឱ្យរាជរដ្ឋាភិបាលបាត់បង់ប្រាក់ចំណូល។
  - **បញ្ហាជំនួយពីបរទេសៈ** ដើម្បីគេចចេញពីសង្គ្រាមនៅវៀតណាមនៅឆ្នាំ១៩៦៣ សម្ដេចនរោត្តម សីហនុ បានបដិសេធជំនួយយោធាពីអាម៉េរិក ដែលមានតម្លៃចំនួន១៥ភាគរយនៃថវិកាជាតិ ឯជំនួយពីប្រទេសចិនពុំអាចស្តារស្ថានភាពចុះខ្សោយនៃកងទ័ពបានទេ។
  - **នៅក្នុងឆ្នាំ១៩៦៧-១៩៦៨** សេដ្ឋកិច្ចរបស់កម្ពុជាមានដំណើររាំងស្ទះ ចំណែកឯប្រជាប្រិយភាពរបស់សម្ដេចព្រះនរោត្តម សីហនុ ក៏មានការថយចុះ។

- ការពង្រឹងកម្លាំងរបស់បក្សកុម្មុយនីស្តកម្ពុជា
  - ក្នុងឆ្នាំ១៩៦៥ សាឡុត ស(ប៉ុល ពត) ទៅវៀតណាមខាងជើងដើម្បីចូលរួមការពិគ្រោះយោបល់
  - ក្នុងដំណើរទស្សនកិច្ចនៅប្រទេសចិនឆ្នាំ១៩៦៦ សាឡុត ស បានឃើញបដិវត្តន៍វប្បធម៌ចិន ដែលធ្វើឱ្យគាត់យកគំរូតាម
  - ក្រោយពីត្រឡប់មកពីប្រទេសចិនវិញ សាឡុត ស បានតាំងបញ្ជាការដ្ឋាននៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ហើយដាក់ឈ្មោះចលនារបស់ខ្លួន

ថា បក្សកុម្មុយនីស្តកម្ពុជា(ប.ក.ក.)ដែលមានមូលដ្ឋាននៅភូមិភាគឦសាន និងពាយព្យ។

  - នៅដើមឆ្នាំ១៩៧០ កងកម្លាំងបក្សកុម្មុយនីស្តកម្ពុជា(ទ័ពរបស់ខ្មែរក្រហម) បានបង្កអសន្តិសុខ និងបានកាន់កាប់ទឹកដីស្មើ១/៥ លើទឹកដីកម្ពុជាទាំងមូល។ ក្នុងពេលនោះ ពួកនិស្សិត និងគ្រូបង្រៀនជាច្រើននៅទីក្រុងភ្នំពេញពេញចិត្តនឹងមនោគមវិជ្ជាថ្មី ដែលជាលទ្ធផលនៃបដិវត្តន៍វប្បធម៌ចិន។

- វិបត្តិផ្ទៃក្នុងរាជរដ្ឋាភិបាល
  - នៅចុងឆ្នាំ១៩៦៩ មន្ត្រីអភិរក្សនិយមជាន់ខ្ពស់មួយចំនួន ជាពិសេស ទ្រង់ស៊ីសុវត្ថិ សិរីមតៈ បានចាប់ផ្តើមធ្វើផែនការក្បត់សម្តេចព្រះនរោត្តម សីហនុ
  - ចំណែកលោកលន់ នល់ ដែលជានាយករដ្ឋមន្ត្រីពុំបានជំទាស់នឹងសម្តេចនរោត្តមសីហនុ ចំពោះការបដិសេធជំនួយពីសហរដ្ឋអាមេរិក និងចងសម្ព័ន្ធភាពជាមួយកុម្មុយនីស្តក្នុងការដឹកជញ្ជូនអាវុធឆ្លងទឹកដីកម្ពុជាទេ។

សរុបមករបបសង្គមរាស្ត្រនិយមបានដួលរលំដោយសារវិបត្តិសេដ្ឋកិច្ច វិបត្តិនយោបាយផ្ទៃក្នុង វត្តមានកងទ័ពវៀតណាមខាងជើងលើទឹកដីខ្មែរ និងការប្រឈមគ្នារវាងពួកមហាអំណាចសេរីនិងកុម្មុយនីស្តក្នុងបរិបទនៃសង្គ្រាមត្រជាក់។

- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៦-មូលហេតុដែលបណ្តាលឱ្យរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមាន៖

- **បញ្ហានយោបាយ**

**ការអនុវត្តនយោបាយសម្រិតសម្រាំង**

- មេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យសម្រិតសម្រាំងយកមនុស្សបដិវត្តន៍ល្អបរិសុទ្ធ នាំឱ្យពួកប៉ុល ពត លែងទុកចិត្តគ្នាឯង តាំងពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ជាក់ស្តែង ប៉ុល ពត បានសម្លាប់ វន វ៉េត ,កុយ ធួន,ញឹម រស់,សោភឹម...។

**ការធ្វើសង្គ្រាមប្រឆាំងវៀតណាម**

- ១៩៧៥: ប៉ុលពតបានបង្កសង្គ្រាមជាមួយវៀតណាមនៅតាមព្រំដែន
- ១៩៧៧: សង្គ្រាមឆាបឆេះខ្លាំងជាមួយវៀតណាម
- ១៩៧៨: វៀតណាមវាយបកមកវិញយ៉ាងខ្លាំង
- ១៩៧៩:ទ័ពវៀតណាម និងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ

## ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា៖

- នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្តហ៊ុន សែន និងយុទ្ធមិត្ត៤រូប(នុច ថន, វ៉ា ប៉ោអៀន, ញឹក ហួន, សាន សាញ់) បានសម្រេចចិត្តចេញពីកម្ពុជាដើម្បីស្វែងរកការគាំទ្រ ក្នុងការរំដោះប្រទេសជាតិ
- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានបង្កើតឡើងក្នុងបំណងរំដោះប្រទេសពី របបកម្ពុជាប្រជាធិបតេយ្យដែលជារបបប្រល័យពូជសាសន៍
- រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានបើកការវាយប្រហារលើទ័ពកម្ពុជាប្រជាធិបតេយ្យ ហើយបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។
- **ចម្លើយត្រឹមត្រូវផ្សេងៗទៀត។**

## បញ្ហាសេដ្ឋកិច្ច

- ការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន មហាលោតផ្លោះ មហាអស្ចារ្យ ការសម្លាប់អ្នកចេះដឹង ការប្រើកម្លាំងមនុស្សជំនួសបច្ចេកវិជ្ជា ដែលនាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ
- ការអនុវត្តរបស់ខ្មែរក្រហមបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាដើរថយក្រោយ
- ចម្លើយត្រឹមត្រូវផ្សេងៗទៀត។

## បញ្ហាសង្គម

- ខ្មែរក្រហមបំភិតបំភ័យ ធ្វើទារុណកម្ម កាប់សម្លាប់ ប្រជាជនរស់ក្នុងភាពភ័យខ្លាចតក់ស្លុត
- ខ្មែរក្រហមបង្ខំឱ្យប្រជាជនធ្វើការលើស១២ម៉ោងក្នុង១ថ្ងៃ និង៧ថ្ងៃក្នុង១សប្តាហ៍ គ្មានពេលឈប់សម្រាក
- ប្រជាជនរស់នៅដោយកង្វះអាហារ កង្វះជម្រក ខ្វះថ្នាំសម្រាប់ព្យាបាល គឺរស់រង់ចាំតែថ្ងៃស្លាប់
- បំបិទសិទ្ធិសេរីភាពខាងសាសនា ជំនឿ ប្រពៃណី ទំនៀមទម្លាប់
- ឪពុកម្តាយគ្មានសិទ្ធិលើកូន
- កុមារទទួលបាននូវការអប់រំមនោគមវិជ្ជាបដិវត្តន៍ ដោយឱ្យកុមារស្រឡាញ់ ជឿជាក់ ស្មោះត្រង់អង្គការ ហ៊ានពលីដើម្បីអង្គការ យកការណ៍ពីឪពុកម្តាយ ពីជួរប្រជាជនជូនអង្គការ
- ប្រជាជនរស់ក្រោមពាក្យស្លោក « ទុកក៏មិនចំណេញ ដកចេញក៏មិនខាត »
- **ចម្លើយត្រឹមត្រូវផ្សេងទៀត។**

# វិញ្ញាសាត្រៀមទី១៧

**ប្រធាន**

1. ចូររៀបឈ្មោះមេដឹកនាំសំខាន់ៗនៃសម័យសាធារណរដ្ឋខ្មែរឱ្យបានប្រាំរូប។
2. តើមូលហេតុអ្វីបានជាសៀមប្តូរឈ្មោះទៅជាថៃ? ហើយមានការផ្លាស់ប្តូររបបនយោបាយបែបណា?
3. តើរាជធានីឥសានបុរៈស្ថិតក្នុងសម័យណា? ហើយវប្បធម៌ខ្មែរសម័យនោះបានបន្សល់ទុកអ្វីខ្លះ សម្រាប់កូនខ្មែរជំនាន់ក្រោយ។
4. ក្រោយសង្គ្រាមលោកលើកទី២ ទ្វីបអឺរ៉ុបត្រូវបានបែងចែកជាអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។ តើការបែងចែកនេះដោយសារមូលហេតុអ្វីខ្លះ? ហើយមានបច្ច័យអ្វីខ្លះសម្រាប់ទំនាក់ទំនងអន្តរជាតិ?
5. ចូរពន្យល់ពីមូលហេតុដែលនាំឱ្យកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមឆ្នាំ១៩៧០។ តើបញ្ហាអ្វីខ្លះដែលពលរដ្ឋកម្ពុជាត្រូវចងចាំមេរៀនប្រវត្តិសាស្ត្រ សង្គ្រាមស៊ីវិល និងមនោគមវិជ្ជានយោបាយដែលបានកើតឡើងនេះ?

## អត្រាកំណែ

១-មេដឹកនាំសំខាន់ៗនៃសម័យសាធារណរដ្ឋខ្មែរឱ្យបានប្រាំរូបៈ

- លន់ នល់
- ទ្រង់ សិរីមតៈ
- សឺង ង៉ុកថាញ់
- ចេង ហេង
- ហង្ស ធនហាក់

**ចំណាំ៖ មានផ្សេងទៀតដូចជា ឡុង បូរ៉េត, អ៊ិន តាំ...។**

២-មូលហេតុដែលសៀមប្តូរឈ្មោះទៅថៃ

- រដ្ឋប្រហារយោធាឆ្នាំ១៩៣២
- គំនិតជាតិនិយម
- ឥស្សរភាពជាតិនិយម
- ឥទ្ធិពលនៃការអប់រំនៅបស្ចឹមប្រទេស
- បញ្ហាសេដ្ឋកិច្ចគ្រប់គ្រងដោយជនជាតិចិន

**មានការផ្លាស់ប្តូររបបនយោបាយដូចជា៖**

- ពីរាជានិយមផ្តាច់ការ ទៅជារាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ(កំណត់អំណាចស្តេច)
- ប្តូរពីរាជានិយមផ្តាច់ការទៅជាស៊ីវិលវិញ
- អនុវត្តតាមលទ្ធិប្រជាធិបតេយ្យ
- រដ្ឋាភិបាលគ្រប់គ្រងដោយពួកយោធា។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៣-រាជធានីឥសានបុរៈស្ថិតក្នុងសម័យចេនឡាហើយវប្បធម៌ខ្មែរសម័យចេនឡាបានបន្សល់ទុកសម្រាប់កូនខ្មែរជំនាន់ក្រោយមានដូចជា៖

- **ចំណេះដឹង**
  - ជំនឿលើអារុក្ខ អារក្ស អ្នកតា...
  - សាសនា៖ បានបង្ហាញភាពសុខដុមផ្នែកសាសនាព្រះពុទ្ធ និងហិណ្ឌូ ហើយក្រៅពីនេះមានការបង្រួបបង្រួមសាសនាព្រាហ្មណ៍ដោយកសាងរូបហរិហរៈ
  - ស្ថាបត្យកម្ម ដែលមានប្រាសាទសំបូរព្រៃគុក សំណង់ដីឥដ្ឋ...
  - មរតកវប្បធម៌ដ៏សំខាន់គឺប្រាសាទសំបូរព្រៃគុក
- **ការផ្សព្វផ្សាយចំណេះដឹង**
  - អក្សរ
  - ភាសា
  - សិល្បៈ(រចនាបទប្រាសាទខ្មែរ)
  - របាំអប្សរា
- **ប្រពៃណីទំនៀមទម្លាប់**
  - ការជ្រើសរើសគូស្រករ
  - ពិធីបុណ្យសព
  - ការចែកមរតកពីម្ដាយទៅកូនក្រោយពេលរៀបការ
  - ឱ្យខ្មែរចេះរួបរួមគ្នាតាមរយៈជំនឿ
- **សីលធម៌-យុត្តិធម៌៖ ឱ្យពលរដ្ឋចេះស្រលាញ់យុត្តិធម៌ សច្ចធម៌**
- **ការឱ្យតម្លៃលើវិស័យអប់រំ**
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-ក្រោយសង្គ្រាមលោកលើកទី២ ទ្វីបអឺរ៉ុបត្រូវបានបែងចែកជាអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។ ការបែងចែកនេះដោយសារមូលហេតុជាច្រើនដូចជា៖

- **ឥទ្ធិពលនៃសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥)៖**
  - នៅក្នុងសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើនគ្រប់គ្រងដោយអាល្លឺម៉ង់
  - នៅចុងបញ្ចប់នៃសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ត្រូវរំដោះដោយសូវៀត និងអាម៉េរិក
  - សេដ្ឋកិច្ចទ្វីបអឺរ៉ុបចុះទន់ខ្សោយងាយទទួលរងឥទ្ធិពល អឺរ៉ុបត្រូវពឹងផ្អែកលើជំនួយសហរដ្ឋអាម៉េរិក និងសហភាពសូវៀត

- **សន្និសីទក្រុងយ៉ាល់តា និងសន្និសីទ ពតស្ដាំ(Potsdam) ឆ្នាំ១៩៤៥ ស្ដីពីការបែងចែកទ្វីបអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២**
  - ការបែងចែកទឹកដីអាល្លឺម៉ង់ដោយមហាអំណាចទាំងបួន ជាបួនតំបន់កាន់កាប់
  - ការបែងចែកទីក្រុងប៊ែរឡាំងជាបួនផ្នែក
  - ភាពទំលចេកផ្នែកនយោបាយ និងភាពប្រេះឆាគ្នា នៃមហាអំណាចសម្ព័ន្ធមិត្ត ដែលធ្វើឱ្យជំណោះស្រាយពីបញ្ហាអាល្លឺម៉ង់ ត្រូវបរាជ័យ
- **ការប្រជែងគ្នារបស់មហាអំណាចពីរគឺ សហរដ្ឋអាម៉េរិកនិងសហភាពសូវៀត**
  - នៅក្នុងសង្គ្រាម មហាអំណាច សហរដ្ឋអាម៉េរិក អង់គ្លេស និងសហភាពសូវៀត បានរួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងណាស៊ីអាល្លឺម៉ង់ តែមហាអំណាចទាំងនេះមានលក្ខណៈប្លែកគ្នាទាំងស្រុង ទាំងផ្នែកមនោគមវិជ្ជានយោបាយ និងសេដ្ឋកិច្ច
  - ការមិនទុកចិត្តគ្នារវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀតនៅចុងបញ្ចប់នៃសង្គ្រាម
  - ការប្រជែងមនោគមវិជ្ជានយោបាយ បែបប្រជាធិបតេយ្យសេរី និងកុម្មុយនីស្ត
  - ការប្រជែងផ្នែកសេដ្ឋកិច្ច តាមបែបមូលធននិយម និងសង្គមនិយម
  - ការប្រជែងផ្នែកសព្វាវុធ អាវុធនុយក្លេអ៊ែរ ព្រមទាំងការប្រជែងបច្ចេកវិជ្ជា និងការទូត
  - អឺរ៉ុបប៉ែកខាងកើតត្រូវរំដោះដោយសូវៀតក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានធ្លាក់ក្រោមឥទ្ធិពលកុម្មុយនីស្តសូវៀត និងក្រោយមកប្រកាន់យករបបកុម្មុយនីស្តតាមបែបសូវៀត
  - អឺរ៉ុបខាងលិចត្រូវបានរំដោះដោយអង់គ្លេស និងសហរដ្ឋអាម៉េរិកក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានប្រកាន់យករបបប្រជាធិបតេយ្យសេរី
- **ទ្រឹស្ដីទ្រូម៉ាន់ និងផែនការម៉ាសាល ឆ្នាំ១៩៤៧៖ អាម៉េរិកអនុវត្តនយោបាយទប់ទល់ និងរុញច្រានរបបកុម្មុយនីស្ត**

**បច្ច័យសម្រាប់ទំនាក់ទំនងអន្តរជាតិ**

- ពិភពលោកត្រូវបានបែងចែកជាពីរប្លុកគឺប្លុកលោកខាងកើត(ប្លុកកុម្មុយនីស្ត)និងប្លុកលោកខាងលិច(ប្លុកសេរី)
- ការបង្កើតបក្សសម្ព័ន្ធយោធានៅតាមតំបន់ ដូចជាអង្គការអូតង់(នៅអឺរ៉ុបខាងលិច) បក្សសម្ព័ន្ធវ៉ាសូវី(អឺរ៉ុបខាងកើត) សេអាតូ(អាស៊ីអាគ្នេយ៍) បាដាត(មជ្ឈិមបូព៌ា)...
- បណ្ដាប្រទេសក្រោមអាណានិគមទទួលបានឯករាជ្យជាបន្តបន្ទាប់ (ទ្វីបអាស៊ី អាហ្វ្រិក និងអាម៉េរិកឡាទីន)
- ផ្ទុះសង្គ្រាមស៊ីវិលនៅតាមប្រទេសមួយចំនួនដែលទើបទទួលបានឯករាជ្យ និងទទួលមនោគមវិជ្ជាទាំងពីរ(សង្គ្រាមឧបទ្វីបកូរ៉េ សង្គ្រាមវៀតណាម កម្ពុជា...)

- **មានចំណុចត្រឹមត្រូវផ្សេងទៀត**

៥-មូលហេតុដែលនាំឱ្យកម្ពុជាធ្លាក់ចូលក្នុងភ្លើងសង្គ្រាមឆ្នាំ១៩៧០

- ឥទ្ធិពលនៃសង្គ្រាមត្រជាក់(១៩៤៥-១៩៩១) គឺជាការប្រជែងឥទ្ធិពលគ្នារវាងអាម៉េរិក និងសហភាពសូវៀត
- ការអនុវត្តនយោបាយអព្យាក្រឹតរបស់សម្តេចនរោត្តម សីហនុ(១៩៥៥-១៩៧០) មិនបានសម្រេចគោលដៅ
- រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០
- អំពើពុករលួយ បក្សពួកនិយម កុប្បកម្មពេញផ្ទៃប្រទេស
- ការជ្រៀតជ្រែករបស់ប្រទេសវៀតណាម ចិន និងសហរដ្ឋអាម៉េរិកក្នុងនយោបាយខ្មែរ
- ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជារបស់សម្តេចព្រះនរោត្តម សីហនុ
- ការគាំទ្ររបស់អាម៉េរិកចំពោះរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ របស់លោកសេនាប្រមុខលន់ នល់
- ការគាំទ្ររបស់ចិនចំពោះ រណសិរ្សរបស់សម្តេចនរោត្តម សីហនុ និងក្រុមខ្មែរក្រហម
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

ពលរដ្ឋកម្ពុជាត្រូវចងចាំមេរៀនប្រវត្តិសាស្រ្ត សង្គ្រាមស៊ីវិល និងមនោគមវិជ្ជានយោបាយៈ

**ផ្នែកនយោបាយ**

- ការបែកបាក់ផ្ទៃក្នុង និងការជ្រៀតជ្រែកពីបរទេសនាំឱ្យប្រទេសជាតិរងគ្រោះមហន្តរាយ និងភាពរីករវនយោបាយផ្ទៃក្នុង
- អស្ថិរភាពនយោបាយ អសន្តិសុខសង្គម
- ប្រទេសបាត់បង់កិត្តិយស បាត់បង់កិត្យានុភាព

**ផ្នែកសេដ្ឋកិច្ច**

- ការធ្លាក់ចុះនៃសេដ្ឋកិច្ច អតិផរណា វិបត្តិហិរញ្ញវត្ថុ
- ដីស្រែចម្ការត្រូវទំនេរចោល ខូចខាតផលដំណាំ
- ឧស្សាហកម្មពុំមានដំណើរការ
- ពាណិជ្ជកម្មត្រូវរាំងស្ទះ

**បាត់បង់ឱកាស**

- ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច កសាងសង្គម
- ការរួបរួមជាតិ និងការពារជាតិ
- ចូលរួមក្នុងឆាកអន្តរជាតិដោយសមភាព
- ទទួលយកវិនិយោគទុនពីបរទេស

- **ផ្នែកសង្គម**
  - ខូចខាតហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ ផ្ទះសម្បែង
  - ការសម្លាប់របស់ប្រជាជនខ្មែរ
  - ការបែកបាក់គ្រួសារ ប្រពន្ធ ប្តី
  - បន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ
  - ការរស់នៅដោយការភិតភ័យ និងគ្មានសិទ្ធិសេរី
  - បាត់បង់ឱកាសការងារ ការអប់រំ សុខភាព
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

## **វិញ្ញាសាត្រៀមទី១៨**

**ប្រធាន**

1. តើហ្វូណាន បានទទួលឥទ្ធិពលខ្លាំងពីប្រទេសណា?
2. ចូរប្រៀបធៀបតួនាទីរបស់សភានៃសាធារណរដ្ឋទី៤ និងទី៥នៃប្រទេសបារាំង។
3. ចូរពន្យល់ពីមូលហេតុនៃការដួលរលំនៃប្រទេសអឺរ៉ុបខាងកើតនាចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ និងការបង្កើតពិភពលោកឯកប៉ូល។
4. តើបញ្ហាប្រឈម និងកាលានុវត្តភាពអ្វីខ្លះរបស់កម្ពុជានីតិកាលទី៤ នៃរដ្ឋសភា?
5. នៅក្នុងការអភិវឌ្ឍប្រទេស រាជរដ្ឋាភិបាលមានទិសដៅ និងផែនការច្បាស់លាស់។ ចូរពន្យល់ពីយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ។

## **អត្រាកំណែ**

១-ហ្វូណាន បានទទួលឥទ្ធិពលខ្លាំងពីប្រទេស**ឥណ្ឌា**។

២-ប្រៀបធៀបសភាសាធារណរដ្ឋបារាំង

- **ភាពដូចគ្នា**
    - សភាត្រួតពិនិត្យការងាររដ្ឋបាល
    - សភាមានសិទ្ធរំលាយរដ្ឋាភិបាល
    - សភាមានអណត្តិ៥ឆ្នាំ

- **ភាពខុសគ្នា**

**សាធារណរដ្ឋទី៤**

- សភាជ្រើសរើសនាយករដ្ឋមន្ត្រី
- សភាជ្រើសតាំងប្រធានាធិបតី
- គ្មានស្ថាប័នព្រឹត្តិសភា

**សាធារណរដ្ឋទី៥**

- ប្រធានាធិបតីជ្រើសរើសនាយករដ្ឋមន្ត្រី
- ប្រធានាធិបតីជ្រើសរើសដោយការបោះឆ្នោត
- មានព្រឹទ្ធសភា។

៣-មូលហេតុនៃការដួលរលំនៃប្រទេសអឺរ៉ុបខាងកើត នាចុងទសវត្សរ៍ឆ្នាំ១៩៨០ និងដើមទសវត្សរ៍ឆ្នាំ១៩៩០ និងការបង្កើតពិភពលោកឯកប៉ូល

- កំណែទម្រង់ប៉េរេស្ត្រូយការរបស់សហភាពសូវៀតនាឆ្នាំ១៩៨៩ ដែលជាការបើកចំហពីវិស័យសេដ្ឋកិច្ច និងនយោបាយពីការគ្រប់គ្រងរបស់បក្សកុម្មុយនីស្ត
- លោកហ្គោបាឆូវ បានសម្រេចចិត្តកាត់បន្ថយអន្តរាគមន៍យោធារបស់សូវៀតនៅបរទេស និងងាកមកស្តារសេដ្ឋកិច្ចក្នុងប្រទេសខ្លួនឯងផ្ទាល់
- ការដកកងទ័ពរបស់សហភាពសូវៀតចេញពីអាហ្គានីស្ថានឆ្នាំ១៩៨៩

- ការបន្ធូរបន្ថយអំណាចកុម្មុយនីស្តនៅអឺរ៉ុបខាងកើត
- លោកហ្គោបាឆូវបានបញ្ជាក់ថាគ្រប់ប្រជាជាតិគួរតែជ្រើសរើសផ្លូវដើរដោយខ្លួនឯង
- លោកហ្គោបាឆូវបានប្រកាសកាត់បន្ថយទ័ពរបស់សូវៀតដែលកំពុងឈរជើងនៅប្រទេសកុម្មុយនីស្ត និងតំបន់អឺរ៉ុបខាងកើត
- ការងើបបះបោររបស់ប្រជាជនអឺរ៉ុបខាងកើត
- ការដួលរលំជញ្ជាំងប៊ែកឡាំង
- ការដួលរលំបានចាប់ផ្តើមជាបន្តបន្ទាប់ដែលចាប់ផ្តើមដំបូងនៅប្រទេសប៉ូឡូញ ហុងគ្រី អាឡឺម៉ង់ខាងកើត យូហ្គោស្លាវីគី ប៊ុលការី និងរ៉ូម៉ានី។
- មានចំណុចត្រឹមត្រូវផ្សេងទៀត

៤-បញ្ហាប្រឈម និងកាលានុវត្តភាពរបស់កម្ពុជានីតិកាលទី៤ នៃរដ្ឋសភា

### កម្ពុជាជួបបញ្ហាប្រឈមសំខាន់ៗមាន

- ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកគំរាមដល់សេដ្ឋកិច្ចកម្ពុជា
- អត្រាភាពក្រីក្រនៅតំបន់ជនបទនៅមានកម្រិតខ្ពស់
- វិសមភាពរវាងអ្នកមាន អ្នកក្រ រវាងអ្នកទីក្រុង និងជនបទដែលសម្រេចបាន នៅមានភាពផុយស្រួយ
- ការអនុវត្តគោលនយោបាយ រូបិយវត្ថុ នៅមានកម្រិតដោយសារដុល្លារូបនីយកម្មខ្ពស់នៃ សេដ្ឋកិច្ចកម្ពុជា
- ការផ្តល់សេវាសាធារណៈ និងសេវាយុត្តិធម៌នៅមិនទាន់ទទួលបានជំនឿទុកចិត្តពេញលេញពីសំណាក់មហាជន
- ប្រព័ន្ធផ្លូវគមនាគមន៍ គ្រប់ប្រភេទបើប្រៀបធៀបទៅនឹងប្រទេសជិតខាង យើងនៅមាន កម្រិតដូចជាសេវាដឹកជញ្ជូន បញ្ហាសុវត្ថិភាព ការថែទាំនិងជួសជុល
- ថ្លៃថាមពលអគ្គិសនីនៅមានកម្រិតខ្ពស់បើធៀបនឹងប្រទេសជិតខាង
- អនុវត្តប្រព័ន្ធជារាសាស្ត្រនៅមិនទាន់ឆ្លើយតបពេញលេញទៅនឹងតម្រូវការជាំដុះរបស់ប្រជាពលរដ្ឋ
- ធនធានមនុស្សដើម្បីប្រកួតប្រជែងក្នុងបណ្តាប្រទេសក្នុងតំបន់មិនទាន់ឆ្លើយតប
- ការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិនៅមានកម្រិត
- **មានចំណុចត្រឹមត្រូវផ្សេងទៀត**

### កាលានុវត្តភាព(ឱកាស)របស់កម្ពុជានីតិកាលទី៤ នៃរដ្ឋសភា

- ស្ថានភាពភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ច ជាឱកាសមានសម្រាប់ការអភិវឌ្ឍនិងទំនើបកម្មវិស័យឧស្សាហកម្ម ផលិតកម្ម និងសេវាក្នុងតំបន់
- ភាពជាដៃគូរសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក និងបង្កើតឡើងនូវចលនាសេរីភាវូបនីយកម្មពាណិជ្ជកម្ម ទំនិញ សេវា និងការវិនិយោគដ៏ធំក្នុងតំបន់

- ផលលាភប្រជាសាស្ត្រ និងអត្រាទាបនៃអ្នករស់នៅក្នុងបន្ទុកគួបផ្សំនឹងការកើនឡើងនៃចំនួនប្រជាជន ដែលមានចំណូលមធ្យម និងបង្កើតកាលានុវត្តភាព សម្រាប់កម្ពុជាសម្រេច សេដ្ឋកិច្ចខ្ពស់។
- **មានចំណុចត្រឹមត្រូវផ្សេងទៀត**

៥-នៅក្នុងការអភិវឌ្ឍប្រទេស រាជរដ្ឋាភិបាលមានទិសដៅ និងផែនការច្បាស់លាស់។

យុទ្ធសាស្ត្រពីរដែលរាជរដ្ឋាភិបាលបាន និងកំពុងធ្វើគឺយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ។

### ក.យុទ្ធសាស្ត្រត្រីកោណ

- **មុំទីមួយ៖** សន្តិភាវូបនីយកម្មគឺការនាំសុខសន្តិភាព ស្ថិរភាពមកវិញ រក្សាបាននូវសន្តិសុខសម្រាប់ប្រទេស និងប្រជាជនខ្លួន។ ចំណុចទាំងនេះរាជរដ្ឋាភិបាលធ្វើបានសម្រេចហើយ។
- **មុំទីពីរ៖** សមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងសហគមន៍អន្តរជាតិសម្រេចបានជោគជ័យដូចជា៖

1. ប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួននៅអង្គការសហប្រជាជាតិមកវិញដែលអាសនៈនេះបានបាត់បង់កាលពីក្រោយការប្រឈមគ្នាខាងប្រដាប់អាវុធនៅខែកក្កដា ឆ្នាំ១៩៩៧
2. នៅថ្ងៃទី៣០ មេសា ឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាសមាជិកទី១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)។ ការដែលកម្ពុជាបានចូលជាសមាជិកអាស៊ានបានធ្វើឱ្យកម្ពុជាលែងជាប្រទេសឯកោតទៅទៀត។

- ខាងផ្នែកនយោបាយ កម្ពុជាអាចឈរស្មើមុខស្មើមាត់ជាមួយប្រទេសដែលជាសមាជិក និងចូលរួមនូវរាល់ការសម្រេចចិត្តនៅក្នុងតំបន់។
- ខាងផ្នែកសេដ្ឋកិច្ច កម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ។ ការធ្វើពាណិជ្ជកម្មក៏មានភាពងាយស្រួលជាងមុន។ ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្នុងប្រទេស និងក្នុងតំបន់។ ទេសចរក៏មានការកើនឡើង។ ដូច្នេះការចូលជាសមាជិកអាស៊ានក៏ជាផ្នែកមួយដែលជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនជារៀងរាល់ឆ្នាំផងដែរ។
- ខាងផ្នែកទំនាក់ទំនង គឺជំរុញឱ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធនិងផ្លូវថ្នល់ព្រមទាំងការលើកលែងទិដ្ឋាការ។
- ខាងផ្នែកសង្គម កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម។ ការជួយគ្នាទៅវិញទៅមក រវាងប្រទេសសមាជិកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹង អាហារូបករណ៍សម្រាប់និស្សិតបានធ្វើឱ្យមន្ត្រីរាជការ ប្រជាជន និងយុវជនកម្ពុជាបានរៀនសូត្រ និងទទួលបាននូវឱកាសល្អៗជាច្រើន...។

- **មុំទី៣៖** ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចត្រូវធ្វើឡើងតាមរយៈកម្មវិធីកំណែទម្រង់ទូលំទូលាយដែលពាក់ព័ន្ធនឹងកំណែទម្រង់សាធារណៈ រិមជ្ឈការ ការរំសាយកងទ័ពកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ សមភាពយេនឌ័រ ហិរញ្ញវត្ថុសាធារណៈ ការលុបបំបាត់អំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

### ខ. យុទ្ធសាស្ត្រចតុកោណ

ចំណុចស្នូលនៃយុទ្ធសាស្ត្រនេះគឺអភិបាលកិច្ចល្អ។ មកទល់ពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើយុទ្ធសាស្ត្រចតុកោណចំនួនបី ដំណាក់កាល ៖

- ដំណាក់កាលទី១ (២០០៤-២០០៨)
- ដំណាក់កាលទី២ (២០០៨-២០១៣)
- ដំណាក់កាលទី៣ (២០១៣-២០១៨)។

ជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះគឺអាស្រ័យលើការបង្កើតនូវបរិយាកាសអំណោយផលមួយក្នុងផ្នែកសំខាន់ៗទាំងបួន៖

1. សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម
2. ភាពជាដៃគូសម្រាប់ការអភិវឌ្ឍ ជាពិសេសភាពជាដៃគូជាមួយវិស័យឯកជនសហគមន៍ ម្ចាស់ជំនួយ និងសង្គមស៊ីវិល
3. ស្ថិរភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
4. សមាហរណកម្មកម្ពុជាចូលក្នុងតំបន់ និងពិភពលោក។

មុំទាំងបួននៃចតុកោណដែលផ្តោតលើកំណែទម្រង់មាន

- ការលុបបំបាត់អំពើពុករលួយ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ
- កំណែទម្រង់រដ្ឋបាលសាធារណៈរួមទាំងវិមជ្ឈការ និងវិសហមជ្ឈការ
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ជាពិសេសការកាត់រំសាយទ័ព។

មុំទាំងបួននៃចតុកោណសម្រាប់ការបង្កើតកំណើនគឺ

- ការជំរុញវិស័យកសិកម្ម
- ការអភិវឌ្ឍវិស័យឯកជន និងការបង្កើតការងារ
- ការស្តារនីតិសម្បទា និងការស្ថាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ
- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។

## វិញ្ញាសាត្រៀមទី១៩

### ប្រធាន

1. តើរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបង្កើតឡើងនៅថ្ងៃ ខែ ឆ្នាំណា?
2. តើការស្តារឡើងវិញនូវវិស័យនយោបាយរបស់ប្រទេសប៉ូឡូញក្រោយសង្គ្រាមលោកលើកទី២ បានប្រព្រឹត្តទៅយ៉ាងណាខ្លះ?
3. តើនៅពេលបច្ចុប្បន្ននេះដំណើរសមាហរណកម្មនៃសមាគមអាស៊ាន់កំពុងប្រឈមនឹងបញ្ហាសំខាន់ៗអ្វីខ្លះ?
4. តើកត្តាដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំរដ្ឋតែមួយ(សកលភាវូបនីយកម្ម) មានអ្វីខ្លះ?
5. តើប្រាសាទព្រះវិហារបានដាក់ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាថ្ងៃខែឆ្នាំណា? ហើយបានផ្តល់អត្ថន័យយ៉ាងណាសម្រាប់កម្ពុជា?

## អត្រាកំណែ

១-រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបង្កើតឡើងនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨។

២- ការស្តារឡើងវិញនូវវិស័យនយោបាយរបស់ប៉ូឡូញ

- បង្កើតរដ្ឋាភិបាលបណ្តោះអាសន្នឯកភាពជាតិ
- មានការបោះឆ្នោតដោយសេរីដែលពេលនោះពួកកុម្មុយនីស្ត និងអ្នកកាន់អំណាច
- មានការគៀបសង្កត់ទៅលើសាសនា
- មានការជ្រើសរើសពីបរទេសនាំឱ្យមានការរើបំរះពីប្រជាជនប៉ូឡូញដែលមានគំនិតជាតិនិយម។
- បរាជ័យកំណែទម្រង់លោកកូមុលការ ដើម្បីដោះស្រាយ សង្គម និងសេដ្ឋកិច្ចនៅឆ្នាំ១៩៥៦។
- ធ្វើការបង្ក្រាបលើ ចលនារបស់សហជីពរបស់ ឡិចវ៉ាលេសាដោយលោកស៊ីវិច។
- សហភាពសូវៀតធ្វើអន្តរាគមន៍ផ្តួលរំលំសហជីពកម្មករនាសមាជឆ្នាំ១៩៨១ មកពីចលនានេះ រីកសាយពេញផ្ទៃប្រទេស។
- នៅឆ្នាំ១៩៨១មានការបង្កើតច្បាប់អាជ្ញាសឹកដើម្បីចាប់ពួកប្រឆាំង
- ឆ្នាំ១៩៩០-១៩៩៧ ក្លាយទៅជាសាធារណរដ្ឋប្រជាធិបតេយ្យនិងក្លាយជាសមាជិក OTANនិងផ្សារួមអឺរ៉ុប។

៣-នៅពេលបច្ចុប្បន្ននេះ ដំណើរសមាហរណកម្ម នៃសមាគមអាស៊ានកំពុងប្រឈមនឹងបញ្ហាសំខាន់ៗ ដូចជា៖

- **បញ្ហាសេដ្ឋកិច្ច**
  - វិសមភាពរវាងប្រទេសអ្នកមាន និងអ្នកក្រ
  - ប្រាក់បៀវត្សរ៍កម្មករមានគម្លាតគ្នាឆ្ងាយពីប្រទេសមួយទៅប្រទេសមួយទៀត
  - ការនាំចេញ និងនាំចូល
  - ការរីកចម្រើនផ្នែកទំនាក់ទំនងក្នុងវិស័យសេដ្ឋកិច្ច
- **បញ្ហានយោបាយ**
  - មនោគមវិជ្ជា(ប្រទេសខ្លះប្រកាន់របបនយោបាយប្រជាធិបតេយ្យសេរី ប្រទេសខ្លះជាប្រទេសសង្គមនិយម)
  - ការគោរពសិទ្ធិមនុស្ស
  - លទ្ធិប្រជាធិបតេយ្យ
  - បញ្ហាអស្ថិរភាពនយោបាយ
- **បញ្ហាវប្បធម៌**
  - វប្បធម៌១០ អាស៊ាន១
  - សាសនា ដោយឡែកពីគ្នា
  - ការអប់រំនៅមានគម្លាតគ្នាឆ្ងាយ
  - ការប្រកាន់ជាតិសាសន៍ នៅតែមាននៅក្នុងតំបន់
- **បញ្ហាជម្លោះព្រំដែន និងដែនកោះ**
  - បញ្ហាព្រំដែននៃប្រទេសជាសមាជិកមួយចំនួនពុំទាន់បានដោះស្រាយចប់សព្វគ្រប់
  - ជម្លោះដែនកោះនៅក្នុងសមុទ្រចិនខាងត្បូង
  - អធិបតេយ្យភាពរបស់រដ្ឋ
- **បញ្ហាអន្តោប្រវេសន៍៖** ការគាបសង្កត់ពីរដ្ឋអំណាច គ្រឿងញៀន ពេស្យាកម្ម ការរត់ពន្ធ
- **បញ្ហាបរិស្ថាន៖** ការប្រែប្រួលអាកាសធាតុ ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បន្ទុះភ្នំភ្លើង
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-កត្តាដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំរដ្ឋតែមួយ(សកលភាវូបនីយកម្ម)មាន៖

- កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោកដែលជំរុញឱ្យកាន់តែលេចឡើងនូវ អស្ថិរភាព និង ផលវិបាកចំពោះបញ្ហាផ្ទៃក្នុងប្រទេសនិងទំនាក់ទំនងរវាងប្រទេសលើសកលលោក
- បញ្ហារួមជាច្រើនបានកើនឡើងដែលទាមទារមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំរដ្ឋាភិបាលអង្គការអន្តរជាតិនិងសហគមន៍អន្តរជាតិ និងសមាគមអន្តរជាតិ
- មានកំណើនខ្លាំងក្នុងការបំលាស់ទីលំនៅរបស់ប្រជាជនលើពិភពលោក

- មានការរីកចម្រើននូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ
- ការរីកសាយភាយនូវបច្ចេកវិជ្ជាឃោជាទំនើប។

៥-ប្រាសាទព្រះវិហារបានដាក់ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាថ្ងៃ៧ ខែកក្កដា ឆ្នាំ២០០៨។ ប្រាសាទព្រះវិហារជាមរតកវប្បធម៌របស់ខ្មែរ និងមនុស្សទាំងអស់ក្នុងពិភពលោក បានផ្តល់អត្ថន័យសម្រាប់កម្ពុជា៖

- បង្ហាញពីអត្តសញ្ញាណជាតិខ្មែរ
- រក្សាបូរណភាព និងអធិបតេយ្យភាពទឹកដីកម្ពុជា
- បណ្តុះស្មារតីកូនខ្មែរជំនាន់ក្រោយត្រូវចេះស្រឡាញ់ ថែរក្សាវប្បធម៌ និងរក្សាការពារសម្បត្តិវប្បធម៌ដែលជាមរតកបន្សល់ទុករបស់ដូនតា
- បង្ហាញដល់ពិភពលោកពីតម្លៃរបស់កម្ពុជា
- ពិភពលោកទទួលស្គាល់ និងទទួលថែរក្សាការពារសម្រាប់មនុស្សជាតិ
- បង្ហាញពីតម្លៃឯករបស់ផ្នែកស្ថាបត្យកម្ម និងសិល្បៈរបស់ដូនតាខ្មែរ
- បង្ហាញពីឥទ្ធិពលអំណាច និងវិសាលភាពរបស់កម្ពុជានាសម័យមហានគរ
- ផ្តល់កំណើនសេដ្ឋកិច្ចដល់កម្ពុជាតាមរយៈវិស័យទេសចរណ៍
- ផ្តល់ការងារជូនពលរដ្ឋដែលរស់នៅតំបន់នោះ
- បង្ហាញពីទេព្យកោសល្យរបស់ព្រះរាជាខ្មែរនិងពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់នាសម័យនោះ
- មានអត្ថន័យជាប្រវត្តិសាស្ត្រសម្រាប់ពលរដ្ឋខ្មែរ ដែលមានមោទនភាពជាមួយពិភពលោកដែលធ្វើឱ្យជាតិខ្មែរល្បីរន្ទឺ។
- **មានចម្លើយត្រឹមត្រូវផ្សេងទៀត**

# វិញ្ញាសាត្រៀមទី២០

**ប្រធាន**

1. តើនរណាជាប្រធានមន្ទីរសន្តិសុខ **ស.២១**?
2. ប្រាសាទបាយ័ន ឬអង្គរធំ គឺជាប្រាសាទបែបពុទ្ធសាសនា។ ចូរពន្យល់ពីមូលហេតុនៃការគោរពពុទ្ធសាសនាពេលនោះ។
3. តើមានមូលហេតុអ្វីខ្លះ ដែលនាំឱ្យព្រះបាទពញាយ៉ាត ផ្លាស់រាជធានីមកចតុមុខ?
4. តើវិមានឈ្នះ-ឈ្នះបានសម្ពោធថ្ងៃខែឆ្នាំណា? ហើយបានផ្តល់អត្ថន័យយ៉ាងណាខ្លះសម្រាប់កម្ពុជា?
5. តើមូលហេតុអ្វីខ្លះបានជានៅក្រោយសង្គ្រាមលោកលើកទី២ប្រទេសនៅទ្វីបអឺរ៉ុបត្រូវបានបែងចែកជាពីរផ្នែកគឺអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។

# អត្រាកំណែ

១-ប្រធានមន្ទីរសន្តិសុខ ស.២១ គឺលោកកាំង ហ្កេចអ៊ាវ ហៅឌុច។

២-ប្រាសាទបាយ័ន ឬអង្គរធំ គឺជាប្រាសាទបែបពុទ្ធសាសនា។ មូលហេតុនៃការគោរពពុទ្ធសាសនានាពេលនោះ ៖

- នៅមុនរជ្ជកាលរបស់ព្រះបាទជយវរ្ម័ទី៧កើតមាននូវកុបកម្ម ការបះបោរ និងទំនាស់រាជ្យសម្បត្តិ ជាហេតុធ្វើឱ្យមានភាពចលាចល និងអស្ថិរភាពសង្គម
- ការលុកលុយក្រុងអង្គរដោយកងទ័ពចាម្បនៅឆ្នាំ១១៧៧ ជាអន្លងមួយយ៉ាងធ្ងន់វាយទៅលើលទ្ធិទេវរាជ
- ប្រជាជនលែងជឿទៅលើប្រសិទ្ធភាពនៃលទ្ធិទេវរាជ ក្នុងព្រហ្មញ្ញសាសនា
- ប្រជាជនជាច្រើនបានក្លាយជាពុទ្ធសានិករួចស្រេចទៅហើយក្នុងខណៈដែលមន្ត្រីរាជវាំងជឿលើព្រាហ្មណ៍សាសនា
- ដើម្បីស្រោចស្រង់ជាតិឱ្យមានពន្លឺឡើងវិញបន្ទាប់ពីការឈ្លានពានរបស់ចាម្ប នាឆ្នាំ១១៧៧
- ព្រះបាទជយវរ្ម័ទី៧(១១៨១-១២២១) ទ្រង់បានខិតខំរកមធ្យោបាយការពារក្រុងតាមបែបពុទ្ធសាសនាមហាយាន ដែលទ្រង់យល់ថាមានប្រសិទ្ធភាពជាងសាសនារបស់រាជាមុនៗ
- ព្រះបាទជយវរ្ម័ទី៧ទ្រង់ពឹងផ្អែកទៅលើព្រះពោធិសត្វ «អវលោកេស្វរៈ» ដែលពោរពេញដោយធម៌ មេត្តា ករុណា ហើយប្រមើលមើលសុខទុក្ខរបស់សត្វលោក
- លទ្ធិពុទ្ធសាសនាជាលទ្ធិបែបមនុស្សនិយម មានទំនោរទៅរកជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជារាស្ត្រទូទៅ
- ព្រះបាទជយវរ្ម័ទី៧ ជាអ្នករំដោះក្រុងអង្គរពីចាម្ប៉ា ទ្រង់មានមហេសីព្រះនាងជ័យរាជទេវី និងព្រះនាងឥន្ទ្រទេវី ដែលសុទ្ធតែជាអ្នកជ្រះថ្លាក្នុងពុទ្ធសាសនា

- ចំពោះប្រជារាស្ត្រវិញ លទ្ធិពុទ្ធសាសនាមហាយាន មានសមត្ថភាពស្រោចស្រង់ ការពារ និងបម្រើរាស្ត្រ
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

៣-ការផ្លាស់រាជធានីនេះដោយសារៈ

- ព្រះបាទពញាយ៉ាតមានកំណើតនៅខាងត្បូងជាប់ទន្លេមេគង្គទើបព្រះអង្គគ្មានទម្លាប់រស់នៅតំបន់អង្គរ
- ជាភូមិដ្ឋានចាស់៖ ដោយមានប្រជាពលរដ្ឋខ្មែររស់នៅយូរមកហើយ
- ទឹកជំនន់នៅអង្គរ ដែលជាមហន្តរាយធម្មជាតិនៅសតវត្សរ៍ទី១៤ និងដើម១៥ (១៤០០-១៤២០)
- បារាយណ៍យសោធរតេជាកត្រូវរីងស្ងួតដោយការប្រែប្រួលនូវផ្លូវទឹក( តាមការស្រាវជ្រាវិភាគតាមរូបថតពីលើអាកាស)
- គិតពីពាណិជ្ជកម្ម៖អាចទាក់ទងនិងការរីកចម្រើនយ៉ាងឆាប់រហ័សនៃពាណិជ្ជកម្មតាមសមុទ្ររបស់ចិនជាមួយ និងអាស៊ីអាគ្នេយ៍ជាពិសេសជាមួយប្រទេសដីគោកសម័យម៉ុងហ្គោលគ្រប់គ្រងចិន
- ជាតំបន់ដែលអំណោយផលដល់សេដ្ឋកិច្ចនិងជាយុទ្ធសាស្ត្រការពារសត្រូវ
- គិតពីភូមិសាស្ត្រជាទន្លេមុខបួន៖ ចំពោះមុខបួននេះបើគិតតាមទ្រឹស្តីសាសនារបស់ឥណ្ឌាវិញ កន្លែងដែលមានប្រសព្វគ្នាគេចាត់ទុកជាអ្នកតាផ្លូវទឹកដ៏សំខាន់។ បើតាមសាសនាវាជាកន្លែងជ័យភូមិ ដ៏ប្រសើរជាងគេ។ តែតាមលក្ខណៈទេសចរណ៍វាពិតជាអស្ចារ្យដោយជាកន្លែងទឹកហូរទៅហើយត្រឡប់វិញ។
- ដើម្បីបង្កើតស្នាដៃថ្មីសម្រាប់អ្នកជំនាន់ក្រោយ និងជាប្រយោជន៍មួយយូរអង្វែង។
- នៅឆ្ងាយពីអយុធ្យា
- **មានចំណុចត្រឹមត្រូវផ្សេងទៀត**

៤-វិមានឈ្នះ-ឈ្នះបានសម្ពោធថ្ងៃ២៩ខែធ្នូឆ្នាំ២០១៨ ហើយបានផ្តល់អត្ថន័យ សម្រាប់កម្ពុជាដូចជា៖

- **វិស័យនយោបាយ**
  - បង្ហាញពីការបញ្ចប់សង្គ្រាមដ៏រ៉ាំរ៉ៃនៅកម្ពុជា
  - កម្ពុជាមានសុខសន្តិភាព
  - បង្ហាញពីការធានាបាននូវ រូបកាយ អាយុជីវិត ធានាអាជីព និងមុខរបប ការធានាកម្មសិទ្ធិ និងទ្រព្យសម្បត្តិរបស់ពលរដ្ឋ
  - បង្ហាញពីការលះបង់ និងភាពថ្លៃប្រឌិតរបស់អ្នកដឹកនាំដែលនាំមកនូវការបញ្ចប់សង្គ្រាមស៊ីវិល
- **វិស័យសង្គម**
  - បង្ហាញពីការធ្វើសមាហរណកម្ម និងការអភិវឌ្ឍ
  - ពលរដ្ឋកម្ពុជាមានឯកភាពជាតិ
  - មានសុខដុមភាពសាសនា

- បង្ហាញពីការកសាងសមិទ្ធផលនានា
- ជាឧទ្យានកម្សាន្តរបស់ពលរដ្ឋ

**វិស័យវប្បធម៌**

- ជាមជ្ឈមណ្ឌលដែលផ្តល់នូវការសិក្សារៀនសូត្ររបស់ពលរដ្ឋកម្ពុជា
- បង្ហាញពីតម្លៃវប្បធម៌ អរិយធម៌ និងស្ថាបត្យកម្មខ្មែរ

**តម្លៃប្រវត្តិសាស្ត្រ**

- ទុកជាការចងចាំ និងជាមេរៀនសម្រាប់មនុស្សជំនាន់ក្រោយ
- បង្ហាញពីសុខដុមភាពក្នុងប្រវត្តិសាស្ត្រ
- ចារឹកពីសុខដុមភាពផ្នែកនយោបាយ

**មានចំណុចត្រឹមត្រូវផ្សេងទៀត**

៥-ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសនៅទ្វីបអឺរ៉ុបត្រូវបានបែងចែកជាពីរផ្នែក គឺអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។ ការបែងចែកនេះដោយសារមូលហេតុជាច្រើនដូចជាៈ

**ឥទ្ធិពលនៃសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)**

- នៅក្នុងសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើនគ្រប់គ្រងដោយអាល្លឺម៉ង់
- នៅចុងបញ្ចប់នៃសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ត្រូវរំដោះដោយសហភាពសូវៀត និងសហរដ្ឋអាម៉េរិក
- សេដ្ឋកិច្ចទ្វីបអឺរ៉ុបចុះទន់ខ្សោយ ងាយទទួលរងឥទ្ធិពល អឺរ៉ុបត្រូវពឹងផ្អែកលើជំនួយអាម៉េរិក និងសូវៀត

**សន្និសីទក្រុងយ៉ាល់តា និងសន្និសីទ ពតស្តាំ(Potsdam) ឆ្នាំ១៩៤៥ ស្តីពីការបែងចែកទ្វីបអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២**

- ការបែងចែកទឹកដីអាល្លឺម៉ង់ដោយមហាអំណាចទាំងបួន ជាបួនតំបន់កាន់កាប់
- ការបែងចែកទីក្រុងប៊ែរឡាំងជាបួនផ្នែក
- ភាពទ័លច្រកផ្នែកនយោបាយ និងភាពប្រេះឆាគ្នា នៃមហាអំណាចសម្ព័ន្ធមិត្ត ដែលធ្វើឱ្យដំណោះស្រាយពីបញ្ហាអាល្លឺម៉ង់ ត្រូវបរាជ័យ

**ការប្រជែងគ្នារបស់មហាអំណាចពីរគឺ សហរដ្ឋអាម៉េរិក និងសហភាពសូវៀត**

- នៅក្នុងសង្គ្រាម មហាអំណាចសហរដ្ឋអាម៉េរិក អង់គ្លេស និងសហភាពសូវៀត បានរួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងណាស៊ីអាល្លឺម៉ង់ តែមហាអំណាចទាំងនេះមានលក្ខណៈប្លែកគ្នាទាំងស្រុង ទាំងផ្នែកមនោគមវិជ្ជានយោបាយ និងសេដ្ឋកិច្ច
- ការមិនទុកចិត្តគ្នារវាងសហរដ្ឋអាម៉េរិក និងសហភាពសូវៀតនៅចុងបញ្ចប់នៃសង្គ្រាម
- ការប្រជែងមនោគមវិជ្ជា នយោបាយ បែបប្រជាធិបតេយ្យសេរី និងកុម្មុយនីស្ត
- ការប្រជែងផ្នែកសេដ្ឋកិច្ច តាមបែបមូលធននិយម និងសង្គមនិយម
- ការប្រជែងផ្នែកសព្វាវុធ អាវុធនុយក្លេអ៊ែរ ព្រមទាំងការប្រជែងបច្ចេកវិជ្ជា និងការទូត

- នៅចុងសង្គ្រាមឥទ្ធិពលកុម្មុយនីស្តបានរីករាលដាលយ៉ាងរហ័សនៅអឺរ៉ុប ធ្វើឱ្យមានការប្រជែងពីអាម៉េរិក
- អឺរ៉ុបប៉ែកខាងកើតត្រូវរំដោះដោយសូវៀតក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានធ្លាក់ក្រោមឥទ្ធិពលកុម្មុយនីស្តសូវៀត និងក្រោយមកប្រកាន់យករបបកុម្មុយនីស្តតាមបែបសូវៀត
- អឺរ៉ុបខាងលិចត្រូវបានរំដោះដោយអង់គ្លេស និងសហរដ្ឋអាម៉េរិកក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានប្រកាន់យករបបប្រជាធិបតេយ្យសេរី

**ទ្រឹស្តីទ្រូម៉ាន់ និងផែនការម៉ាសាល ឆ្នាំ១៩៤៧ ៖ អាម៉េរិក អនុវត្តនយោបាយទប់ទល់ និងរុញច្រានរបបកុម្មុយនីស្ត។**

## វិញ្ញាសាត្រៀមទី២១(ដកស្រង់)

**ប្រធានទី១**

កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ត្រូវបានភាគីខ្មែរទាំងបួន និងប្រទេសមួយចំនួនចុះហត្ថលេខានាថ្ងៃទី២៣ តុលា ឆ្នាំ១៩៩១។ ចូររៀបរាប់ អធិប្បាយ និងវិភាគៈ

- អំពីការវិវត្តនយោបាយក្នុងនិងក្រៅប្រទេសដែលនាំអោយឈានឆ្ពោះទៅរកកិច្ចព្រមព្រៀងនេះ
- ទិដ្ឋភាព និងខ្លឹមសារនៃកិច្ចព្រមព្រៀង
- ការអនុវត្តកិច្ចព្រមព្រៀង និងលទ្ធផលផ្តល់ចំពោះកម្ពុជា។

I-ការអនុវត្តនយោបាយក្នុង និងក្រៅប្រទេសដែលនាំឱ្យឈានឆ្ពោះទៅរកកិច្ចព្រមព្រៀង

១.សេចក្តីផ្តើម

- វត្តមានកងទ័ពវៀតណាមនៅកម្ពុជា
- ចលនាតស៊ូ នៅតាមព្រំដែនប្រទាំងយៀកណាម

២.កម្លាំងដែលប្រឈមមុខ

- ចលនាតស៊ូ: FUNCINPEC,FNLPK,KD(GCKD)
- រដ្ឋកម្ពុជា និងយៀកណាម
- គោលជំហររបស់ក្រុមនីមួយៗ

៣.ការដួលរលំរបបកុម្មុយនីស្ត

- ការដួលរលំជញ្ជាំងប៊ែរឡាំង(១៩៨៩)
- ការកែប្រែនយោបាយរបស់យៀកណាម( Doi Moi)

II-ទិដ្ឋភាព និងខ្លឹមសារនៃកិច្ចព្រមព្រៀង

១.ការកែប្រែឥរិយាបទរបស់រដ្ឋកម្ពុជា និងយៀកណាម

២.កិច្ចប្រជុំនៅទីក្រុងប៉ារីសជាលើកដំបូង(CIPC)

- JIM (Jakarta Informal Meeting)

៣.កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ក្រោមអធិបតីភាពប្រទេសបារាំង និងឥណ្ឌូនេស៊ីៈ

- ការប្រគល់សិទ្ធឱ្យ UNTAC ឬ APRONUC គ្រប់គ្រងប្រទេសកម្ពុជា
- ការបញ្ចប់សង្គ្រាម រៀបចំការបោះឆ្នោត បង្កើតស្ថាប័នប្រជាធិបតេយ្យសម្រាប់កម្ពុជា ការពារសិទ្ធិមនុស្ស និងសេរីភាព។
- ការធ្វើមាតុភូមិនិវត្តន៍ជនភៀសខ្លួនខ្មែរ ដែលរស់នៅតាមជំរុំក្នុងប្រទេសថៃ
- ការរៀបចំស្ថាបនាកម្ពុជា ដែលថ្ងៃក្រោយក្លាយទៅជាICORC

៤.ការផ្ទេរអំណាច និងគ្រប់គ្រងកងទ័ព

ក.ក្រសួង៥ដែលត្រូវគ្រប់គ្រងដោយអ៊ុនតាក់

ខ.កងទ័ពទាំងគ្រប់ភាគី(៧០%)ត្រូវប្រមូលផ្ដុំតាមបន្ទាយ

III-ការអនុវត្តកិច្ចព្រមព្រៀង

១.ក្រសួងទាំងប្រាំមិនបានប្រគល់ឱ្យអ៊ុនតាក់

២.កងទ័ពទាំង៤ភាគីមិនបានប្រមូលផ្ដុំតាមគម្រោង

៣.កងទ័ពខ្មែរក្រហមបានគំរាមកំហែងនឹងបន្តសង្គ្រាម

៤.ការបោះឆ្នោត(ឧសភា ១៩៩៣)

- គណៈបក្សនយោបាយចំនួន២០បានចូលរួម
- កម្ពុជាប្រជាធិបតេយ្យមិនបានចូលរួម
- គ្មានផលវិបាកក្នុងដំណើរការបោះឆ្នោត

៥.លទ្ធផលនៃការបោះឆ្នោត(ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៣): ១២០កៅអី

- FUNCINPECបានសម្លេងលើសគេ
- PPCជាបន្ទាប់
- ប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា
- ម៉ូលីណាកា

IV-លទ្ធផល

១.សភាធម្មនុញ្ញ(ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៣)

២.ប្រកាសរបស់រដ្ឋសភាថ្ងៃទី១៨ខែមិថុនាឆ្នាំ១៩៩៣ ទទួលស្គាល់សម្ដេចនរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋកម្ពុជាជារៀងរហូតពីមុនឆ្នាំ១៩៧០មកដល់បច្ចុប្បន្ននិងប្រគល់គ្រប់អំណាច និងបុព្វសិទ្ធដល់ព្រះអង្គ។

៣.រដ្ឋាភិបាលបណ្ដោះអាសន្ន

- មានការចូលរួមពីគ្រប់និន្នាការ
- មិនបានដំណើរការ

៤.រដ្ឋធម្មនុញ្ញ(២៤ កញ្ញា ១៩៩៣)

៥.រាជានិយមបានវិលត្រឡប់មកវិញៈ សម្ដេចសីហនុបានតែងតាំងជាព្រះមហាក្សត្រកម្ពុជា។

**យោបល់រួម**

- ស្តីពីដំណើរការរបស់រដ្ឋាភិបាលចម្រុះ ៖ វិជ្ជមាន ឬអវិជ្ជមាន
- ផ្នែកសិទ្ធមនុស្ស។

## ប្រធានទី២

សង្គ្រាមឥណ្ឌូចិនទាំងបីលើក៖ ដំណើរប្រព្រឹត្តទៅនៃសង្គ្រាមនីមួយៗ គូប្រយុទ្ធសំខាន់ៗនៅក្នុងសង្គ្រាមនីមួយៗនិងផលប៉ះពាល់នៃសង្គ្រាមនីមួយៗនោះមកលើកម្ពុជា។

## សេចក្តីផ្តើម

ចាប់ពីឆ្នាំ១៩៤៥ ពួកមហាអំណាចអង់គ្លេស អាល្លឺម៉ង់ និងបារាំងមានបំណងពង្រីកឥទ្ធិពលមកលើរដ្ឋនានានៅអាស៊ីអាគ្នេយ៍ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់ខ្លួនពីមុនសង្គ្រាមលោកលើកទី២។ នៅខែកក្កដា ចក្រភពជប៉ុន សហរដ្ឋអាម៉េរិក អង់គ្លេស និងចិនបានបែងចែកតំបន់ត្រួតត្រាខាងផ្នែកយោធា។ និន្នាការនេះជំរុញ វៀតណាម ដែលប្រឈមនឹងការកាន់កាប់របស់ប្រទេសចិន ឱ្យរៀបចំបង្កើតរណសិរ្សជាតិ ដឹកនាំដោយគណៈបក្សកុម្មុយនីស្តឥណ្ឌូចិន ក្នុងការកាន់កាប់រដ្ឋអំណាចទូទៅនៅប្រទេសវៀតណាម។

## I-ដំណើរប្រព្រឹត្តទៅនៃសង្គ្រាមឥណ្ឌូចិន ចែកជាបីដំណាក់

១-សង្គ្រាមឥណ្ឌូចិនលើកទី១៖១៩៤៦-១៩៥៤

- ថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៤៥: ការប្រកាសសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម នៅទីក្រុងហាណូយ។ នៅពេលនោះកងទ័ពចិនស្ថិតក្រោមបញ្ជាការឧត្តមសេនីយ Siao Wai មានចំនួន ១៨០.០០០នាក់បានតាំងទីនៅទីក្រុងហាណូយ(៩កញ្ញា)។ ចំណែកកងទ័ពអង់គ្លេសស្ថិតក្រោមបញ្ជាការ Douglas Gracey ចូលកាន់ទីក្រុងព្រៃនគរ(១៣កញ្ញា)។ ចំណែកបារាំងបានប្រគល់ភារកិច្ចឧត្តមនាវី George Thierry d'Argenlieu ទទួលបន្ទុក ឥណ្ឌូចិន ហើយបន្ទាប់មកឧត្តមសេនីយ៍ Phillippe Leclerc ដែលបញ្ជាទ័ពនៅចុងបូព៌ា បានមកដល់ទីក្រុងព្រៃនគរនៅថ្ងៃទី៥តុលា។ ឥរិយាបទនៃរដ្ឋាភិបាលបារាំង របស់ឧត្តមសេនីយ៍De Gaulles ដែលមិនព្រមទទួលស្គាល់ការប្រកាសឯករាជ្យ និងការបង្រួបបង្រួមប្រទេសវៀតណាម និងការប្រើកម្លាំងបង្ក្រាបចលនាទាមទារទាំងនេះធ្វើឱ្យកើតមានសង្គ្រាមឥណ្ឌូចិន។ ការប្រកាសធ្វើកុបកម្ម របស់គណៈកម្មការភាគខាងត្បូងវៀតណាមជំរុញឱ្យអាជ្ញាធរ បារាំង ប្រកាសបំរាមគោចរនៅទីក្រុងព្រៃនគរ-ចឺឡឺន និងច្បាប់ប្រទេសស្ថិតនៅក្នុងសង្គ្រាមទូទាំងឥណ្ឌូចិននៅភាគខាងត្បូងខ្សែស្របទី១៦នៅថ្ងៃទី២១ ខែកញ្ញា។ ថ្ងៃទី២៣ ខែកញ្ញា កងទ័ពចម្រុះបារាំង អង់គ្លេស បានចូលលុកសណ្ឋាគារព្រៃនគរ ដែលជា ទីស្នាក់ការរបស់គណៈកម្មការភាគខាងត្បូង។ សមាជិកនៃគណៈកម្មការខាងត្បូង ដែលបានភៀសខ្លួនរួចបានបន្តការតស៊ូនៅជនបទ ជាហេតុនាំឱ្យសង្គ្រាមទ័ពព្រៃផ្ទុះឡើង។

ចំណែកនៅវៀតណាមភាគខាងជើងខ្សែស្របទី១៦ ក៏មានសកម្មភាពប្រឆាំងនឹងកងទ័ពបារាំងជាបន្តបន្ទាប់៖

- ថ្ងៃទី២៣ ខែវិច្ឆិកា បារាំងបានទម្លាក់គ្រាប់បែកលើទីក្រុង ហៃហ្វុង ធ្វើឱ្យអ្នកតស៊ូ និងប្រជាជនស៊ីវិលស្លាប់អស់ជាច្រើនជាហេតុបង្កភ្លើងសង្គ្រាមឥណ្ឌូចិនឱ្យឆេះកាន់តែខ្លាំង។ ឧត្តមសេនីយ៍ Grap បានរៀបចំ រាំងស្ទាក់ផ្លូវហៃហ្វុង-ហាណូយ។

- ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៤៦៖ សកម្មភាពប្រឆាំងកងទ័ពបារាំងពីសំណាក់វៀតមិញនៅទីក្រុងហាណូយ។
- ខែកុម្ភៈ ឆ្នាំ១៩៤៧៖ បារាំងកាន់កាប់ទីក្រុងហាណូយ
    - ហូជីមិញប្រកាសធ្វើសង្គ្រាមតស៊ូប្រឆាំងនឹងបារាំង
    - គាំទ្រការតស៊ូរបស់សឹងង៉ុកថាញ់នៅកម្ពុជា
    - គាំទ្រការតស៊ូរបស់អ្នកអង្គម្ចាស់សុផាណាវង្សនៅឡាវ
- ឆ្នាំ១៩៤៩៖ ជ័យជំនះរបស់ពួកកុម្មុយនីស្តនៅប្រទេសចិន
- ឆ្នាំ១៩៥០៖ ជម្លោះនៅកូរ៉េ
    - នាំឱ្យប្រទេសនានានៅឥណ្ឌូចិនចូលរួមក្នុងសង្គ្រាមត្រជាក់
    - ចាប់ពីនេះចិនគាំទ្រផ្នែកយោធាដល់ពួកវៀតមិញ
    - សហរដ្ឋអាម៉េរិកគាំទ្រផ្នែកហិរញ្ញវត្ថុដល់ប្រទេសបារាំង
- ខែមីនា ឆ្នាំ១៩៥៤ ទ័ពវៀតមិញ វាយឡៀនបៀនភូ
- ថ្ងៃទី៧ខែឧសភា ឆ្នាំ១៩៥៤៖ ទ័ពវៀតមិញបាន វាយបានឡៀនបៀនហ្វូ។
- ខែកក្កដាឆ្នាំ១៩៥៤៖ សន្និសីទហ្សឺណែវបានបញ្ចប់ដោយចែកប្រទេសវៀតណាមជាពីរដែលមានព្រំដែនស្ថិតនៅតាមខ្សែស្របទី១៧។

២-សង្គ្រាមឥណ្ឌូចិនលើកទី២៖១៩៦២-១៩៧៥

- ឥទ្ធិពលសង្គ្រាមឥណ្ឌូចិនលើកទី២គឺតាំងពីឆ្នាំ១៩៥៥ក្រោយពេលការបង្កើតSEATO
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៦១ លោកកេណ្ណឺឌី ប្រធានាធិតីសហរដ្ឋអាម៉េរិក អនុញ្ញាតឱ្យបញ្ជូន កងកុំម៉ង់ដូប្រឆាំងទ័ពព្រៃមកកាន់វៀតណាម។
- ឆ្នាំ១៩៦២៖ អាម៉េរិកត្រៀមធ្វើសង្គ្រាមនៅវៀតណាម ដោយតាំងទីបញ្ជាការសឹកនៅក្រុងព្រៃនគរ។
- ឆ្នាំ១៩៦៣៖ អាម៉េរិកបញ្ជូនកងទ័ពគាំទ្ររដ្ឋាភិបាល ង៉ូ ឌិញយៀម។
- ពីខែមករាឆ្នាំ១៩៦៤៖ អាម៉េរិកចាប់ផ្ដើមធ្វើសង្គ្រាមទ្រង់ទ្រាយធំ
- ឆ្នាំ១៩៦៧៖ ចំនួនកងទ័ពអាម៉េរិកដែលមកធ្វើសង្គ្រាមនៅវៀតណាមបានកើនឡើងជាងកន្លះលាននាក់។
- ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៦៨៖ មានការវាយលុកចូលទីក្រុងព្រៃនគរនៅពេលបុណ្យចូលឆ្នាំតែត្រូវបរាជ័យ។
- ចាប់ពីឆ្នាំ១៩៦៨៖ មានការស្នើចរចាដើម្បីបញ្ចប់សង្គ្រាមវៀតណាម
- ខែមករា ឆ្នាំ១៩៧៣៖ មានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស តែសង្គ្រាមនៅតែបន្តនៅឥណ្ឌូចិនរហូតដល់ខែមេសាឆ្នាំ១៩៧៥។

៣-សង្គ្រាមឥណ្ឌូចិនលើកទី២(១៩៧៨-១៩៩១)

- ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥៖ ពួកខ្មែរក្រហមឡើងកាន់អំណាចនៅកម្ពុជាដោយអនុវត្តនយោបាយប្រល័យពូជសាសន៍។
- ថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៨ការបង្កើតរណសិរ្សសង្គ្រោះជាតិ
- ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩៖ ជោគជ័យនៃរណសិរ្សសង្គ្រោះជាតិកម្ពុជាលើរដ្ឋអំណាចខ្មែរក្រហម។
- ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៩៖ កងទ័ពចិនវាយប្រហារលើវៀតណាម សង្គ្រាមឥណ្ឌូចិនបានផ្ទុះឡើងវិញ។

II-គូរប្រយុទ្ធសំខាន់ៗនៃសង្គ្រាមឥណ្ឌូចិន

**១-សង្គ្រាមឥណ្ឌូចិនលើកទី១**

- នៅប្រទេសវៀតណាម៖ ប្រទេសបារាំងទល់នឹងវៀតណាមការចុះចាញ់របស់ប្រទេសជប៉ុនក្នុងសង្គ្រាមលោកលើកទី២ និងដោយមានការព្រមព្រៀងពីប្រទេសចិន ដែលបានដកទ័ពថយពីប្រទេសវៀតណាម(តាមកិច្ចព្រមព្រៀងថ្ងៃទី២៨ កុម្ភៈឆ្នាំ១៩៤៦)។ ប្រទេសបារាំងបានមកជំនួសកងទ័ពកូមិញតាង នៅពាក់កណ្តាលខែមីនាដោយអនុញ្ញាតឱ្យប្រទេសចិនស្ថិតនៅក្នុងតំបន់សេរីហៃហ្វុងនិងទទួលស្គាល់កម្មសិទ្ធិចិនតាមបណ្តោយផ្លូវដែក យុនណាន។ ការមិនឯកភាពគ្នាតាមកិច្ចចរចាចាប់តាំងពីខែធ្នូឆ្នាំ១៩៤៥លើបញ្ហាឯកភាពនៃប្រទេសវៀតណាម(តុងកឹង-អាណ្ណាម និងកូសាំងស៊ីន)បញ្ហាឯករាជភាពនៃប្រទេសវៀតណាម(ស្នើដោយវៀតណាម) និងបញ្ហាពង្រឹងអំណាចត្រួតត្រាបារាំងលើសហភាពឥណ្ឌូចិនធ្វើឱ្យមានដំណោះស្រាយតាមផ្នែកយោធា រវាងភាគីបារាំង និងវៀតណាម។
- នៅប្រទេសកម្ពុជា៖ប្រទេសបារាំងទល់នឹងខ្មែរឥស្សរៈ បន្ទាប់មកបារាំងគាំទ្រព្រះបាទនរោត្តម សីហនុ រំលាយរដ្ឋាភិបាលប្រជាធិបតេយ្យកម្ពុជា។ ចលនាខ្មែរឥស្សរៈក៏បានងើបប្រឆាំងរដ្ឋាភិបាលខ្មែរ និងបារាំង។
- **នៅប្រទេសឡាវ៖** ប្រទេសបារាំងទល់ និងឡាវឥស្សរៈ ចំណែកនៅឡាវក៏មានឡាវឥស្សរៈប្រឆាំងនឹងបារាំងដែរ។

**២-សង្គ្រាមឥណ្ឌូចិនលើកទី២**

- **នៅប្រទេសវៀតណាម៖** អាម៉េរិកជាមួយវៀតកុង
- **នៅប្រទេសកម្ពុជា៖** សាធារណរដ្ឋខ្មែរជាមួយខ្មែរក្រហម
- **នៅប្រទេសឡាវ៖** ឡាវសេរីជាមួយប៉ាថេតឡាវ

**៣-សង្គ្រាមឥណ្ឌូចិនលើកទី៣**

- **នៅប្រទេសវៀតណាម៖** ចិនទល់នឹងវៀតណាម
- **នៅប្រទេសកម្ពុជា៖** សាធារណរដ្ឋប្រជាមានិតកម្ពុជានិងកម្ពុជាប្រជាធិបតេយ្យបន្ទាប់មករដ្ឋាភិបាលចម្រុះត្រីភាគី។

III-ផលប៉ះពាល់មកលើប្រទេសកម្ពុជា

**១-សង្គ្រាមឥណ្ឌូចិនលើកទី១**

- ថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥៖ ប្រទេសកម្ពុជាប្រកាសឯករាជ្យ
- ឥទ្ធិពលជប៉ុន(សឺង ង៉ុកថាញ់)
- យុទ្ធសាមគ្គីនៃប្រទេសទាំងបីនៅឥណ្ឌូចិន(កម្ពុជា វៀតណាម ឡាវ)នាំឱ្យមានកម្លាំងប្រយុទ្ធ។
- អំណោយផលដល់ព្រះរាជបូជនីយកិច្ច
- ការប្រកាសឯករាជ្យថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣
- ក្រោយសន្និសីទហ្សឺណែវ កម្ពុជាមានឯកភាពទឹកដី

**២-សង្គ្រាមឥណ្ឌូចិនលើកទី២**

- ឆ្នាំ១៩៦៣ មេខ្មែរក្រហមរត់ចូលព្រៃ
- ឆ្នាំ១៩៦៧ ឧទ្ទាមកម្មនៅសំឡូត
- ឆ្នាំ១៩៧០ ការផ្ទុះនៅសង្គ្រាមនៅកម្ពុជា ក្រោយព្រឹត្តិការណ៍១៨មីនា
- ពីឆ្នាំ១៩៧០-១៩៧៥ សង្គ្រាមរវាងកងទ័ពសាធារណរដ្ឋនិងកងទ័ពរំដោះ
- មកទល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៣ ការទម្លាក់គ្រាប់បែករបស់អាម៉េរិកមកលើប្រទេសកម្ពុជា។
- ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមឡើងកាន់អំណាចនៅកម្ពុជា ដោយអនុវត្តនយោបាយប្រល័យពូជសាសន៍។
- សាធារណមតិអន្តរជាតិបានចាត់ទុកថាជាសង្គ្រាមវៀតណាម ប៉ុន្តែវិនាសកម្មនៅកម្ពុជាមានទំហំធំធេង។

**៣-សង្គ្រាមឥណ្ឌូចិនលើកទី៣**

**នៅប្រទេសកម្ពុជា**

- ៧ មករា ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារំដោះទីក្រុងភ្នំពេញ។
- ការតស៊ូរវាងសាធារណរដ្ឋប្រជាមានិតទល់នឹងកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម-រាជរដ្ឋាភិបាលចម្រុះត្រីភាគី)។
- ឆ្នាំ១៩៨៧ ការចាប់ផ្តើមចរចាបញ្ចប់សង្គ្រាមនៅកម្ពុជា
- ២៣ តុលា ១៩៩១ កិច្ចព្រមព្រៀងក្រុងប៉ារីស
- ឆ្នាំ១៩៩៣ ការបោះឆ្នោតក្រោមការឧបត្ថម្ភនៃអង្គការសហប្រជាជាតិ(UNTAC) ដើម្បីជ្រើសរើសរដ្ឋសភានិតិកាលទី១និងការចាប់ផ្តើមនៃព្រះរាជាណាចក្រកម្ពុជាលើកទី២។

## សេចក្តីសន្និដ្ឋានរួម

សង្គ្រាមឥណ្ឌូចិនបានផ្តល់ផលវិបាកយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនកម្ពុជា នៅរយៈពេល៦ខែក្រោយថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៣ ការទម្លាក់គ្រាប់បែកលើប្រទេសកម្ពុជាមានទំហំច្រើនជាងការទម្លាក់គ្រាប់បែកនៅជប៉ុននៅក្នុងសង្គ្រាមលោកលើកទី២។ សង្គ្រាមនេះមិនគ្រាន់តែបំផ្លាញជីវិត ទ្រព្យសម្បត្តិ និងធនធានរបស់ប្រជាជនស្លូតត្រង់កម្ពុជាប៉ុណ្ណោះទេ តែជាកត្តាជំរុញអោយខ្មែរក្រហមបានទទួលជោគជ័យលើរបបសាធារណរដ្ឋខ្មែរ ហើយឡើងកាន់អំណាចដោយអនុវត្តនយោបាយប្រល័យពូជសាសន៍ និងបំផ្លាញជីវិតប្រជាជនស្លូតត្រង់កម្ពុជាអស់រាប់លាននាក់ថែមទៀត។

## ប្រធានបទទី៣

ចូរអធិប្បាយពីសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា(១៩៧៩-១៩៩៣)។

### អធិប្បាយ

**I-ការរំដោះប្រទេសកម្ពុជាពីរបបកម្ពុជាប្រជាធិបតេយ្យ**

**១. កំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា**

- នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ក្នុងមូលដ្ឋានតស៊ូក្នុងស្រុកស្នួល ខេត្តក្រចេះមហាសន្និបាត បានប្រារព្ធឡើងដោយមានតំណាងកម្លាំងរំដោះគ្រប់តំបន់ទូទាំងប្រទេសចូលរួម។
- មហាសន្និបាតបានសម្រេចជាឯកច្ឆន្ទបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការមជ្ឈិមរណសិរ្សដែលមានសមាជិក ១៤រូប ក្នុងនោះ លោកហេង សំរិន ជាប្រធាន។
- មហាសន្និបាតបានអនុម័តកម្មវិធីនយោបាយដូចតទៅៈ
  - គោរពឆន្ទៈ និងគោលបំណងរបស់ប្រជាពលរដ្ឋ
  - ផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ
  - កសាងប្រទេសកម្ពុជាប្រកបដោយឯករាជ្យ សន្តិភាព សេរីភាព និងសុភមង្គល។

**២. ជ័យជម្នះថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩**

- ដោយមានជំនួយពីកងទ័ពវៀតណាមនិងការគាំទ្រពីប្រជាជនកម្ពុជា នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨
- នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ភ្នំពេញត្រូវបានរំដោះ
- កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមប្រើរយៈពេលបីសប្តាហ៍ក្នុងការរំដោះប្រទេសកម្ពុជាស្ទើរតែទាំងស្រុង។

**II-សាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩)**

- នៅថ្ងៃទី៧ខែមករា ឆ្នាំ១៩៧៩ របបថ្មីមួយដែលបានចាប់បដិសន្ធិឡើងក្រោមជំនួយឧបត្ថម្ភពីកម្លាំងកងទ័ពវៀតណាម គឺរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។
- កិច្ចការចាំបាច់ចំនួនពីរដែលរដ្ឋាភិបាលថ្មីមួយនេះត្រូវធ្វើ គឺការកសាងសន្តិភាព និងការស្តាបនាជាតិឡើងវិញ។

**១. អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា**

របបថ្មីនេះគ្រប់គ្រងដោយបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជានិងមានអង្គការគ្រប់គ្រងសំខាន់ៗចំនួន៤គឺ ៖

- គណបក្សប្រជាជនបដិវត្តន៍កម្ពុជាដឹកនាំដោយលោក ប៉ែន សុវណ្ណ នៅខែធ្នូ ឆ្នាំ ១៩៨១ លោក ហេង សំរិន បានកាន់តំណែងនេះជំនួសវិញ

- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រីមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យសម្រេច ទិសដៅសំខាន់ៗរបស់បក្ស។ ក្រុមប្រឹក្សានេះមានលោក ប៉ែន សុវណ្ណ ជាប្រធាន។ ចុងឆ្នាំ១៩៨១លោក ចាន់ ស៊ីបានឡើងជំនួសលោកប៉ែន សុវណ្ណ។

ក្រុមប្រឹក្សារដ្ឋមន្ត្រីត្រូវកំណត់ការប្រជុំយ៉ាងទៀងទាត់ដើម្បីៈ

- ចាត់វិធានការរដ្ឋបាលយ៉ាងច្បាស់លាស់សម្រាប់រដ្ឋមន្ត្រីយកទៅផ្សព្វផ្សាយតាមក្រសួង មន្ទីរនានាចៀសវាងការអនុវត្តខុសទិសដៅ
- ឱ្យតំណាងក្រសួងនីមួយៗឡើងរាយការណ៍បង្ហាញពីសមិទ្ធផល និងបញ្ហាផ្សេងៗដែលកើតមាន។

- ក្រុមប្រឹក្សារដ្ឋ ដែលមានលោក ហេង សំរិន ជាប្រធាន
- រដ្ឋសភាជាតិ មាន១១៧អាសនៈ។ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៨១ សភាជាតិបានអនុម័តរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងតែងតាំងលោក ហេង សំរិន ជាប្រធានក្រុមប្រឹក្សារដ្ឋ លោក ប៉ែនសុវណ្ណ ជាប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី។

### ២. សមាសភាពអ្នកគ្រប់គ្រង

**រដ្ឋអំណាចខ្មែរ**

ក្នុងដំណាក់កាលដំបូង ក្រសួងសំខាន់ៗកាន់កាប់ដោយមនុស្សពីរក្រុមគឺៈ

- ក្រុមអ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ា ពិសេសមកពីខេត្តកំពង់ចាម ស្វាយរៀង
- ក្រុមអ្នកបានទៅហាត់រៀននៅប្រទេសវៀតណាមក្រោយសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤។

**ជំនាញការ និងកងទ័ពវៀតណាម**

- នៅក្នុងដំណាក់កាលនេះ មានវត្តមានកងទ័ពវៀតណាមនៅពាសពេញផ្ទៃប្រទេសដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍ប៉ុលពត
- អ្នកជំនាញការវៀតណាមជាច្រើនរូបដែលធ្វើការអមរដ្ឋអំណាចខ្មែរតាំងពីថ្នាក់ក្រសួង រហូតដល់ថ្នាក់មូលដ្ឋានដើម្បីជួយពង្រឹងរដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា។

## III-ការកសាងសន្តិភាព និងការកសាងជាតិឡើងវិញ

### ១. ខ្មែរទាំង៤ភាគី

**ភាគីទី១** គឺរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលដឹកនាំដោយហេង សំរិន

**ភាគីទី២** គឺកម្ពុជាប្រជាធិបតេយ្យ ឬខ្មែរក្រហម ដែលដឹកនាំដោយប៉ុល ពត

**ភាគីទី៣** គឺរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរប្រជាធិបតេយ្យ ដែលដឹកនាំដោយ សឺន សាន

**ភាគីទី៤** គឺក្រុមរាជានិយមរបស់សម្តេច នរោត្តម សីហនុ(FUNCINPEC-ហ្វ៊ុនស៊ិនប៉ិច)

នៅឆ្នាំ១៩៨២ ក្រុមខ្មែរក្រហម(ភាគីទី២) ក្រុមសឺន សាន(ភាគីទី៣) និងក្រុមរាជានិយម (ភាគីទី៤)**បានរួបរួមគ្នាបង្កើតជារដ្ឋាភិបាលសម្ព័ន្ធត្រីភាគី** ហើយដឹកនាំដោយសម្តេចនរោត្តម សីហនុ។ គោលជំហររបស់រដ្ឋាភិបាលត្រីភាគីនេះ គឺប្រឆាំងនឹងវត្តមានវៀតណាមនៅកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា(ភាគីទី១) តាមរយៈការទូត និងសង្គ្រាមឈ្លប។

## ២. សង្គ្រាមក្នុងស្រុក

- ក្រុមខ្មែរក្រហមដែលនៅសេសសល់លាក់ខ្លួននៅតាមតំបន់ព្រៃក្រាស់ដែលពិបាកចូលទៅដល់។
- ពួកគេតែងធ្វើសកម្មភាពជាក្រុមតូចៗក្នុងទ្រង់ទ្រាយជាសង្គ្រាមឈ្លប ដើម្បីឆក់ប្លន់ស្បៀង អុកឡុកបង្កអសន្តិសុខដល់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងផ្តួលរំលំរដ្ឋអំណាចភូមិ ឃុំ ក្នុងគោលបំណងវិលមកកាន់អំណាចឡើងវិញ។
- តាមបណ្តោយព្រំដែនខ្មែរ-ថៃ និងជុំវិញបឹងទន្លេសាបបានក្លាយទៅជាតំបន់អសន្តិសុខ រីឯតំបន់ផ្សេងទៀតក្រៅពីនោះ ក៏រងការគំរាមកំហែងជាញឹកញាប់ផងដែរ។

## ៣. ការទប់ស្កាត់ការវិលត្រឡប់របស់ពួកខ្មែរក្រហម

### ការរំដោះតំបន់នៅតាមព្រំដែន

- មូលហេតុដែលរដ្ឋាភិបាលត្រូវដកទ័ពត្រលប់មកវិញនៅរដូវវស្សាគឺ ៖
  - ប្រព័ន្ធផ្លូវថ្នល់មានការលំបាកខ្លាំង ពិបាកក្នុងការដឹកជញ្ជូនផ្គត់ផ្គង់ស្បៀង និងសព្វាវុធ
  - កម្លាំងនៅសមរភូមិក្រោយនៅមិនទាន់រឹងមាំដែលទាមទារការដកកម្លាំងពីព្រំដែនឬសមរភូមិមុខមកពង្រឹង។
- នៅឆ្នាំ១៩៨៤ កងកម្លាំងនៅសមរភូមិក្រោយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាមានការរីកចម្រើនច្រើនដែលអាចបន្តវាយលុកនៅរដូវវស្សា និងការពារទីតាំងដែលដណ្តើមបានកាលពីរដូវប្រាំង។

### ផែនការ ក៥

- នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៨៤ ការិយាល័យនយោបាយមជ្ឈិមបក្សបានចេញសេចក្តីសម្រេចចិត្តមួយស្តីពីការបង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃដោយឱ្យឈ្មោះថា «ផែនការ ក៥»
- ផែនការនេះតម្រូវឱ្យមានការចូលរួមពីប្រជាជនខ្មែរដើម្បីៈ
  - សាងសង់ផ្លូវនៅតាមព្រំដែនដើម្បីសម្រួលក្នុងការដឹកជញ្ជូនកងទ័ព អាវុធស្បៀង ជាដើម។
  - កាប់ឆ្ការព្រៃនៅក្បែរភូមិ ជុំវិញផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក តាមជនបទ និងតាមតំបន់ព្រំដែនដើម្បីបំផ្លាញជម្រកលាក់ខ្លួនរបស់ពួកកងទ័ពនៃរដ្ឋាភិបាលត្រីភាគី

- ○ រៀបចំកសាងប្រព័ន្ធការពារនៅតាមបណ្តោយព្រំដែនខ្មែរ-ថៃដោយក្នុងនោះមានការដាក់ចម្រូងឫស្សី ដាក់មីន លើកទំនប់ និងជីកលេណដ្ឋានជាដើម។
- នៅរដូវប្រាំងចុងឆ្នាំ១៩៨៤ ដើមឆ្នាំ១៩៨៥ កងទ័ពរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានទទួលជោគជ័យច្រើនជាងមុននៅតាមព្រំដែនក៏ប៉ុន្តែពួកកងទ័ពត្រីភាគីបានឆ្លៀតឱកាសនោះប្រើប្រាស់ក្រុមតូចៗក្នុងការបំផ្លាញ និងបង្កអស្ថិរភាពនៅសមរភូមិក្រោយ។

## ៤. ការកសាងជាតិឡើងវិញ

- រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបង្កើតឡើងតាមរយៈការជួយជ្រោមជ្រែងរបស់វៀតណាម មិនត្រូវបានអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិ ព្រមទាំងប្រទេសសមាជិកអាស៊ានទទួលស្គាល់នោះទេ។
- ជំនួយមនុស្សធម៌ទាំងប៉ុន្មានត្រូវបង្វែរទៅផ្គត់ផ្គង់ប្រជាជនខ្មែរដែលរស់នៅតាមជំរុំជនភៀសខ្លួននៅតាមព្រំដែនខ្មែរ-ថៃ ដែលជំរុំនីមួយៗស្ថិតនៅក្រោមអំណាចរបស់ក្រុមដឹកនាំពាផ្សេងទៀតគឺក្រុមខ្មែរក្រហម, ក្រុមរាជានិយមដឹកនាំដោយសម្តេចនរោត្តម សីហនុ ឬក្រុមរបស់លោកសឺន សាន។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវកសាងប្រទេសឡើងវិញពីចំណុចសូន្យ ដោយពឹងផ្អែកទាំងស្រុងលើជំនួយពីវៀតណាម សហភាពសូវៀត និងប្រទេសសង្គមនិយម។
- ក្រោយសម័យខ្មែរក្រហម កម្ពុជាទទួលរងនូវការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងប្រឈមទៅនឹងគ្រោះទុរ្ភិក្ស។ បញ្ហាចម្បងដែលរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវធ្វើគឺដោះស្រាយបញ្ហាស្បៀងរបស់ប្រជាជនទូទាំងប្រទេស។
- សហភាពសូវៀត វៀតណាម និងប្រទេសសង្គមនិយមបានផ្គត់ផ្គង់ស្បៀងអាហារសម្ភារប្រើប្រាស់ បច្ចេកទេស ពូជស្រូវ ដំណាំ វត្ថុធាតុដើម និងបច្ចេកទេស ដើម្បីចាប់ផ្តើមឱ្យមានផលិតកម្ម សិប្បកម្ម និងឧស្សាហកម្មនៅកម្ពុជា។
- ជំហានដំបូងក្នុងការស្តារបនាសេដ្ឋកិច្ចរដ្ឋាភិបាលបានបង្កើតក្រុមសាមគ្គីបង្កបង្កើនផល ឬក្រុមប្រវាស់ដៃក្នុងគោលបំណងឱ្យប្រជាជនចេះជួយគ្នាក្នុងកាលៈទេសៈដែលខ្វះខាតឧបករណ៍និងមធ្យោបាយបង្កបង្កើនផល កម្លាំងពលកម្ម គោក្របីគ្រាប់ពូជ និងធនធាន។
- តម្រូវការ និងកិច្ចការដែលត្រូវធ្វើដើម្បីស្តារបនាសង្គមលើគ្រប់វិស័យមានទំហំធំធេងប៉ុន្តែកម្ពុជាជួបប្រទះនូវបញ្ហាកង្វះខាតធនធានមនុស្ស កង្វះខាតថវិកា កង្វះខាតធនធានគ្រប់សព្វបែបយ៉ាង និងរងគំនាបរបស់មហាអំណាចសេរីនិងប្រទេសដែលជាសម្ព័ន្ធមិត្ត។
- ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិស័យអប់រំ និងវប្បធម៌ដែលពួកខ្មែរក្រហមព្យាយាមកម្ទេចចោលត្រូវបានស្តារឡើងវិញភ្លាមៗ។
- ការប្រមូលគ្រូបង្រៀនដែលនៅរស់ និងសិស្សានុសិស្សត្រូវបានប្រព្រឹត្តទៅគ្រប់

ទិសទី។

- រដ្ឋាភិបាលបានប្រើគោលនយោបាយមួយគឺ«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកមិនចេះ»។
- ការបង្រៀននិងផ្ទេរចំណេះដឹងបានចាប់ផ្តើមឡើងយ៉ាងផុសផុលក្នុងសាលារៀន វត្តអារាម តាមផ្ទះប្រជាជន និងក្រោមដើមឈើជាដើម។ សិស្សានុសិស្សប្រើក្រដាសចាស់ៗនិងធ្យូងមកសរសេរ។
- រដ្ឋបានប្រមូលផ្តុំអ្នកសិល្បៈ និងសាស្ត្រាចារ្យផ្នែកសិល្បៈដែលនៅសេសសល់
- សាលាវិចិត្រសិល្បៈបានបើកទ្វារឡើងវិញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨១
- រោងភាពយន្តមួយចំនួនចាប់ផ្តើមបើកទ្វារឡើងវិញជាបណ្តើរៗ
- វត្តអារាមត្រូវបានជួសជុល និងដំណើរការឡើងវិញ
- ការរើសគូស្រករ និងការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមានការបើកទូលាយឡើងវិញ។
- មជ្ឈមណ្ឌលកុមារកំព្រាជាច្រើនបានបើកទ្វារ និងទទួលកុមារប្រមាណ៦ ០០០ នាក់នៅទូទាំងប្រទេស
- ជនពិការ និងស្ត្រីមេម៉ាយត្រូវបានបែងចែកទៅតាមក្រុមសាមគ្គី ឯសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ជនពិការមួយចំនួនក៏បានបើកទ្វារ
- ការផ្គត់ផ្គង់ទឹកស្អាត និងភ្លើងអគ្គិសនីបានចាប់ផ្តើមបន្តិចម្តងៗ
- ច្បាប់ការពារកម្មសិទ្ធិឯកជនដោយផ្តល់កម្មសិទ្ធិដល់ប្រជាពលរដ្ឋខ្មែរត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៨៧។
- មន្ទីរពេទ្យជាច្រើនបានដំណើរការឡើងវិញ ប៉ុន្តែកង្វះខាតធនធានមនុស្ស គ្រឿងបរិក្ខារ ថ្នាំសង្កូវនៅតែជាបញ្ហាប្រឈមដ៏សំខាន់
- មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រត្រូវបើកឱ្យដំណើរការវិញនៅថ្ងៃទី១៩ ខែមករាឆ្នាំ១៩៨០
- សាលាសុខាភិបាលមធ្យម និងខេត្តក្រុងបានបើកឱ្យដំណើរការវិញជាបន្តបន្ទាប់។

### ៥. ការចរចារកសន្តិភាព និងការបង្រួបបង្រួមជាតិ

- នៅខែវិច្ឆិកា ឆ្នាំ១៩៨៤គម្រោងជួបចរចានៅប្រទេសបារាំង រវាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសម្តេចនរោត្តម សីហនុ ដែលជាតំណាងរដ្ឋាភិបាលសម្ព័ន្ធត្រីភាគីត្រូវអាក់ខានដោយសារចិន និងខ្មែរក្រហមបានដាក់គំនាបលើសម្តេចនរោត្តម សីហនុ។
- ចាប់ពីឆ្នាំ១៩៨៥ ស្ថានភាពនយោបាយនៅអាស៊ី និងក្នុងពិភពលោកមានភាពធូរស្រាលជាងមុន។ សហភាពសូវៀតបានប្រកាសយកកំណែទម្រង់សេដ្ឋកិច្ច និងសង្គមដែលមិនធ្លាប់មានពីមុនមកឈ្មោះថា«Perestroika»ព្រមទាំងដកទ័ពចេញពីអាហ្វហ្គានីស្ថាននៅឆ្នាំ១៩៨៩។
- នៅឆ្នាំ១៩៨៧ ជំនួបកំពូលរវាងសហរដ្ឋអាម៉េរិកនិងសហភាពសូវៀត បានធ្វើឱ្យ

ស្ថានការណ៍នយោបាយនៅកម្ពុជាប្រសើរជាងមុន។

- នៅថ្ងៃទី២ខែធ្នូ ឆ្នាំ១៩៨៧ មានការជួបគ្នាលើកទី១នៅហ្វែអង់តាដឺន័រ ប្រទេសបារាំងរវាងសម្តេច នរោត្តម សីហនុ និងលោកហ៊ុន សែន ដែលជាតំណាងសាធារណរដ្ឋប្រជាមានិតកម្ពុជា។
- ក្រោមអន្តរាគមន៍របស់បរទេស លោក សឺន សាន និងលោក ខៀវ សំផនក៏ព្រមចូលតុចរចា។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៨៨ ការចរចាលើកដំបូងដោយមានការចូលរួមទាំង៤ភាគី និងប្រទេសដែលពាក់ព័ន្ធបានប្រព្រឹត្តឡើងនៅប្រទេសឥណ្ឌូណេស៊ី។ ជំនួបនេះបានផ្តល់នូវលទ្ធផលជាច្រើនដូចជា ៖
  - ការកំណត់ការដកកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា
  - ការទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឱ្យវិលត្រឡប់មកវិញ
  - ការបញ្ឈប់ជំនួយរបស់បរទេស ទៅឱ្យក្រុមដែលប្រឆាំងនឹងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
  - ការបញ្ឈប់ការជ្រៀតជ្រែកពីខាងក្រៅក្នុងកិច្ចការរបស់កម្ពុជា។
- នៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៨៩ វៀតណាមបានប្រកាសថា កងទ័ពរបស់ខ្លួននឹងដកចេញឱ្យអស់ពីកម្ពុជានៅចុងខែកញ្ញា ឆ្នាំ១៩៨៩ ហើយនៅថ្ងៃទី២៩-៣០ ខែមេសា ឆ្នាំ១៩៨៩ សភាជាតិនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានសម្រេចធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ៖
  - ប្តូរឈ្មោះប្រទេសពី«សាធារណរដ្ឋប្រជាមានិតកម្ពុជា» ទៅជា«រដ្ឋកម្ពុជា»
  - ប្តូរទង់ជាតិ និងភ្លេងជាតិ
  - លុបបំបាត់ច្បាប់ប្រហារជីវិត(លុបទោសប្រហារជីវិត)
  - ទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ និងលុបចោលការកំហិត(លក្ខខណ្ឌ) អ្នកសាងផ្នួស(អ្នកបួស)
  - បង្កើតទីផ្សារសេរីផ្តល់សេរីភាពសារព័ត៌មាន និងការបង្កើតអង្គការសង្គមស៊ីវិល។
- នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨៩មក វេទិការបស់សម្តេច នរោត្តមសីហនុ និងលោកហ៊ុន សែន ដើម្បីស្វែងរកដំណោះស្រាយវិបត្តិនយោបាយនៅកម្ពុជាបានប្រព្រឹត្តទៅជាបន្តបន្ទាប់ នៅទីក្រុងប៉ារីស(ប្រទេសបារាំង)ទីក្រុងហ្សាកាតា(ឥណ្ឌូណេស៊ី) ទីក្រុងតូក្យូ(ប្រទេសជប៉ុន) និងទីក្រុងប៉ាតាយ៉ា(ប្រទេសថៃ)។
- ក្រុមប្រឹក្សាជាតិជាន់ខ្ពស់(SNC: Supreme National Council) បានបង្កើតឡើងនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩០ ដែលមានសម្តេច នរោត្តម សីហនុជាប្រធាន និងមានសមាជិក១២រូប ដែលមកពីរដ្ឋកម្ពុជា៦រូប និងសម្ព័ន្ធត្រីភាគី៦រូប។
- ថ្ងៃទី២៣-២៤ ខែមិថុនា ឆ្នាំ១៩៩១ នៅទីក្រុងប៉ាតាយ៉ា គូបដិបក្ខខ្មែរទាំងបួនបានជួបជុំគ្នា និងបានចុះសម្រុងគ្នាអំពីគម្រោងការដោះស្រាយបញ្ហាជាតិ។
- ក្រោយពីមានការជួបចរចារវាងបណ្តាភាគីខ្មែរនិងប្រទេសពាក់ព័ន្ធ ភាគីជម្លោះ

ទាំងបួននៅកម្ពុជា និងប្រទេសចំនួន១៨ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។ បញ្ហាកម្ពុជាក៏បានដោះស្រាយ។

**កិច្ចព្រមព្រៀងទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១**

កិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ផ្តោតទៅលើចំណុចពីរសំខាន់ៗគឺ៖

- កិច្ចព្រមព្រៀងទាក់ទងទៅនឹងអធិបតេយ្យភាព បូរណភាពទឹកដី អព្យាក្រឹត ឯករាជ្យជាតិកម្ពុជា
- សេចក្តីថ្លែងការណ៍ស្តីពីការស្តារ និងកសាងប្រទេសកម្ពុជាឡើងវិញ។

អ៊ុនតាក់មានថវិកាចំនួន ៣ ០០០ លានដុល្លារ ដើម្បីបំពេញបេសកកម្ម៤យ៉ាងគឺ ៖

- ដកអាវុធពីកងទ័ពរដ្ឋកម្ពុជាកងទ័ពខ្មែរក្រហមរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ (FNLPK)និងកងទ័ពរាជានិយមហ៊្វុនស៊ិនប៉ិច
- បញ្ចូលរដ្ឋអំណាចទាំងសងខាងឱ្យរួមគ្នា(រដ្ឋកម្ពុជា និងរដ្ឋាភិបាលសម្ព័ន្ធត្រីភាគី)
- រៀបចំការបោះឆ្នោតដោយសេរីដោយអ៊ុនតាក់
- នាំជនភៀសខ្លួនប្រហែល៣៥០ ០០០ នាក់ត្រឡប់មកមាតុភូមិវិញ។

# វិញ្ញាសារៀមទី២២

## ប្រធាន

1. តើលោកនួន ជា បានទទួលមរណភាពនៅថ្ងៃ ខែ ឆ្នាំណា?
2. ដូចម្តេចដែលហៅថាសង្គ្រាមត្រជាក់? តើសង្គ្រាមត្រជាក់ និងសង្គ្រាមក្តៅ ខុសគ្នាដូចម្តេច? ចូរលើកឧទាហរណ៍បញ្ជាក់។
3. ក្រោយសង្គ្រាមលោកលើកទី២ ទ្វីបអឺរ៉ុបត្រូវបានបែងចែកជាពីរគឺអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។ ចូរពន្យល់ពីមូលហេតុ និងបច្ច័យសម្រាប់ទំនាក់ទំនងអន្តរជាតិ។
4. ចូរពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា(១៩៧៩-១៩៨៩)។

## អត្រាកំណែ

១-លោកនួន ជា បានទទួលមរណភាពនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩។

២-សង្គ្រាមត្រជាក់ គឺជាការប្រឈមមុខដាក់គ្នារវាងប្លុកលោកខាងលិច ដែលប្រកាន់យកលទ្ធិសេរីនិយម (Liberalism) ដឹកនាំដោយសហរដ្ឋអាម៉េរិកនិងប្លុកលោកខាងកើត ដែលប្រកាន់យកលទ្ធិកុម្មុយនីស្ត (Communism) ដឹកនាំដោយសហភាពសូវៀត។ ការប្រឈមមុខរវាង ប្លុកទាំងពីរនេះកើតមានក្នុងវិស័យមនោគមវិជ្ជា នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម យោធា ការទូតនិងទំនាក់ទំនងអន្តរជាតិ។

**សង្គ្រាមត្រជាក់ខុសពីសង្គ្រាមក្តៅ**ត្រង់ថាសង្គ្រាមត្រជាក់ជាសង្គ្រាមមនោគមវិជ្ជា មេដឹកនាំនៃប្លុកទាំងពីរពុំបានបង្កជាការផ្ទុះអាវុធដោយផ្ទាល់ឡើយ តែការផ្ទុះអាវុធកើតឡើងនៅតាមបណ្តាប្រទេសដែលស្ថិតនៅក្រោមឥទ្ធិពលនៃមហាអំណាចទាំងពីរនេះ។ ឧទាហរណ៍ដូចជាសង្គ្រាមនៅឧបទ្វីបកូរ៉េ សង្គ្រាមឥណ្ឌូចិន...។ ចំណែកសង្គ្រាមក្តៅជាការប្រឈមមុខដាក់គ្នាផ្នែកយោធា ហើយមានការផ្ទុះអាវុធដោយផ្ទាល់រវាងភាគីជម្លោះ។ ឧទាហរណ៍សង្គ្រាមលោកលើកទី១ សង្គ្រាមលោកលើកទី២ សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន...។

៣-ក្រោយសង្គ្រាមលោកលើកទី២ ទ្វីបអឺរ៉ុបត្រូវបានបែងចែកជាអឺរ៉ុបខាងកើត និងអឺរ៉ុបខាងលិច។

**មូលហេតុ**

- ឥទ្ធិពលនៃសង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥)៖
  - នៅក្នុងសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបភាគច្រើនគ្រប់គ្រងដោយអាល្លឺម៉ង់
  - នៅចុងបញ្ចប់នៃសង្គ្រាមប្រទេសនៅទ្វីបអឺរ៉ុបមួយចំនួន ត្រូវរំដោះដោយសូវៀត និងអាម៉េរិក
  - សេដ្ឋកិច្ចទ្វីបអឺរ៉ុបចុះទន់ខ្សោយ ងាយទទួលរងឥទ្ធិពល អឺរ៉ុបត្រូវពឹងផ្អែកលើជំនួយសហរដ្ឋអាម៉េរិក និងសូវៀត
- សន្និសីទក្រុងយ៉ាល់តា និងសន្និសីទ ពតស្តាំ(Potsdam) ឆ្នាំ១៩៤៥ ស្តីពីការបែងចែកទ្វីបអឺរ៉ុបក្រោយសង្គ្រាមលោកលើកទី២
  - ការបែងចែកទឹកដីអាល្លឺម៉ង់ដោយមហាអំណាចទាំងបួនជាបួនតំបន់កាន់កាប់

- ការបែងចែកទីក្រុងប៊ែរឡាំងជាបួនផ្នែក
- ភាពទន់លេចក្នុងផ្នែកនយោបាយ និងភាពប្រេះឆាគ្នា នៃមហាអំណាចសម្ព័ន្ធមិត្ត ដែលធ្វើឱ្យដំណោះស្រាយពីបញ្ហាអាល្លឺម៉ង់ ត្រូវបរាជ័យ

- ការប្រជែងគ្នារបស់មហាអំណាចពីរគឺ សហរដ្ឋអាម៉េរិកនិងសហភាពសូវៀត
  - នៅក្នុងសង្គ្រាម មហាអំណាចសហរដ្ឋអាម៉េរិក អង់គ្លេស និងសហភាពសូវៀត បានរួបរួមគ្នាប្រយុទ្ធប្រឆាំងនឹងណាស៊ីអាល្លឺម៉ង់ តែមហាអំណាចទាំងនេះមានលក្ខណៈប្លែកគ្នាទាំងស្រុង ទាំងផ្នែកមនោគមវិជ្ជានយោបាយ និងសេដ្ឋកិច្ច
  - ការមិនទុកចិត្តគ្នារវាងសហរដ្ឋអាម៉េរិកនិងសហភាពសូវៀតនៅចុងបញ្ចប់នៃសង្គ្រាម
  - ការប្រជែងមនោគមវិជ្ជា នយោបាយ បែបប្រជាធិបតេយ្យសេរី និងកុម្មុយនីស្ត
  - ការប្រជែងផ្នែកសេដ្ឋកិច្ច តាមបែបមូលធននិយម និងសង្គមនិយម
  - ការប្រជែងផ្នែកសព្វាវុធ អាវុធនុយក្លេអ៊ែរ ព្រមទាំងការប្រជែងបច្ចេកវិទ្យា និងការទូត
  - អឺរ៉ុបប៉ែកខាងកើតត្រូវរំដោះដោយសូវៀតក្នុងអំឡុងឆ្នាំ១៩៤៤-១៩៤៥ បានធ្លាក់ក្រោមឥទ្ធិពលកុម្មុយនីស្តសូវៀត និងក្រោយមកប្រកាន់យករបបកុម្មុយនីស្តតាមបែបសូវៀត
  - អឺរ៉ុបខាងលិចត្រូវបានរំដោះដោយអង់គ្លេស និងអាមេរិកក្នុងអំឡុងឆ្នាំ១៩៤៤ ដល់ ១៩៤៥ បានប្រកាន់យករបបប្រជាធិបតេយ្យសេរី

- ទ្រឹស្តីទ្រូម៉ាន់ និងផែនការម៉ាសាល ឆ្នាំ១៩៤៧ ៖ អាម៉េរិក អនុវត្តនយោបាយទប់ទល់ និងរុញច្រានរបបកុម្មុយនីស្ត
- **ចម្លើយត្រឹមត្រូវផ្សេងទៀត**

**បច្ច័យសម្រាប់ទំនាក់ទំនងអន្តរជាតិ**

- ពិភពលោកត្រូវបានបែងចែកជាពីរប្លុក គឺប្លុកលោកខាងកើត (ប្លុកកុម្មុយនីស្ត) និងប្លុកលោកខាងលិច (ប្លុកសេរី)
- ការបង្កើតបក្សសម្ព័ន្ធយោធានៅតាមតំបន់នានាដូចជា អង្គការអូតង់(នៅអឺរ៉ុបខាងលិច) បក្សសម្ព័ន្ធវ៉ាសូវី (អឺរ៉ុបខាងកើត) សេអាតូ(អាស៊ីអាគ្នេយ៍) បាដាត (មជ្ឈិមបូព៌ា)...
- បណ្តាប្រទេសក្រោមអាណានិគមទទួលបានឯករាជ្យជាបន្តបន្ទាប់ (ទ្វីបអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីន)
- ផ្ទុះសង្គ្រាមស៊ីវិលនៅតាមប្រទេសមួយចំនួនដែលទើបទទួលបានឯករាជ្យ និងទទួលមនោគមវិជ្ជាទាំងពីរ( សង្គ្រាមឧបទ្វីបកូរ៉េ សង្គ្រាមវៀតណាម កម្ពុជា...)
- **ចម្លើយត្រឹមត្រូវផ្សេងទៀត**

៤-ពិពណ៌នាពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា

- អង្គការគ្រប់គ្រងសំខាន់ៗនៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាគ្រប់គ្រងដោយគណបក្សតែមួយគឺគណបក្សប្រជាជនបដិវត្តន៍កម្ពុជា និងមានអង្គការគ្រប់គ្រងសំខាន់ៗ៤គឺ៖

- គណបក្សប្រជាជនបដិវត្តន៍កម្ពុជា
- ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ឬក្រុមប្រឹក្សារដ្ឋមន្ត្រី
- ក្រុមប្រឹក្សារដ្ឋ
- រដ្ឋសភាជាតិ

- រដ្ឋអំណាចខ្មែរ
  - ដំណាក់កាលដំបូង៖ ក្រសួងសំខាន់ៗគ្រប់គ្រងដោយមនុស្សពីរក្រុមគឺ អ្នកតស៊ូចាស់ៗនៅភូមិភាគបូព៌ា (សមមិត្ត ហេង សំរិន ,ជា ស៊ីម ,ហ៊ុន សែន )និងអ្នករៀននៅវៀតណាមក្រោយសន្និសីទហ្សឺណែវឆ្នាំ១៩៥៤( សមមិត្ត ប៉ែន សុវណ្ណ ,ចាន់ ស៊ី )
  - ដំណាក់កាលបន្ទាប់៖ ពេលសន្តិសុខប្រទេសមានលំនឹង រដ្ឋាភិបាលជ្រើសរើសអ្នកមានសមត្ថភាពឱ្យបម្រើក្នុងក្បាលម៉ាស៊ីនដឹកនាំរដ្ឋ ។

- ជំនាញការ និងកងទ័ពវៀតណាម
  - អ្នកជំនាញការវៀតណាមអមរដ្ឋអំណាចខ្មែរតាំងពីថ្នាក់ក្រសួងដល់ថ្នាក់មូលដ្ឋានដើម្បីជួយពង្រឹងរដ្ឋបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា
  - កងទ័ពវៀតណាមនៅពេញផ្ទៃប្រទេសដើម្បីជួយទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍

- កិច្ចការពារជាតិ

ដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញរបស់ខ្មែរក្រហមរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាបានចាត់វិធានការដូចតទៅ ៖

- បង្កើតកងសេនាជនភូមិ
- បង្កើតក្រុមស្វ័យការពារ ក្រុមយាមកាម
- ធ្វើការជ្រើសកងទ័ព
- បង្កើតកាតព្វកិច្ចយោធា
- ធ្វើការហ្វឹកហាត់ក្បួនយោធាដល់សិស្ស និស្សិត មុនចូលរៀន
- លើកទ័ពវាយលុកលើខ្មែរក្រហមនារដូវប្រាំង និងធ្វើការគ្រប់គ្រងតំបន់តាមព្រំដែន
- បង្កើនការការពារនៅតាមព្រំដែនកម្ពុជា-ថៃ ដោយអនុវត្តផែនការ«ក៥»
- ផែនការអូសទាញជនវង្វេងផ្លូវ
- សង្គ្រាមរដូវប្រាំង
- ស្វែងរកការចរចាបញ្ចប់សង្គ្រាម

- ការស្តាបនាសេដ្ឋកិច្ច

បញ្ហាបន្ទាន់គឺ បញ្ហាស្បៀងដូចនេះរដ្ឋាភិបាលបានៈ

- អំពាវនាវសុំជំនួយពីសហគមន៍អន្តរជាតិ
- បង្កើតក្រុមសាមគ្គីបង្កបង្កើនផល
- ឆ្នាំ១៩៨០បោះពុម្ពក្រដាសប្រាក់ឱ្យចាយវាយទូទាំងប្រទេស
- ឆ្នាំ១៩៨៣-១៩៨៦ ប្តូរពីក្រុមសាមគ្គីបង្កបង្កើនផលទៅជាម្ចាស់ការទាំងស្រុង ដោយធ្វើការបែងចែកដីធ្លី និងឈានទៅរកកម្មសិទ្ធិឯកជន
- អនុវត្តមុខព្រួញទាំង៤នៃសេដ្ឋកិច្ច

- ការស្តាបនាសង្គម
  - បើកទ្វារសាលាទទួលសិស្ស និស្សិតឱ្យចូលរៀន
  - ធ្វើការជ្រើសរើស និងបណ្តុះបណ្តាលគ្រូ
  - ជំរុញចលនាអក្ខរកម្ម និងបំពេញវិជ្ជា
  - អនុវត្តនយោបាយ«អ្នកចេះច្រើនបង្រៀនអ្នកចេះតិច ឯអ្នកចេះតិចបង្រៀនអ្នកអត់ចេះ »
  - បញ្ជូននិស្សិតទៅសិក្សានៅបរទេស
  - បើកសេរីភាពដល់ជំនឿ សាសនា ប្រពៃណីទំនៀម ទម្លាប់
  - បើកទ្វារសាលាវិចិត្រសិល្បៈ និងប្រមូលផ្តុំសិល្បករ
  - បង្កើតមជ្ឈមណ្ឌលកុមារកំព្រា
  - បង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ជនពិការ និងស្ត្រីមេម៉ាយ
  - បង្កើតច្បាប់ការពារកម្មសិទ្ធិឯកជន
  - បើកទ្វារមន្ទីរពេទ្យទទួលពិនិត្យ និងព្យាបាលជំងឺ
  - បើកទ្វារសាលាបណ្តុះបណ្តាលពេទ្យ មានមហាវិទ្យាល័យវេជ្ជសាស្ត្រឱសថសាស្ត្រ ទន្តសាស្ត្រ

- **ចម្លើយត្រឹមត្រូវផ្សេងៗទៀត**

# វិញ្ញាសាត្រៀមទី២៣

1. តើសហភាពឥណ្ឌូចិន(បារាំង) ដែលបង្កើតនៅឆ្នាំ១៨៨៧ មានរដ្ឋប៉ុន្មាន នៅក្រោមបារាំង?
2. ចូរពណ៌នាពីការការវិវត្តនៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា។
3. តើកម្ពុជាបានដោះស្រាយបញ្ហាទឹកដីដែលបាត់ក្នុងសង្គ្រាមលោកទី២ តាមរបៀបណា?
4. តើក្រោយសម័យអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) កម្ពុជាបានឆ្លងកាត់សម័យឬរបបអ្វីខ្លះ? ចូររៀបរាប់។
5. ចូររៀបរាប់ពីមូលហេតុដែលរុស្ស៊ីចាប់ផ្តើមបើកប្រតិបត្តិការវាយប្រហារ អ៊ុយក្រែន នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២?

## អត្រាកំណែ

១- សហភាពឥណ្ឌូចិន(បារាំង) ដែលបង្កើតនៅឆ្នាំ១៨៨៧ មានរដ្ឋ៥គឺ

- រដ្ឋក្រោមអាណានិគម៖ កូសាំងស៊ីន
- រដ្ឋក្រោមអាណាព្យាបាល៖ ឡាវ តុងកឹង អណ្ណាម កម្ពុជា។

២-ការវិវត្តនៃរបបអាណាព្យាបាលបារាំងនៅកម្ពុជា

- សន្ធិសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១១ សីហា ១៨៦៣ (បង្កើតរបបអាណាព្យាបាលបារាំងនៅកម្ពុជា) ត្រូវបានចុះហត្ថលេខា នៅរាជវាំងឧដុង្គ។ មាត្រា១ចែងថា៖ អធិរាជបារាំងផ្តល់នូវកិច្ចការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា។
- អនុសញ្ញាបារាំង-ខ្មែរ ថ្ងៃទី១៧ មិថុនា ១៨៨៤ (បារាំងប៉ុនប៉ងដណ្តើមអំណាច) ត្រូវបានចុះហត្ថលេខា នៅរាជវាំងភ្នំពេញ។ បារាំងបានបង្ខំឱ្យព្រះរាជាកម្ពុជាទទួលយកកំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។
- ព្រះរាជប្រកាស ថ្ងៃទី១១ កក្កដា ១៨៩៧ (បារាំងដណ្តើមអំណាចបាន)ព្រះរាជប្រកាសនេះ បានដកអំណាចពីព្រះរាជាខ្មែរ ហើយប្រគល់ទៅឱ្យរេស៊ីដង់ជាន់ខ្ពស់បារាំងជំនួសវិញ តាមរយៈកិច្ចប្រជុំគណៈរដ្ឋមន្ត្រីខ្មែរ នៅក្រោមអធិបតីភាពរបស់រេស៊ីដង់ជាន់ខ្ពស់ ដោយមិនមានវត្តមានព្រះរាជាខ្មែរ និងការចុះហត្ថលេខាអមដោយរេស៊ីដង់ជាន់ខ្ពស់លើលិខិតបទដ្ឋានគតិយុត្តដែលព្រះរាជាខ្មែរបានឡាយព្រះហស្តលេខាមុននឹងដាក់ឱ្យអនុវត្ត។

៣-កម្ពុជា បានពឹងបារាំងឱ្យយកទឹកដីខ្មែរដែលបាត់ក្នុងសង្គ្រាមលោកទី២មកវិញដោយ៖

- នៅឆ្នាំ១៩៤១៖ ក្នុងសង្គ្រាមលោកលើកទី២ កម្ពុជាបានបាត់បង់ទឹកដីជថ្មី។ តាមអនុសញ្ញាបារាំង-សៀមថ្ងៃទី៩ឧសភា១៩៤១ នោះសៀមកាន់កាប់ខេត្តខ្មែរចំនួន៤គឺ៖ ខេត្តបាត់ដំបង, សៀមរាប, កំពង់ធំ និងស្ទឹងត្រែង(ត្រើយខាងលិចទន្លេមេគង្គ)។
- នៅខែធ្នូ១៩៤៥៖ កាសែត«កម្ពុជា» បានចុះផ្សាយអត្ថបទ«ពង្សាវតារខ្មែរ»ជាប់គ្នា៤លេខនៅថ្ងៃទី១៧-១៨-១៩-២០ធ្នូ១៩៤៥ រៀបរាប់អំពីប្រវត្តិដ៏ជូរចត់របស់ខ្មែរចាប់ពីរជ្ជកាលព្រះអង្គអេង។ ការចុះផ្សាយអត្ថបទប្រវត្តិសាស្ត្រនេះបង្ហាញឱ្យឃើញច្បាស់អំពីសារៈសំខាន់នៃចំណេះដឹងប្រវត្តិសាស្ត្រជាក់ស្តែងគឺ៖ កាលពីចុងសតវត្សរ៍ទី១៩

ខ្មែរបានប្រើ«រាជពង្សាវតារខ្មែរ»ដើម្បីទាមទារទឹកដី ដោយមានសាមគ្គីភាពបារាំង-ខ្មែរ អស់រយៈពេល៤០(ឆ្នាំ១៨៦៧-១៩០៧)។

- នៅឆ្នាំ១៩៤៥ ខ្មែរបានប្រើយន្តការដដែលគឺ«រាជពង្សាវតារខ្មែរ»បូកជាមួយនឹងសាមគ្គីភាពបារាំង-ខ្មែរ ដើម្បីទាមទារទឹកដីសាជាថ្មី។

**សេចក្តីសន្និដ្ឋាន**គឺដោយសារមូលហេតុខាងលើនេះហើយបានជា «ប្រទេសកម្ពុជា នាសម័យនោះ នៅតែត្រូវការបារាំង»។

៤-ក្រោយសម័យអាណាព្យាបាលបារាំង(១៨៦៣-១៩៥៣) កម្ពុជាបានឆ្លងកាត់សម័យ ឬរបបជាច្រើនដូចជា ៖

- របបសង្គមរាស្រ្តនិយម ៖ ១៩៥៥-១៩៧០
- របបសាធារណរដ្ឋខ្មែរ ៖ ១៩៧០-១៩៧៥
- របបកម្ពុជាប្រជាធិបតេយ្យ ៖ ១៩៧៥-១៩៧៩
- របបសាធារណរដ្ឋប្រជាមានិតកម្ពុជា៖ ១៩៧៩-១៩៨៩
- របបរដ្ឋកម្ពុជា ៖ ១៩៨៩-១៩៩១
- អន្តរកាល(អ៊ុនតាក់ UNTAC និងឧត្តមក្រុមប្រឹក្សាជាតិ SNC)៖១៩៩១-១៩៩៣
- ព្រះរាជាណាចក្រកម្ពុជា«ទី២» ៖ ១៩៩៣-បច្ចុប្បន្ន

៥-មូលហេតុដែលរុស្ស៊ីចាប់ផ្តើមបើកប្រតិបត្តិការវាយប្រហារអ៊ុយក្រែននាថ្ងៃទី២៤ កុម្ភៈ ២០២២៖

- បុព្វហេតុប្រវត្តិសាស្រ្ត
  - ក្រោយឆ្នាំ១៩៩១ រុស្ស៊ីជាអតីតអំណាចកណ្តាលដែលមានឥទ្ធិពលជាងគេ ហើយក្រោយពីរដ្ឋទាំង១៥(រុស្ស៊ី អ៊ុយក្រែន បេឡារុស ហ្សកហ្ស៊ី ម៉ុលដាវី អាមេនី អេស្តូនី ឡេតូនី លីទុយអានី អាស៊ែបៃហ្សង់ កាហ្សាក់ស្ថាន អ៊ូសបេគីស្ថាន តាហ្ស៊ីគីស្ថាន កៀហ្ស៊ីស៊ីស្ថាន និងតួកម៉េនីស្ថាន) នៅក្រោមសហភាពសូវៀតទទួលបានឯករាជ្យអស់ហើយ តែរុស្ស៊ីនៅតែបន្តចាត់ទុកលំហ ដែនដីនៃអតីតសហភាពសូវៀត ថាជាដែនអំណាចរបស់ខ្លួន ដោយមូលហេតុជនជាតិរបស់រុស្ស៊ីជាច្រើនលាននាក់បន្តរស់នៅលើទឹកដីទាំងនោះ ដូចជាប៉ែកឦសាន្តនៃប្រទេសអ៊ុយក្រែន
  - រុស្ស៊ីចង់បន្តគ្រប់គ្រងបណ្តាប្រទេសដែលជាអតីតសហភាពសូវៀតឱ្យនៅជាមួយខ្លួន
  - រុស្ស៊ីមិនចង់ឱ្យបរទេសផ្សេងលូកដៃចូលក្នុងបណ្តាប្រទេសអតីតសហភាពសូវៀតឡើយ
  - អ៊ុយក្រែនជាបរទេសមួយដែលស្និទ្ធជាងគេជាមួយរុស្ស៊ីដែលមិនត្រូវឱ្យមានចិត្តបែរទៅរកពួកលោកសេរី ឬអូតង់(OTAN)ឡើយ
  - នៅឆ្នាំ១៩៩១ មកពួកអាម៉េរិក និងអឺរ៉ុបចង់ស្រូបយកបណ្តាប្រទេសអឺរ៉ុបខាងកើតចូលមកក្នុងសហភាពអឺរ៉ុប និងអង្គការសន្ធិសញ្ញាអាត្លង់ទិកខាងជើង(OTAN)
  - ពួកអឺរ៉ុបបានស្រូបយករដ្ឋជាប់នឹងសមុទ្របាល់ទិក គឺអេស្តូនី ឡេតូនី និងលីទុយអានី ហើយក៏ត្រៀមយកអ៊ុយក្រែន និងហ្សកហ្ស៊ី ជាដើម

- នយោបាយរបស់លោកប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀ ពូទីន
  - តំបន់ដុងបាសនៅប៉ែកឦសាប្រទេសអ៊ុយក្រែនមានជនជាតិរុស្ស៊ី និងអ្នកប្រើប្រាស់ភាសារុស្ស៊ីច្រើន
  - នៅឆ្នាំ២០១៤ រុស្ស៊ីបានក្រសោបយកគ្រីមេក្រោមរូបភាពថារុស្ស៊ីត្រូវតែការពារជនជាតិរុស្ស៊ីនៅគ្រីមេ និងក្រោមរូបភាពថាប្រជាជននៅគ្រីមេ សម្រេចប្រកាសឯករាជ្យរួចហើយផ្ដាច់ខ្លួនពីអ៊ុយក្រែន មកចុះចូលជាមួយរុស្ស៊ី ដែលនាំឱ្យអ៊ុយក្រែន ក្លាយជាវិបត្តិអន្តរជាតិដ៏ធ្ងន់ធ្ងរមួយរវាងរុស្ស៊ី និងអ៊ុយក្រែន
  - អឺរ៉ុបកំពុងជាប់ដៃប្រយុទ្ធជាមួយកូវីដ១៩ អាឡឺម៉ង់ក៏ទើបមានមេដឹកនាំថ្មី ហើយបារាំងក៏កំពុងត្រៀមរៀបចំបោះឆ្នោតជ្រើសរើសប្រធានធិបតី ហើយសហរដ្ឋអាម៉េរិកក៏កំពុងផ្ដោតការចាប់អារម្មណ៍លើចិន ដែលនេះគឺជាឱកាសល្អមួយសម្រាប់រុស្ស៊ីធ្វើសកម្មភាពនេះ
- អង្គការណាតូ(OTAN)និងរុស្ស៊ី
  - អង្គការអូតង់ ជាមរតកនៃសង្គ្រាមត្រជាក់(១៩៤៥-១៩៩១) ដែលបង្ហាញពីការមិនត្រូវគ្នារវាងសហរដ្ឋអាម៉េរិក និងរុស្ស៊ី។
  - អង្គការអូតង់ បន្តពង្រីកខ្លួនចូលដល់ជិតទឹកដីរុស្ស៊ី ដែលជាហេតុនាំឱ្យរុស្ស៊ីបារម្ភហេតុនេះហើយដែលលោកប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀ ពូទីន មិនអាចទទួលយកបានហើយត្រូវផ្ដួលរំលំប្រធានាធិបតីអ៊ុយក្រែន គឺលោក Zelensky ដែលមានទំនោរទៅរកសហភាពអឺរ៉ុប និងអូតង់
  - អង្គការអូតង់ បង្កើតឡើងដើម្បីទប់ទល់នឹងសហភាពសូវៀត។ ប្រសិនបើអ៊ុយក្រែនក្លាយជាសមាជិកអូតង់នោះអ៊ុយក្រែន អាចទាមទារយកតំបន់គ្រីមេ នៅពេលណាមួយ
  - បើអ៊ុយក្រែន ជាសមាជិករបស់សហភាពអឺរ៉ុប ឬជាសមាជិករបស់អូតង់ នោះពួកលោកសេរី និងមានព្រំដែនជាប់រុស្ស៊ី ដែលនាំឱ្យសន្តិសុខរបស់រុស្ស៊ី នឹងត្រូវមានការគំរាមកំហែង
- ផលប្រយោជន៍របស់ប្រទេសអ៊ុយក្រែនចំពោះរុស្ស៊ី
  - អ៊ុយក្រែនជាតំបន់ទ្រនាបមួយយ៉ាងសំខាន់របស់រុស្ស៊ី តែអ៊ុយក្រែនបានខិតទៅកាន់អឺរ៉ុបខាងលិច ដែលធ្វើឱ្យរុស្ស៊ីមិនចង់ឱ្យអ៊ុយក្រែន មានកម្លាំងយោធាខ្លាំងដែលជាហេតុនាំឱ្យមានការគំរាមកំហែងទៅថ្ងៃខាងមុខ
  - អ៊ុយក្រែន ជាប្រទេសដែលមានប្រជាជនច្រើនជាងគេក្នុងចំណោមរដ្ឋទាំង១៥ របស់សហភាពសូវៀត
  - ទឹកដីអ៊ុយក្រែនមានអំណោយផលខ្លាំងសម្រាប់ការដាំដុះ និងសម្បូរដោយត្បូងថ្ម...
  - អ៊ុយក្រែន ជាច្រកចេញទៅកាន់សមុទ្រខ្មៅ តាមកំពង់ផែSevastopol នៅត្រង់តំបន់គ្រីមេ។
- មានចម្លើយត្រឹមត្រូវផ្សេងទៀត

# ឯកសារយោង

## ១. ស្នាដៃនិពន្ធ


- ក្រសួងអប់រំ យុវជន និងកីឡា ខ្មែរ និងដំណើរឆ្ពោះទៅសម័យអង្គរដ៏រុងរឿង(*ប្រវត្តិវិទ្យា ថ្នាក់ទី៤*),២០២១។
- ក្រសួងអប់រំ យុវជន និងកីឡា សិក្សាសង្គម ថ្នាក់ទី៧ បោះពុម្ពឆ្នាំ២០១៦។
- ក្រសួងអប់រំ យុវជន និងកីឡា សិក្សាសង្គម ថ្នាក់ទី៧ បោះពុម្ពឆ្នាំ២០១៩។
- ក្រសួងអប់រំ យុវជន និងកីឡា ប្រវត្តិវិទ្យាថ្នាក់ទី១០ ដល់ទី១២ បោះពុម្ពឆ្នាំ២០២០។
- ក្រសួងអប់រំ យុវជន និងកីឡា សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រខ្មែរ *សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២* បោះពុម្ពឆ្នាំ២០១៧។
- ក្រសួងអប់រំ យុវជន និងកីឡា សេចក្តីសង្ខេបមេរៀនប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ និងពិភពលោក *សម្រាប់ជំនួយស្មារតីដល់សិស្សថ្នាក់ទី១២* បោះពុម្ពឆ្នាំ២០២០។
- ក្រសួងអប់រំ យុវជន និងកីឡា កម្រងវិញ្ញាសាប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ *ថ្នាក់វិទ្យាសាស្ត្រសង្គម ឆ្នាំ២០១៤-២០១៧។*
- ដេវិឌ ឆាន្ទល័រ ប្រវត្តិសាស្ត្រខ្មែរ ,*មជ្ឈមណ្ឌលខេមរសិក្សា, ២០០៥។*
- ទី សុផល កម្រងវិញ្ញាសាត្រៀម ប្រវត្តិវិទ្យា(*ប្រើប្រាស់ផ្ទៃក្នុង នៅវិទ្យាល័យហេបកីច័ន្ទតារានារីព្រែកថ្មី)* ២០១៨-២០១៩។
- ទី សុផល ប្រវត្តិសាស្ត្រសង្ខេប *(ប្រើប្រាស់ផ្ទៃក្នុង) ២០២០។*
- បណ្ឌិត ម៉ាឃើល វីឃើរី ប្រវត្តិសាស្ត្រកម្ពុជា និងតំបន់: *សម្រាប់និស្សិតសិក្សាថ្នាក់ឆ្នាំមូលដ្ឋាននៅវិទ្យាស្ថានភាសាបរទេស* (បកប្រែដោយ ប្រាក់ សុវណ្ណារ៉ា និងកែសម្រួលដោយវង់ សុជារ៉ា), ភ្នំពេញ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០១២-២០១៣។
- រស់ ចន្ត្រាបុត្រ សាធារណរដ្ឋខ្មែរ, ប្រែសម្រួលដោយទីឃាយុ, ១៩៩៣ ។
- វង់ សុជារ៉ា និងណុប សុខា ប្រវត្តិសាស្ត្រកម្ពុជា,*សម្រាប់ឆ្នាំមូលដ្ឋានភ្នំពេញ*,២០០៩។
- សៅឆាត ឯកសារប្រវត្តិសាស្ត្រ *វិបត្តិកម្ពុជា*, ឆ្នាំ១៩៩៤។
- សុខ ទូច និង ប៊ុនជឿន ទំនាក់ទំនងអន្តរជាតិ រវាងកម្ពុជា និង សហរដ្ឋអាម៉េរិក ចិន និងវៀតណាម បោះពុម្ពឆ្នាំ២០០៧។
- ហ្វ្រង់ ស្វ័រប៉ុងសូដ៍ ប្រវត្តិសង្ខេបនៃប្រទេសកម្ពុជា , ភ្នំពេញ ឆ្នាំ២០០៤។
- ឡឹក សំអឿន ខ្មែរអ្នកជាតិនិយម, បោះពុម្ពឆ្នាំ២០០៥ ។

## ២. សារព័ត៌មាន

- https://khmer.voanews.com/
- https://www.rfi.fr/km
- https://www.vodkhmer.news/
- https://thmeythmey.com/
- http://www.freshnewsasia.com/index.php/en/
- https://www.rfa.org/khmer/audio